សាកលវិទ្យាល័យភូមិន្ទកសិកម្ម

មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍជនបទ


# ហិរញ្ញប្បទានជនបទ

# RURAL FINANCIAL


លោកស្រី ហ៊ីង សាលីន



ឧបត្ថម្ភដោយ

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍជនបទ

# ហិរញ្ញប្បទានជនបទ
## Rural Financial

លោកស្រី ហ៊ឹង សាលីន

២០២១

## គណៈកម្មការបច្ចេកទេស

# ចំណាងជើងសៀវភៅ៖ ហិរញ្ញប្បទានជនបទ

| ល.រ | គោត្តនាម និងនាម | សមាសភាពគណៈកម្មការ | ហត្ថលេខា |
|---|---|---|---|
| ១ | លោក អេង លេង | ប្រធាន | |
| ២ | បណ្ឌិត ឆាយ គង្គា | អនុប្រធាន | |
| ៣ | បណ្ឌិត អ៊ុន ប៊ុនលាង | សមាជិក | |

២០២១

# រក្សាសិទ្ធ

© ឆ្នាំ ២០២១

**រក្សាសិទ្ធគ្រប់យ៉ាង**

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ (ស.គ.ន) នៃក្រសួងអប់រំ យុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា។

**ទំនាក់ទំនងព័ត៌មាន:**

អ្នកនិពន្ធ៖ លោកស្រី ហ៊ីង សាលីន

ទូរស័ព្ទ៖ (+៨៥៥) ៩៦ ៣៥៩ ៨៣៤០

អ៊ីមែល៖ salin_hing@outlook.com

©. 2021, Hing Salin, all rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition

Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sport, the Kingdom of Cambodia

Enquiries about the book:

Author: Mrs. Hing Salin

Mobile phone: (+855) 96 359 8340

Email: salin_hing@outlook.com

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សារជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្របដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញ ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះនៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរ៉េខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពវូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់ឋានៈសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

# សេចក្តីបញ្ជាក់
# នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត ង៉ោ ប៊ុនថាន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍជនបទនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលបានផ្តល់ការអនុញ្ញាត និងលើកទឹកចិត្តនៅក្នុងការរៀបចំសរសេរសៀវភៅមួយក្បាលនេះ ដើម្បីចែករំលែកចំណេះដឹងខ្លះៗដល់សិស្ស និស្សិត និងមិត្តអ្នកអានទាំងអស់ដើម្បីជាស្វ័យសិក្សា ស្វែងយល់ពីចំណេះដឹងដែលទាក់ទងនឹងសេដ្ឋកិច្ច ក្នុងប្រទេសកម្ពុជាយើង។ ហើយក៏សូមថ្លែងអំណរគុណជាពិសេសដល់ មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡា និង ឯកឧត្តម សាន វឌ្ឍនា អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានផ្តល់ឱកាសដ៏កម្រកបាននេះដល់លោកគ្រូ អ្នកគ្រូនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម បន្សល់នៅស្នាដៃទុកសម្រាប់សិស្ស និស្សិតជំនាន់ក្រោយ បានរៀនសូត្រ។

ឆ្លៀតក្នុងឱកាសនេះ នាងខ្ញុំក៏សូមថ្លែងអំណរគុណ អង្គភាព/ស្ថាប័ននានា ក្រៅពីស.វ.ភ.កគណៈកម្មការត្រួតពិនិត្យ អ្នកផ្តល់យោបល់ ក៏ដូចជាអ្នកផ្តល់ឯកសារយោងដែលបានជួយជ្រុមជ្រែងក្នុងការស្រាវជ្រាវនេះអោយលេចចេញជារូបរាងឡើង។

# អារម្ភកថា

សៀវភៅហិរញ្ញប្បទានជនបទ ដែលបានរៀបរៀងឡើងនេះ បានពីការស្រាវជ្រាវពី ឯកសារដែលដកស្រង់ចេញ ពីសៀវភៅសម្រាប់ចំណេះដឹងទូទៅ ឯកសារជំនួយផ្សេងៗ និងតាមអ៊ីនធើណែត ។ គោលបំណងនៃការរៀបរៀង សៀវភៅនេះ គឺដើម្បី ជាឯកសារបន្ថែមទៅកាន់ និស្សិត ដែលកំពុងសិក្សាក្នុង មហាវិទ្យាល័យ អភិវឌ្ឍជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលនាងខ្ញុំកំពុងបង្រៀនផ្ទាល់ផង អោយបានយល់ដឹងពីការប្រើប្រាស់ហិរញ្ញប្បទានជនបទ នៅក្នុងប្រទេសកម្ពុជា។

ក្នុងសៀវភៅនេះ ខ្ញុំបានព្យាយាមកែសម្រួល ឃ្លាប្រយោគ ដោយធ្វើអោយ អ្នកអានមានភាពងាយស្រួល។ តែទោះបីជា ខ្ញុំខំកែសម្រួល និងត្រួតពិនិត្យឡើងវិញជាច្រើនសារយ៉ាងណា ក៏សៀវភៅនេះនៅតែអាចមានចន្លោះខ្វះខាតជាក់ជាមិនខាន។ ខ្ញុំរីករាយនៅការស្តាបនា ការកែតម្រូវផ្សេងៗ ពីប្រិយមិត្តអ្នកអាន ហើយក៏សូមអភ័យទោសនូវកំហុសឆ្គង ដែលកើតមានជាយថាហេតុនៅក្នុងសៀវភៅមិនថា ជាខ្លឹមសារ ឬអក្ខរាវិរុទ្ធ។ ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នករាល់គ្នា នាងខ្ញុំសប្បាយចិត្ត ទទួលយកយោបល់ ហើយប្រមូលយកជាគំនិតបន្ថែម ពីអស់លោកអ្នក និង មិត្តអ្នកអានទាំងអស់។ ដោយក្តីគោរពពីនាងខ្ញុំ ហ៊ីង សាលីន។

ថ្ងៃ .......... ខែ............... ឆ្នាំ.................. ព.ស .........

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ........... គ.ស ២០២១

**អ្នកនិពន្ធ**

**លោកស្រី ហ៊ីង សាលីន**

# អ្នកនិពន្ធ



**នាម និងគោត្តនាម** ៖ លោកស្រី **ហ៊ីង សាលីន**
**អាស័យដ្ឋាន** ៖ ភូមិខ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ ភ្នំពេញ
**ស្ថាប័នការងារ** ៖ សាកលវិទ្យាល័យភូមិន្ទកសិកម្ម
**ឯកទេស ឬមុខជំនាញ** ៖ សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍជនបទ
**ប្រវត្តិការសិក្សា** ៖ អនុបណ្ឌិតផ្នែក សេដ្ឋកិច្ចកសិកម្ម និង អភិវឌ្ឍជនបទ ឆ្នាំ ២០០២
**បទពិសោធន៍ការងារ** ៖ គ្រូបង្រៀនសាកលវិទ្យាល័យភូមិន្ទកសិកម្ម ១៩៩៨-បច្ចុប្បន្ន

# បញ្ជីចិត្ររូប

## រូបភាព និងរូបថត

ទំព័រ


រូបភាព ១៖លំហូរមូលនិធិតាមរយៈទីផ្សារហិរញ្ញវត្ថុ ............ ១៦

រូបភាព ២៖ លំហូរសាច់ប្រាក់ដោយមិនមានការសន្សំ ............ ១៧

រូបភាព ៣៖ លំហូរមូលនិធិរវាងឯកតាអតិរេកនិងអង្គភាពឱនភាព ហិរញ្ញប្បទានផ្ទាល់............ ២១

រូបភាព ៤៖ ប្រាក់ចំណូលអាជីវកម្មនិងគ្រួសារក្នុងរយៈពេល ១............ ២២

រូបភាព ៥៖ បរិមាណកម្ចីឥណទាន............ ២៥

រូបភាព ៦៖សមតាដើមនៃអត្រាការប្រាក់ពិត............ ២៦

រូបភាព ៧៖ មុខងារទូទាត់សម្រាប់អ្នកទិញ............ ៣២

រូបភាព ៨៖ មុខងារទូទាត់សម្រាប់អ្នកលក់ ............ ៣៣

រូបភាព ៩៖ មុខងារទូទាត់សម្រាប់អ្នកទិញ ............ ៣៤

រូបភាព ១០៖ មុខងារទូទាត់សម្រាប់អ្នកលក់............ ៣៥

រូបភាព ១១៖ ការផ្គត់ផ្គង់ទឹកប្រាក់............ ៤៩

រូបភាព ១២៖ គំនូសបង្ហាញប្រព័ន្ធធនាគារនៅកម្ពុជាមុនឆ្នាំ ១៩៧៥............ ៦០

រូបភាព ១៣៖ ខួបអាជីវកម្ម............ ៨៤

# បញ្ជីតារាង

**តារាង** **ទំព័រ**

តារាង ១៖ ចំនួនថ្លៃក្នុងសេដ្ឋកិច្ច Barter ធៀបទៅនឹងសេដ្ឋកិច្ចរូបិយវត្ថុ.................................... ៥

តារាង ២៖ តារាងតុល្យការធនាគារកណ្តាល ...................................................................... ៥១

តារាង ៣៖ តារាងតុល្យការរួមសម្រាប់ស្ថាប័នតំកល់ប្រាក់និងផ្នែកឯកជនមិនមែនធនាគារ ........... ៥១

តារាង ៤៖ជួរទីផ្សារ .................................................................................................... ៧៨

តារាង ៥៖ បង្ហាញអំពី ការផ្សព្វផ្សាយ ការលើកទឹកចិត្តការប្រើឥណទាន (Newspaper Ad Promoting Use of Credit) ....................................................................................................... ៩២

# មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

**ទំព័រ**

សេចក្តីថ្លែងអំណរគុណ....................i
អារម្ភកថា....................ii
បញ្ជីវិចិត្ររូប ....................iv
បញ្ជីតារាង .................... v
មាតិកា....................vi

**ជំពូក ១៖ សញ្ញាណទូទៅនៃរូបិយវត្ថុ**

១.១ ប្រវត្តិទូទៅនៃរូបិយវត្ថុអន្តរជាតិ និងកម្ពុជា.................... ១
១.២ មុខងាររូបិយវត្ថុ ....................៣
១.៣. ទំរង់រូបិយវត្ថុ .................... ៦
១.៤ សមាសភាគផ្គត់ផ្គង់រូបិយវត្ថុ.................... ១០
១.៥ រូបិយវត្ថុ និងវដ្តសេដ្ឋកិច្ច....................១៣
១.៦ តំលៃរូបិយវត្ថុ និងអតិផរណា ....................១៣

**ជំពូក ២ ទីផ្សារហិរញ្ញវត្ថុ និង លក្ខណៈអត្រាការប្រាក់**

២.១ ទីផ្សារហិរញ្ញវត្ថុ .................... ១៥
២.២ ឧបកណ៏ហិញ្ញវត្ថុ.................... ១៨
២.៣ អន្តរការីហិរញ្ញវត្ថុ ....................២០
២.៤ សេវាសំខាន់ៗនៃប្រព័ន្ធហិរញ្ញវត្ថុ....................២៣
២.៥ លក្ខណៈនៃអត្រាការប្រាក់....................២៤

**ជំពូក ៣៖ ទីផ្សារប្តូរប្រាក់**

៣.១ អត្រាប្តូរប្រាក់ ....................២៧

៣.២ ប្រតិបត្តិការប្តូរប្រាក់ ........................................................ ២៨
៣.២.១ ប្រតិបត្តិការប្តូរប្រាក់ប្រគល់ភ្លាម ........................................................ ៣០
៣.២.២ ប្រតិបត្តិការប្តូរប្រាក់មានគ្នាកំណត់ ........................................................ ៣០
៣.២.៣ សិទ្ធិជ្រើសរើសរូបិយប័ណ្ណ ........................................................ ៣១
៣.២.៤ ហានិភ័យ និងកំរៃនៃកិច្ចសន្យាលើរូបិយប័ណ្ណ ........................................................ ៣៥

៣.៣ ភ្នាក់ងារប្តូរប្រាក់ ........................................................ ៣៦
៣.៣.១ អតិថិជន ........................................................ ៣៦
៣.៣.២ ធនាគារពាណិជ្ជ ........................................................ ៣៦
៣.៣.៣ អ្នកជួកជេ ........................................................ ៣៦
៣.៣.៤ ធនាគារកណ្ដាជ ........................................................ ៣៧
៣.៣.៥ ស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារ ........................................................ ៣៧
៣.៣.៦ ស្ថាប័នវិនិយោគិន ........................................................ ៣៨

**ជំពូក ៤ សញ្ញាណទូទៅនៃធនាគារ**

**ជំពូក ៥៖ ធនាគារកេណ្ដាល និង គោលនយោបាយរូបិយវត្ថុ**

៥.១ លំនាំធនាគារកណ្ដាល ........................................................ ៤៦
៥.១.១ តួនាទីធនាគាកណ្ដោល ........................................................ ៤៦
៥.១.២ ផ្នែកប្រតិបត្តិការរបស់ធនាគារកណ្ដាល ........................................................ ៤៧

៥.២ គោលនយោបាយកាតព្វកិច្ចប្រាក់បំរុងរបស់ធនាគារកណ្ដាល ........................................................ ៤៨
៥.២.១ ការឆ្លើយតបទៅនឹងកាតព្វកិច្ចប្រាក់បំរុង ........................................................ ៤៩
៥.២.២ ការកំនត់នូវប្រភេទខុសៗគ្នានៃប្រាក់បំរុង និងរូបិយវត្ថុគោល ........................................................ ៥១

៥.៣ គោលនយោបាយអត្រាអប្បហាររបស់ធនាគារកណ្ដា
ល........................................................ ៥៣

៥.៤ ប្រតិបត្តិការទីផ្សាររបើកចំហ ........................................................ ៥៥

៥.៥ ការត្រួតពិនិត្យរបស់ធនាគារកណ្ដោល ........................................................ ៥៧

៥.៦ ប្រព័ន្ធធនាគារជាតិ ........................................................ ៥៨

**ជំពូក ៦ ឥណទានជនបទនៅកម្ពុជា**

៨.១ ប្រវត្តិឥណទាននៅកម្ពុជា ........................................ ៦៧

៨.២ ឥណទាន-សេវាមីក្រូហិរញ្ញវត្ថុ ........................................ ៦៨

៨.៣. គោលនយោបាយរដ្ឋាភិបាលក្នុងវិស័យឥណទានជនបទ ........................................ ៦៩

៨.៤ មីក្រូហិរញ្ញវត្ថុ និង ការអភិវឌ្ឍន៍ជនបទនៅកម្ពុជា ........................................ ៧០

**ជំពូក ៧ ឥណទានក្នុងសេដ្ឋកិច្ច**

៧.១ គោលដៅនៃការសិក្សា ........................................ ៧៤

**ជំពូក ៨ ការគ្រប់គ្រង និងការលើកទឹកចិត្តនៃឥណទានសំរាប់អ្នកប្រើប្រាស់**

៨.១ គោលដៅនៃការសិក្សា ........................................ ៨៧

៨.២ សកម្មភាពគ្រប់គ្រងឥណទាន ........................................ ៨៩

៨.២.១ ការបង្កើតនយោបាយ, បទបញ្ញត្តិ និងទំរង់ការ ........................................ ៨៩

៨.៣ ការរៀបចំនៅក្នុងផ្នែកឥណទាន ........................................ ៩០

៨.៣.១ ចាត់តាំងតាមមុខងារ ........................................ ៩០

៨.៣.២ការរៀបចំអតិថិជន ........................................ ៩១

៨.៤ការបង្កើតការត្រួតពិនិត្យការវាស់វែង ........................................ ៩១

៨.៥ ទីផ្សារកម្មវិធីឥណទាន ........................................ ៩១

៨.៥.១ តើអតិថិជនឥណទានណាមួយដែលគួរស្វែងរក? ........................................ ៩២

៨.៦. ប្រភពបន្ថែមសំរាប់ការលក់ជាឥណទាន ........................................ ៩៤

៨.៦.១ អតិថិជនថ្មី ........................................ ៩៤

៨.៦.២ អតិថិជនអសកម្ម ........................................ ៩៤

៨.៦.៣ អតិថិជនមានសកម្មភាព ........................................ ៩៤

៨.៧. ទីផ្សារចំរុះ ........................................ ៩៥

៨.៧.១ ផលិតផល ........................................ ៩៥

៨.៧.២ ថ្លៃ ........................................................................................................ ៩៥
៨.៧.៣ ទីកន្លែង........................................................................................................ ៩៦
៨.៧.៤ ការលើកទឹកចិត្ត ........................................................................................ ៩៦

**ជំពូក ៩ការស៊ើបអង្កេតឥណទានអ្នកប្រើប្រាស់**

៩.១ គោលដៅនៃការសិក្សា ........................................................................................ ៩៧
៩.១.១. ភាពពិត ឬយោបល់ ........................................................................................ ៩៧
៩.១.២ អ្វីជាការស៊ើបអង្កេត........................................................................................ ៩៨
៩.១.៣ គុណសម្បត្តិនៃការស៊ើបអង្កេតឥណទាន ........................................................ ១០០
៩.១.៤ អនុភាពនៃលក្ខខ័ណ្ឌសេដ្ឋកិច្ច........................................................................ ១០២
៩.១.៥ តើត្រូវធ្វើការស៊ើបអង្កេតប៉ុន្មាន........................................................................ ១០៣
៩.១.៦ កន្លែងណាដែលត្រូវស៊ើបអង្កេត........................................................................ ១០៣
៩.១.៧ ការផ្តត់ផ្គង់ពត៌មានដោយអ្នកស្នើសុំឥណទាន ................................................ ១០៣

**ជំពូក ១០ ប្រវត្តិនៃវិវត្តន៍របស់ប្រព័ន្ធមូលនិធិអន្តរជាតិ**

១០.១ មូលនិធិរូបិយវត្ថុអន្តរជាតិ ........................................................................................ ១០៦
១០.២ ធនាគារពិភពលោក ........................................................................................ ១០៦

**ជំពូកទី ១១ គោលបំណងនយោបាយរូបិយវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ**

១១.១ គោលបំណងនយោបាយរូបិយវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ................................ ១០៨
១១.២ ការបង្កើតការងារ ........................................................................................ ១០៨
១១.៣ វិបត្តិសេដ្ឋកិច្ច........................................................................................ ១១០
១១.៤ ស្ថេរភាពតំលៃទំនិញ-សេវាកម្ម........................................................................ ១១០
១១.៥ ស្ថេរភាពអត្រាការប្រាក់ ........................................................................................ ១១១
១១.៦ សុវត្ថិភាព និង ស្ថេរភាពទីផ្សារហិរញ្ញវត្ថុ ........................................................ ១១១
១១.៧ ស្ថេរភាពទីផ្សារប្តូរប្រាក់អន្តរជាតិ........................................................................ ១១១
១១.៨ គោលដៅជាយុទ្ធសាស្ត្រសំខាន់ៗរបស់រដ្ឋាភិបាល ................................................ ១១៣
១១.៩ ប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ........................................................................ ១១៣

# ជំពូក ១
# សញ្ញាណទូទៅនៃរូបិយវត្ថុ

## ១.១ ប្រវត្តិទូទៅនៃរូបិយវត្ថុអន្តរជាតិ និងកម្ពុជា

រូបិយវត្ថុដែលបានប្រើប្រាស់នៅលើពិភពលោករហូតដល់សព្វថ្ងៃនេះមានប្រវត្តិវែងឆ្ងាយណាស់ ដោយផ្អែកទៅលើឯកសារប្រទេសអង់គ្លេសដែលបានផ្សព្វផ្សាយជុំវិញពិភពលោក។ ប្រទេសក្រិកបានប្រើប្រាស់លុយលោហៈធាតុមុនគេបង្អស់កាលសតវត្សទី១៧ នាក្រុងលីឌី និងបន្ទាប់មកចក្រភពអង់គ្លេសដែលបានណែនាំប្រើប្រាស់លុយជាផ្លូវការដោយមានការទទួលស្គាល់ពីធនាគារអង់គ្លេស(The Bank of England)។រហូតមកដល់ពេលនេះធនាគារនេះមានអាយុជាង ២០០ ឆ្នាំមកហើយ។ លោក **អាដាម ស្មីត** (Adam Smith, 1723-1790) ជាសេដ្ឋកិច្ចអង់គ្លេសដ៏ល្បីល្បាញបានណែនាំពីអត្ថប្រយោជន៍នៃការ ប្រើប្រាស់រូបិយវត្ថុតាំងពីមុនការបើកធនាគារនេះទៅទៀត ។ ជាការរំលឹកគុណូបការៈគុណដល់លោក ធនាគារអង់គ្លេសបានយករូបលោកដាក់នៅក្នុងប្រាក់កាស១ផោន។

និយាយដោយឡែកសហរដ្ឋអាមេរិកបានឆ្លងកាត់ការផ្លាស់ប្តូរ នៃការប្រើប្រាស់ប្រភេទរូបិយវត្ថុជាច្រើនយ៉ាងពោល គឺមុនពេលសង្គ្រាមទាមទារឯករាជ្យពីអេស្បាញសហរដ្ឋបានប្រើរូបិយវត្ថុអេស្បាញដែលមានឈ្មោះថា Spanish Doubloons ។ ប្រាក់កាសលោហៈនេះមាន៨ចំណែក ដែលប្រើកាសជាប្រាក់រាយបាន ៨ភាគនៅពេលណាគេប្រើសំរាប់ដូរប្រាក់ (លុយអាប់)។ ក្រោយពេលអង់គ្លេសបានមកដល់ សហរដ្ឋបាន ប្រើប្រាស់ក្រដាស់ប្រាក់ (Notes) និងលុយកាស (Coins)មានលំនាំដូចធនាគារអង់គ្លេសដែរ ដោយគ្រាន់តែបញ្ចូលអត្តសញ្ញាណជាតិ និងវប្បធម៌អាមេរិក តែប៉ុណ្ណោះ ។ ដោយមានការរីកចំរើនសេដ្ឋកិច្ចសហព័ន្ធ និងការទទួលបានឯករាជ្យពីអាណានិគមអង់គ្លេស សហរដ្ឋអាមេរិកបានរួបរួម និងឯកភាពគ្នាលើការបង្កើតប្រព័ន្ធរូបិយវត្ថុដ៏ទំនើបដូចជាៈ ក្រដាសប្រាក់ ប្រាក់កាស មូលប្បទានប័ត្រ ឥណទាន និងអេឡិចត្រូនិច រូបិយវត្ថុ។ បច្ចុប្បន្ននេះពិភពលោកទាំងមូលឈានដល់ដំណាក់កាលប្រើប្រាស់ដូចគ្នាទៅនឹងសហរដ្ឋអាមេរិក លើកលែងតែបណ្តាប្រទេសតតិយលោកមួយចំនួន។ គួរកត់សម្គាល់ថារូបិយវត្ថុតែងតែមានការផ្លាស់ប្តូរ រចនាបទរបស់វាទៅតាមវប្បធម៌ សេដ្ឋកិច្ច និងនយោបាយប្រទេស។ នៅបណ្តាប្រទេសខ្លះ គេនៅតែនិយម ប្រើការដោះដូរជាផលិតផល និងអាចប្រើរូបិយប័ណ្ណបរទេសដូចជាៈ ប្រទេសជីកោះប៉ាស៊ីហ្វិក និងអាហ្វ្រិកមួយចំនួនដែលបានប្រើក្រដាស់ប្រាក់អូស្ត្រាលី អាមេរិក និងហ្វ្រង់បារាំង ។ គេសម្គាល់ប្រទេសទាំងនោះមានលក្ខណៈពាណិជ្ជកម្មអន្តរជាតិទាប និងចំនួនប្រជាករតិចផងដែរ។ ប្រទេសមួយចំនួននិយមប្រើឈ្មោះដុល្លាដូចគ្នា តែខុសគ្នាដោយឈ្មោះប្រទេសពីមុខ ដាក់ស្តែង Singapore Dollar and American Dollar ។

នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជារូបិយវត្ថុខ្មែរត្រូវបានប្រើប្រាស់តាំងពីសម័យនគរភ្នំសតវត្សទី១ នៃគ្រឹះ សករាជដោយសារការជីក (Soil Profile) នៅតំបន់ភ្នំដិន ខេត្តតាកែវរបស់ក្រុមភូមិសាស្ត្រ និងបូរាណ វិទូហើយស្របគ្នាទៅនិងការរកឃើញរបស់បារាំងនៅកំពង់ផែអុកកែវ ខេត្តអានយ៉ាងទឹកដីកម្ពុជាក្រោម។ សម័យកាលនោះគេប្រើរូបិយវត្ថុដែលមានរូបខ្យងសាំង និងព្រះអាទិត្យ។ រូបិយវត្ថុដែល

គេប្រើប្រាស់នោះ គឺជាគហបណៈមាសប្រាក់ សម្រាប់ជាមធ្យោបាយក្នុងការដោះដូរទំនិញ។ នៅអំឡុងសតវត្សទី៩-១០ នគរខ្មែរមានពាណិជ្ជកម្មជាមួយចក្រភពរ៉ូម៉ាំងដោយសារសំណាកសំណល់លុយកាក់ក្នុងព្រះបរមរាជវាំង។ រូបរាងរបស់គហបណៈប្រែប្រួលទៅតាមទំហំនៃសាច់ប្រាក់ និងវិវត្តន៍តាមសម័យកាល ( Cambodian Currency, National Bank Achieve, 2000 )។ នៅក្នុងសតវត្សទី១នៃគ្រឹះសករាជ រហូតសម័យអង្គរ រាជាណាចក្រខ្មែរប្រើរូបិយវត្ថុដែលមានរាងស្នូកជ្រូក រាងចតុកោណស្មើ រហូតដល់រាងដូចមាស-ប្រាក់ សន្លឹកនាពេលបច្ចុប្បន្នកាលនេះ បើយោងទៅលើភស្តុតាងប្រវត្តិសាស្ត្រដែលរកឃើញដោយក្រុមអ្នកភូមិសាស្ត្រកម្ពុជាកាលសម័យអាណានិគមបារាំង ដែលរកឃើញនៅម្លូវព្រៃនិងតាមការសិក្សារបស់អ្នកស្រី ត្រឹង ងាន សាស្ត្រាចារ្យប្រវត្តិសាស្ត្រកម្ពុជាដែលសរសេរកាលពីសម័យសង្គមរាស្ត្រនិយម ។ នៅលើមាសសន្លឹកគឺបាន ប្រថាប់ត្រាសម្គាល់នូវទំហំសាច់ប្រាក់ទៅតាមទម្ងន់ និងផ្ទៃរបស់វា។ នាសម័យកាលនោះការចាយវាយមានអារិយភាពតាំងពីយូរណាស់មកហើយ បើប្រៀបទៅនឹងប្រទេសអឺរ៉ុប និងអាស៊ីមួយចំនួនដែលពាក្យនេះបានសរសេរនៅក្នុងសៀវភៅមួយរបស់ជនជាតិព័រទុយហ្គាលដែលបានមកដល់កម្ពុជាមុនពេលដំណើរមកដល់របស់បារាំងសេសដោយគ្រោះថ្នាក់ខ្យល់ព្យុះ ហើយមិនបានចូលទៅឥណ្ឌូនេស៊ី តែបែរជាធ្លាក់មកដល់ឈូងសមុទ្រខ្មែរវិញ។

បើយើងនិយាយជាគោលការណ៍ ប្រទេសកម្ពុជាបានប្រើប្រាស់រូបិយវត្ថុជាផ្លូវការមុនបច្ចឹមប្រទេសប្រមាណ១០០០ ឆ្នាំ និង ១៦០០ ឆ្នាំមុនបណ្ដាប្រទេសក្រិក និង អង់គ្លេស តែគួរអោយស្ដាយណាស់ការផ្សព្វផ្សាយឯកសារជាតិមិនបានទូលំទូលាយទៅដល់កម្រិតអន្តរជាតិ។ ប៉ុន្តែពុំមានឯកសារណាមួយបញ្ជាក់ពី ផលវិបាកណាមួយនៃការចាយវាយនោះទេ នេះប្រហែលជាសង្គមខ្មែរសម័យកាលនោះពោរពេញដោយជីវភាពធូរធារ និងមនុស្សប្រកបដោយចរិយាធម៌។ រីឯឈ្មោះទៀតសោតមានការហៅខុសគ្នា ដែលនៅតំបន់រដ្ឋភាគកណ្ដាលគេហៅថារៀល តំបន់រដ្ឋភាគខាងជើងគេហៅថាត្រណោត និងតំបន់រដ្ឋភាគខាងក្រោមគេហៅថា ស្លឹង។ រហូតដល់សម័យអង្គឌូង ប្រទេសកម្ពុជាមានប្រើប្រាស់លុយលង្ហិនដែលគេហៅថាប្រាក់ឌូង។ គេបានរកឃើញលុយនេះនៅតំបន់មាត់ទន្លេជិតវត្តវាំងចាស់ ស្រុកឧត្តុង្គ។ ផ្ទាំងគំនូរស្ដីពីជីវភាពអ្នកសម័យឧត្តុង្គមានតាំងនៅសារៈមន្ទីរជាតិបារាំង បានឆ្លុះបញ្ចាំងពីចរាចររូបិយវត្ថុសម័យកាលនោះ ។

ក្រោយមកមានការផ្លាស់ប្ដូរទាំងស្រុងបន្ទាប់ពីរការចូលមកនៃពួកអាណានិគមបារាំង នាពេលដែលប្រទេសយើងពោរពេញដោយការហែហូរនៃសង្គ្រាម។ បារាំងបានប្រមូលយកមាសសន្លឹក និងប្រាក់សន្លឹកទុក ដោយគេយល់ឃើញថាៈ មាសសន្លឹកមានតម្លៃសម្រាប់ប្រើប្រាស់ដទៃទៀត និងពិបាកចាយវាយ ។ ក្នុងសម័យអាណានិគមបារាំងប្រទេសកម្ពុជាស្ថិតនៅក្នុងការគ្រប់គ្រងរបស់បារាំងដែលហាក់ដូចជារដ្ឋមួយនៃឥណ្ឌូចិន នាពេលនោះយើងបានប្រើប្រាស់ក្រដាស់ប្រាក់កាសរួមមួយហៅថាពីយ៉ាស្រ្ទី Piastre។ក្រដាស់ប្រាក់មានតម្លៃធំជាងគេគឺ១០០ពីយ៉ាស្រ្ទី ដែលមានរូបស្រ្តីបីនាក់ដែលតំណាងអោយស្រ្តីនៃប្រទេសទាំងបី នៃឥណ្ឌូចិន និងម្ខាងទៀតមានរូបអង្គរវត្ត។ គិតចាប់តាំងពីពេលដែលកម្ពុជាទទួលបានឯករាជ្យ យើងបានប្រើប្រាស់ក្រដាស់ប្រាក់ជារៀលជាមធ្យោបាយនៃការដោះដូរនាថ្ងៃទី២៣ ធ្នូ ឆ្នាំ ១៩៥៤ ទន្ទឹមនឹងការបង្កើតធនាគារជាតិនៃកម្ពុជា។ ការប្រើឈ្មោះប្រាក់រៀលប្រហែល

ផ្អែកទៅលើការនិយមហៅរបស់ពលរដ្ឋ-ខ្មែរដែលមានចំនួនដ៏ច្រើនលើសលប់។ ប្រហែលជាពាក់ កណ្តាលដើមទសវត្សទី៥០ ក្រដាស់ប្រាក់ខ្មែរមានសិទ្ធ ហែកពាក់កណ្តាលជាពីរ ចាយ សម្រាប់ជាលុយអាប់។ នេះប្រហែលជាតំរូវការរូបិយវត្ថុជាច្រើនពេក នៅពេលដែលកំនើនប្រជាជនកើន និងការហូរចូលនៃជនអន្តោប្រវេសន៍ពីវៀតណាម និង ចិន។ នាពេលបច្ចុប្បន្ននេះប្រាក់កាសទាំងអស់ និង ក្រដាស់ប្រាក់រៀលដែលមានតម្លៃតូចៗមិនមានចរាចរទៀតទេ (ក្រដាសប្រាក់ តូចជាង ៥០ រៀល)គឺនៅសល់តែក្រដាសប្រាក់រៀលដែលមានតម្លៃធំសម្រាប់ការចាយវាយប៉ុណ្ណោះ។

- **និយមន័យរូបិយវត្ថុ**

មនុស្សជាច្រើនបានស្គាល់ពាក្យថា**រូបិយវត្ថុ** រឺ ភាសាសាមញ្ញមួយហៅថា **លុយ** ប៉ុន្តែមានពេលខ្លះគេពិបាករកពាក្យមកពន្យល់ថា អ្វីទៅជាលុយនោះ? តាមធម្មតាយើងអាចអោយនិយមន័យច្រើនយ៉ាងទៅលើពាក្យនេះតែសម្រាប់សិក្សាសេដ្ឋកិច្ចជាពិសេសការគ្រប់គ្រងធនាគារនិងហិរញ្ញវត្ថុវិញគេត្រូវការនិយមន័យដ៏ជាក់លាក់មួយសម្រាប់ការងារ និងសម្រួលដល់ការកំណត់ប្រើប្រាស់។ គេអោយនិយមន័យរូបិយវត្ថុថា: ***គឺជាអ្វីដែលត្រូវបានគេទទួលស្គាល់ជាទូទៅនិងត្រូវបានគេប្រើប្រាស់ ដោយផ្ទាល់នៅក្នុងការទិញទំនិញ, សេវា នានា*** ឬ អាចហៅម៉្យាងទៀតថា ***ជាមធ្យោបាយនៃការចាយវាយទូទាត់បំណុលដែលត្រូវបានគេទទួលស្គាល់ជា សកល និងមាននៅក្នុងដៃអ្នកសេដ្ឋកិច្ចទៀត។*** ជាការពិតណាស់ និយមន័យនេះត្រូវបានគេប្រើប្រាស់ជាទូទៅ ប៉ុន្តែយើងក៏ត្រូវធ្វើការកត់សម្គាល់ថារូបិយប័ណ្ណដូចជា: មូលប្បទានប័ត្រ និងឥណទានក៏ជារូបិយវត្ថុដែរព្រោះវាអាចបង្វិលជាប្រាក់កាសពីធនាគារ បានហើយគេក៏អាចយកវាមកផ្ទេរដូចជាបរិមាណរូបិយវត្ថុដល់ជនណាម្នាក់ រឺទិញទំនិញ-សេវាកម្មបានដូចគ្នា។ ទន្ទឹមនឹងនេះផងដែរ បរិមាណរូបិយវត្ថុគឺឆ្លុះបញ្ចាំងពីទ្រព្យសម្បត្តិ និងទ្រព្យទុនដ៏ទៃទៀត។ ឧទាហរណ៍ លោកគង់ មានលុយច្រើនណាស់ មានន័យថាគាត់មានទ្រព្យសម្បត្តិ ច្រើនដូចជា ឡាន ផ្ទះ ក្រុមហ៊ុន និង អចលនទ្រព្យជាច្រើនទៀត។**១.២ មុខងាររូបិយវត្ថុ**

រូបិយវត្ថុបានបំរើអតិថិជនក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ជាពិសេសក្នុងដំណើរការជំនួញក្តី និងសេវាកម្ម ហិរញ្ញវត្ថុក្តី។ រូបិយវត្ថុ មានតួនាទីពីរសំខាន់ទៅក្នុងសេដ្ឋកិច្ច។ តួនាទីទីមួយ គឺសម្រាប់បែងចែកពលកម្ម និង ជំនាញផលិតកម្មនៅក្នុង សង្គមអារិយធម៌ (The role of money in economy is that the use of money allowed division of labor and specialization in the civilization world) ។ វាជាការពិតណាស់ ផលិតផលសរុបកាន់តែខ្ពស់ដរាបណាបុគ្គលិកប្រកបដោយជំនាញ និងបំពេញការគ្រប់គ្រង បានជោគជ័យហើយ អ្វីៗដែលយើងបានលុះណាតែមានការដូរលុយ និងការងារសម្រាប់ស្តេរភាពជីវភាព។ ក្រៅពីនេះរូបិយវត្ថុ អាចមានតួនាទីទី២ សម្រាប់ចូលរួមបង្កើតទ្រព្យក្នុងសង្គមតាមរយៈជំនាញ និងពាណិជ្ជកម្ម រឺតាមរយៈការប្រាក់។ ដោយឡែករូបិយវត្ថុបានបំពេញមុខងារបួនយ៉ាងសំខាន់ ទៀតគឺ:

- សំភារៈ រឺគ្រឿងដំណូរ (Medium of Exchange)

សំភារៈដំណូរគឺជាការទទួលស្គាល់ជាទូទៅរវាងអ្នកលក់ និងអ្នកទិញក្នុងការដោះដូរទំនិញ និងសេវាកម្មទៅវិញទៅមក។ សំភារៈដំណូរអាចធ្វើការដោះដូរដោយផ្ទាល់គេហៅថាៈពាណិជ្ជកម្មតាមរូបភាពផ្លាស់ប្តូរទំនិញដោយមិនចាំបាច់ប្រើក្រដាស់ប្រាក់ (Barter)។ ឧទាហរណ៍ លោកអ្នកអាចធ្វើការដោះដូរដោយផ្ទាល់រវាង អង្ករ និងក្រូចពោធិសាត់ តាមសមាមាត្រដែលអ្នកព្រមព្រៀងគ្នា។ ម៉្យាងទៀតលោក-អ្នក បានដឹងហើយថាកាលពីមុនពេលបោះឆ្នោតនៅស្រុកយើង គេសម្គាល់ឃើញថាមានការដោះដូរសំភារៈ រវាងប្រទេសអតីតប្លុកសង្គមនិយម និងកម្ពុជា ដូចជា ការផ្លាស់ប្តូរ កៅស៊ូក្រែប និងឡានដឹកជញ្ជូនពីសហភាពសូវៀត ។ ទោះបីនាពេលបច្ចុប្បន្ននេះការដោះដូរផលិតផលស្ទើរគ្មានរូបរាងក៏ដោយ (លើកលែងតំបន់ដាច់ស្រយាល) គេសង្កេតឃើញមានការចាយរូបិប័ណ្ណដូចជាមូលប្បទានប័ត្រ និងឥណទាន (Check and Credit)។ ឧទាហរណ៍យើងអាចប្រើមូលប្បប័ត្រដែលចេញដោយធនាគារកាណាឌីយ៉ាសម្រាប់ចាយវាយនៅតាមភោជនីយដ្ឋានធំៗមួយចំនួន និងផ្សារស្វ័យសេវាមួយចំនួននៅកម្ពុជា។

លក្ខណៈពិសេសមួយដែលសំភារៈដំណូរនេះអាចប្រព្រឹត្តទៅបានដោយសារ ភាពគាប់ជួននៃតំរូវការ (Double Coincidence of wants) មានន័យថា រាល់ស្ថានភាពដែលអ្នកលក់ អ្នកទិញមានសេចក្តីត្រូវការដូចគ្នាក្នុងការដោះដូរទំនិញ រឺផលិតផល រឺសំភារៈដំណូរផ្សេងៗ។ ឧទាហរណ៍ៈ នាងណារីចង់បានក្រវិលមួយគូ ដោយព្រមដូរជាមួយអង្ករ ៥០ គីឡូក្រាម ហើយលោកសុភាពចង់បានអង្ករសម្រាប់ចិញ្ចឹមជីវិតដោយយល់ព្រម ដូរក្រវិល ១ ដីរបស់ប្រពន្ធគាត់ទៅអោយនាងណារី។ដូចនេះអ្នកទាំងពីរមានសេចក្តីត្រូវការដែលអាចដោះដូរបានទៅវិញទៅមក។ ទោះបីយ៉ាងណាក៏ដោយ គ្រឿងដំណូរជួបការលំបាកមួយចំនួន ដែលបង្កអោយស្ថានភាពដោះដូររបៀបនេះប្រព្រឹត្តិទៅមិនបានល្អ។ ផលវិបាកទី១គឺៈ ចំណាយពេលវេលាច្រើនសម្រាប់រកដៃគូដោះដូរ។ ផលវិបាកទី២ៈ មិនអាចប្រើប្រាស់ទូលំទូលាយជាក់ស្តែងមូលប្បទានប័ត្រមិនបានទទួលស្គាល់ជាទូទៅតាម កន្លែងរានលក់តំនិញទេ។ ផលវិបាកទី៣ៈ ការរកភាពកាប់ជួននៃសេចក្តីត្រូវការពិតជាពិបាក និងអាចធ្វើ អោយការដោះដូរគ្មានប្រសិទ្ធភាព។ ដោយយោងទៅលើស្ថានភាពខាងលើនេះ យើងអាចសន្និដ្ឋានថាគ្រឿង រឺ សំភារៈដំណូរពិតជាមិនស្របសំរាប់ការចាយវាយជាទូទៅបានទេ។ ហេតុនេះហើយបានជាអតិថិជនបានទទួលស្គាល់ថារូបិយវត្ថុពិតជាមានអត្ថប្រយោជន៍សំខាន់ប្រៀបបីដូចជាប្រេងរំអិលដែលជួយជំរុញ ចលករ ម៉ាស៊ីនបានលឿន និងរលូន។ សូមមេត្តាតាមដានរូបខាងក្រោមៈ




- **ឯកតាគណនី**

រូបិយវត្ថុមានមុខងារទីពីរគឺជាឯកតាគណនីដែលប្រៀបបីដូចជាខ្នាតក្នុងការប្រើប្រាស់ដែរ ។ ឯកតាគណនី គឺជាការវាស់វែងស្ថានភាពថ្លៃនាពេលដែលអ្នកប្រើប្រាស់ រឺ អតិថិជនបានគិតគូរអំពីតំលៃសមស្របនៃទំនិញនិង សេវាកម្មដែលគេចង់បាន។ អតិថិជនតែងតែធ្វើការប្រៀបធៀបផងដែរនូវតំលៃ និង ប្រភេទទំនិញ និងសេវាកម្ម ដែលគេចង់បាន ។ ឧទាហរណ៍ ប្រសិនបើលោកអ្នកមើលលើតំលៃកាហ្វេ (១២០០ រៀល )និងសំបុត្រភាពយន្ត នៅវិមានទិព្វ (៣៦០០រៀល)លោកអ្នកពិតជាគិតថាតំលៃសំបុត្រចូលទស្សនាភាពយន្តលើសពីតំលៃកាហ្វេ៣ដង។ ហេតុនេះឯកតាគណនីជួយអ្នកគិតពីការសំរេចចិត្តតាមទឹកលុយ និង ចំណង់ចំណូលចិត្ត ។ លោកអ្នកអាចវិភាគបាន យ៉ាងស្រួលថាតើការប្រើប្រាស់លុយងាយស្រួលយ៉ាងណាបើប្រៀបទៅនឹងសំភារៈដំណូរ ។ លោកអ្នកពិតជាយល់ថាការរស់នៅក្នុងសង្គមអរិយធម៌មានភាពប្រសើរជាងសម័យបុរាណព្រោះថា លោកអ្នកមិនចាំបាច់កាន់កាហ្វេ៣កែវធ្វើដំណើរទៅដូរសំបុត្រភាពយន្តមួយ ។

បើយើងអោយ P ជាចំនួនថ្លៃនៅក្នុងសេដ្ឋកិច្ចបែប Barter និង n ជាចំនួនមុខទំនិញដែលត្រូវយកមកធ្វើការ ដោះដូរ នោះគេបានរូបមន្តមួយគឺៈ

| **អត្រាដោះដូរ ឬ ថ្លៃ** (Exchange rate or Prices) $P = n(n-1)/2$ |
|---|

តារាង១.១ បង្ហាញថារូបិយវត្ថុជាឯកតាទូទាត់បានកាត់បន្ថយថ្លៃលើប្រតិបត្តិការដោះដូរតាមរយៈការកាត់បន្ថយចំនួនថ្លៃ។ ជាការពិតណាស់នៅពេលដែលសេដ្ឋកិច្ចកើនឡើងកាន់តែខ្លាំងនោះ ក៏កាន់តែមានភាពស្មុគស្មាញ ខ្លាំងណាស់ដែរនោះអត្ថប្រយោជន៍ដែលបានពីការប្រើប្រាស់រូបិយវត្ថុកើនឡើង ។ ការប្រើប្រាស់រូបិយវត្ថុបានកាត់ បន្ថយនូវពេលវេលាដែលគេត្រូវការដើម្បីធ្វើការសំរេចចិត្តខាងសេដ្ឋកិច្ចឱ្យបានកាន់តែល្អហើយជាលទ្ធផលនាំឱ្យកាន់តែមានប្រសិទ្ធិភាពថែមទៀតនៅក្នុងសេដ្ឋកិច្ច។

តារាង១.១៖ ចំនួនថ្លៃក្នុងសេដ្ឋកិច្ច Barter ធៀបទៅនឹងសេដ្ឋកិច្ចរូបិយវត្ថុ

| ចំនួនទំនិញដែលយកដោះដូរ | ចំនួនថ្លៃនៅក្នុងសេដ្ឋកិច្ចBarter | ចំនួនថ្លៃនៅក្នុងសេដ្ឋកិច្ចរូបិយវត្ថុ |
|---|---|---|
| 3 | 3 | 3 |
| 4 | 6 | 4 |
| 5 | 10 | 5 |
| 10 | 45 | 10 |
| 100 | 4950 | 100 |
| 1000 | 499500 | 1000 |
| 10000 | 49995000 | 10000 |

- **ការរក្សា រឺ បន្ទុកតំលៃ** (Stores of Value)

សំដៅទៅលើផលិតផល រឺ ទំនិញទាំងឡាយ រឺ វត្ថុតាងនានាដែលអាចយកទៅប្រើប្រាស់ជាផ្លូវក្នុងការដោះដូរ ទំនិញ និងសេវាកម្មក្រោយពីការកាន់កាប់ទុកមួយរយៈ ។ ឧទាហរណ៍ យើងទុកមាស រឺ ពេជ្រ រឺ អចលនទ្រព្យ ផ្សេងៗមួយរយៈក្រោយមកយើងអាចយកទៅលក់ និងទិញទំនិញសំរាប់ប្រើប្រាស់បាន ។ គួរកត់សំគាល់ថាការ រក្សាទុកមាស រឺពេជ្រ រឺអចលនទ្រព្យនេះ គឺទាក់ទងទៅនឹងចិត្តសាស្ត្រអតិថិជន ព្រោះគេយល់ថា: (១)ការទុកទ្រព្យទាំងនេះអាចជៀសវាងបាននូវការចាយវាយលឿនពេក រឺដើម្បីបង្កើនការសន្សំសំចៃ។ (២)ប្រើប្រាស់ផ្ទាល់ខ្លួនសំរាប់គ្រឿងសំអាងដែលរូបិយវត្ថុ គ្មានលទ្ធភាពផ្តល់បាន (៣)ការទុកអបលនទ្រព្យផ្តល់នូវផលចំណេញក្នុងរយៈពេលវេងចាំដូចជា ផ្ទះសំបែង និងវត្ថុបញ្ចាំ (ប៉ុន្តែមានករណីខ្លះដែលអាចខាតផងដែរប្រសិនបើមានរំលោះ រឺ ភាពប្រចុយប្រថាន)។ នៅក្នុងករណីទី៣ គេសំគាល់ថាអ្នកជំនួញ រឺអ្នកមានទុនទ្រព្យច្រើននិយមវិនិយោគ ដោយសារ គេអាចជៀសវាងរួចពីអតិផរណាខ្ពស់ដែលកើតឡើងនៅពេលអតិផរណាអាចប្រមើលមើលបាន ពោល គាត់អាចជៀសផុតពីការធ្លាក់ចុះតំលៃរូបិយវត្ថុ ការបោះចោលធនធានក្នុងធុងសំរាម និងការបាត់បង់ការសន្សំសំចៃ ។ ផ្ទុយមកវិញ រូបិយវត្ថុនៅតែជាទីពេញនិយមក្នុងករណីទូទៅដោយសារ ការបង្វិលមានភាពងាយស្រួល ជាងអចលនទ្រព្យ និងមិនចាំបាច់ចំណាយពេលដកសាច់ប្រាក់ រឺ ថ្លៃដើមប្រតិបត្តិការ (Transaction costs) ។ ករណីមួយទៀតដែលគេសំគាល់ឃើញទៅលើផ្ទះសំបែងដែលមានការសង្កត់តំលៃនាពេលណាដែលម្ចាស់ចង់លក់ជា ពិសេសពេលគេជួបស្ថានភាពផុនដាប រឺតំរូវការចៃដន្យ ហេតុនេះរូបិយវត្ថុជាទ្រព្យសកម្មដែលងាយស្រួលដោះស្រាយបានភ្លាមៗ។

**•បទដ្ឋានពន្យាចំណាយ**

ប្រសិនបើរាស្ត្រយល់ព្រមលើកិច្ចសន្យាកំចី គេនឹងសងនាពេលអនាគតជាចំនួនទឹកលុយតាមកិច្ចព្រមព្រៀង ។ ការសន្មត់នូវរូបិយវត្ថុដែលអនុញ្ញាតិអោយគេប្រើប្រាស់មួយរយៈ និងមធ្យោបាយដែលគេវាយតំលៃទទួលបានមកពីកំចីនាពេលអនាគតតាមរយៈការយល់ព្រមលើកិច្ចសន្យា គេហៅថា បទដ្ឋានពន្យាចំណាយ ។ ឧទាហរណ៍ សុខខ្ចីពីធនាគារ ១០០.០០០ ដុល្លា គាត់នឹងសងជាទឹកលុយវិញ តាមកិច្ចសន្យារយៈពេល៣ឆ្នាំ ដែលមានចែងក្នុង កិច្ចព្រមព្រៀង ។

## ១.៣ ទំរង់រូបិយវត្ថុ

ទំរង់រូបិយវត្ថុ (ប្រភេទរូបិយវត្ថុ)ប្រែប្រួលតាមប្រព័ន្ធនៃការទូទាត់ដែលមានការផ្លាស់ប្តូរតាមសម័យកាល និង ទីកន្លែង ។ ទំរង់នេះមានការអភិវឌ្ឍន៍តាមការយល់ដឹងរបស់មនុស្សជាតិ បទពិសោធន៍ដែលឆ្លងកាត់ពីផលវិបាកនៃការ ប្រើប្រាស់ និងភាពងាយស្រួលនានាដែលទាមទារអោយធនាគារបង្កើតឡើង ។ ឧទាហរណ៍ក្នុងសម័យដើមរាស្ត្រនិយម ប្រើគហបណមាស រឺ ប្រាក់សំរាប់ការដោះដូរ តែក្រោយមកគេបានបង្កើតក្រិត្យរូបិយវត្ថុ ដោយសារគុណសម្បត្តិជាច្រើន របស់វាដែលយើងអាចដឹងបានតាមរយៈការអានទំរង់រូបិយវត្ថុខាងក្រោមនេះ។ រូបិយវត្ថុអាចបែងចែកជាបួនទំរង់សំខាន់ៗ:

- ផលិតផលរូបិយវត្ថុ គឺជារូបលក្ខណៈផលិតផលដែលមានតំលៃពិតប្រាកដ ហើយគេក៏អាចប្រើប្រាស់វាជាមធ្យោបាយសំរាប់ការដោះដូរ ។ ទំរង់រូបិយវត្ថុនេះ គឺជាទូទៅធ្វើអំពីលោហៈ ដែលគេបានជួបប្រទះនៅលើដី នៃទីក្រុងមួយក្នុងប្រទេសក្រិកនាដើមសតវត្សទី ១៧ ។ ជួនកាល គេក៏អាចជួបប្រទះផងដែរនូវការប្រើប្រាស់ ទំនិញ និងទំនិញសំរាប់ការដោះដូរ ជាពិសេសក្រោយពេលរំដោះពីរបបខ្មែរក្រហមនាឆ្នាំ១៩៧៩។ ផលិតផលរូបិយវត្ថុអាចជាកាសលោហៈ គហបណៈ មាស ប្រាក់ រឺចំរុះលោហៈ ផលិតផលផ្សេងៗ រឺកាសអេស្បាញ (Spanish Doubloons)។ កាលពីឆ្នាំ ១៨១៣ ទេសាភិបាល អូស្ត្រាលី Maquarie បានសំរេចចិត្តអោយបំបែកកាសលោហៈនេះជាបំនែកតូចៗ គឺប្រៀបដូចគ្នានឹងសម័យកាលដើមនៃកម្ពុជាដែល គេអាចបំបែកគហបណៈមាស រឺប្រាក់ជាបំនែកតូចៗដែរហើយគេនៅតែអាចចាយវាយបានដោយផ្អែកលើ ប្រព័ន្ធខ្នាតតូច រឺធំ ។ មូលហេតុនៃការបំបែកនេះដោយសារមូលហេតុពីរយ៉ាងគឺ៖ (១) តំរូវការបរិមាណរូបិយវត្ថុសំរាប់ចរាចរកើនឡើង ។ ការកើនឡើងនូវតំរូវការនេះគឺបណ្តាលមកពីមូលហេតុចំបងនៃកំនើនប្រជាជន ជាពិសេសវាមានលក្ខណៈដូចគ្នានឹង ពាក់កណ្តាលទសវត្សទី៥០ ដែលការហែក លុយជាពីរ ពាក់កណ្តាលសំរាប់ចាយវាយដោយសារកំនើនប្រជាជនក្នុងប្រទេសនិងអន្តោប្រវេសន៍ពីចិនដីគោក និងវៀតណាមមកប្រទេសកម្ពុជា ។ (២) ទំរង់លោហៈនោះវាធ្ងន់ពេកនិងពិបាកចាយវាយ។ វាមានព្រឹត្តិការណ៍ដូចគ្នាទៅនឹងមូលហេតុទី២ របស់បារាំងក្នុងប្រមូលប្រាក់ខ្ទង់ និងកាសជាមាស ប្រាក់នាសម័យអាណានិគមនិយម ។ គួរកត់សំគាល់ថាការប្រើប្រាស់ផលិតផលរូបិយវត្ថុមានផលវិបាកពីរយ៉ាងគឺៈ

ក. ការទាស់ទែងគ្នាដោយសារមានបំណងឆបោកពីតំលៃទឹកប្រាក់ ។ ឧទាហរណ៍ការប្រើអង្ករសំរាប់ចាយវាយពិតជាមិនងាយស្រួលទេ ដោយសារកំប៉ុងសំរាប់វាល់អង្ករមានប្រព័ន្ធខ្នាតបន្លំជាមួយភាពផត និង ប៉ាំងនៃកំប៉ុង ។ ចំនែកការប្រើប្រាស់លោហៈក៏មានបញ្ហាជាច្រើនដែរដូចជាការលួចឆៀរចេញ (Clipping) និងការបញ្ចុះទឹកមាស រឺ ប្រាក់ (Debasement) ។ ការលួចឆៀរចេញ គឺជាការបន្ថយ បរិមាណរឺកំរាស់ នៃលោហៈជាកាសដែលយើងពិបាកប៉ាន់ស្មានដោយផ្ទាល់ភ្នែកដែលជាហេតុ បណ្តាលអោយទំងន់របស់វាស្រាលជាងមុន ។ ការបញ្ចុះទឹកមាស រឺប្រាក់ គឺជាការលួចបន្លំសមាសភាគមាស រឺប្រាក់ ដែលទោះបីជាទំងន់របស់វានៅដដែល តែគេជំនួសលាយជាមួយលោហៈដែលថោកជាងដូចជា ស្ពាន់ រឺដែក រឺសំណ ។

ការលួចបន្លំនេះត្រូវបានរកដំណោះស្រាយដោយលោក Gresham ដែលក្រោយមកគេហៅច្បាប់នេះ ថា Gresham's law ។ លោក Gresham ជាអ្នកជំនាញហិរញ្ញវត្ថុអង់គ្លេសនាសតវត្សទី១៦ ដែលបាន ធ្វើការសិក្សាប្រៀបធៀបរវាងផលិតផលបន្លំ និងមិនបន្លំតាមរយៈទំងន់ ដោយឡែកការលួចទឹកមាស រឺ ប្រាក់មានការលំបាកបន្តិច ។ យោងតាមលក្ខខ័ណ្ឌនេះលោកសំរេចចិត្តប្រើ លោហៈដែលមានតំលៃ ថោកជាងគេសំរាប់ប្រើប្រាស់ (ប្រាក់កាសដែក) ព្រោះច្បាប់របស់លោកចែងថា៖ អ្នកប្រើកាសលួច ទឹកមាស រឺ ប្រាក់បន្លំកើនឡើងរហូតដល់ពេល ណាដែលប្រាក់កាស រឺ មាសសុទ្ធ

បាន រលត់ចេញពីទីផ្សាររូបិយវត្ថុ ។ លក្ខខ័ណ្ឌនៃការរលត់បាត់ ផលិតផលសុទ្ធគេហៅថា ***ភាពស្ងួតនៃផលិតផលល្អ***។

ខ. ការបាត់បង់ឱកាស ពីព្រោះផលិតផលរូបិយវត្ថុមានតំលៃសំរាប់ការប្រើប្រាស់ដទៃទៀតដូចជាគ្រឿងសំអាង និងវត្ថុជាតុដើមក្នុងបច្ចេកវិទ្យាយុទ្ធភ័ណ្ឌ ។ នៅជំនាន់អាណានិគមបារាំង លុយកាសមាសប្រាក់ ត្រូវបានបារាំងប្រមូលទុក ដោយសារលុយទាំងនេះអាចយកទៅប្រើនៅ ក្នុងផ្នែកបច្ចេកវិទ្យាយោធា។

- រូបិយប័ណ្ណដែលអាចប្តូរជាសាច់ប្រាក់គឺជាក្រដាស់ដែលអាចបញ្ជាក់ពីលទ្ធភាពនៃការដោនដូរតាមរយៈការ ចេញអោយចរាចរដោយហាងសម្បត្តិ ។ ឧទាហរណ៍ ក្រដាស់ប្រាក់ នេះបានប្រើប្រាស់ នៅប្រទេសចិន ក្នុង រាជវង្សម៉េង ១៣៦៨-៩៩។ វាជាក្រដាសទទួលប្រាក់ មានពណ៌មាស ហើយតំលៃរបស់វាប្រែប្រួលទៅតាម ការកំនត់របស់ អ្នកចេញអោយប្រើព្រមជាមួយគ្នានេះ គេអាចប្រើប្រាស់ វាជាកម្មសិទ្ធកំចីនិងជំពាក់។ គេកត់សំគាល់ថា រូបិយប័ណ្ណប្រៀបបី ដូចជាមូលប្បទានប័ត្រសម័យដើមអញ្ចឹង និងប្រហែលជាពាក់កណ្តាលសហសតវត្សបណ្តាប្រទេសអឺរ៉ុប ភាគច្រើនបានចំលងយកទៅប្រើប្រាស់ដោយជនពនេចរអ៊ីតាលីម្នាក់ ដែលជនរូបនេះក៏បានចំលងយកនូវប្បធម៌ហូបចុកផងដែរ ។ ដោយសារការវិវត្តិការប្រើប្រាស់រូបិយប័ណ្ណនេះនៅអឺរ៉ុបគេសង្កេតឃើញហាងសម្បត្តិ ដ៏ល្បីឈ្មោះមួយគឺឈ្មោះ Goldsmiths ជួបបញ្ហាដ៏ធ្ងន់ធ្ងរ ព្រោះអតិថិជនយក រូបិយប័ណ្ណមកដូរយកមាសសំរាប់ធ្វើគ្រឿងសំអាង ហេតុនេះមាសដែលស្តុកអាចរលំរលាយ ។ ពេលនោះ Goldsmiths បានរកឃើញវិធីសាស្ត្រមួយគឺ អត្រាការប្រាក់សំរាប់អ្នកយករូបិយប័ណ្ណមកដូរយកមាស ។ ដូច្នេះ ធនាគារបច្ចុប្បន្នបានចំលងយកបែបបទអត្រាប្តូរប្រាក់តាម Goldsmiths ។ រូបិយប័ណ្ណដែលអាចប្តូរ ជាសាច់ប្រាក់នេះមិនត្រូវបានគេប្រើប្រាស់ដល់សព្វថ្ងៃ ដោយសារគ្មានការទទួលស្គាល់ទូលំទូលាយ ។ សូម្បីតែ នៅក្នុងប្រទេសចិននាសម័យរាជ្យវង្សម៉េងក៏គេសំគាល់ថានៅបណ្តាខេត្ត និងហាងសម្បត្តិមានការរើសអើង ទៅវិញទៅមក ។
- ក្រិត្យរូបិយវត្ថុ គឺជាក្រដាស់ប្រាក់ និងលុយកាសដែលត្រូវបានគេស្គាល់ថាជារូបិយវត្ថុនាពេលបច្ចុប្បន្នយើង សង្កេតឃើញថា ការទទួលស្គាល់របស់អតិថិជន និង ភាពជឿទុកចិត្តពិតជាមានសារៈសំខាន់ណាស់សំរាប់ ក្រិត្យរូបិយវត្ថុ ព្រោះថាធម្មតាក្រដាស់ និង លោហៈគ្មានតំលៃអ្វីទេ ហើយវាក្លាយជារូបិយវត្ថុដោយសារ ការធានារបស់ធនាគារជាតិ។ បណ្តាប្រទេសមួយចំនួនចរាចរលុយកាសលែងត្រូវបានយកមកប្រើប្រាស់ ដោយសារៈ

(១) រាស្ត្រមិនប្រើប្រាស់ប្រចាំថ្ងៃ ដូចជា សេវាកម្មទូរស័ព្ទ រថយន្តក្រុង ទស្សនាវដ្តី ភេសជ្ជៈ ។ល ។ (២) អតិផរណាមានកំរិតខ្ពស់ពេក ជួនកាលមិនត្រឹមតែលុយកាក់ទេដែលលែងប្រើប្រាស់ សូម្បីតែ ក្រដាសមាន គណនីតូចក៏គេលែងប្រើដូចគ្នាដែរ ។ (៣) ការជំរុញការធានាពីរដ្ឋាភិបាលមានកំរិតខ្សោយពេក និង ជំនឿទុកចិត្តរបស់ប្រជាជនមានកំរិត ទាប ។ តាមធម្មតារាស្ត្រផ្តើមចេញពីការទុកចិត្តលើរដ្ឋាភិបាលរបស់ខ្លួន ប៉ុន្តែ ស្ថានភាពទុកចិត្តទាប មិនមែនបណ្តាលមកពីកង្វះជាតិនិយមតែមួយនោះទេ តែក៏អាចបណ្តាលមកពីសង្គ្រាម ដែលបំផ្លាញទ្រព្យសម្បត្តិរបស់គាត់ដែលមាននៅធនាគារ រឺ ជួនកាលរដ្ឋាភិបាល

ថ្មីក៏មិនបានទទួលស្គាល់ រូបិយវត្ថុ មុនៗដែលជាហេតុបណ្តាលអោយជីវិតរបស់គាត់មានវិបត្តិ និង ចង ចាំជាប់ចិត្តរឺ ជាពិសេសការបោះពុម្ពញឹកញាប់ពេក និង ការប្តូរគំរូរូបិយវត្ថុថ្មីៗដោយកំនត់សុពលភាព ។ (៤) ការគ្រប់គ្រងធនាគារមិនបានល្អ ជាពិសេសចរាចរលុយបរទេស ។

- បញ្ជីរូបិយវត្ថុ គឺជាប្រាក់ដែលបានដាក់ចូលក្នុងគណនីអេឡិចត្រូនិចក្នុងធនាគារ និង ស្ថាប័នហិរញ្ញវត្ថុវា គឺជា រូបិយប័ណ្ណនាពេលបច្ចុប្បន្ន ដូចជា មូលប្បទានប័ត្រឥណទាន ។ ដើម្បីប្រើប្រាស់លុយនេះ បណ្តា ប្រទេសជា ច្រើនបានចេញអោយប្រើប្រាស់នូវកាតធនាគារដូចជា មាស្ទ័រកាត (Master Card) ស្មាតកាត (Smart, Card) វីសាកាត (Visa Card) មូលប្បទានប័ត្រទេសចរណ៍ (Traveler's Check) និង ឥណទាន កាត (Credit Card)។ លោកអ្នកអាចជ្រើសរើសគណនី និង ធនាគារដែលអ្នកចូលចិត្ត និងមានទំនាក់ ទំនងល្អ។

ការប្រើប្រាស់ទាំងនេះ គឺជានានូវសុវត្ថិភាព ជួយដល់ការសន្សំសំចៃ និង ងាយស្រួលបង្វិលក្នុង វិនិយោគ។ ពិភពលោកបច្ចុប្បន្នមានដំណើរវិវត្តន៍យ៉ាងលឿន ដោយសារការរីកចំរើននៃបច្ចេកវិទ្យា។ កាលពីពេលមុន យើងបានសិក្សាថា បញ្ញើរូបិយវត្ថុសំគាល់ទៅលើប្រាក់ដែលផ្ញើរនៅធនាគារ ប៉ុន្តែនៅ ប្រទេសអភិវឌ្ឍន៍គេបាន ឈានដល់ការប្រើប្រាស់ E-Money ( ជារូបិយវត្ថុដែលយើងអាចដកយកមក ប្រើ រឺ ផ្ទេរអោយអ្នកដទៃដោយ ផ្ទាល់តាមរយៈប្រព័ន្ធបញ្ញាអេឡិចត្រូនិកទំនើប) ។

### *ហេតុអ្វីបានជាសង្គមបច្ចុប្បន្នឈានទៅរកការប្រើប្រាស់ដោះដូរដែលមានល្បឿនលឿន?*

តាមធម្មតាចំណាយការរងចាំសរុបនៃការដោះដូរកាន់តែមានកំរិតខ្ពស់ កាលណាអតិថិជន ចំណាយពេលវេលា កាន់តែយូរក្នុងអំឡុងពេលរងចាំប្រគល់ប្រាក់ និងទំនិញ ហើយធនធានរបស់គេ អាចធ្លាក់ចុះប្រសិនបើគេចំណាយពេល សំរាប់ធ្វើពាណិជ្ជកម្មដ៏លំបាករបៀបនេះ ។ក្នុងកិច្ចខិតខំធ្វើ អោយមានការបន្ថយជាអប្បរមានូវចំណាយទាំងពីរនេះ ការអភិវឌ្ឍន៍នូវបច្ចេកវិទ្យាដ៏មានប្រសិទ្ធភាព សំរាប់សំរួលដល់ការដោះដូរដូចជា ម៉ាស៊ីនគិតលុយ ម៉ាញេទិចនិងកាំរស្មីព្រមទាំងប្រព័ន្ធតភ្ជាប់កំព្យូទ័រ ។ ហេតុនេះ អតិថិជនអាចជៀសវៀងបាននូវការខាត បង់ពេលវេលា ចំណូលប្រចាំម៉ោង និងជានាសុវត្ថិ ភាពអ្នកប្រើប្រាស់ ។ អាស្រ័យដោយការពិនិត្យ និងវិភាគទៅលើទំរង់ និងមុខងារនៃរូបិយវត្ថុ យើងអាច និយាយបានថា សេចក្តីត្រូវការរូបិយវត្ថុមានវិសាលភាពធំធេង និងជាទីទុកចិត្តរបស់រាស្ត្រទាំងមូល ដោយសារមូលហេតុ ចំនួនប្រាំយ៉ាងគឺៈ

1. **លទ្ធភាពដែលអាចកាន់បាន** (Portability) រូបិយវត្ថុប្រាកដជាមានលក្ខណៈងាយស្រួល ណាស់ ក្នុងការ លើកដាក់យូរកាន់បានស្រេចចិត្ត ហើយអាចធ្វើការដូរផ្លាស់ ធ្វើការទិញដូររបស់របរនៅ ទីតាំងផ្សេងៗ បានដោយងាយ ស្រួលទៀតផង ។ បើសិនជាគ្មានលទ្ធភាពបែបនេះទេ នោះរូបិយវត្ថុ ទាំងឡាយច្បាស់ជាគ្មានលទ្ធភាពប្រើប្រាស់ជា ទូទៅបានទេ ។

2. **លទ្ធភាពជាប់បានយូរ** (Durability) រូបិយវត្ថុទាំងអស់បើគ្មានគុណភាពនៃទំរង់រូបរាងរបស់វា ជាប់មាំទេ នោះប្រាកដជាបាត់នូវតំលៃជារូបិយវត្ថុមិនខាន។

3. **លទ្ធភាពចែកចាយ** (Divisibility) រូបិយវត្ថុប្រាកដជាគេអាចធ្វើការបែងចែកបានយ៉ាងងាយស្រួលដើម្បី ធ្វើការទិញដូរនៃឯកតាមុខទំនិញដែលមានលក្ខណៈតូចល្មម រឺ ធំទៅតាមបែបប្រភេទនីមួយៗ ទោះជាយ៉ាងណា រូបិយវត្ថុខ្លះក៏មិនអាចធ្វើការបែងចែកបានដែរ ។

4. **លទ្ធភាពខ្នាតគំរូ** (Standardizability) ដើម្បីអោយមានអត្ថប្រយោជន៍ នោះរូបិយវត្ថុប្រាកដជាត្រូវ បានកំរិតថ្លៃជាមិនខាន ។ ឯកតារបស់វានឹងគុណភាពស្មើគ្នា ហើយតាមរយៈរូបសាស្ត្រក៏មិនមានលក្ខណៈប្លែកគ្នា អ្វីដែរ ។

5. **លទ្ធភាពទទួលស្គាល់** (Recognizability) រូបិយវត្ថុប្រាកដត្រូវតែបានទទួលស្គាល់ដោយងាយស្រួល ។ រូបិយវត្ថុក៏គេមិនទទួលស្គាល់ដោយងាយបានដែរ បុគ្គលិកម្នាក់ៗមានការពិបាកក្នុងការកំនត់ថា តើពួកគេកំពុងតែគិតពី រូបិយវត្ថុ រឺ ក៏ពីទ្រព្យដែលមានលក្ខណៈអន់ជាង រឺ យ៉ាងណា ។ នៅក្នុងយុគសម័យបច្ចុប្បន្ននេះប្រទេសជាតិដែលមាន លក្ខណៈទំនើបជឿនលឿនទាំងឡាយតាមធម្មតាគិតថា រូបិយវត្ថុជាក្រដាសប្រាក់ និង គណនីចរន្ត (Checking Account) គឺថា រូបិយវត្ថុទាំងអស់សុទ្ធតែមានលក្ខណៈជាទ្រព្យធន ពិសេសដូចចំណុចទាំងប្រាំខាងលើ។

## ១.៤ សមាសភាគផ្គត់ផ្គង់រូបិយវត្ថុ

តាមនិយមន័យរូបិយវត្ថុជាវត្ថុអ្វីមួយ ដែលជាទូទៅត្រូវបានគេទទួលយកក្នុងការទូទាត់ទំនិញនិងសេវាកម្ម ដែលបានប្រាប់យើងថារូបិយវត្ថុត្រូវបានកំនត់និយមន័យដោយឥរិយាបទរបស់មនុស្ស។ អ្វីដែលបង្កើតទ្រព្យសម្បត្តិ រូបិយវត្ថុ គឺថាមនុស្សជឿជាក់ថាវានឹងបានទទួលយកដោយមនុស្សផ្សេងទៀតពេលដែលធ្វើការទូទាត់ ។ដូចយើងឃើញស្រាប់ហើយទ្រព្យសម្បត្តិផ្សេងៗគ្នាជាច្រើនបានអនុវត្តតួនាទីនេះជាច្រើនសតវត្សមកហើយ ដោយគិតចាប់តាំងពីមាស ទៅជារូបិយប័ណ្ណ និងរហូតដល់គណនីចរន្ត ។ តាមឥរិយាបទនេះគេមិនបានប្រាប់យើងពិតប្រាកដថា តើទ្រព្យសម្បត្តិ អ្វីខ្លះក្នុងសេដ្ឋកិច្ចយើងគួរតែគិតជារូបិយវត្ថុ នោះ ។

### ១.១.៤.១ រូបិយវត្ថុធ្វើចរាចរ

ចំណុចសំខាន់និងការដែលមើលអោយឃើញជិតដល់បើការវាស់វែងថ្លឹងថ្លែងរូបិយវត្ថុគឺ M1 ដោយរួមមានប្រភេទមួយចំនួនដែលត្រូវបានប្រើប្រាស់សំរាប់ប្រតិបត្តិការទូទាត់គឺសំរាប់ធ្វើការទិញ និងលក់របស់របរផ្សេងៗ។ រូបិយវត្ថុប្រភេទ M1 រួមមាន ប្រាក់កាស ក្រដាសប្រាក់នៅក្រៅធនាគារ, គណនីចរន្តនៅក្នុងធនាគារ និងស្ថាប័នបញ្ញើផ្សេងៗទៀត ព្រមទាំង មូលប្បទានប័ត្ររបស់អ្នកទេសចរណ៍។

- ប្រាក់កាស (Coins) ដំបូងយើងយកមកធ្វើការដោះដូរតិចតួចទេ ដោយមិនកំណត់ និង មិនប្រើប្រាស់នៅ ក្នុងធនាគារទេ គឺប្រើប្រាស់សំរាប់តែចរាចរនៅលើទីផ្សារប៉ុណ្ណោះ ។
- រូបិយវត្ថុជាក្រដាស (Paper Currency) សំខាន់បំផុតគឺជាប្រភេទទីពីររបស់រូបិយវត្ថុនៅចរាចរលើទីផ្សារគឺជាក្រដាសប្រាក់។ ឥឡូវប្រាក់កាស និងក្រដាសប្រាក់ទាំងអស់ជារូបិយវត្ថុមានក្រិត

(Fiat money) ព្រោះរដ្ឋាភិបាលបានចេញក្រិតទៅលើវាថាជាលុយដែលត្រូវបានគេទទួលយកគ្រប់បំណុល ទាំងផ្នែកឯកជននិងសាធារណៈ "**ប្រាក់កាស + ក្រដាសប្រាក់ = រូបិយវត្ថុ**"។

- គណនីចរន្តនៅក្នុងធនាគារ (Checking/Transaction account in commercial bank)។ វាជាចំណែកទី៦ នៃរូបិយវត្ថុដែលធ្វើចរាចរវាគឺជាប្រាក់បញ្ញើចុះបញ្ជី រឺ ប្រាក់ធនាគារ។ មូលនិធិបែបនេះ ត្រូវបានគេតំកល់ទុកនៅក្នុងធនាគារនិងនៅស្ថាប័នហិរញ្ញវត្ថុផ្សេងៗទៀត ។ អ្នកបញ្ញើអាចសរសេរមូលប្បទានប័ត្របាន ។ តាមលក្ខណៈបច្ចេកទេស គេហៅថាប្រាក់បញ្ញើបែបនេះជាសាច់ប្រាក់បញ្ញើតាមតំរូវការ ដែលគ្មានការផ្តល់ ការប្រាក់អោយអតិថិជនទេ ។

– ប្រាក់បញ្ញើផ្សេងៗទៀត (Other deposit) ប្រាក់បញ្ញើផ្សេងៗ ដូចជាមានប្រាក់ដែលអាចដកបានដោយមានលិខិតបញ្ជា (Negotiable Order of Withdrawal : NOW account) ហើយនឹងគណនីដែលប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិ (Automatic Transfer System : ATS...) នៅតាម ស្ថាប័នបញ្ញើផ្សេងៗ ។

– មូលប្បទានប័ត្ររបស់អ្នកទេសចរណ៍ (Traveler's check) ជាប្រភេទមូលប្បទានប័ត្រត្រូវបានទូទាត់ដោយ អ្នកទិញនៅពេលណាគេចង់បង្វិលជាសាច់ប្រាក់។

### ១.១.៣.២- រូបិយវត្ថុទូទៅ (Broad money)

ទោះបីជា M1 កំពុងតែត្រូវបានមើលឃើញយ៉ាងកៀកបំផុត នូវតួលេខរូបិយវត្ថុក៏ឃើញមាននូវអង្គផ្សំ ផ្សេងៗ ទៀតដែលធ្វើអោយមានការចាប់អារម្មណ៍ពីពេលមួយទៅពេលមួយ ដែលរូបិយវត្ថុមានលក្ខណៈទូទៅ (Board money)។ រូបិយវត្ថុទូទៅតាងដោយ M2 ដែលគេអាចហៅថាជារូបិយវត្ថុព្រទ្យសកម្ម (Assets money) រឺមាន លក្ខណៈជិតក្បែរនឹងរូបិយវត្ថុ (Near money)។ M2 រួមមាន M1 ព្រមទាំងទ្រព្យផ្សេងទៀត ដែលជាការដាក់ ជំនួសដោយរូបិយវត្ថុសំរាប់ប្រតិបត្តិការទូទាត់ គឺមានគណនីសន្សំ(Saving account) នៅក្នុងធនាគារ និងគណនី មានកាលវសាន(Fixed account)។

- Saving deposits គឺជាប្រាក់បញ្ញើនៅក្នុង Regular savings account ឬហៅថាPassbook account ដែលភាគច្រើនឥតចាំបាច់មានទឹកប្រាក់អប្បបរមាទេ ប៉ុន្តែអត្រាការប្រាក់មានកំរិតមួយទាប ។ អតិថិជនអាចដក ប្រាក់ពីគណនីបានតាមតំរូវការ តែតាមធម្មតាត្រូវសរសេរពាក្យសុំដកប្រាក់កក់ជាមុន ចំនួន៣០ថ្ងៃ ។ គណនីសន្សំ ខ្លះអាច មានទំរង់ជា ATS-account (Automatic Transfer Services) ដែលផ្តល់លទ្ធភាពអោយអតិថិជន អាចផ្ទេរប្រាក់ដោយស្វ័យប្រវត្តិពី Interest-bearing savings account ទៅក្នុង Checking accounts បាន ។
- Time deposits or Fixed Account គឺជាប្រាក់បញ្ញើមានកាលវសាន ដែលតំរូវអោយមានទឹកប្រាក់ អប្បបរមាពី 1.000 ដល់ 5.000 ដុល្លា នឹង អាច មានកាលកំណត់ពី ៣០ថ្ងៃ រហូតដល់ ១០ឆ្នាំ រឺច្រើនជាងនេះ ។ ការដកប្រាក់ចេញពីគណនីមុនកាលវសានដែលម្ចាស់បានចុះកិច្ចសន្យា ត្រូវពិន័យតាមការកាត់បន្ថយការប្រាក់ពី សំណាក់ធនាគារ ។
- ទ្រព្យផ្សេងៗទៀត មានដូចជាការព្រមព្រៀងត្រលប់ក្នុងរយៈពេលមួយថ្ងៃ នៅធនាគារពាណិជ្ជ (Overnight repurchase agreements រឺ Repo) ធនាគារពាណិជ្ជលក់ធនប័ណ្ណទៅអោយ អតិថិជន។ កើតឡើងដោយការឯកភាពយល់ព្រមទិញក្រដាសប្រាក់មានតំលៃពីគ្រឹះស្ថានហិរញ្ញវត្ថុត្រលប់មកវិញ ហើយលក់អោយវិញនៅថ្ងៃបន្ទាប់តាមថ្លៃខ្ពស់ជាងមុន ដោយបូកទាំងការប្រាក់ដែលបាននិយាយគ្នាផង ។

### ១.១.៣.៣- ការផ្លាស់ប្តូរនៃរូបិយវត្ថុទូទៅ (Changing of broad money)

ការកំណត់កាន់តែមានលក្ខណៈ ទូរទៅនៃការផ្គត់ផ្គង់រូបិយវត្ថុ ត្រូវបានគេទទួលយកជាផ្លូវការដោយប្រព័ន្ធទុន បំរុងសហព័ន្ធ (Federal Reserve System) របស់សហរដ្ឋអាមេរិច គឺត្រូវបានគេតាងដោយ ប៉ារ៉ាម៉ែត្រ M3 រួមមាន M2

- ប្រាក់បញ្ញើមានកាលវសានដែលមានចំនួនទឹកប្រាក់ពិត 100,000 ដុល្លា រឺលើសពីនេះ ដែលគេហៅថា ជាទូទៅថា វិញ្ញាបនប័ត្រប្រាក់បញ្ញើច្រើន (Jumbo/Large Certificate of Deposit) ។

– ការព្រមព្រៀងទិញត្រលប់តាមកាលវសាននៅធនាគារពាណិជ្ជ (Term repurchase agreement រឺ Term Repo) ដែលវាមានរយៈពេលការសងត្រលប់វែងជាងមួយថ្ងៃមួយយប់ អាចមួយសប្តាហ៍ រឺ មួយខែ ។

## ១.៥ រូបិយវត្ថុ និងវដ្តសេដ្ឋកិច្ច

វដ្តសេដ្ឋកិច្ចគឺជាការវាស់វែងភាពមិនទៀងទាត់នៃសេដ្ឋកិច្ច។ ក្នុងវដ្តសេដ្ឋកិច្ចកាលណាមានការធ្លាក់ ចុះដល់ បាតនៃសេដ្ឋកិច្ចវាឆ្លុះបញ្ចាំងពីព្រឹត្តការណ៍ដែលមានវិបត្តិនយោបាយនិងកំនើននិកម្មភាព ។ ហេតុនេះយើងចង់ដឹងថា តើវាមានទំនាក់ទំនងយ៉ាងណាជាមួយរូបិយវត្ថុ?

យើងសង្កេតឃើញថា នៅពេលសេដ្ឋកិច្ចស្រុតចុះភាពអត់ការងារកើនឡើង ផលិតផលសរុបធ្លាក់ចុះការផ្គត់ផ្គង់ រយៈពេលខ្លីបានស្រុតចុះ និង អាជីវកម្មជួបប្រទះនូវផលវិបាកជាច្រើន ។ ហេតុនេះ ពាស្ត្រទាំងអស់ទទួលរងនូវសំពាធ នេះហើយមានតែនយោបាយរូបិយវត្ថុមួយតែប៉ុណ្ណោះ ដែលដើរតួនាទីជាស្នូល ក្នុងដំណោះស្រាយភ្លាម ។ ការបញ្ចេញ រូបិយវត្ថុតំកល់ទុកពីធនាគារដល់ទីផ្សាររូបិយវត្ថុតាមរយៈការបញ្ចូន អត្រាការប្រាក់បានជំរុញអោយសេដ្ឋកិច្ចងើបឡើង ជាថ្មី ។ យោងតាមរបាយការណ៍ធនាគារកណ្តាល សហរដ្ឋអាមេរិច និងមូលនិធិរូបិយវត្ថុអន្តរជាតិបានបញ្ជាក់ថា ដោយ សារដំណើរធ្លាក់ចុះនៃការកាន់កាប់រូបិយវត្ថុ របស់ពាស្ត្រម្នាក់ៗ ( កំនើនប្រជាជន និង ការស្រុតចុះនៃជីវភាព) និងរបស់ធនាគា( ហិរញ្ញប្បទាន ដល់ រដ្ឋាភិបាល) នាសតវត្សទី២១ នេះបានធ្វើឱ្យវដ្តសេដ្ឋកិច្ចឈានដល់ចលនាស្រុតចុះ ជាបន្តបន្ទាប់ ។ កត្តាទាំងនេះ ជាការបញ្ជាក់នូវភាពទន់ ខ្សោយបន្តិចម្តងៗនៃប្រទេសអភិវឌ្ឍន៍នាសម័យកាលនេះ ។

## ១.៦ តំលៃរូបិយវត្ថុ និងអតិផរណា

ប្រហែលជា ២០ ឆ្នាំមុននេះ អ្នកអាចកាន់លុយ ២ រៀល គឺគ្រប់គ្រាន់សំរាប់ទស្សនាភាពយន្តនៅរោងភាពយន្តវិមានទិព្វ និងអាចទិញទឹកកកឈូសមួយកែវ និងគ្រាប់ឈូកលីង២កញ្ចប់ ។ តែសំរាប់ពេលនេះដោគវាសនា២រៀលរបស់អ្នកមិនអាចទិញបានទេ ដូច្នេះហើយរូបរាង្គនៃក្រដាស់ប្រាក់ ២រៀលរបស់អ្នកបានបាត់ស្រមោលពីទីផ្សា រូបិយវត្ថុទៅហើយ ។តើអ្នកយល់ឃើញយ៉ាងណាអំពីតំលៃរូបិយវត្ថុរបស់អ្នក? យើងសំគាល់ឃើញថាតំលៃរូបិយវត្ថុធ្លាក់ ចុះជាមួយនឹងការកើនឡើងនៃអតិផរណា ។ អតិផរណាគឺជាការកើនឡើងថ្លៃនៃ ទំនិញ និងការធ្លាក់ចុះតំលៃរូបិយវត្ថុ ។ ហេតុនេះប្រភពមួយនៃការឆ្លុះបញ្ចាំងទំនាក់ទំនងតំលៃរូបិយវត្ថុ និងអតិផរណា គឺការកើនឡើងនៃកំរិតថ្លៃនិងការ ផ្គត់ផ្គង់រូបិយវត្ថុ។ នៅពេលមានការកើនឡើងនូវការផ្គត់ផ្គង់រូបិយវត្ថុ ជាពិសេសនៅពេលរដ្ឋាភិបាលបោះពុម្ភបន្ថែមកំរិតថ្លៃនឹងកើនឡើងព្រមគ្នាដែរហេតុនេះ៖ អតិផរណាក៏កើនឡើងដែលបណ្តាលអោយតំលៃរូបិយវត្ថុកាន់តែធ្លាក់ចុះ ។

គេធ្វើការកត់សំគាល់ថា ប្រទេសដែលមានអត្រាកំនើនបរិមាណរូបិយវត្ថុកាន់តែខ្ពស់ អតិផរណាក៏មានកំរិតខ្ពស់ ដែរដូចជា ប្រទេសម៉ិចស៊ីកូ អាហ្សង់ទីន ពេរូ ។ល។ និងផ្ទុយមកវិញភាគច្រើននៃប្រទេសអឺរ៉ុបខាងលិច និងអាមេរិចមានកំរិតអតិផរណាទាបដោយសារអត្រាកំនើនបរិមាណរូបិយវត្ថុកាន់តែទាប មានន័យថាប្រទេសនោះមាន រូបិយវត្ថុគ្រប់គ្រាន់សំរាប់ចរាចរ និងរដ្ឋាភិបាលគេមិនចាំបាច់បោះពុម្ពលុយ បន្ថែមទៀត ឡើយ ។

# ជំពូក ២
# ទីផ្សារហិរញ្ញវត្ថុ និង លក្ខណៈអត្រាការប្រាក់

## ២.១ ទីផ្សារហិរញ្ញវត្ថុ

បញ្ហារចនាសម្ព័ន្ធហិរញ្ញវត្ថុអាចញែកឱ្យដាច់ពីបញ្ហាគោលនយោបាយហិរញ្ញវត្ថុ។ ចំពោះបញ្ហាគោលនយោបាយរូបិយវត្ថុគឺ ជាការគ្រប់គ្រងរូបិយវត្ថុនិងឥណទានដើម្បីព្យាយាមរក្សាសេដ្ឋកិច្ចឱ្យមានផលិតកម្មពេញលេញដោយគ្មានអតិផរណា។ ឯបញ្ហារចនាសម្ព័ន្ធហិរញ្ញវត្ថុគ្របដប់ស្ថាប័ននៃប្រព័ន្ធហិរញ្ញវត្ថុដែលមានដូចជាធនាគារកណ្តាលធនាគារពាណិជ្ជនានា ធនាគារអភិវឌ្ឍន៍ ផ្សារទុន ...។ របៀបដែលតរៀបចំស្ថាប័នទាំងនេះ និងគោលនយោបាយ ហើយនិយ័តកម្មបែបណាមួយនោះដែលគេត្រូវការដើម្បី ធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុដំណើរការបានល្អ ។

### ២.១.១- លំនាចំពោះទីផ្សារហិរញ្ញវត្ថុ

យោងទៅតាមស្ថាប័ននិង បច្ចេកទេសមួយចំនួន នារទីផ្សារហិរញ្ញវត្ថុប្រមូលយកប្រាក់សន្សំហើយក៏ធ្វើឱ្យមូលនិធិ ដែលជាប្រាក់សន្សំនេះមាន លទ្ធភាពនាំទៅដល់អ្នកដែលមានបំណងចង់ខ្ចីលុយ ។ ដូចនេះទីផ្សារហិរញ្ញវត្ថុបានរួមច្របាច់បញ្ចូលគ្នាដោយប្រយោល ចំពោះអ្នកដែលមិនចង់ចំណាយនូវប្រាក់ចំណូលរបស់ខ្លួន ជាមួយអ្នកដែលបាន ចំណាយនូវប្រាក់ចំណូលរបស់ខ្លួនយ៉ាង ច្រើន។ នៅក្នុងទីផ្សារហិរញ្ញវត្ថុព័ត៌មានគ្រប់គ្រាន់គឺសំខាន់ណាស់ការបាត់បង់ព័ត៌មាន ឬព័ត៌មានមិនពិតតាមការពិចារណា និងបានកំនត់នូវទំហំទីផ្សារនោះក៏បានកំនត់នូវការកើនឡើងនូវហានិភ័យដែលបានភ្ជាប់ទៅនឹងការធ្វើ ពាណិជ្ជកម្មនៅក្នុងនោះដែរ ។ ដើម្បីជំនះនូវបញ្ហាទាំងនេះ ស្ថាប័នហិរញ្ញវត្ថុដូចជា ( ធនាគារពាណិជ្ជ ក្រុមហ៊ុនធានារ៉ាប់រងសហគមន៍ឥណទាន...) ដែលប្រមូលវិភាគ និងចែកចាយព័ត៌មានដែលពាក់ព័ន្ធទៅឱ្យទីផ្សារដែលបង្កើត ឡើងនេះ។

ការឱ្យមាននូវទីផ្សារហិរញ្ញវត្ថុដែលគេបានបង្កើត និងដែលមានប្រសិទ្ធិភាពនោះបានបង្កលក្ខណៈងាយស្រួលដល់ ការបង្វែរនូវប្រាក់សន្សំទៅឱ្យអ្នកដែលមានបំណងចង់ខ្ចី ។ ដូចរូប 2.1 បានបញ្ជាក់ច្បាស់នូវទំរង់គំរូដ៏សាមញ្ញមួយនៃ ដំណើរបញ្ជូននេះ ។




រូបភាព ១៖លំហូរមូលនិធិតាមរយៈទីផ្សារហិរញ្ញវត្ថុ

ទីផ្សារហិរញ្ញវត្ថុដែលគេបានកំនត់សំរាប់ប្រតិបត្តិការទូទាត់ធនប័ណ្ណ គឺត្រូវបានគេរៀបចំចាត់ចែងដ៏មានប្រសិទ្ធភាព និងដ៏ល្អក្នុងនោះមានស្ថាប័នមួយចំនួនដើម្បីកំនត់នូវចលនាមូលធននៅក្នុងសេដ្ឋកិច្ច ។

### ២.១.២-មុខងារទីផ្សារហិរញ្ញវត្ថុ (Financial Market Functions)

**ក-មុខងារទីមួយ:**

បង្កលក្ខណៈងាយស្រួលដល់ការធ្វើពាណិជ្ជកម្ម និងការវិនិយោគ (Facilitating Trade and Investment) បានបង្កើននូវការធ្វើពាណិជ្ជកម្ម និងការវិនិយោគដែលជាចំនុចកណ្តាលចំពោះ ការកែលំអនៃសុខមាលភាពរបស់ មនុស្ស។ បើកាលណាប្រព័ន្ធរូបិយវត្ថុមានលក្ខណៈរឹងមាំល្អនោះ នឹងបានកាត់បន្ថយនូវហានិភ័យ និងនាំឱ្យមានការ វិនិយោគ និងការធ្វើពាណិជ្ជកម្មកាន់តែកើនឡើង ហើយមុខងារនេះក៏សរសេរគោលសំរាប់ ការអភិវឌ្ឍន៍សេដ្ឋកិច្ចដែរ ។

**ខ-មុខងារទីពីរ:**

ផ្ទេរធនធាន ឬមូលធនពីអ្នកសន្សំទៅឱ្យអ្នកខ្ចី ឬអ្នកវិនិយោគ (Transferring Resources or Capital from Saver to Borrower or Investors) ក្នុងសេដ្ឋកិច្ចមួយបើគ្មានការសន្សំនោះក៏អាចគ្មានការវិនិយោគកើតឡើងច្រើនដែរ។ ប្រព័ន្ធហិរញ្ញវត្ថុមួយដែលរឹងមាំផ្តល់នូវការជំរុញឱ្យមានការសន្សំប្រាក់និងក៏ធ្វើជាបណ្តាញនៃការនាំប្រាក់សន្សំទៅឱ្យមានការវិនិយោគផលិតផល។ ធម្មតាការដែលដាក់ប្រាក់សន្សំចូលទៅក្នុងការវិនិយោគ ជានិច្ចកាលតែងតែជួបនូវហានិភ័យ នោះបើពិនិត្យឱ្យមែនទែនឃើញថា ទីផ្សារមូលធន (Capital Market) បានកាត់បន្ថយនូវ ហានិភ័យ ដល់អ្នកសន្សំបានខ្លះដែរ ។




រូបភាព ២៖ លំហូរសាច់ប្រាក់ដោយមិនមានការសន្សំ

**គ-មុខងារទីបី:** ប្រមូលផ្តុំមូលធន (Assembling Capital)

គំរោងវិនិយោគនានាតំរូវឱ្យមានមូលធនច្រើន ហើយធនាគារ និងទីផ្សារភាគហ៊ុនអាចសរុបនូវចំនួនប្រាក់សន្សំ ដើម្បីធ្វើហិរញ្ញប្បទានលើការធ្វើវិនិយោគបែបទ្រង់ទ្រាយធំ ។

**ឃ-មុខងារទីបួន:** ធ្វើការជ្រើសរើសគំរោង (Selecting Projects)

ជានិច្ចកាលមានគំរោងវិនិយោគជាច្រើន ដែលស្វះស្វែងរកមូលនិធិ ដែលមូលនិធិនេះ អាចត្រូវបានគេផ្តល់ដោយ ប្រាក់សន្សំដែលមាន ។ ប្រព័ន្ធហិរញ្ញវត្ថុមួយដែលរឹងមាំល្អបានធ្វើ ឱ្យប្រាក់សន្សំទាំងនេះទៅជាការវិនិយោលើផលិតកម្ម ជាច្រើនហើយធម្មតាធនាគារធ្វើការឲ្យខ្ចីតែទៅលើគំរោងណាដែលចេះកែសំរួលនូវហានិភ័យខ្ពស់ៗឱ្យមកទាបវិញបាន ។

**ង-មុខងារទីប្រាំ:** ការផ្ទេរ ការចែក និងការចូលរួមហានិភ័យ
(Transferring. Sharing and Polling of Risk)

នៅក្នុងទីផ្សារមូលធនបានធ្វើឱ្យមានការបង្វែរហានិភ័យ ការធានានូវហានិភ័យ និងការចែកនូវហានិភ័យ ។

**ច-មុខងារទីប្រាំមួយ:** ការបង្វែហានិភ័យឱ្យទៅផ្នែកផ្សេងៗ (Risk Diversification)

ការទទួលយកគំរោងវិនិយោគមួយចំនួនធំបានធ្វើឱ្យកាត់បន្ថយនូវហានិភ័យនូវវិនិយោគម្នាក់ៗ ។

**ឆ-មុខងារទីប្រាំពីរ:** ធ្វើការត្រួតពិនិត្យ (Monitoring)

ធនាគារត្រូវតែធ្វើឱ្យប្រាកដថា អ្នកខ្ចីប្រើប្រាស់នូវមូលនិធិដែលគេបានខ្ចីដូចតាមកិច្ចសន្យា ដែលបានធ្វើជាមួយ ម្ចាស់បំណុល ។ ធនាគារក៏ត្រូវតែត្រួតពិនិត្យជាបន្តទៀតនូវសកម្មភាព នៃគំរោងវិនិយោគរបស់អ្នកខ្ចីផងដែរ ។

**ជ-មុខងារទីប្រាំបី:** ប្រតិបត្តិតាមកិច្ចសន្យា (Enforcing contract)

ធនាគារត្រូវតែធ្វើឱ្យប្រាកដថាអ្នកខ្ចី នឹងបង់ការប្រាក់ហើយព្រមទាំងសងនូវប្រាក់ដើមទៀតផង ។ ធនាគារ តំរូវឱ្យកូនបំណុលស្ថិតនៅក្រោមច្បាប់ស្តីពីរបស់ដាក់បញ្ចាំ និងច្បាប់ស្តីពីការក្ស័យធនហើយធនាគារពាណិជ្ជនានាត្រូវ ស្ថិត នៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាល និងរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមកិច្ច សន្យា ។

## ២.២ ឧបករណ៍ហិរញ្ញវត្ថុ

ធនប័ត្រដែលមានរយៈពេលមិនដល់មួយឆ្នាំ គេហៅថាធនប័ត្ររយៈពេលខ្លី និងនៅពេលណាដែលធនប័ត្រទាំង នោះមានរយៈពេលមួយឆ្នាំ ឬលើសពីនេះនោះហៅថាធនប័ត្ររយៈពេលវែង ។ ក្រៅពីនេះថា តើឧបករណ៍ហិរញ្ញវត្ថុ ជាធនប័ត្ររយៈពេលខ្លី ឬវែងក៏ត្រូវបានគេកំនត់ថាតើត្រូវបានគេធ្វើពាណិជ្ជកម្មនៅក្នុងទីផ្សាររូបិយវត្ថុ ឬក៏ទីផ្សារ ដើមទុន ។

### ២.២.១ ទីផ្សារដើមទុន

ទីផ្សារដើមទុនរួមបញ្ចូលទាំងការទិញលក់មូលប័ត្រដែលមានរយៈពេលមួយឆ្នាំ ឬលើសពីនេះ និយាយរួម មូលប័ត្ររយៈពេលវែងធម្មតាមានរយៈពេល៥ឆ្នាំ ឬលើសពីនេះ ។ អ្នកឱ្យខ្ចីទទួលមូលនិធិពីទីផ្សារមូលធនដើម្បីទិញ ទំនិញមូលធនសំរាប់ធ្វើការវិនិយោគ ។

ឧបករណ៍ទីផ្សារដើមទុនរួមមាន (ក) ធនប័ត្ររបស់រដ្ឋាភិបាលរយៈពេលវែង (ខ) ប័ណ្ណសាជីវកម្ម (គ) សន្លឹកហ៊ុន ...

ទីផ្សារដើមទុននាំមូលនិធិអ្នកសន្សំ (ឬអ្នកឱ្យខ្ចី)ទៅឱ្យអ្នកខ្ចី (ឬអ្នកវិនិយោគ) សំរាប់ធ្វើការទិញទំនិញមុន ឬសំរាប់វិនិយោគពិត។ម្យ៉ាងទៀតទីផ្សារដើមទុន រួមមានទីផ្សារដំបូងនិងទីផ្សារបន្ទាប់។

ធម្មតាការចេញនូវធនប័ត្រថ្មីដំបូង គឺត្រូវបានគេផ្តល់ឱ្យសំរាប់ធ្វើការលក់នៅលើទីផ្សារដំបូង។ ក្រោយមកនៅពេលដែលក្រុមហ៊ុនចង់ដោះដូរនូវសមាសភាគនៃមូលប័ត្រពាណិជ្ជកម្ម នោះក៏អាចបង្វិលទៅក្នុងទីផ្សារបន្ទាប់។

⁎ **ទីផ្សារដំបូង និងទីផ្សារបន្ទាប់** (Primary and Secondary market)

ប្រតិបត្តិការហិរញ្ញវត្ថុបានកើតឡើង ទាំងលើទីផ្សារហិរញ្ញវត្ថុដំបូង និងបន្ទាប់ ។

-ទីផ្សារដំបូង (Primary market): គឺជាទីផ្សារមួយដែលទីផ្សារនោះត្រូវបានគេលក់ និងទិញធនប័ត្រថ្មីៗ ។

-ទីផ្សារបន្ទាប់ (Secondary market): គឺជាទីផ្សារដែលនៅក្នុងទីផ្សារនោះត្រូវបានគេធ្វើការដោះដូរ ធនប័ត្រដែលមានស្រាប់ ។ ទីផ្សារបន្ទាប់នេះ គឺសំខាន់ណាស់ដល់ទីផ្សារដំបូង ពីព្រោះគេអាចធ្វើឱ្យឧបករណ៍នានាដំណើរការរកស៊ីធ្វើពាណិជ្ជកម្មកាន់តែមានលក្ខណៈរស់រវើកនៅក្នុងទីផ្សារលើកក្រោយទៀត។

### ២.២.២-ទីផ្សាររូបិយវត្ថុ (Money Market)

គឺជាកន្លែងដែលគេទិញលក់ធនប័ត្ររយៈពេលខ្លី ជាដំបូងគោលដៅសំខាន់គឺធ្វើឱ្យមានឧបករណ៍ បំណុលហើយ បន្ទាប់មកគឺបង្កលក្ខណៈងាយស្រួលក្នុងការប្តូរទៅជាសាច់ប្រាក់បានយ៉ាងងាយស្រួលដោយមានហានិភ័យតិចទៀតផង ។

ទោះបីជាយ៉ាងណា ការដែលគេហៅថាទីផ្សារហិរញ្ញវត្ថុ ឬឧបករណ៍ទីផ្សារហិរញ្ញវត្ថុ ដែលមិនមែនជារូបិយវត្ថុ នោះ គឺត្រូវបានគេធ្វើពាណិជ្ជកម្ម រកស៊ីនៅក្នុងទីផ្សារនេះ។ ឧបករណ៍ទីផ្សារហិរញ្ញវត្ថុដែលត្រូវបានគេទិញ និងលក់ ធម្មតាមានរយៈពេលមិនដល់មួយឆ្នាំ។ ឧបករណ៍ទីផ្សារហិរញ្ញវត្ថុនេះរួមមានក្រដាស ពាណិជ្ជកម្ម វិញ្ញាបនប័ត្របញ្ញើ និងប័ណ្ណរតនគារ ខ្លះទៀត ... ។

⁎ **ធនប័ណ្ណដែលចេញដោយរដ្ឋាភិបាល** (Securities issued by government)

រដ្ឋាភិបាលបានចេញនូវធនប័ណ្ណ(Securities) ឬឧបករណ៍ឥណទាន(Credit instruments) បីបែបគឺ:

❶ Treasury bill: ធនប័ណ្ណរតនាគាររបស់រដ្ឋាភិបាលរយៈពេលខ្លី គឺជាប័ណ្ណរតនាគារ (treasury bill) ដែលគេចេញឱ្យប្រើមានរយៈពេល ១៥ ថ្ងៃ ទៅ១ឆ្នាំ ជានិច្ចកាលគេចូល ចិត្តចេញនូវប័ណ្ណប្រភេទនេះ រយៈពេល ៣ខែ ទៅ៦ខែ ។ តំលៃទឹកលុយនៃប័ណ្ណនេះយ៉ាងតិចបំផុតគឺ 10000$ ហើយចំពោះប័ណ្ណនេះវិញ គឺគេមិនបានបញ្ជាក់នូវការប្រាក់ទេ។ ប័ណ្ណនេះត្រូវបានគេលក់តាមរបៀបអប្បហារ ។

### ការគណនាអត្រាប័ណ្ណរតនាគារដែលគេបានធ្វើការបោះផ្សាយ

ចំពោះករណីនៃការគណនា នោះគេកំណត់យក 360 ថ្ងៃក្នុងមួយឆ្នាំ សំរាប់ធ្វើការ គណនា អត្រាប័ណ្ណរតនាគារដែលគេបានបោះផ្សាយ គឺជាអត្រាអប្បហារ ។

$$rB = \frac{F-P}{F} \times \frac{360}{n}$$

P= ថ្ងៃដែលបង់ទៅលើប័ណ្ណ F= តំលៃពិតនៃប័ណ្ណរតនាគារ n= ចំនួនថ្ងៃដែលគេបានកំនត់

❷ Treasury notes: ចំពោះ treasury notes គេមានបញ្ជាក់អត្រាការប្រាក់លើប័ណ្ណតំណាងទ្រព្យ ហើយការប្រាក់នោះត្រូវបានគេបង់ទូទាត់រៀងរាល់ ៦ខែម្តង ។ តំលៃទឹក លុយ នៅក្នុង treasury notes នោះគឺ 1000$ និងរយៈកាលដែលគេចេញឱ្យប្រើប្រាស់មានពី ១ឆ្នាំ ទៅ១០ឆ្នាំ ។

❸ Treasury bonds: ប័ណ្ណប្រភេទនៃធម្មតាមមានរយៈពេលពី ១០ឆ្នាំឡើងទៅ ហើយប័ណ្ណនេះក៏ ត្រូវបានគេបញ្ជាក់ពីការប្រាក់ផងដែរ ដែលជាទូទៅ គេបង់រៀងរាល់មួយ ឆមាសម្តង ។

## ២.៣ អន្តរការីហិរញ្ញវត្ថុ

នៅក្នុងសេដ្ឋកិច្ច ដែលមានប្រើប្រាស់នូវរូបិយវត្ថុការសន្សំត្រូវបានគេកំនត់ថាជាការមិនប្រើប្រាស់នូវប្រាក់ចំណូល ការសន្សំស្មើប្រាក់ចំណូលដកការប្រើប្រាស់ ។ នៅក្នុងសេដ្ឋកិច្ចប្រើប្រាស់រូបិយវត្ថុ ទោះបីជាយ៉ាងណាការសន្សំ ជាទំរង់នៃអំណាចទិញជាទូទៅ ។ មនុស្សអាច ត្រូវការលុយជំនួសឱ្យទំនិញនានា ។

ពេលសេដ្ឋកិច្ចបានរំកិលចេញពីរបៀប Barter ទៅរបៀបរូបិយវត្ថុ ជាការងាយស្រួលណាស់សំរាប់អ្នករាល់គ្នា ធ្វើការចែកឱ្យដាច់នូវសកម្មភាពនៃការសន្សំដែលចេញពីសកម្មភាព វិនិយោគ ។ អ្នកវិនិយោគមិនមានការសន្សំផ្ទាល់ ខ្លួនទេ គេអាចទទួលនូវអំណាចទិញជាទូទៅ (លុយ) ពីអ្នកសន្សំបាន ។ នេះជាផលប្រយោជន៍មួយសំរាប់អ្នកសន្សំ ពីព្រោះគេបានទទួល នូវមុខងារសម្មាច្ច័យជាទូទៅមួយ និងក៏ព្រោះតែគេអាច រកបាននូវការប្រាក់ពីអ្នកអោយឥណទាន។

ជាសង្ខេបសេដ្ឋកិច្ចរូបិយវត្ថុមួយបានលើកទឹកចិត្ត ឬជំរុញឱ្យមាននូវការសន្សំ និងការវិនិយោគឡើង ហើយក៏បាន បង្កលក្ខណៈងាយស្រួលច្រើនដល់ការបញ្ជូន នៃអំណាចទិញពីអ្នកសន្សំទៅអ្នកវិនិយោគ ។ គុណសម្បត្តិនេះបានជំរុញឱ្យ សេដ្ឋកិច្ចរីកចំរើន ហើយក៏បានលើក កំពស់កិរិតជីវភាពរបស់សហគមផងដែរ ។

នៅពេលសេដ្ឋកិច្ច និងប្រព័ន្ធហិរញ្ញវត្ថុមានការវិវឌ្ឍន៍ នោះស្ថាប័នហិរញ្ញវត្ថុ (ឬអន្តរការីហិរញ្ញវត្ថុ) បានកើតឡើង ។ បច្ចុប្បន្នរដ្ឋាភិបាល ធនាគារពាណិជ្ជនានា សហគមន៍ ឥណទាន ក្រុមហ៊ុនធានា

រ៉ាប់រងទាំងអស់នេះគឺស្ថិតនៅ ជាអាជីវកម្មក្នុងការបង្វែមូលនិធិពី អ្នកសន្សំទៅឱ្យអ្នកវិនិយោគ ។ ដំណើរការបែបនេះត្រូវបានគេស្គាល់ថា អន្តរការីហិរញ្ញវត្ថុ ។

### ២.៣.១-នាំប្រាក់សន្សំទៅឱ្យមានការវិនិយោគ (Channeling Saving to Investment)

ទីផ្សារហិរញ្ញវត្ថុសំដែងនូវមុខងារជាបណ្តាញ នាំមូលនិធិសន្សំទៅឱ្យការវិនិយោគអាជីវកម្ម។ មានក្រុមសេដ្ឋកិច្ច ជាមូលដ្ឋានពីរៈ គ្រួសារ (Households) និងអាជីវកម្ម (Business) ។ គ្រួសារ ឬអាជីវកម្មដែលមានលក្ខណៈពិសេស អាច ជាអ្នកសន្សំសុទ្ធ ឬអ្នកខ្ចីសុទ្ធ ។

**ក-ហិរញ្ញប្បទានផ្ទាល់** (Direct Financing): អាជីវកម្មអាចចាប់ផ្តើមជាថ្មីម្តងទៀត ឬពង្រីកដោយការទទួលយកមូលនិធិដោយផ្ទាល់ពីក្រុមគ្រួសារនានា ។ របៀបមួយដើម្បីធ្វើបែបហ្នឹង គឺដោយលក់ប័ណ្ណភាគហ៊ុន (Common Stock) ដល់សាធារណៈជន ។

ភាគហ៊ុនដែលបានពីប័ណ្ណភាគហ៊ុន (A Share of Common Stock) នេះគេហៅថា ទ្រព្យសកម្មហិរញ្ញវត្ថុ (Financial Asset) ចំពោះម្ចាស់ភាគហ៊ុន ហើយក៏ក្លាយទៅជាទ្រព្យអកម្មហិរញ្ញវត្ថុផងដែរ (Financial Liabilities) ចំពោះអ្នកចេញប័ណ្ណ ឬចំពោះម្ចាស់ សាជីវកម្ម ។

**ខ-ហិរញ្ញប្បទានដោយប្រយោល** (Indirect Financing): ហិរញ្ញប្បទានដោយប្រយោលកើតឡើងនៅក្នុង ដំណើរការជាលទ្ធផលនៃអន្តរការីហិរញ្ញវត្ថុ ។តាមរយៈដំណើការនៃសហគ្រាសទទួលលុយពីការវិនិយោគ ពីស្ថាប័ន ហិរញ្ញវត្ថុ ដែលធ្វើសកម្មភាពជាអន្តរការី បានសំដែងចេញនូវ មុខងារធ្វើជាបណ្តាញនាំមូលនិធិសន្សំក្រុមគ្រួសារ ( អ្នកឱ្យខ្ចីចុងក្រោយ ) ទៅអាជីវកម្ម ( អ្នកខ្ចីចុងក្រោយ ) ។ ឧទាហរណ៍ធនាគារពាណិជ្ជទទួលបំណុលជារូបិយវត្ថុ ដូចជាប្រាក់បញ្ញើតាម តំរូវការ និងប្រាក់បញ្ញើបែបសន្សំ ... ។




រូបភាព៣៖ លំហូរមូលនិធិរវាងឯកតាអតិរេកនិងអង្គភាពឱនភាព ហិរញ្ញប្បទានផ្ទាល់

### ២.៣.២-តួនាទីប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ច

ដូចរូបទី 2.4 ខាងលើនេះបានបង្ហាញថា អន្តរការីហិរញ្ញវត្ថុបង្កើតនូវទីផ្សារ ដាច់ដោយឡែកពីរផ្សេងគ្នា នៅ ក្នុងការបង្កលក្ខណៈងាយស្រួលដល់ចរន្តមូលនិធិរវាងអង្គភាពដែលមានទុនលើស នឹងអង្គភាពដែលមានឱនភាព។ ទំហំ អន្តរការីហិរញ្ញវត្ថុធ្វើឱ្យគេរក្សាទុកនូវមូលប័ត្រ ពាណិជ្ជកម្មជាច្រើនក្នុងការកាត់បន្ថយហានិភ័យ (រូបទី 2.4)។

អន្តរការីហិរញ្ញវត្ថុនៅក្នុងចរន្តមូលនិធិរវាងអង្គភាពដែលមានទុនលើសនឹងអង្គភាពមានឱនភាពតួនាទីប្រាំ។ ហិរញ្ញវត្ថុអាចឱ្យគេយល់បានដោយការត្រួតពិនិត្យ ចរន្តហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចទៅលើអំឡុងពេលណាមួយដែលបាន បញ្ជាក់ច្បាស់លាស់ ។

មើលរូបទី 2.5 ខាងក្រោមបានបកស្រាយនូវរបៀបបីយ៉ាង ដែលនៅក្នុងរបៀបនោះ ប្រាក់ចំណូលអាជីវកម្មនិង គ្រួសារសំរាប់រយៈពេលមួយដែលគេអាចយកមកប្រើប្រាស់បាន ។




រូបភាព ៤៖ ប្រាក់ចំណូលអាជីវកម្មនិងគ្រួសារក្នុងរយៈពេល ១

## ២.៤ សេវាសំខាន់ៗនៃប្រព័ន្ធហិរញ្ញវត្ថុ

សេដ្ឋកិច្ចភាគច្រើនមានប្រព័ន្ធពីរដែលគេប្រមូលនិងបែងចែកធនធានស្របគ្នា។ ទីមួយគឺប្រព័ន្ធសារពើពន្ធ ដែលកេណ្ឌប្រមូលព័ន្ធតាមរយៈការយកពន្ធ និងប្រាក់ចំណេញរក្សាទុករបស់សហគ្រាសរដ្ឋ ហើយបែងចែកទុននេះតាមរយៈដំណើរការធ្វើផែនការ និងថវិកា ។ ទីពីរ គឺប្រព័ន្ធហិរញ្ញវត្ថុ ដែលគេប្រមូល ប្រាក់បញ្ញើដោយស្ម័គ្រចិត្ត ហើយ បែងចែកវា ទៅឱ្យ សហគ្រាសណាដែលមានបំណងធ្វើការវិនិយោគ។

ប្រព័ន្ធហិរញ្ញវត្ថុផ្តល់នូវសេវាដែលពាក់ព័ន្ធទៅនឹងការផ្គត់ផ្គង់សកម្មភាពបីយ៉ាងជាសំខាន់គឺៈ

### ២.៤.១-មធ្យោបាយទូទាត់

នៅពេលប្រព័ន្ធប្រើប្រាស់រូបិយវត្ថុមកជំនួសឱ្យប្រព័ន្ធយកទំនិញដូរទំនិញ នោះកិរិតឯកទេសកម្មកើនឡើងទីផ្សារ រីកសុះសាយ ហើយសេដ្ឋកិច្ចក៏មានប្រសិទ្ធភាពខ្ពស់ជាងមុន។

នៅពេលពាណិជ្ជកម្មនៃប្រទេសមួយរីកចំរើន ពីពាណិជ្ជកម្មក្នុងមូលដ្ឋានទៅ ពាណិជ្ជកម្មតំបន់ ទៅពាណិជ្ជកម្មជាតិ ហើយនឹងឆ្ពោះទៅពាណិជ្ជកម្មអន្តរជាតិនោះគេត្រូវការមធ្យោបាយទូទាត់មានលក្ខណៈទំនើបខ្លាំងឡើង។ នោះក៏មានការវិវត្តន៍តាមរយៈកំរិតឯកទេសកម្ម ក្នុងមធ្យោបាយទូទាត់។

### ២.៤.២-ការកេណ្ឌប្រមូលធនធាន

សេវាទាំងពីរដែលផ្តល់ដោយប្រព័ន្ធហិរញ្ញវត្ថុ គឺការកេណ្ឌប្រមូលទុន ពោលគឺការប្រមូល ប្រាក់សន្សំ ដោយស្ម័គ្រ ចិត្តក្នុងរូបភាពជាទ្រព្យសកម្មហិរញ្ញវត្ថុ ។ ទាល់តែពេលណាទ្រព្យសកម្មហិរញ្ញវត្ថុមានការរីកចំរើនដែលជាជំរើសមួយ ទាក់ទាញឱ្យមានការសន្សំ នោះប្រជាជននឹងមានបំណងរក្សាការសន្សំរបស់ខ្លួនក្នុង រូបភាពជាទ្រព្យហិរញ្ញវត្ថុ។

ប្រព័ន្ធហិរញ្ញវត្ថុនឹងរីកចំរើននៅពេលមានប្រជាជនច្រើនឡើងកាន់កាប់ទ្រព្យសកម្មហិរញ្ញវត្ថុដោយស្ម័គ្រចិត្ត ហើយនឹងនៅពេលណាគេមានទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខណៈទាក់ទាញខ្លាំងឡើង។

### ២.៤.៣-ការបែងចែកធនធាន

សេវាបីដែលផ្តល់ដោយប្រព័ន្ធហិរញ្ញវត្ថុ គឺការបែងចែកធនធានសំរាប់ការវិនិយោគ ។ ប្រទេសផ្សេងៗគ្នាបាន ជ្រើសរើសដំណោះស្រាយខុសៗគ្នាចំពោះបញ្ហា ស្តីអំពីតួនាទីដែល រដ្ឋាភិបាល ត្រូវបំពេញ ក្នុងការបែង ចែកធនធាន ។ ថ្វីបើការពឹងផ្អែកទៅលើប្រព័ន្ធហិរញ្ញវត្ថុមានកំរិតខ្លាំងជាងទៅលើថវិការរដ្ឋក្នុងការផ្តល់ទុនសំរាប់ការវិនិយោគក៏ ដោយក៏រដ្ឋាភិបាលក្នុងប្រទេសកំពុងអភិវឌ្ឍន៍រមែងណែនាំធនាគារ អំពីរបៀបបែងចែក យ៉ាងហោចណាស់ក៏ជាចំណែក មួយនៃធនធានដែរ ។

មូលហេតុដែលនាំឱ្យមានអន្តរាគមន៍ពីរដ្ឋាភិបាលក្នុងការបែងចែកហិរញ្ញវត្ថុក្នុងប្រទេសស្ទើរតែទាំងអស់ គឺថា ទីផ្សារហិរញ្ញវត្ថុខ្លួនឯង មិនដែលប្រព្រឹត្តទៅយ៉ាងពេញលេញឡើយ ។

នៅពេលរដ្ឋាភិបាលធ្វើការកែប្រែពីការធ្វើផែនការប្រមូលផ្តុំឆ្ពោះទៅរកការប្រើប្រាស់ទីផ្សារ នោះការគ្រប់គ្រង របស់រដ្ឋាភិបាលទៅលើការបែងចែកឥណទានចាប់ផ្តើមមានលក្ខណៈបន្ធូបន្ថយ ហើយគេអនុញ្ញាតិឱ្យស្ថាប័នហិរញ្ញវត្ថុធ្វើ ការសំរេចពីការបែងចែកឱ្យបានច្រើនជាងមុន ។

## ២.៥ លក្ខណៈនៃអត្រាការប្រាក់

ការប្រាក់(Interest)គឺជាចំនួនសាច់ប្រាក់ដែលអ្នកឱ្យខ្ចីទទួលបាននៅពេលដែល គេធ្វើឥណទាន។អត្រាការប្រាក់(interest rate) គឺជាអត្រាការប្រាក់ទៅលើចំនួនលុយដែលឱ្យខ្ចីនោះ។ ឧទាហរណ៍ ឧបមាថាឱ្យលុយគេខ្ចី100ដុល្លានៅដាច់ឆ្នាំទទួលបាន 110ដុល្លា ។ ចំនួន10ដុល្លាដែលគេបង់ឱ្យគឺជាការប្រាក់ហើយ 10% នេះគឺជាអត្រាការប្រាក់ព្រោះ( $10 / $100 = 0.10 ) ។

### ២.៥.១ ការកំនត់អត្រាការប្រាក់នៅលើទីផ្សារ

អ្នកសន្សំប្រាក់ ឬអ្នកឱ្យខ្ចីនឹងផ្គត់ផ្គង់មូលនិធិទៅលើទីផ្សារឥណទាន ។ អ្នកខ្ចីនឹងត្រូវការមូលនិធិពីទីផ្សារ ឥណទានមកវិញ ។

បរិយាកាសបច្ចុប្បន្ន ផ្តល់នូវរូបភាពទំនាក់ទំនងកាន់តែសំខាន់ឡើង១ ទៅលើការប្រកួតប្រជែងពីថ្លៃ ហើយថ្លៃ ដែលសំខាន់នៅក្នុងការប្រកួតប្រជែងនេះ គឺអត្រាការប្រាក់ ។

#### ក.អត្រាការប្រាក់ទៅលើមូលនិធិដែលត្រូវអោយខ្ចី

គេកំនត់អត្រាការប្រាក់ដោយកត្តាតំរូវការនិងផ្គត់ផ្គង់ ។ គេកំនត់នូវការផ្គត់ផ្គង់និងតំរូវការមូលនិធិដោយ កត្តាជាច្រើន ។ ក្នុងចំណោមកត្តាដែលគេបានកំនត់ទាំងនោះ គឺភាពរំពឹងទុកអំពីអតិផរណាដែលនឹងកើតមាន ឬថ្លៃ នាពេលអនាគត ជាពិសេសគឺផ្នែកឯកជន ហានិភ័យ និងភាពអនុគ្រោះខាងសន្ទនីយភាព ។

#### ខ.ការផ្គត់ផ្គង់ឥណទាន

គេកំនត់អត្រាការប្រាក់ឱ្យស្ថិតនៅក្នុងភាពសមតាដោយសារអន្តរសកម្មនៃតំរូវការ និង ការផ្គត់ផ្គង់នូវមូលនិធិ ដែលត្រូវឱ្យខ្ចីនោះ។ អ្នកសេដ្ឋកិច្ចបែបក្លាស៊ីក (Classical economist) ជឿជាក់ថាការសន្សំ ឬការផ្គត់ផ្គង់នៃ មូលនិធិដែលត្រូវឱ្យខ្ចីនេះ គឺមានទំនាក់ ទំនងវិជ្ជមានដល់អត្រាការប្រាក់។ ក្រោយមកអ្នក សេដ្ឋកិច្ចក៏បានបញ្ជាក់ថា ការសន្សំ គឺគ្រាន់ជាមុខងារនៃកំរិតប្រាក់ចំណូលរបស់គ្រួសារប៉ុណ្ណោះ ។

អត្រាការប្រាក់ជាដំបូងរងឥទ្ធិពលដោយសារចរន្តមូលនិធិដែលត្រូវឱ្យខ្ចីនោះ ( ទាំងការ ផ្គត់ផ្គង់ និងតំរូវការ ) មិនតាមរយៈសន្និធិមូលនិធិដែលមិនទាន់សងនោះទេ ។ ក្រៅពីចរន្ត នៃប្រាក់សន្សំកំនើន ការផ្គត់ ផ្គង់រូបិយវត្ថុ និងការ ថយចុះតំរូវការរូបិយវត្ថុ ក៏មានផលប៉ះពាល់ដល់ការផ្គត់ផ្គង់មូលនិធិដែលត្រូវឱ្យខ្ចីនោះ ។

### គ.តំរូវការឥណទាន

តំរូវការលើមូលនិធិ ដែលត្រូវឱ្យខ្ចីនោះអាស្រ័យលើ តំលៃនៃមូលនិធិទាំងនោះ ឬអាស្រ័យលើ អត្រាការប្រាក់ពិត ។ ជាទូទៅគេជឿជាក់ថា នៅពេលផ្នែកឯកជនធ្វើការខ្ចី នោះគឺមានលក្ខណៈភ្លោច ឬ មានភាពរួញយឺតនៅការ ប្រាក់ ។ បើសិនយើងដាក់ឱ្យមាន ខ្សែកោងតំរូវការសំរាប់មូលនិធិដែលត្រូវឱ្យ ខ្ចីនោះជាមួយ ខ្សែកោងផ្គត់ផ្គង់ នោះយើងកំនត់បាននូវអត្រាការប្រាក់ដែលមានលក្ខណៈសមតាបាន។




រូបភាព ៥៖ បរិមាណកម្ចីឥណទាន

## ២.៥.២-អត្រាការប្រាក់ធម្មតា និងអត្រាការប្រាក់ពិត

**-អត្រាការប្រាក់ធម្មតា** (Nominal interest rate): គឺជាអ្វីដែលអ្នកឱ្យខ្ចីទទួលបាន ឬត្រូវបាន គេកំនត់ថាជា អត្រាប្តូររវាង មួយដុល្លាថ្ងៃនេះជាមួយនឹងមួយដុល្លាថ្ងៃខាងមុខ ។

**-អត្រាការប្រាក់ពិត** (Real interest rate): គឺត្រង់ថា អ្នកឱ្យខ្ចីបានចាប់អារម្មណ៍ទៅលើតំលៃពិត នៃលុយ របស់ខ្លួនប៉ុន្មាន ដែលកើនឡើងនោះ ។ យើងហៅករណីបែបនេះថាជាអត្រាការប្រាក់ពិត ម្យ៉ាងទៀតគេថា អត្រាការ ប្រាក់ ពិតគឺជាអត្រាប្តូររវាងទំនិញ និងសេវា (របស់ពិត) បច្ចុប្បន្នជាមួយនឹង ទំនិញ ឬសេវានាពេលខាងមុខ ។

អត្រាការប្រាក់ពិតគឺស្មើទៅនឹងអត្រាការធម្មតាដកអត្រាអតិផរណា ។

- សមីការដែលទាក់ទងទៅនឹងអត្រាការប្រាក់ពិត និងអត្រាការប្រាក់ធម្មតា

(An equation relating real and nominal-interest rate)

គេអាចប្រើប្រាស់សមីការធម្មតាមួយដើម្បីបង្ហាញនូវទំនាក់ទំនងរវាងអត្រាការប្រាក់ធម្មតា និង អត្រាការប្រាក់ ពិត ។ គេត្រូវបានគេបង្ហាញដូចខាងក្រោម៖

**អត្រាការប្រាក់ធម្មតា(i)= អត្រាការប្រាក់ពិត(r) + អត្រាអតិផរណាដែលរំពឹងនឹងកើតមាន(Pe)**
**(Nominal interest rate = Real interest rate + Expected inflation rate)**

សមីការនេះគេក៏អាចរៀបចំចាត់ចែងឡើងវិញដោយបង្ហាញដូចខាងក្រោមៈ

អត្រាការប្រាក់ពិត (x)= អត្រាការប្រាក់ធម្មតា(i) - អត្រាអតិផរណាដែលរំពឹងនឹងកើតមាន (Pe)

យើងអាចធ្វើការបកស្រាយរវាងអត្រាការប្រាក់ពិត និងអត្រាការប្រាក់ធម្មតាដោយតាម ខ្សែកោង តំរូវការ និងខ្សែកោងផ្គត់ផ្គង់ចំពោះមូលនិធិដែលត្រូវឱ្យខ្ចី ។ ក្នុងរូប 2.7 គឺគេបានកំនត់នូវសមតាដើមនៃអត្រាការប្រាក់ពិត ro ដោយអន្តរសកម្មរវាងតំរូវការ (D) និងការផ្គត់ផ្គង់ (S) នៅត្រង់ចំនុច (E1, D1 និង S1) តំណាងតំរូវការ និងការផ្គត់ផ្គង់ បើសិនជាអតិផរណាមានតំលៃសូន្យ ។




រូបភាព ៦ៈសមតាដើមនៃអត្រាការប្រាក់ពិត

# ជំពូក ៣ ទីផ្សារប្ដូរប្រាក់

## ៣.១ អត្រាប្ដូរប្រាក់

ការទូទាត់ប្រតិបត្តិការដោះដូរសំរាប់ការធ្វើពាណិជ្ជកម្មអន្តរជាតិ និង ធ្វើការវិនិយោគរវាងភ្នាក់ងារសេដ្ឋកិច្ច ក្នុងស្រុកនិងភ្នាក់ងារសេដ្ឋកិច្ចបរទេស តំរូវអោយកើតមាននូវប្រតិបត្តិការប្ដូរប្រាក់ ពោលគឺប្ដូរពីរូបិយ វត្ថុជាតិទៅរូបិយ ប័ណ្ណរបស់ប្រទេសមួយទៀត ។ ថ្លៃនៃរូបិយវត្ថុធៀបទៅនិងរូបិយប័ណ្ណត្រូវគេអោយឈ្មោះថា "អត្រាប្ដូរប្រាក់" (Exchange rate) ដែលត្រូវបានគេប្រើប្រតិបត្តិនៅក្នុងការដោះដូរ ហើយវាតែងតែមានការប្រែប្រួលគ្រប់ពេល វេលា ។ ឧទាហរណ៍ កិច្ចព្រមព្រៀង ប្រេតុនវូត "Bretton Woods" នៅឆ្នាំ 1944-1971 បានកំណត់អត្រាការប្រាក់ នៃរូបិយវត្ថុមួយធៀបទៅ នឹងរូបិយប័ណ្ណប្រទេសមួយទៀត ($35/តំឡើង) ត្រូវមានកម្រិតរលកមួយថេរទាបជាក់លាក់ ±1% ដើម្បីអោយរដ្ឋាភិបាលងាយស្រួលក្នុងការជួយអន្តរាគមន៍ ។ កិច្ចព្រមព្រៀង Bretton Woods បានធ្វើអោយ រូបិយវត្ថុខ្លះមានការកើនតំលៃខ្ពស់(Overvalue)និងខ្លះទៀតមានការចុះតំលៃ(Undervalue)យ៉ាងខ្លាំង ។នៅឆ្នាំ1971 កិច្ចព្រមព្រៀង Smithsonian បានស្វែងរកឃើញនូវវិធីដោះស្រាយបញ្ហានេះ ។ ក្រោមកិច្ចព្រមព្រៀង Smithsonian នៅក្នុងបណ្ដាប្រទេសធំៗអនុញ្ញាតិអោយធ្វើការបញ្ចុះតំលៃរូបិយវត្ថុនិងព្រំដែននៃអត្រាប្ដូរប្រាក់មួយដែលអាចប្រែប្រួលនៅចន្លោះ±2.25% ។ នៅក្នុងឆ្នាំ 1973 កិច្ចព្រមព្រៀង Smithsonian 11 បានលុបចោលទាំងអស់នូវ ព្រំដែនអត្រាប្ដូរប្រាក់ ។តាមរយៈការលប់ចោលនេះបានធ្វើអោយរូបិយវត្ថុសំខាន់ទាំងអស់ អាចធ្វើការដោះដូរបានដោយ សេរីជាមួយអត្រាប្ដូរប្រាក់អណ្ដែត (Floating rate) តែទោះយ៉ាងណាក៏ដោយធនាគារកណ្ដាលនៅតែធ្វើការអន្តរាគមន៍ដោយផ្ទាល់ទៅក្នុងទីផ្សារប្ដូរប្រាក់ ដើម្បីកំណត់នូវគោលដៅនៃអត្រាប្ដូរប្រាក់ នៃរូបិយវត្ថុរបស់ប្រទេសគេធៀប ទៅនឹងរូបិយប័ណ្ណបរទេស ។

អត្រាប្ដូរប្រាក់គឺជា តំលៃ (Price) នៃរូបិយវត្ថុមួយ (ឧ. រៀល) ដូរជាមួយ រូបិយប័ណ្ណ របស់ប្រទេស មួយទៀត (ឧ. ដុល្លារ) ។នៅក្នុងតារាង 3-1 គឺជាបញ្ជីនៃអត្រាប្ដូរប្រាក់ រវាងដុល្លា U.S.A និងរូបិយវត្ថុនៃ ប្រទេសមួយចំនួន ។អត្រានៅក្នុងតារាងបង្ហាញតាមលក្ខណៈពីរយ៉ាង សំរាប់ការដូរដោយប្រយោល ឯកតា រូបិយប័ណ្ណ បរទេស ដែលត្រូវទទួលស្មើ x ដុល្លា U.S.A (U.S $ Equivalent) និងការដូរដោយផ្ទាល់ ឯកតានៃ ដុល្លា U.S.A ដែលត្រូវទទួល ស្មើ x រូបិយប័ណ្ណបរទេស (Currency per U.S $) ។ឧទាហរណ៍ អត្រាប្ដូរប្រាក់ ដុល្លាU.S.A ជាមួយនឹងដុល្លា Canada នៅថ្ងៃទី ២០ ឧសភា ឆ្នាំ ២០០២ គឺ 0.6486(US$/C$) រឺ អាចនិយាយថា 0.6486 $ US អាចដូរបានគ្រប់1ដុល្លា Canada។

ផ្ទុយមកវិញ បើអត្រាប្ដូរប្រាក់ Canada ធៀបទៅនឹង ដុល្លា US គឺ 1.5418 (C$/US$) រឺអាចនិយាយថា1.5418 ដុល្លា Canada សំរាប់ធ្វើការដូរគ្រប់ 1 ដុល្លា US ។

ជាក់ស្ដែងក្នុងករណីការដាក់តំលៃដោយផ្ទាល់ ការថយចុះនៃអត្រាប្ដូរប្រាក់ មានន័យថារូបិយវត្ថុជាតិ ចុះថ្លៃ ។ បើក្នុងករណីការដាក់តំលៃដោយប្រយោលវិញ ការថយចុះនៃអត្រាប្ដូរប្រាក់ មានន័យថារូបិយវត្ថុជាតិ ឡើងថ្លៃធៀបជា មួយរូបិយប័ណ្ណ ។

## ៣.២ ប្រតិបត្តិការប្តូរប្រាក់

ដោយសារតែចរិតលក្ខណៈមិនអាច ព្យាករណ៍ បានទាំងស្រុងនៃអត្រាប្តូរ ប្រាក់បង្កនូវហានិភ័យសំរាប់គ្រប់ ភ្នាក់ងារ ដែលអន្តរាគមមកលើទីផ្សារប្តូរប្រាក់ ។ ដើម្បីការពារ រឺ ទប់ស្កាត់ហានិភ័យនេះ ភ្នាក់ងារទាំងនោះអាច ធ្វើប្រតិបត្តិ ការមួយប្រភេទគឺ Hedging ។

EX: អ្នកនាំចូលជនជាតិខ្មែរម្នាក់ត្រូវទូទាត់ថ្លៃទំនិញចំនួនទឹកប្រាក់200,000$ទៅក្រុមហ៊ុននាំចេញអាមេរិចកាំងនៅរយៈ៣ខែ ក្រោយគិតចាប់តាំងពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៣។ បើអ្នកនាំចូលខ្មែររក្សាបំណុលនេះជា រូបិយវត្ថុជាតិ នោះអាចជួបហានិភ័យដែលបណ្តាលមកពីបំរែបំរួលអត្រាប្តូរប្រាក់ ។

សន្មត់ថាអ្នកនាំចូលរូបនេះព្យាករណ៍ឃើញថា តំលៃដុល្លានឹងកើនឡើងក្នុងចន្លោះពេលរងចាំ គេអាចទប់ស្កាត់ការ ខាតបង់ដោយសារការឡើងថ្លៃនៃរូបិយប័ណ្ណដុល្លានេះដោយសំរេចចិត្តយកលុយរៀល ទិញដុល្លា ចំនួន 200,000$ នេះភ្លាមតែម្តង ។ ករណីនេះបំណុលមិនប្រែប្រួលទៀតទេ វាជាក់លាក់តែម្តង។ ទង្វើនេះគេអោយឈ្មោះថាការ សំរេចធ្វើប្រតិបត្តិការ Hedging ។

បើនៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៣ តំលៃអត្រាប្តូរប្រាក់ 1$ = ៣០០០រៀល ហើយអ្នកនាំចូល ព្យាករណ៍ ឃើញថាអត្រានេះនឹងកើនឡើង នោះគេសំរេចប្តូរប្រាក់តែម្តងចំនួន 200,000$ ដែលសមមូល 200,000 x 3,000 = 600,000,000រៀល។ ប្រាក់ដែលប្តូររួចនេះ (200,000$) ត្រូវរក្សាទុកសងបំណុល ពេលថ្ងៃកំណត់មកដល់ ។

នៅថ្ងៃកំណត់សងបំណុលមកដល់ បើអត្រាប្តូរប្រាក់ក្នុង15កើនលើសពី 3,000រៀល នោះគេថា ប្រតិបត្តិការ Hedging ផ្ទៀងផ្ទាត់ ។ផ្ទុយទៅវិញ បើអត្រានេះបែរជាថយចុះទាបជាង 3,000រៀល នោះគេថា ប្រតិបត្តិការ Hedging មិនផ្ទៀងផ្ទាត់ ។

*សំគាល់:* ទោះជាយ៉ាងនេះក្តីប្រតិបត្តិករភាគច្រើនមានចំណូលចិត្តប្រើប្រាស់ Hedging ជាជាងរក្សាបំណុល ជារូបិយវត្ថុ ជាតិ ដែលតំលៃបំណុលប្រែប្រួលមិនទៀងទាត់អាស្រ័យតាមបំរែបំរួលនៃអត្រាប្តូរប្រាក់ ។

### អ្វីទៅដែលហៅថាប្រតិបត្តិការកំណែខយកកំរៃ (Speculation)?

ផ្ទុយពី Hedging ដែលប្រតិបត្តិករភ័យខ្លាចហានិភ័យករណី Speculation ប្រតិបត្តិករស្ម័គ្រចិត្តទទួលយក ហានិភ័យដោយសង្ឃឹមថានឹងទាញយកកំរៃពីហានិភ័យនេះ ។ កំរៃនេះជាប្រាក់ចំណេញ នៃប្រតិបត្តិការ Speculation ហើយវាស្មើ និងផលដក រវាងថ្លៃលក់រូបិយប័ណ្ណ និងថ្លៃទិញរូបិយប័ណ្ណ ។ ក្នុងករណីដែលថ្លៃលក់រូបិយប័ណ្ណ ថយចុះ ទាបជាងថ្លៃទិញចូលនោះប្រតិបត្តិករ(Operator) រងនូវការខាតបង់ ។សកម្មភាព Speculation ត្រូវពឹងផ្អែកទាំង ស្រុងលើការព្យាករណ៍ (Anticipation) របស់ប្រតិបត្តិករ ។

EX: ប្រតិបត្តិករម្នាក់ព្យាករណ៍ឃើញថារូបិយប័ណ្ណដុល្លានឹងឡើងថ្លៃក្នុងកំឡុង ១ ខែ ក្រោយពេលនោះគេសំរេចចិត្តទិញដុល្លាស្តុកទុក រងចាំលក់នៅ ១ខែក្រោយពេលដែលតំលៃដុល្លាកើនឡើង។ សំនួរចោទឡើង គឺថា តើធ្វើ ដូចម្តេចអាចជឿជាក់បានទាំងស្រុងលើការព្យាករណ៍ព្រោះវាមិនមែនជាការពិតជាក់ស្តែង ហើយ គ្មាននរណាម្នាក់អាច ដឹងការពិតបាន?

ចំលើយនៃសំនួរនេះត្រូវផ្អែកលើទស្សនៈរបស់លោក J.M.Keynes ស្តីអំពី "Animal Spirits"។ លោក J.M.Keynes យល់ស្របថា សមត្ថភាពរបស់មនុស្សមានកំណត់គេពុំអាចយល់ និងស្គាល់បានច្បាស់ ពីអ្វីដែល នៅជុំវិញ ខ្លួននិងពីអ្វីដែលអាចនឹងកើតឡើងក្នុងអនាគតកាលបានឡើយ ព្រោះសកម្មភាពសេដ្ឋកិច្ចប្រព្រឹត្ត ទៅក្នុងស្ថានភាព មិនប្រាកដ ពោលគឺគេមិនអាចកំណត់ប្រូបាប៊ីលីតេ លើព្រឹត្តិការណ៍នោះបាន ។ ហេតុនេះ ភាពមិនប្រាកដប្រជា (Uncertainty) គ្របដណ្តប់ទាំងស្រុងលើសកម្មភាពរបស់ភ្នាក់ងារសេដ្ឋកិច្ច ។

ចំនុចចាប់ផ្តើមលោក J.M.Keynes បានលើកឧទាហរណ៍មួយដែលបញ្ជាក់ពីការចាប់កំនើត នៃវាក្យសព្ទ "Animal Spirits" ។ លោកសន្មត់ថា គេដឹកជញ្ជូនសត្វចៀមមួយចំនួនតាមកាណូត ឆ្លងកាត់ទន្លេមួយ ។ មួយរយៈ ពេលនៃការធ្វើដំណើរ មានសត្វចៀមមួយបានលោតចុះទឹក ហើយសត្វចៀម ផ្សេងៗទៀតឃើញ សភាពបែបនេះ (តែ ពុំដឹងពីហេតុដែលបណ្តាលអោយសត្វចៀមទី១លោតចុះទឹកទេ) ក៏ចាប់លោតចុះទឹកម្តងមួយៗ តាមគ្នា រហូតទាល់តែ អស់ពីកាណូត។ ឧទាហរណ៍ នេះឆ្លុះបញ្ចាំងអោយឃើញថា សត្វចៀមទាំងនេះ ធ្វើតាមគ្នាដោយគ្មានមូលហេតុ ទាល់តែសោះ ។ លោក Keynes បញ្ជាក់ថា ចំពោះមនុស្សវិញក៏ដូច្នោះដែរ ។

សត្វចៀមជាឧទាហរណ៍ស្រាប់ហើយ មិនមែនតែសត្វចៀមទេ មនុស្សយើងក៏ដូច្នេះដែរ និងត្រូវតែធ្វើដូច្នេះ ។ លោក J.M.Keynes ផ្តល់ទស្សនៈថាមនុស្សយើងពុំអាចស្គាល់បានពិតប្រាកដ ពីអ្វីដែលនឹងកើតឡើងទៅអនាគត កាល ប៉ុន្តែការពិតអ្វីដែលនឹងកើតឡើងក្នុងអនាគតកាល គឺជាអ្វី ដែលជាការយល់ឃើញ របស់មនុស្សភាគច្រើនទោះ ជាការយល់ឃើញនោះខុសក៏ដោយ ត្រូវក៏ដោយ ។ ទស្សនៈនេះអាចបកស្រាយ ម្យ៉ាងទៀតបាន ថាបើមនុស្សភាគ ច្រើនយល់ឃើញយ៉ាងណា នោះអ្វីៗនឹងកើតឡើងយ៉ាងនោះយ៉ាងពិតប្រាកដ ។

EX1: នៅបំណាច់ឆ្នាំ ២០០០ មានពាក្យចចាមរាមថា ប្រព័ន្ធកុំព្យូទ័រត្រូវជួប Error ។ ពាក្យចចាមរាមនេះបានដក់ជាប់ក្នុងគោលគំនិតរបស់មនុស្សគ្រប់រូប ។ម្នាក់ៗមិនហ៊ានជឿជាក់ទាំងស្រុង លើពាក្យនេះ ហើយក៏មិនហ៊ាន ជឿជាក់ដែរ ព្រោះហេតុផលមានលក្ខណៈសមរម្យ ហើយម្យ៉ាងទៀតខ្លួន ពុំអាចមាន សម្ថត្ថភាពវិនិច្ឆ័យបាន ។ ទិដ្ឋភាព នេះមានឥទ្ធិពលលើអត្តចរិតរបស់គេម្នាក់ៗ សំរេចចិត្តមិនទិញកុំព្យូទ័រ (ព្រោះខ្លាចភាពប្រថុយប្រថាន) ក្នុងកំឡុង ពេលខែ ១២ឆ្នាំ ១៩៩៩ ដល់ខែ ០១ឆ្នាំ ២០០០ ។ ភាពជាក់ស្តែងបានបង្ហាញអោយឃើញពីការធ្លាក់ចុះនៃចំណូលនៃក្រុមហ៊ុនលក់Computer។ ដូចគ្នា ចំពោះក្រុមហ៊ុន អាកាសចរ ។

EX2: សន្មត់ថាមនុស្សមួយចំនួនធំព្យាករណ៍ឃើញថា តំលៃដុល្លា នឹងកើនឡើងនាពេល ៣ខែខាងមុខ ។ ពេលនោះគេគ្រប់ៗគ្នាសំរេចទិញដុល្លាហើយបន្ទាប់មកតំលៃរូបិយប័ណ្ណដុល្លាក៏កើនឡើងពិតមែន ។

ប្រតិបត្តិការដោះដូរលើទីផ្សារប្តូរប្រាក់សំរេចឡើងដោយអ្នកកាន់កាប់ប្តូររូបិយវត្ថុ "Cambists" សំរាប់គណនី របស់ធនាគារ ។ ទំនាក់ទំនងរវាង Cambists អាចធ្វើឡើងតាមរយៈទូរស័ព្ទ ឬ Telex ។ ម្យ៉ាងទៀត កិច្ចសន្យា (Contracts) ដែលគេកំណត់ ឡើងជាមួយគ្នាច្រើនតែធ្វើដោយផ្ទាល់មាត់ ។

អត្រាប្តូរប្រាក់រវាងរូបិយប័ណ្ណពីរ កំណត់ដោយកិច្ចព្រមព្រៀងរវាង Cambists ពីរវាមិនមែនជាអត្រាប្តូរប្រាក់ លំនឹងនៃទីផ្សារប្តូរប្រាក់ទេ វាគ្រាន់តែជាការដោះដូរដោយឡែកមួយរវាងភ្នាក់ងារពីរ ក្នុងពេលមួយកំណត់ ។ អាស្រ័យ ដោយការរីកចំរើនបច្ចេកវិជ្ជាតាំងពី ២០ ឆ្នាំកន្លងមកនេះ ប្រតិបត្តិការដោះដូរអាចត្រូវ សំរេចឡើងក្នុងរយៈពេលដ៏ខ្លី ជាមួយអត្រាប្តូរប្រាក់ប្រហាក់ប្រហែលគ្នា ឬ ស្មើគ្នា ។ អត្រានេះប្រែប្រួលជា ប្រចាំអាស្រ័យតាមការព្យាករណ៍របស់ Cambists ។ ទីផ្សារប្តូរប្រាក់ រួមមាន ប្រតិបត្តិការច្រើនបែបដែលប្រភេទនីមួយៗមានវិធានដោយឡែកៗពីគ្នា សំរាប់ ដំណើរការ ។

### ៣.២.១ ប្រតិបត្តិការប្តូរប្រាក់ប្រគល់ភ្លាម (Spot foreign exchange transaction)

នៅលើទីផ្សារប្រភេទនេះ លក្ខខ័ណ្ឌនៃការដោះដូររូបិយប័ណ្ណ (ថ្លៃ និង បរិមាណ) ត្រូវកំណត់ដោយ ភាគីនៃកិច្ចសន្យានៅថ្ងៃ D ហើយ ការដោះដូរជាក់លាក់ យ៉ាងយូរបំផុតពីរថ្ងៃ ក្រោយថ្ងៃ D ។

EX: នៅថ្ងៃទី ១០ ខែ ០៨ ឆ្នាំ ២០០៤ លោក A សំរេចលក់អោយ លោក B នូវរូបិយប័ណ្ណដុល្លាចំនួន 5,000,000$ ជាមួយរូបិយវត្ថុរៀលសំរាប់អត្រា 1$ = 3,800រៀល ។

ការដោះដូរនេះប្រព្រឹត្តទៅលើ Spot transaction លុះត្រាតែយ៉ាងយូរបំផុតនៅថ្ងៃទី ១២ ខែ ០៨ ឆ្នាំ ២០០៤:

-លោក A ផ្ទេរប្រាក់ចំនួន 5,000,000$ ទៅអោយគណនីរបស់លោក B

-លោក B ផ្ទេរប្រាក់ចំនួន 5,000,000$ x 3,800 =19,000,000,000រៀល ទៅអោយគណនីលោក A ។

### ៣.២.២ ប្រតិបត្តិការប្តូរប្រាក់មានភ្នាក់កំណត់ (Forward foreign exchange transaction)

វិធានសំរាប់ដំណើរការចំពោះ Forward Transaction គឺលក្ខខ័ណ្ឌនៃការដោះដូរកំណត់ ឡើងនៅថ្ងៃ D ហើយការដោះដូរជាក់លាក់នឹង ប្រព្រឹត្តទៅ យ៉ាងឆាប់បំផុតក្រោយពីរថ្ងៃ ក្រោយថ្ងៃ D។ រយៈពេលដែលគេ និយម ប្រើជាញឹកញាប់គឺ ៣០ ថ្ងៃ ៦០ថ្ងៃ ៩០ថ្ងៃ ៨០ថ្ងៃ ៦ខែ ឬ ១ ឆ្នាំ ។

គុណប្រយោជន៍នៃ Forward Transaction គឺទប់ស្កាត់ហានិភ័យដែលបណ្តាលមកពី បំរែបំរួល នៃអត្រាប្តូរប្រាក់ព្រោះតំលៃអត្រាប្តូរប្រាក់ និង បរិមាណសាច់ប្រាក់ដែលត្រូវប្តូរត្រូវកំណត់រួចជាស្រេចនៅថ្ងៃ D ។ ភាពខុសគ្នានៃ ប្រតិបត្តិការលើ Forward និង Spot គឺត្រង់ថាលើ Forward នៅថ្ងៃ D

គេគ្រាន់ តែធ្វើកិច្ចសន្យា រីឯការទូទាត់ (បង់លុយទិញ) ត្រូវកំណត់ធ្វើនៅពេលកំណត់មកដល់ ចំណែក Spotវិញការទូទាត់ (បង់លុយទិញ) ត្រូវធ្វើឡើង តែម្តងនៅថ្ងៃD រីឯការទូទាត់ត្រូវរងចាំថ្ងៃកំណត់មកដល់( សងម្ចាស់ បំណុល) ។

EX: អ្នកនាំចូលកម្ពុជាម្នាក់ត្រូវទូទាត់សងបំណុលក្រុមហ៊ុនលក់រថយន្តរបស់អាមេរិចនៅ បីខែក្រោយ គិតចាប់តាំងពីថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៣ ។ បំណុលដែលត្រូវសងមានចំនួន 10,000$ ។

-បើអ្នកនាំចូលរូបនេះទុកបំណុលជារូបិយវត្ថុនោះ អាចជួបការខាតបង់ បើតំលៃដុល្លា នៅបីខែខាងមុខកើនឡើង (Forward transaction) ។

-Spot អនុញ្ញាតិអោយអ្នកនាំចូលទប់ស្កាត់ហានិភ័យដោយផ្ទេរបំណុល 10.000$ នេះជារូបិយប័ណ្ណដុល្លា ភ្លាមតែម្តងទុកសងបំណុលពេលកំណត់មកដល់ ។

-លទ្ធភាពមួយទៀតគឺ អ្នកនាំចូលអនុវត្តកិច្ចសន្យាប្រតិបត្តិការ Forward ពោលគឺ ចុះកិច្ចសន្យាទិញ ដុល្លាចំនួន 10.000$ភ្លាមតែម្តងដោយកំណត់អត្រាប្តូរប្រាក់នៅថ្ងៃចុះកិច្ចសន្យានេះហើយ បីខែក្រោយ មក ដល់ទើបប្តូរប្រាក់ចំនួន 10.000$ នេះជាមួយអត្រាប្តូរប្រាក់ក្នុងកិច្ចសន្យា ។

វិធីទប់ស្កាត់ហានិភ័យទាំងពីរនេះ នៅតែមានកង្វះខាតព្រោះបើតំលៃរូបិយប័ណ្ណដុល្លា បែរជាចុះថោកវិញ នៅបីខែ ក្រោយ កូនបំណុលត្រូវរងនូវការខាតបង់ ។ ក្រៅពីស្តង់ដារកិច្ចសន្យា Forward មានជំរើសទំរង់ ប្រភេទទៀត អាច ជួយកែលំអរបញ្ហានេះ គឺកិច្ចសន្យាមានគ្រាកំណត់ជ្រើសរើសសិទ្ធ Forward "Options forward contract" ។

### ៣.២.៣ សិទ្ធិជ្រើសរើសរូបិយប័ណ្ណ (Options on currencies)

សំរាប់ស្ថាប័នវិនិយោគណាដែលមិនប្រាកដប្រជាក្នុងចិត្ត ចំពោះការប្រែប្រួលតំលៃនៃរូបិយប័ណ្ណ នោះកិច្ច សន្យា Option អនុញ្ញាតិអោយអ្នកទិញគេចផុតពីកាតព្វកិច្ចគោរពកិច្ចសន្យា (បដិសេធ) តាមការសំរេចចិត្ត របស់គេ ។ ភាគី អ្នកលក់នៃកិច្ចសន្យា Option តំរូវអោយអ្នកទិញបង់បុព្វលាភ (Premiums) ដើម្បីទទួលបានសិទ្ធិខាងលើ (គោរពកិច្ចសន្យាក៏បាន មិនគោរពតាមក៏បាន) ។ សំរាប់ភាគីអ្នកលក់ Option ត្រូវតែ គោរពដាច់ខាតតាមកិច្ចសន្យា ។

Option លើរូបិយបណ្ណ័មួយគឺជាសិទ្ធិទិញ (Call-Option) ឬលក់ (Put-Option) រូបិយប័ណ្ណនោះជាមួយ រូបិយប័ណ្ណមួយទៀត សំរាប់ពេលកំណត់មួយសំរាប់ថ្លៃកំណត់មួយ (Strike price/Exercise price) ហើយអ្នកទិញ ត្រូវទូទាត់បុព្វលាភអោយអ្នកលក់ក្នុងពេលធ្វើកិច្ចសន្យា ។ EX1: Call Option មួយលើរូបិយប័ណ្ណ Sterling ជាមួយរូបិយប័ណ្ណដុល្លា:

-Strike price 1 £=1.550$ - Premium 3.03 សេន/£

*<u>សំគាល់:</u>* ក្នុងកំឡុងពេលសុពលភាពនៃកិច្ចសន្យា Options :

-អ្នកទិញ Call-Option លើ Sterling គឺទិញសិទ្ធិទិញ £ មានន័យថា កាលកំនត់មកដល់គេទិញ £ លក់ $ ។

-អ្នកលក់ Call-Option លើ Sterling គឺលក់សិទ្ធិទិញ £ មានន័យថា ពេលកំណត់មកដល់ គេទិញ $ លក់ £ ។

- ➢ អ្នកទិញ (Buyer): សូមមើលរូបភាពទី 3-2
- កណើ Spot price 〉 1.5803$/£ អ្នកទិញ ទទួលបានប្រាក់ចំណេញ
- កណើ Spot price 〈 1.5803$/£ អ្នកទិញ ទទួលការខាតបង់ (មានកំណត់ស្មើនឹងទឹកប្រាក់បុព្វលាភ)
- ➢ ចំពោះអ្នកលក់ (Seller): សូមមើលរូបភាពទី 3-3
- កណើ spot price 〈1.5903$/£ អ្នកលក់ទទួលបានប្រាក់ចំណេញ (យ៉ាងច្រើនស្មើនឹងបុព្វលាភ ដែលអ្នកទិញត្រូវបង់)
- កណើ Spot price 〉 1.5803$/£ អ្នកលក់ ទទួលការខាតបង់ឥតកំណត់ បើសិនជា Spot price កាន់តែកើនឡើងជាង Strike price/exercise price (1.5803)




រូបភាព ៧៖ មុខងារទូទាត់សម្រាប់អ្នកទិញ




រូបភាព ៨៖ មុខងារទូទាត់សម្រាប់អ្នកលក់

EX2: Put-Option មួយលើរូបិយប័ណ្ណ Sterling (£) ជាមួយរូបិយបណ្ណ័ដុល្លា ($) ។

-Strike Price គឺ 1£ = 1.550$ -Premium គឺ 1.0 សេន/£

*សំគាល់:*

-អ្នកទិញ Put-Option លើ Sterling គឺទិញសិទ្ធិលក់£ មានន័យថាពេលកំណត់មកដល់គេលក់£ ទិញ$

-អ្នកលក់ Put-Option លើ Sterling គឺលក់សិទ្ធិលក់£ មានន័យថាពេលកំណត់មកដល់គេទិញ£ លក់$

នៅក្នុងរយៈពេលសុពលភាពនៃកិច្ចសន្យា Option នេះ លក្ខ័ណ្ឌ ចំណេញ និង ខាត នៃភាគីទាំងពីរ មានបញ្ជាក់ដូចខាងក្រោមៈ

➢ ចំពោះអ្នកទិញ :

- ចំណេញនៅពេលដែលតំលៃទីផ្សារ ( Spot price ) ចុះទាបជាង 1.539$/£ ។
- ខាតនៅពេលដែល Spot price ឡើងខ្ពស់ជាង 1.539$/£ ហើយការខាតបង់អតិបរមាគឺ 1.10 សេន/£ ពេលដែល Spot price កើនខ្ពស់ជាង 1.550$/£ (អ្នកទិញបដិសេធកិច្ចសន្យា)




រូបភាព ៩៖ មុខងារទូទាត់សម្រាប់អ្នកទិញ

➢ ចំពោះអ្នកលក់:

-ចំណេញនៅពេលដែល Spot price 〉 1.539$/£ ហើយចំណេញអតិបរមា 1.10សេន/£ ពេលដែល Spot price 〉 1.550$

-ខាតនៅពេលដែល Spot price 〈 1.539$/£ 〉




រូបភាព ១០៖ មុខងារទូទាត់សម្រាប់អ្នកលក់

ករណី Options ទាំងពីរ Put និង Call អ្នកលក់ Option ចំណេញច្រើនបំផុតត្រឹម បុព្វលាភដែលអ្នកទិញបង់ ព្រោះអ្នកទិញបដិសេធ កិច្ចសន្យា នៅពេលដែលស្ថានភាពទីផ្សារ Spot Market ផ្តល់ផលចំណេញជាង ។ ផ្ទុយទៅវិញអ្នកលក់អាចរងនូវការខាតបង់លើសពីទំហំ នៃបុព្វលាភ។

### ៣.២.៤ ហានិភ័យ និងគំរែនៃកិច្ចសន្យាលើរូបិយប័ណ្ណ

កិច្ចសន្យាលើរូបិយប័ណ្ណ គឺជាមូលប័ត្រលើទឹកប្រាក់មួយនៃរូបិយប័ណ្ណ A មួយដែលនឹងត្រូវដោះដូរជាមួយរូបិយប័ណ្ណ B មួយទៀត ហើយអត្រាប្តូរប្រាក់នៃ A ធៀប B ប្រែប្រួលជាប្រចាំទៅតាម បរិមាណនៃតំរូវការ និងការ ផ្គត់ផ្គង់នៃកិច្ចសន្យាប្រភេទដូចគ្នា ។

អ្នកទិញកិច្ចសន្យានៅថ្ងៃ D សង្ឃឹមថាថ្លៃនៃកិច្ចសន្យា នឹងកើនឡើងក្នុងពេលអនាគត ចំណែកអ្នកលក់ ព្យាករណ៍ផ្ទុយពីនេះ (ហាក់ដូច ជាការភ្នាល់គ្នា) ។

<u>EX:</u> កិច្ចសន្យាលើរូបិយបណ្ណ័ $ ធៀប និងរូបិយវត្ថុ រៀល សំរាប់រយៈពេលកំណត់ ៣ខែ ។ ថ្លៃទិញកិច្ចសន្យា នេះនៅថ្ងៃ i គឺ $P_i$= 3900 ៛/$ ។ អ្នកទិញកិច្ចសន្យាអាចលក់ទៅវិញ បានគ្រប់ពេល ក្នុងកំឡុងពេលកំណត់ ៣ ខែនេះ ។ សន្មត់ថានៅថ្ងៃ j មួយតំលៃកិច្ចសន្យា $P_j \rangle P_i$ នោះអ្នកទិញលក់កិច្ចសន្យានេះវិញជាមួយថ្ងៃ $P_j \rangle P_i$ នោះអ្នកទិញលក់កិច្ចសន្យានេះ វិញជាមួយថ្ងៃ $P_j$ ។ អ្នកទិញបានចំណេញស្មើ $P_j$-$P_i$ រីឯអ្នកលក់ខាត $P_j$ - $P_i$។ បើ $P_j \langle P_i$ នោះអ្នកទិញជាអ្នកខាត រីឯអ្នកលក់ជាអ្នកចំណេញវិញម្តង។

## ៣.៣ ឈ្មួញដូរប្រាក់ (Money changers)

### ៣.៣.១ អតិថិជន (Customers)

អតិថិជនឯកជនដែលមានវត្តមានលើទីផ្សារប្តូរប្រាក់ មានដូចជាបុគ្គលនានា និងសហគ្រាស (សហគ្រាស ឧស្សាហកម្ម ពាណិជ្ជកម្ម និងសហគ្រាសហិរញ្ញវត្ថុដែលមិនមានវត្តមានជាប្រចាំលើ ទីផ្សារប្តូរប្រាក់ ពោលគឺ សហគ្រាស ដែលគ្មាន Founds Prospers )។ ក្រុមភ្នាក់ងារនេះមិនអន្តរាគមដោយផ្ទាល់ទេ សកម្មភាពរបស់គេ គឺធ្វើតាមរយៈ ការធ្វើលិខិតបញ្ជាទិញ រឺលក់ រូបិយបណ្ណ័ A ជាមួយ រូបិយប័ណ្ណ B រួចឆ្លងតាម ធនាគារ រឺ អ្នកជួកជេ ។

### ៣.៣.២ ធនាគារពាណិជ្ជ (Commercial banks)

ធនាគារជាភ្នាក់ងារមួយធំជាងគេនៅលើទីផ្សារប្តូរប្រាក់ គេធ្វើសកម្មភាពប្តូរប្រាក់សំរាប់គណនីផ្ទាល់ខ្លួន គេនឹង ម្តង (ស្វែងរកចំណេញពីសកម្មភាពប្តូរប្រាក់) ។ ធនាគារបន្ទាប់ពីបានទទួលលិខិតបញ្ជា ទិញ រឺ លក់ របស់អតិថិជន ដោយផ្ទាល់ រឺដោយប្រយោល តាមរយៈឈ្មួញកណ្តាល (Dealers) សំរេចទូទាត់បញ្ចប់ ប្រតិបត្តិការប្តូរប្រាក់ ។ ប្រាក់ចំណេញដែលធនាគារទទួលបាន ត្រូវចាត់ទុកថាជាកំរៃនៃហានិភ័យ ដែលគេហ៊ានប្រថុយ ។ ប្រាក់ចំណេញនេះ គឺជាផលដករវាងថ្លៃលក់រូបិយបណ្ណ័ និង ថ្លៃទិញរូបិយប័ណ្ណ ។

ធនាគារត្រូវគេចាត់ទុកថាជាក្រុមភ្នាក់ងារមួយធំផង និង ដ៏មានឥទ្ធិពលលើទីផ្សារប្តូរប្រាក់ ដោយសារ វាមាន ចំនួនច្រើនព្រមទាំងដើមទុនខ្ពស់ ។ ឥទ្ធិពលរបស់ធនាគារលើទីផ្សារប្តូរប្រាក់ មានរហូតដល់ អាចកំនត់ បាននូវទិសដៅ នៃបំរែបំរួលអត្រាប្តូរប្រាក់នៃរូបិយប័ណ្ណធំៗមួយចំនួន ពិសេស ដុល្លា ស.ហ.រ ម៉ាក អាឡឺម៉ង់ និង យេន ជប៉ុន ។ អ្នកដែលទទួលបន្ទុកប្តូរប្រាក់នៅតាមធនាគារត្រូវគេអោយឈ្មោះ ថា "Cambist " ។ Cambist មានអំណាចសំរេច ផ្ទាល់ខ្លួនចំពោះតំលៃអត្រាប្តូរប្រាក់ និងទំហំសាច់ប្រាក់ដែលត្រូវប្តូរ ដែលអាច នាំមកនូវប្រាក់ចំណេញ ឬ ការខាតបង់ របស់ធនាគារ ។ សារៈសំខាន់នៃតួនាទីរបស់ Cambist តំរូវអោយ ប្រធានធនាគារគ្រប់គ្រងលើគេដោយផ្ទាល់ នឹងត្រូវ ជួបប្រជុំពិភាក្សាញឹកញប់ ដើម្បីជៀសវាងការសំរេច មិនសមស្រប បង្កនូវការខាតបង់ ។

### ៣.៣.៣ អ្នកជួកជេ

ក្រុមនេះមិនអន្តរាគមដោយផ្ទាល់លើទីផ្សារប្តូរប្រាក់ទេ ពោលគឺមិនធ្វើសកម្មភាពសំរាប់គណនីផ្ទាល់ខ្លួន ។ កំរៃដែលទទួលបានពីសកម្មភាពរបស់គេ គឺជា កំរៃជើងសារ (Commissions) មិនចាត់ទុកថាជាប្រាក់ចំណេញទេ ។ ពួកគេមានតួនាទីពីរយ៉ាងលើទីផ្សារប្តូរប្រាក់គឺ :

-ជាអ្នកផ្តល់ព័ត៌មានអំពីតំលៃនៃអត្រាប្តូរប្រាក់ដោយតែមានទំនាក់ទំនងជិតស្និទ្ធ និងជាប្រចាំជាមួយ ក្រុម ធនាគារ ។អតិថិជនដែលត្រូវការប្តូររូបិយបណ្ណ័អាចទទួលបានព័ត៌មានពីអត្រាប្តូរប្រាក់យ៉ាងងាយ ស្រួលពីក្រុមនេះ ។

-ជាអ្នកផ្តល់សេវាប្តូរប្រាក់ ដែលអតិថិជនត្រូវការប្តូរប្រាក់ដោយពួកគេទទួលធ្វើការប្តូរប្រាក់នេះ ហើយ យកប្រាក់ ទៅប្តូរបន្តដល់ធនាគារ (ទទួលលិខិតបញ្ជាទិញរឺលក់រូបិយប័ណ្ណពីអតិថិជនបញ្ជូនទៅធនាគារ ដើម្បីសំរេចប្រតិបត្តិការ) ។

អតិថិជននិយមជាទូទៅប្រើប្រាស់សេវារបស់អ្នកជួកជេ ព្រោះវាផ្តល់ផលចំណេញជាងការប្តូរដោយផ្ទាល់ នៅតាម ធនាគារ ព្រោះខាតបង់ពេលវេលា ហើយអត្រាប្តូរប្រាក់ពេលខ្លះអាចខ្ពស់ជាងតំលៃកំរិតដោយអ្នកជួកជេ ។

### ៣.៣.៤ ធនាគារកណ្តាល (Central banks)

ធនាគារកណ្តាលអន្តរាគមជាចាំបាច់លើទីផ្សារប្តូរប្រាក់ ប៉ុន្តែមិនទៀងទាត់ទេ ។ វាមានតួនាទីសំខាន់ ៣ យ៉ាងលើ ទីផ្សារប្តូរប្រាក់គឺ :

-សំរេច និង អនុវត្តចំពោះលិខិតបញ្ជាទិញ ឬលក់របស់អតិថិជន: ធនាគារកណ្តាលត្រូវមានទុនបំរុងជានិច្ច និងគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹង តំរូវការប្តូរប្រាក់របស់ភ្នាក់ងារប្តូរប្រាក់នៅលើទីផ្សារ។ កាតព្វកិច្ចនេះ តំរូវអោយ គោរពជានិច្ចពិសេសគ្រប់ប្រទេសទាំងអស់ជាសមាជិកមូលនិធិរូបិយវត្ថុអន្តរជាតិ ហៅកាត់ថា IMF (International Monetary Fund) ។

-គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារប្តូរប្រាក់ដើម្បីដំណើរការល្អ និងធានានូវតម្លាភាព ។ សកម្មភាពនេះមានវត្ថុបំណងទប់ស្កាត់រាល់សកម្មភាពប្តូរប្រាក់របស់ភ្នាក់ងារណា ដែលចង់បង្កព្យុះភ្លៀងធ្វើ អោយអត្រា ប្តូរប្រាក់ប្រែប្រួលខ្លាំងបាត់បង់ស្ថេរភាព ។

-រិះរកគ្រប់មធ្យោបាយ ដើម្បីធានានូវស្ថេរភាពអត្រាប្តូរប្រាក់ តាមរយៈនយោបាយប្តូរប្រាក់ (Exchange Policy) ។ ទង្វើនេះមានលក្ខណៈចាំបាច់ ដើម្បីគោរពទៅតាមសន្ធិសញ្ញាអន្តរជាតិ ពិសេសសន្ធិសញ្ញា Bretton- Woods ដែលតំរូវ អោយគ្រប់ប្រទេសជាសមាជិក IMF ទាំងអស់មាន កាតព្វកិច្ចរក្សាអត្រាប្តូរប្រាក់ថេរដោយទុកចន្លោះប្រែប្រួលយ៉ាង ច្រើនបំផុត ±1% (ក្រោយមក អនុញ្ញាតិ ចន្លោះប្រែប្រួល ±2.25% ដើម្បីជួយសំរួលដល់ប្រទេសដែលជួបការលំបាក លើស្ថេរភាព តំលៃរូបិយវត្ថុ) ។

### ៣.៣.៥ ស្ថាប័នហិរញ្ញវត្ថុមិនមែនធនាគារ (Non-bank financial institutions)

ចាប់តាំងពីឆ្នាំ 1990 មកស្ថាប័នទាំងនេះបានក្លាយទៅជាភ្នាក់ងារប្តូរប្រាក់យ៉ាងសំខាន់ នៅលើទីផ្សារប្តូរប្រាក់ ។ ស្ថាប័ននេះរួមមានសាខាហិរញ្ញវត្ថុ និងធនាគាររបស់គ្រប់សហគ្រាសឧស្សាហកម្ម ។ សកម្មភាពរបស់សាខាទាំងនេះ លើទីផ្សារប្តូរប្រាក់កើតមានតាមរយៈសកម្មភាពកំណោងកំរៃ (Speculation) ជាមួយមូលធន ដែលនៅទំនេរ និង តាមរយៈការដាក់ប្រាក់បញ្ញើនៅធនាគារនៅបរទេសដើម្បីស្វែងរកអត្រាការប្រាក់ខ្ពស់ ឬ ដើម្បីបង្កលក្ខណៈងាយស្រួល ចំពោះការទូទាត់ប្រតិបត្តិការ ពាណិជ្ជកម្មអន្តរជាតិរបស់សហគ្រាស ឧស្សាហកម្ម ជាមួយបរទេស ។

### ៣.៣.៦ ស្ថាប័នវិនិយោគិន ( Investment firms)

ក្រុមនេះជាភ្នាក់ងារដ៏សំខាន់ដែលលើទីផ្សារប្តូរប្រាក់ ព្រោះអ្នកគ្រប់គ្រងមូលនិធិទាំងនេះបាន កាត់យកមួយ ផ្នែកនៃ ធនធានដាក់តំកល់នៅបរទេសក្នុងបំណងស្វែងរកទិន្នផលខ្ពស់ និងកាត់បន្ថយ ហានិភ័យ ។ អន្តរាគមរបស់គេ មិនត្រឹម តែសំដៅលើតំរូវការរូបិយបណ្ណ័បរទេស និងការគ្របដណ្តប់ហា និភ័យប៉ុណ្ណោះទេ ករណីខ្លះ គេសំរេចធ្វើសកម្មភាព Speculation ដើម្បីទាញយកចំណេញទៀតផង ។ ស្ថាប័នវិនិយោគិន គឺជាអ្នកចូលរួមលើទីផ្សារប្តូរប្រាក់ដែលពុំមាន លក្ខណៈជាធនាគារ ។ក្រុមនេះ មាន ដូច ជាមូនិធិសង្គម ( សំរាប់ជួយអ្នកគ្មានការងារធ្វើ អ្នកក្រីក្រ ជន ពិការ សិស្ស និស្សិត កុមារកំព្រា...) មូលនិធិចូលនិវត្តន៍ ក្រុមហ៊ុនធានារ៉ាប់រង អន្តរការីហិរញ្ញវត្ថុផ្សេងៗទៀត ។ ល ។

# ជំពូក ៤ សញ្ញាណទូទៅនៃធនាគារ

## ៤.១ ការសិក្សាអំពីធនាគារ ( Banking )

ធនាគារសំដៅលើស្ថាប័នហិរញ្ញវត្ថុដែលទទួលរក្សាទុករូបិយវត្ថុទាំងឡាយដែលការរក្សាទុករូបិយវត្ថុនេះ គឺជាចំនែកមួយនៃការផ្គត់ផ្គង់រូបិយវត្ថុ ទទួលប្រាក់បញ្ញើ និងផ្តល់កំចី មានដូចជា ធនាគារពាណិជ្ជកម្ម សហគមន៍ឥណទាន សហគមន៍កសាង ។ល ។ សុទ្ធតែមានតួនាទីប្រហាក់ប្រហែលគ្នា ប៉ុន្តែ គេសង្កេតឃើញមានភាពខុសគ្នាទៅលើនយោបាយគ្រប់គ្រងហិរញ្ញវត្ថុ ។ធនាគារមានដំណើរការដូចជាក្រុមហុនដែរដោយគ្រាន់តែមានជំនួញលើរូបិយវត្ថុ ។ចាប់ពីក្រោយទសវត្សទី៧០មកចំនួនធនាគារបានកើន ឡើងយ៉ាងច្រើនដោយសារការផ្តល់សុវត្ថិភាពហិរញ្ញវត្ថុដល់អ្នកជំនួញ ។ទន្ទឹមនឹងគ្នានេះដែរដំណើរការ ដែលមានភាពអាប់អួរនិងភាពបរាជ័យនៃធនាគារពាណិជ្ជកម្មក៏មានចំនួនច្រើនដែរ ព្រោះការស្រុតចុះនៃ ល្បឿនសេដ្ឋកិច្ចដែលរដ្ឋាភិបាលមិនអាចត្រួតពិនិត្យបានលើវដ្តសេដ្ឋកិច្ចនិងតំរូវការប្រាក់តំកល់ចេះតែកើន ឡើងច្រើនពេក ។ ធនាគារមានសារៈសំខាន់បីយ៉ាងដែលទាមទារអោយយើងសិក្សាៈ

១. ការភ្ជាប់ទំនាក់ទំនងរវាងអ្នកសន្សំ និង អ្នកត្រូវការលុយវិនិយោគ

២. ធនាគារឈរលើមូលដ្ឋាននៃការផ្គត់ផ្គង់រូបិយវត្ថុ និង ការគ្រប់គ្រងនយោបាយរូបិយវត្ថុដែលជាក្តីសង្ឃឹមរបស់រាស្ត្រ ។

៣. ប្រភពហិរញ្ញវត្ថុសំរាប់ការពង្រីកនូវតុល្យភាពកំចី សន្សំ និង ជំនួយ ។

Banks refer to all the depository institutions whose deposits are part of the money supply. Deposit institutions such as banks, credit unions, building societies and so on have similar role. but the difference is only their own policies in financial management. The study of banking has connected to three important cases:

• Matching the relationship between savers and investors needed money.

• Principal management of banks is to supply money and conduct monetary policy.

• Financial sources to balance lending saving and assistances.

នៅក្នុងស្ថាប័នហិរញ្ញវត្ថុប្រព័ន្ធធនាគារពីរខុសគ្នា ដែលបានប្រើប្រាស់ក្នុងពិភពលោកនេះ។ បណ្តាប្រទេស នៅក្រោមអាណានិគមអង់គ្លេសបានប្រើប្រព័ន្ធរួមគ្នាមួយហៅថា Commonwealth Banks ដោយឡែកប្រទេសនៅក្រោមអាណានិគមបារាំងភាគច្រើនប្រើប្រព័ន្ធធនាគារកណ្តាល រឺ ធនាគារជាតិ Central Bank/National Bank ។ យើងពិតជាមិនអាចពន្យល់ពីហេតុផលណាមួយដែលប្រទេសនីមួយៗ និយមប្រើប្រព័ន្ធខុសគ្នាណាស់ ប៉ុន្តែ ប្រទេសរីកចំរើននិយមប្រើប្រព័ន្ធធនាគារអង់គ្លេស

ដោយសារវិសាលភាពអត្ថប្រយោជន៍ និង ទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ។ សូមអ្នកក្រឡេកមើលតារាងខាង ក្រោមនេះដែលជួយពន្យល់អ្នកអំពីភាពខុសគ្នា :

| Commonwealth Nations | Francophonic Society |
|---|---|
| • Reserve Bank of America | • National Bank of Cambodia |
| • State Banks ( 52 states ) | • Reserve Bank of Cambodia |
| • Financial Intermediaries | • Financial Intermediaries |

ភាពខុសគ្នាបន្តិចនៅក្នុងប្រព័ន្ធនេះគឺនៅក្នុងប្រទេសអតីតអាណានិគមអង់គ្លេស ទាំងអស់មានធនាគាររួម មួយដែលជួយអន្តរាគមន៍រឺឧបត្ថម្ភប្រទេសណាមួយក្នុងករណីចាំបាច់ ។បន្ទាប់មកគេមានធនាគារសហព័ន្ធ ដែលមើលខុសត្រូវលើបណ្តាធនាគារក្នុងរដ្ឋនីមួយៗ ។ ឧទាហរណ៍ អូស្រ្តាលី កាណាដា អង់គ្លេស អាមេរិច ណូវែលសេឡង់ សហរដ្ឋអាមេរិច អតីតសហភាពសូវៀត សុទ្ធតែប្រើប្រព័ន្ធធនាគារសហព័ន្ធ ។ ដោយឡែក ប្រទេសមួយភាគតូចទៀតប្រតិបត្តិធនាគារកណ្តាលដូចជា Dcutch Bank, Banque de la France, National Bank of Cambodia … ។ល ។ យើងពិតជាមិនអាចនិយាយថាធនាគារប្រភេទណាមួយមានសារៈសំខាន់ជាងណាស់ ប៉ុន្តែលក្ខណៈមួយដែលធនាគារបណ្តាប្រទេសអតីត ប្រទេសអង់គ្លេសមានឥទ្ធិពលជាង គឺ ភាពងាយស្រួលក្នុងការ ចាយវាយឆ្លងប្រទេស និងវិនិយោគទុន។

## ❖ អន្តរការីហិរញ្ញវត្ថុ និង និយ័តកម្ម

អន្តរការីធនាគារដូចជាក្រុមហ៊ុនដែរ គឺការទទួលប្រាក់ជានាពីក្រុមគ្រួសារ និង ក្រុមហ៊ុននានា ហើយ ការផ្តល់កំចីដល់ដល់ក្រុមគ្រួសារ និង ក្រុមហ៊ុនឯទៀត ។ អន្តរការីធនាគារមានដំណើរការដូចជាធនាគារកណ្តាល រឺសហព័ន្ធដែរ ដោយសាររាស្ត្រអាចទាក់ទងសំរាប់ការ ខ្ចីបុល និងការផ្ញើបញ្ញើប្រាក់

អន្តរការីធនាគារមានប្រយោជន៍ដល់សេដ្ឋកិច្ចត្រង់ថាវាចល័តមូលនិធិពីជនម្នាក់ ដែលចង់បានការប្រាក់ទៅ ជនម្នាក់ទៀតដែលត្រូវការមូលនិធិសំរាប់ដំណើរការវិនិយោគរឺ ជំនួញផ្សេងៗ។ជាទូទៅគេសង្កេតឃើញមានអន្តរការីធនាគារចំនួន៨ប្រភេទដែលមានដំណើរការ ហើយ ដែលប្រាក់ជានាទាំងនោះជាចំនួនប្រាក់របស់ ប្រជាជាតិមួយ ។

- ធនាគារឯកជន និងពាណិជ្ជកម្ម គឺជាធនាគារដែលអនុញ្ញាតិអោយដំណើរការហិរញ្ញវត្ថុ ក្រោមការផ្តល់អជ្ញាប័ណ្ណពីធនាគារកណ្តាលរឺសហព័ន្ធ ។ ធនាគារនេះត្រូវតែពិនិត្យទៅលើបញ្ជីតុល្យការបំណុលនិងតំលៃសុទ្ធនៃទ្រព្យសកម្ម ។បញ្ជីតុល្យការគឺជាតារាងទ្រព្យសម្បត្តិទាំងអស់ ។ បំណុលរបស់ធនាគារគឺជាប្រាក់បញ្ញើរបស់អតិថិជនដែលបានដាក់បញ្ចូលក្នុងធនាគារហើយ ធនាគារប្រើប្រាស់វាចំនែកមួយនៃការផ្គត់ផ្គង់រូបិយវត្ថុតែធនាគារត្រូវតែផ្តល់អត្រាការប្រាក់ដល់

អតិថិជន ។ដោយឡែកតំលៃសុទ្ធនៃទ្រព្យសកម្មគឺជាភាពខុសគ្នានៃទ្រព្យសម្បត្តិរបស់ ធនាគារទាំងអស់ និង បំណុល ។ រូបមន្តរបស់វាគឺៈ

**បំណុល + តំលៃសុទ្ធនៃទ្រព្យសកម្ម = ទ្រព្យសម្បត្តិរបស់ធនាគារទាំងអស់**

- **ទីផ្សារសាជីវកម្មរូបិយវត្ថុ** គឺជាធនាគារអាជីវកម្មដែលផ្តល់សេវាកម្មហិរញ្ញវត្ថុ ដូចជា អាគារប្តូរប្រាក់និងទីផ្សារស្តុក ។ នៅករណីពិសេសខ្លះគេអាចផ្តល់កំចីរយៈពេលខ្លីទៅដល់ក្រុមហ៊ុន វិនិយោគ ។ ប្រភេទសេវាកម្មបែបនេះត្រូវបានផ្តល់អជ្ញាប័ណ្ណពីធនាគារតាមរយៈការដេញថ្លៃ ។
- **ក្រុមហ៊ុនហិរញ្ញវត្ថុ** គឺជាការសហការជំនួញហិរញ្ញវត្ថុដែលជួយផ្តល់សេវាកម្មកំចី ផ្តល់លុយទិញផ្ទះ និងសំរួលដល់ប័ណ្ណលោះទំនិញ (Debenture Sales) ។ ក្រុមហ៊ុនប្រភេទនេះបង្កើនទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈការចូលរួមពីក្រុមហ៊ុនពាណិជ្ជកម្មធំៗ និង សាធារណជនទូទៅដែលចង់ចូលរួម ។
- **សហគមន៏កសាងអចិន្ត្រៃយ៍**

គឺជាធនាគារដែលទទួលមូលនិធិពីក្រុមគ្រួសារ មួយចំនួនដែលយល់ព្រមផ្តល់ប្រាក់ទៅសហគមន៍ រឺបន្សល់ទុកក្រោយពេលមរណភាពដែលគ្មានអ្នកទទួលកេរ្តិ៍មរតក ។ជាទូទៅអត្រាការប្រាក់មាន កំរិតទាប ហើយ គេកំនត់គោលដៅសំរាប់កសាងសង្គមមួយប្រកបដោយភាពរុងរឿង ។ ប៉ុន្តែ គេមានលក្ខខ័ណ្ឌអនុគ្រោះជាច្រើនដល់សំរាប់និស្សិតជនក្រីក្រ អ្នកបរាជ័យក្នុងជំនួញ ហើយជនទាំងនេះអាចត្រូវបង់អត្រាការប្រាក់យោគយល់បំផុត ។

- **សហករេណទាន** គឺជាធនាគារមិនយកប្រាក់ចំណេញ និង ផ្តល់ទុនកំចីសំរាប់អ្នកវិនិយោគ និងសមាជិក ។ គេភាគច្រើនផ្តល់កំចីដល់អតិថិជនរយៈពេលយូរជាពិសេសកសិករ អ្នកជំនួញ និងវិនិយោគិន ។
- **សហគមគ្រប់គ្រងថវិកា**

គឺជានាយកដ្ឋានថវិការដ្ឋដែលចូលរួមដំណើរជាមួយធនាគារក្នុងការត្រួតពិនិត្យហិរញ្ញវត្ថុពិសេសប័ណ្ណធានា ។

- **សាខាចែកចាយទីផ្សាររូបិយវត្ថុដែលបានទទួលសិទ្ធ**

គឺជាសាខាធនាគារទាំងឡាយដែលយល់ព្រមចុះកិច្ចសន្យាជាមួយធនាគារជាតិដើម្បីបើកសាខារកស៊ីក្នុងតំបន់ ។ គេមានដំណើរដូចធនាគារឯទៀតដែរដូចជា ការផ្តល់កំចី និង ចែកចាយរូបិយវត្ថុ ។

- ក្រុមហ៊ុនហិរញ្ញប្បទាន គឺជាសហគមន៍ពិសេសមួយចូលជួយដល់សង្គមក្នុងវិស័យសិក្សាធិការ និង សុខមាលភាពសង្គម ។

## ❶មុខងារសេដ្ឋកិច្ចនៃអន្តរការីហិរញ្ញវត្ថុ

អន្តរការីហិរញ្ញវត្ថុស្វែងរកប្រាក់ចំណេញតាមរយៈ ភាពខុសគ្នារវាងអត្រាការប្រាក់កំចី និង បញ្ញើ ។ អន្តរការីហិរញ្ញវត្ថុបានផ្តល់សេវាកម្ម ៤ ជាសំខាន់ដែលប្រជាជនយល់ព្រមបង់ជូន :

- **ការបង្កើតសាច់ប្រាក់**គឺជាទ្រព្យសកម្មរាវដែលងាយបំលែងជារូបិយវត្ថុ ។ ទ្រព្យនេះបានមកតាមរយៈអតិថិជនយកប្រាក់មកផ្ញើរហើយធនាគារប្រើប្រាស់វាជាទុនសំរាប់ដំណើរការផ្គត់ផ្គង់រូបិយវត្ថុ ។អន្តរការីធនាគារបង្កើតសាច់ប្រាក់ដោយកំចីរយៈពេលខ្លី (ប្រាក់បញ្ញើ) និង ផ្តល់ កំចីរយៈពេលវែង ។ កំចីរយៈពេលខ្លីមានន័យថា យកប្រាក់បញ្ញើមកប្រើសំរាប់ដំណើរ រួចត្រៀមខ្លួនជាស្រេចសំរាប់បង់ជូនអតិថិជនវិញនៅពេលត្រូវការ ។ ផ្តល់កំចីរយៈពេលវែង មានន័យថាអ្នកមកខ្ចីអាចយកលុយទៅប្រើប្រាស់ បានយូរដោយគ្រាន់តែបង់ការប្រាក់ប៉ុណ្ណោះ និង ជួនកាលមានរហូតដល់ ២០ ឆ្នាំ ដូចជាការទិញអាគារអាជីវកម្ម លំនៅឋាន ។ ល ។
- **ការបន្ថយចំណាយអប្បបរមានៃការទទួលមូលនិធិ** គឺជាមុខងារទី ២ ដែលអន្តរការីហិរញ្ញវត្ថុត្រូវតែប្រតិបត្តិ ។ តាមធម្មតាអ្នកខ្ចីបុលពិតជាមានការលំបាកស្វែងរកប្រាក់កំចីដោយចំណាយទាំង ពេលវេលានិងតំលៃឱកាស ។ ដោយសារអន្តរការីធនាគារអ្នកមកខ្ចីទទួលបាននូវសេវាកម្មដ៏ល្អ ។ ចំណាយសំរាប់កំចីទាប ព្រោះអន្តរការីហិរញ្ញវត្ថុមានលទ្ធភាពប្រមូលប្រាក់បញ្ញើពីអតិថិជនបានច្រើន និង ធ្វើការបែងចែកចំណាយទៅអ្នកកំចី ។
- **ការបន្ថយចំណាយអប្បបរមានៃការត្រួតពិនិត្យអ្នកមកខ្ចី** គឺជាមុខងាររបស់អន្តរការីធនាគារក្នុងការជៀសវាងអ្នកខ្ចីមិនមានលទ្ធភាពសងវិញដោយធ្វើយ៉ាងណាប្រើប្រាស់ចំណាយអធិការកិច្ចមានកំរិតទាប និង ប្រើប្រាស់ពេលវេលាតិចបំផុត ។
- **បង្រួមភាពប្រថុយប្រថាន** គឺអន្តរការីហិរញ្ញវត្ថុចង់កាត់បន្ថយភាពបាត់បង់ប្រាក់ដោយចៃដន្យ ។ គេត្រូវតែកាត់បន្ថយអ្នកមកខ្ចីដែលមិនត្រូវតាមគោលការណ៍ ព្រោះ វាមិនគ្រាន់តែបាត់បង់ប្រាក់ប៉ុណ្ណោះទេ ថែមទាំងបណ្តាលមានការបាត់ជំនឿទុកចិត្តរបស់ម្ចាស់បញ្ញើទៀតផង ។

បទពិសោធន៍មួយពីប្រទេសអូស្ត្រាលីគឺថាធនាគារបានធ្វើការលុបចោលនូវការដាក់កំរិតមួយចំនួនកាលពី ឆ្នាំ១៩៨០ ។នេះក៏ជាចំនុចសំខាន់មួយសំរាប់ការពិចារណាទៅ អនាគតរបស់ធនាគារកម្ពុជា ។និយ័តកម្ម ដែល ធនាគារកណ្តាលបានប្រើប្រាស់ជាមធ្យោបាយគឺ:

- **ការកំនត់បរិមាណកំចីពីធនាគារ**គឺជាការកំនត់របស់ធនាគារកណ្តាលរឺ សហព័ន្ធទៅលើការ កំនត់ លក្ខខ័ណ្ឌកំចីនិងទឹកប្រាក់អតិបរមាដែលអតិថិជនអាចខ្ចីបាន ។ មានករណីមួយចំនួនដែលធនាគារ កំនត់ចង្អុលទៅលើធនាគារណាដែលអាចខ្ចីបានតាមកំរិតប្រាក់តំកល់ ។នៅក្នុងពេលចាំបាច់ធនាគារកណ្តាលមានសិទ្ធផ្អាកអាជីវកម្មជាបណ្តោះអាសន្ន ដើម្បីត្រួតពិនិត្យបរិមាណផ្តល់កំចី ។
- **ការត្រួតពិនិត្យអត្រាការប្រាក់** គឺជាតួនាទីរបស់ធនាគារកណ្តាលក្នុងការត្រួតពិនិត្យអត្រាការប្រាក់ បញ្ញើ និង កំចី ។ តាមធម្មតា ធនាគារកណ្តាលបានចេញច្បាប់អត្រាការប្រាក់ក្នុងកំរិត

ខុសគ្នារវាងកំចីនិងបញ្ញើដើម្បីអោយធនាគារពាណិជ្ជកម្មទទួលបានផលកំរៃ ។ប្រសិនបើធនាគារណាមួយផ្តល់អត្រាការប្រាក់សំរាប់បញ្ញើខ្ពស់ពេកអាចក្លាយជាធនាគារផ្តាច់មុខដែលអាចផ្តល់ផលវិបាកជាច្រើនទៅដល់សេដ្ឋកិច្ច និងសង្គម ។ ឧទាហរណ៍ ភាគច្រើននៃធនាគារសហរដ្ឋអាមេរិចផ្តល់អត្រាការប្រាក់ដល់អ្នកបញ្ញើក្នុងរវាង ៣- ៧ ភាគរយដែលទន្ទឹមនឹងអតិផរណាជាមធ្យម២៣ភាគរយ ។ប្រសិនបើធនាគារណាមួយមិនគោរពតាម អត្រាការប្រាក់កំនត់បែបនេះដូចជាការបង្កើនអត្រាការប្រាក់ខ្ពស់នោះតុលាការសភាពាណិជ្ជកម្មនឹង ធ្វើការផាកពិន័យ ។សំរាប់ប្រទេសអូស្រ្តាលីក៏ដូចគ្នាដែរហើយការប្រតិបត្តិច្បាប់របៀបនេះដើម្បីធានាដល់ការប្រកួតប្រជែងប្រកបដោយសុក្រិតភាព ។ធនាគារកណ្តាលកត់សំគាល់ថាប្រសិនបើគេមិនទប់ស្កាត់ទេ អាចបណ្តាលមានការដួលរលំនៃវិនិយោគទុន ធនាគារតូចៗ និង ការបាត់បង់ការងារ ព្រមទាំងផលវិបាកសង្គមដ៏ទៃទៀត ។ម្យ៉ាងទៀតប្រសិនបើសេដ្ឋកិច្ចមានការរីកដាលធនាគារទាំង ឡាយមិនអាចតំឡើងអត្រាការប្រាក់ដើម្បីទាក់ទាញអតិថិជនបានទេព្រោះអតិថិជនដែលបានធ្វើ ប្រាក់ពេលមុនអាចទទួលនូវការខកចិត្ត និង មិនយុត្តិធម៌ ។

- **អត្រាទុនទ្រព្យសាច់ប្រាក់ទាបបំផុត** គឺជាការកំនត់របស់ធនាគារកណ្តាលទៅលើតំរូវការបញ្ញើប្រាក់បំរុងទុករឺតំកល់ជារូបិយវត្ថុនៅធនាគារកណ្តាលរឺប័ណ្ណធានា។ ប្រការដែលធនាគារកណ្តល ធ្វើរបៀបនេះ គឺចូលរួមចំនែកការពារសំណងអតិថិជនយ៉ាងហោចណាស់ពាក់កណ្តាលប្រសិនបើធនាគារ ឯកជនរឺពាណិជ្ជកម្មណាមួយដួលរលំធនាគារកណ្តាលអាចមានលទ្ធភាពជួយទប់ស្កាត់ការដួលរលំ ធនាគារនានាតាមរយៈការផ្តល់កំចីបន្ថែមនិងកាត់បន្ថយមហិច្ឆតារបស់ធនាគារពាណិជ្ជកម្មមួយ

ចំនួនដែលផ្តល់កំចីដល់ផ្នែកឯកជនច្រើនពេក រឺលួចទៅវិនិយោគក្រៅពីការរកស៊ីធនាគារ ។ នៅកម្ពុជាមានធនាគារ ៤ បានបិទទ្វារ និង ៧ ទៀតស្ថិតនៅក្នុងស្ថានភាពមិននឹងនរ នៅក្នុងនោះមានធនាគារកសិករចាំកាត់ដែលឈានដល់ការដួលរលំប៉ុន្តែការបរាជ័យនេះពុំមានមូល ហេតុប្រកាសជូនជា សាធារណៈទេព្រោះវាជាអាថ៌កំបាំងរបស់ធនាគារ ។ធនាគារនេះ បានជំពាក់បំណុលអតិថិជនជាច្រើនអង្គភាពមួយចំនួននិងជំពាក់ប្រាក់តំកល់ធនាគារជាតិ ។តាមការសន្និដ្ឋានជា បច្ចេកទេសគឺការដួលរលំមានទំនាក់ទំនងទៅនឹង(១) ការបង្វិលទុនទ្រព្យសកម្មក្នុងពាណិជ្ជកម្មរវាងបាត្រនិងដុល្លាដែលស្របពេលនឹងការស្រុតចុះសេដ្ឋកិច្ចនៃប្រទេសថៃក្នុងវិបត្តិសេដ្ឋកិច្ចនៅអាស៊ី នាឆ្នាំ១៩៩៧-៩៨(២) ការជំពាក់របស់អ្នកមកខ្ចីពីធនាគារហើយប័ណ្ណធានារបស់អតិថិជនពិបាក លក់ដោយសារស្ថានភាពជំនួញផ្លាស់ប្តូរនៅកម្ពុជា (៣) ការរកស៊ីឥណទានបរាជ័យជាមួយកសិករ (៤) ប្រាក់តំកល់នៅធនាគារជាតិមានតិចតួចពេកមិនអាចស្រោចស្រង់បាន ។នេះ គ្រាន់តែជាការ វិនិច្ឆ័យនៃអ្នកឯកទេសធនាគារប៉ុណ្ណោះ ។

- **ការដាក់កំនត់ចូលកាន់ទីផ្សារដទៃ**

  គឺជាដាក់បន្តឹងទៅលើធនាគារមិនអោយពង្រីកទីផ្សាររូបិយវត្ថុច្រើនពេក ។ជាទូទៅធនាគារឯកជន តែងចង់បង្កើតមូលនិធិរបស់ខ្លួនតាមរយៈការពង្រីកកំចីទៅផ្នែកឯកជនទោះបីជាគេមាន

ប្រាក់បំរុង ទុកស្តុចស្តើងក៏ដោយ ស្ថានភាពបែបនេះអាចផ្តល់ផលអាក្រក់ដល់ម្ចាស់បញ្ញើដូចជា ការពន្យាពេល សំនង និង ការផ្ទេរចំណេញពីការប្រាក់ស្ទឹកស្រពន់ ។

- **ការត្រួតពិនិត្យអំពីការប្តូរប្រាក់បរទេស**
  គឺជាអនុភាពធនាគារកណ្តាលក្នុងការត្រួតពិនិត្យការប្តូរប្រាក់បរទេស និងការកំហិតតឹងរឹងលើការខ្ចីមូលនិធិបរទេសដើម្បីដំណើរការ ។ធនាគារកណ្តាលបានដាក់លក្ខខ័ណ្ឌរាល់មូលនិធិដែលធនាគារ បានពីក្នុងស្រុកត្រូវតែដំណើរការនៅលើទីផ្សារក្នុងស្រុក និង ទប់ស្កាត់ការហូរចូលលុយខ្មៅ រឺ លុយកខ្វក់ពីបរទេស ។ធនាគារពាណិជ្ជកម្មនិងឯកជនត្រូវតែបង្ហាញនូវបញ្ជីចរន្តតួលេខដូរប្រាក់ជា ប្រចាំ និង ទ្រព្យសកម្មដែលមានដល់ភ្នាក់ងារធនាគារកិច្ច (Bank Inspection Agent) ។

## ❷ បំលាស់ប្តូរហិរញ្ញវត្ថុ (Financial Innovation)

ការបង្កើតនូវផលិតផលហិរញ្ញប្បទានថ្មីដែលជាវិធីសាស្ត្រថ្មីនៃការខ្ចីនិងការផ្តល់កំចី គេហៅថាបំលាស់ប្តូរ ហិរញ្ញវត្ថុ ។គោលដៅនៃបំលាស់ប្តូរហិរញ្ញវត្ថុគឺការកាត់បន្ថយនូវចំណាយសំរាប់កំចី និង បង្កើនចំណូលដល់ម្ចាស់បញ្ញើ និង និយាយជារួមគឺការបង្កើនចំណេញដល់អន្តរការីហិរញ្ញវត្ថុ។ ល្បឿននៃការកែទំរង់ធនាគារ រឺបំលាស់ប្តូរហិរញ្ញវត្ថុនៅប្រទេសអភិវឌ្ឍន៍ភាគច្រើនចាប់ផ្តើមនៅទសវត្សទី៧០ហើយបន្តរហូតដល់សព្វ ថ្ងៃ ។វាមានឥទ្ធិពលបីយ៉ាងទៅលើបំលាស់ប្តូរហិរញ្ញវត្ថុ គឺ បរិស្ថានសេដ្ឋកិច្ច និយាមធនាគារ និង បច្ចេកវិទ្យា។

- **បរិស្ថានសេដ្ឋកិច្ច** គឺវាឆ្លុះបញ្ចាំងពីការប្រែប្រួលសេដ្ឋកិច្ចក្នុងរយៈពេលមួយដែលចាំបាច់ធនាគារកណ្តាលត្រូវធ្វើអន្តរាគមន៍តាមរយៈការផ្លាស់ប្តូរបែបផែននៃការគ្រប់គ្រងហិរញ្ញវត្ថុ។ កាលពីទសវត្សទី70 , ប្រទេសស្ទើរតែទាំងអស់ជួបនូវវិបត្តិហិរញ្ញវត្ថុដោយសារអតិផរណាកើនឡើង ហើយ អតិថិជនចាប់ផ្តើមច្រួលច្របល់អំពីអត្រាការប្រាក់ទាប និង នឹងថ្កល់ ។ ធនាគារពាណិជ្ជកម្ម និង ឯកជននានាពុំមានលទ្ធភាពផ្តល់ជូននូវកំនើនអត្រាការប្រាក់ បើធៀបនឹងកំនើនអតិផរណាប៉ុន្តែធនាគារទាំងនេះមានលទ្ធភាពផ្តល់កំចីដល់អន្តរការីធនាគារ ឯទៀតដែលកំពុងរីកសុះសាយ ដូចជា ក្រុមហ៊ុនហិរញ្ញវត្ថុ សហករណ៍ឥណទាន និង សេវាកម្មហិរញ្ញវត្ថុផ្សេងៗជាលទ្ធផលធនាគារពាណិជ្ជកម្មនិងឯកជនអាចតំឡើងអត្រាការប្រាក់ដល់ម្ចាស់បញ្ញើ។
- **និយាមធនាគារ**
  គឺជានិតិវិធីដែលធនាគារកណ្តាលសំរបសំរួលដោយសារមានការប្រែប្រួលនៅលើ ទីផ្សារហិរញ្ញវត្ថុ ។នៅពេលដែលអន្តរការីហិរញ្ញវត្ថុរីកដុះដាលខ្លាំងបានធ្វើធនាគារជាតិជួបប្រទះនូវការលំបាកក្នុងការគ្រប់គ្រងនយោបាយរូបិយវត្ថុនិងវិធានការពារផ្សេងដូចនេះធនាគារកណ្តាល ធ្វើពិសោធនកម្មច្បាប់អំពីការកែទំរង់និយ័តកម្មដូចជា ជំរុញអោយគណនីមូល្បទានប័ត្រត្រូវផ្តល់ ការប្រាក់ផងដែរ ។
- **បច្ចេកវិទ្យា** គឺជាការណែនាំទំនើបទីយកម្មបច្ចេកទេសធនាគារ ដូចជា ប្រព័ន្ធកុំព្យូទ័រ ម៉ាស៊ីនផ្ទុក និង គិតលុយប្រើកាំរស្មី កាតឥណទាន សាម៉ាតកាត ម៉ាស្ទ័រកាត និង ប្រព័ន្ធតភ្ជាប់ ធនាគារ

។ល ។យើងនៅចាំបានថានាពេលបច្ចុប្បន្ននេះមានឧក្រិដ្ឋជនធនាគារជាច្រើនដែលលួចយកសាច់ប្រាក់ពីធនាគារដោយប្រើប្រព័ន្ធបច្ចេកវិទ្យាទំនើបហេតុនេះធនាគារបានប្រើប្រព័ន្ធគ្រប់គ្រង សំងាត់ និង ប្រព័ន្ធការពារប្រឆាំងមេរោគ និង ទូរទិន្នន័យធំៗ ។ ជាពិសេសការរីកចំរើននៃ Internet Services សំរាប់អតិថិជនធ្វើជំនួញភាគហ៊ុន និង លេងទឹកលុយ តាមរយៈ Online Banking។ ដោយសារបច្ចេកវិទ្យាមានភាពប្រណិត អតិថិជនមានជំនឿទុកចិត្តហើយបញ្ញើ បានកើនឡើងជាពិសេសធនាគារអាចចំណេញពីដំណើរការ ប្រតិបត្តិការរបស់គេ។

# ជំពូក ៥ ធនាគារកណ្តាល និង គោលនយោបាយរូបិយវត្ថុ

## ៥.១ លំនាំធនាគារកណ្តាល (Introduction to central bank)

មុននេះធនាគារកណ្តាល គឺគ្រាន់តែជាធនាគារដ៏សាមញ្ញមួយដែលទទួលរ៉ាប់រងនូវកាតព្វកិច្ចជាតិ និងបានទទួលពីរដ្ឋនូវអភ័យឯកសិទ្ធិជាធនាគារដ៏ពិសេស (ដូចជាចេញក្រដាសប្រាក់ធនាគារ bank notes ) ជាដើម ។

តាមរយៈនៃអភ័យឯកសិទ្ធនេះ ធនាគារកណ្តាល ឬធនាគាររដ្ឋាភិបាលក៏បានរកឃើញដោយខ្លួនឯង នូវការបំពេញ តួនាទីជាធនាគារិករបស់ធនាគារ ( banker's bank ) នេះក៏ព្រោះតែធនាគារនានាបានដាក់ប្រាក់បញ្ញើ នៅធនាគារកណ្តាល ។

នៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ របស់ខ្លួនជាធនាគារិករបស់ធនាគារ នោះធនាគារកណ្តាលទទួលខុសត្រូវជាបណ្តើរៗលើវិនិយ័តកម្ម នៃឥណទានក្នុងស្រុក ។ នៅក្នុងការដាក់កំរិតឥណទានក្នុងស្រុកនោះធនាគារកណ្តាលមានគោលដៅ សំខាន់គឺ ត្រូវតែចៀសវាងនូវការបញ្ឈប់លទ្ធភាពដូរផ្លាស់នៃក្រដាសប្រាក់ទៅជាមាសនិងមួយទៀតគឺត្រូវតែបញ្ចៀសនូវភាពបរាជ័យរបស់ធនាគារកុំឱ្យរាលដាល។

### ៥.១.១ តួនាទីធនាគារកណ្តាល (Role of central bank)

តួនាទីជាទូទៅខាងក្រោមនេះ យើងអាចធ្វើការកំនត់ដល់ផ្នែកសំខាន់ៗបួននៃប្រតិបត្តិការរបស់ធនាគារកណ្តាល :

**ក.ធនាគារិកសំរាប់រដ្ឋ (Banker for the state)**

ធនាគារកណ្តាលមានការទទួលខុសត្រូវដល់ការចេញនូវរូបិយវត្ថុរបស់ប្រទេស និងការគ្រប់គ្រងហិរញ្ញវត្ថុ របស់រដ្ឋាភិបាល ។ នៅពេលដើរតួនាទីជាធនាគារិករបស់រដ្ឋ និងជាអ្នកចេញក្រដាសប្រាក់នោះធនាគារកណ្តាល តំរូវឱ្យមានតួនាទីដ៏ប្លែកមួយនៅក្នុងការបង្កើតឡើង នូវអធិបតេយ្យភាពខាងនយោបាយរូបិយវត្ថុរបស់ប្រទេស។

**ខ.ធនាគារិកចំពោះធនាគារពាណិជ្ជកម្ម (Banker for the commercial bank)**

ធនាគារកណ្តាលទទួលប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនានា

ហើយមានឥទ្ធិពជាបន្តបន្ទាប់ដល់ប្រាក់បំរុងរបស់ ធនាគារនានា។ ធនាគារកណ្តាលឱ្យខ្ចីចំពោះប្រព័ន្ធធនាគារនានា ហើយមានតួនាទីពិសេស នៃការធ្វើសកម្មភាព ជាអ្នកឱ្យខ្ចីដល់ធនាគារពាណិជ្ជណាដែលគេចង់យកទៅ ដោះទាល់ម្តងម្កាល ។

**គ.គោលនយោបាយរូបិយវត្ថុមានលក្ខណៈប្រុងប្រយ័ត្ន (Discretion monetary policy)**

ធនាគារកណ្តាលទទួលខុសត្រូវជាពិសេសចំពោះ ការធ្វើឱ្យមានស្ថេរភាពរូបិយវត្ថុដែលមានលក្ខណៈទាំងខាងក្នុង និងខាងក្រៅ ។ ធនាគារកណ្តាលបានអនុវត្តនូវវិធីនេះដោយឥទ្ធិពលរបស់ខ្លួនទៅលើកំរិត នៃប្រាក់បំរុងកំនត់ដោយ ធនាគារពាណិជ្ជនានា និងក៏ផ្តល់ឱ្យប្រើប្រាស់នូវគោលនយោបាយអត្រាការប្រាក់របស់ខ្លួន ។ ការត្រួតពិនិត្យឥណទាន និង ការធ្វើអន្តរាគមន៍លើចរន្តនៃ អត្រាប្តូរប្រាក់ខាងក្នុងនិងខាងក្រៅប្រទេសផង ដែរ ។

**ឃ.ជាអ្នកត្រួតពិនិត្យប្រព័ន្ធហិរញ្ញវត្ថុ (Supervisor of the financial System)**

មុខងារនេះ រួមបញ្ចូលទាំងការធ្វើនិយ័តកម្ម (Regulation) នៃប្រព័ន្ធហិរញ្ញវត្ថុ និងការជំរុញ នូវអត្ថប្រយោជន៍ ហើយការអភិវឌ្ឍន៍របស់ខ្លួនទៀតផង។ តាមរបៀបផ្សេងទៀត នៅពេលដើរតួនាទីជាអ្នកឱ្យខ្ចីដល់អ្នកទាល់ច្រក ចុងក្រោយ ធនាគារកណ្តាលធ្វើសកម្មភាពជាអ្នកធានា (Guarantors) ដល់ស្ថេរភាពប្រព័ន្ធធនាគារ ទោះបីជាការ ធានារបស់ខ្លួនមិនមានលក្ខណៈ ផ្តាច់មុខក៏ដោយ ។

## ៥.១.២ ផ្នែកប្រតិបត្តិការរបស់ធនាគារកណ្តាល

**ក.ធនាគារិកចំពោះរដ្ឋ (Banker for the state)**

ធនាគារកណ្តាលដែលមានលក្ខណៈទំនើប គឺមានទំនាក់ទំនងយ៉ាងកៀកបំផុតជាមួយរដ្ឋ។ ទ្រឹស្តីសេដ្ឋកិច្ចក៏បាន ទទួលស្គាល់នូវទំនាក់ទំនងនេះដោយសំដៅទៅដល់ធនាគារកណ្តាលជាធនាគារិករបស់រដ្ឋាភិបាល ។ នៅពេលជា ធនាគារិករបស់រដ្ឋាភិបាល នោះធនាគារកណ្តាលមានតួនាទីសំខាន់ៗដូចខាងក្រោមៈ

- ធនាគារកណ្តាលចេញនូវរូបិយវត្ថុសំរាប់ប្រទេស (Issued the currency for the country)
- ធនាគារកណ្តាលទុកមូលនិធិរបស់រដ្ឋាភិបាល (Hold the spare funds of government) មួយភាគណានោះ និងទុកនូវមូលនិធិរបស់ផ្នែកសាធារណៈជនផងដែរ។ពេលជាធនាគារិករបស់រដ្ឋាភិបាលនោះ ធនាគារកណ្តាល បានបង្កលក្ខណៈងាយស្រួលដល់ការទូទាត់ដែល រដ្ឋាភិបាលត្រូវតែធ្វើចំពោះការចំណាយរាល់ថ្ងៃរបស់ខ្លួននិងចំណាយលើការវិនិយោគនានា...។

ធនាគារកណ្តាលឱ្យរដ្ឋាភិបាលខ្ចីដោយផ្ទាល់ (Directly lends to government) ។ ធម្មតាធ្វើបែប នេះកំនត់យកតាមរយៈធនាគារកណ្តាល ទិញធនប័ត្ររបស់រដ្ឋាភិបាល។

- ក្រៅពីការឱ្យខ្ចីដោយផ្ទាល់ ធនាគារកណ្តាលក៏បានរៀបចំចាត់ចែង ការខ្ចីរបស់រដ្ឋាភិបាលនៅក្នុងទីផ្សារបើក ទូលាយ (Open market)ដែរ ការលក់ឧបករណ៍បំណុលរដ្ឋាភិបាលរយៈពេលខ្លី និងវែង មានដូចជា Treasury bills, Treasury bonds ទាំងនេះកំនត់ឡើងនៅក្រោមការឧបត្ថម្ភរបស់ធនាគារកណ្តាល ។

### ខ.ធនាគារិកចំពោះធនាគារពាណិជ្ជកម្មនានា (Banker for the commercial bank)

ធនាគារកណ្តាលទុកប្រាក់បំរុងរបស់ធនាគារពាណិជ្ជនានា និងក៏បានធ្វើឱ្យមានកំចីដល់ធនាគារពាណិជ្ជវិញផងដែរ ។ ធនាគារកណ្តាលក៏បានសំដែងនូវមុខងារជាអ្នកឱ្យខ្ចីដល់ធនាគារពាណិជ្ជណាជួបនូវការខ្វះខាត (Lender of the last resort) ដែលនៅក្នុងនោះធនាគារកណ្តាលធ្វើជាអ្នកធានាដល់ប្រព័ន្ធធនាគារ នានា ។

ដើម្បីយល់នូវវិធីដែលមានដល់ធនាគារកណ្តាល ចំពោះការមានឥទ្ធិពលទៅលើកំរិត នៃប្រាក់បំរុងរបស់ធនាគារ ពាណិជ្ជនានា ហើយនិងរបៀបដែលធនាគារកណ្តាលអាចមានឥទ្ធិពលដល់បំរែបំរួលសន្និធិរូបិយវត្ថុ នោះយើងត្រូវ ក្រឡេកមើលយន្តកម្មនៃប្រាក់បំរុងរបស់ធនាគារ ។ នៅក្នុងដំណើរការនៃសកម្មភាពប្រតិបត្តិការឱ្យខ្ចី និងតាមរយៈ ការអោយខ្ចីនោះធនាគារបង្កើតឡើងនូវមធ្យោបាយទូទាត់ ។

ធនាគារទុកនូវទ្រព្យរបស់ខ្លួនមួយចំណែក នៅក្នុងទំរង់នៃប្រាក់បំរុងជាសាច់ប្រាក់។ ឧទាហរណ៍គេប្រើប្រាស់ ប្រាក់បំរុងក្នុងគោលបំណងដើម្បីប្រឈមមុខនឹងការដកប្រាក់ភ្លាមៗហើយដើម្បីបង្កលក្ខណៈងាយស្រួលដល់ការបង្វែ រូបិយវត្ថុតាមរយៈប្រព័ន្ធទូទាត់ ។

និយ័តកម្មរបស់ធនាគារតែងតែតំរូវឱ្យធនាគារនានា ទុកនូវកំរិតនៃទ្រព្យរបស់ខ្លួនមួយចំនួនដែលជាកំរិតអប្បបរមា នៃប្រាក់បំរុងករណីបែបនេះគេហៅថា កាតព្វកិច្ចប្រាក់បំរុង ។

## ៥.២ គោលនយោបាយកាតព្វកិច្ចប្រាក់បំរុងរបស់ធនាគារកណ្តាល

ធនាគារកណ្តាលអាចតំរូវឱ្យធនាគារពាណិជ្ជទុកមួយផ្នែកនូវប្រាក់បញ្ញើតាមតំរូវការ (Demand deposit) និងប្រាក់បញ្ញើតាមពេលកំនត់ (Time deposit) ត្រូវដកទុកជាប្រាក់បញ្ញើនៅធនាគារកណ្តាល។




រូបភាព ១១៖ ការផ្គត់ផ្គង់ទឹកប្រាក់

គេមានជំនឿជឿជាក់ថា កាតព្វកិច្ចប្រាក់បំរុងគឺសំខាន់ណាស់ដើម្បីធានាដល់សុវត្ថិភាពប្រាក់បញ្ញើ និងភាពមាំមួន របស់ធនាគារ ។

នៅក្រោមប្រព័ន្ធប្រាក់បំរុងនេះ ប្រាក់បំរុងបែបនេះក្លាយទៅជាទ្រព្យ "មានលក្ខណៈបង្កាំងទុក" (Frozen) ក្នុងអំឡុងពេលមានវិបត្តិ ព្រោះប្រាក់បំរុងមិនអាចឱ្យគេប្រើប្រាស់ បានទេ ។

## ៥.២.១ ការឆ្លើយតបទៅនឹងកាតព្វកិច្ចប្រាក់បំរុង

ស្ថាប័នប្រាក់បញ្ញើមួយ អាចទទួលនូវមូលនិធិនានាដើម្បីឆ្លើយតបទៅនឹងកាតព្វកិច្ចប្រាក់បំរុងដោយ តាមរយៈការលក់មូលប័ណ្ណ ( ឬទ្រព្យសកម្មផ្សេងទៀត ) ទៅឱ្យស្ថាប័នប្រាក់បញ្ញើផ្សេង ឬដោយតាមរយៈ នៃការខ្ចីពីស្ថាប័នទទួល បញ្ញើផ្សេងទៀត ។

ម្យ៉ាងទៀត ជាទូទៅស្ថាប័នទទួលប្រាក់បញ្ញើអាចបង្កើនប្រាក់បំរុងទាំងមូល ដោយខ្ចីពីធនាគារកណ្តាល ឬដោយ លក់ធនប័ណ្ណទៅឱ្យធនាគារកណ្តាល ។ ជាទូទៅ ស្ថាប័នទទួលប្រាក់បញ្ញើក៏មាន ជំរើសនៃការបំពេញនូវកាតព្វកិច្ច ប្រាក់បំរុងដោយមានកំចីតិចតួច និងដោយមិនឱ្យមានការខ្ចីថ្មី១ទៀតទេ ដូចដែលគេបានកំនត់ ។

| **Types of deposit and deposit Interval in millions of dollars** | **Percentage** | **Effective date** |
|---|---|---|
| Net demand | 7 | 12/30/76 |
| 0-2 | $9_{1/2}$ | 12/30/76 |

| | | |
|---|---|---|
| 2-10 | $11_{3/4}$ | 12/30/76 |
| 10-100 | $12_{3/4}$ | 12/30/76 |
| 100-400 | $16_{1/4}$ | 12/30/76 |
| Saving deposit | 3 | 3/16/67 |
| Time deposit | | |
| 0-5 by maturity | | |
| 30-179 days | 3 | 3/16/67 |
| 180 days to 4 year | $2_{1/2}$ | 01/08/76 |
| Over 4 year | 1 | 10/30/75 |
| Over 5 year | | |
| 30-179 days | 6 | 12/12/74 |
| 180 days to 4 year | $2_{1/2}$ | 01/08/76 |
| Over 4 year | 1 | 10/30/75 |

### តើគេគួរបង់ការប្រាក់ទៅឱ្យប្រាក់បំរុងទេ?

ប្រាក់បំរុងរបស់ស្ថាប័នទទួលប្រាក់បញ្ញើដែលកំនត់ថាជាប្រាក់បញ្ញើ ឬជា Vault Cash នៅឯធនាគារ កណ្តាលនោះ គឺមិនទទួលនូវការប្រាក់ទេ ។

## ៥.២.២ ការកំនត់នូវប្រភេទខុសៗគ្នានៃប្រាក់បំរុង និងរូបិយវត្ថុគោល

ដើម្បីឱ្យតំលៃទៅលើបញ្ហាដែលពាក់ព័ន្ធទៅនឹងគោលនយោបាយរូបិយវត្ថុនោះបានឱ្យយល់នូវរបៀប ដែលធនាគារ កណ្តាល ផ្នែកឯកជនដែលមិនមែនជាធនាគារ (មានគ្រួសារ និងក្រុមហ៊ុនអាជីវកម្ម) និងស្ថាប័នទទួលប្រាក់បញ្ញើ គឺមានអន្តរទំនាក់ទំនងនឹងគ្នា ។ ពិចារណាតារាង 3-1 ដែលបង្ហាញនូវតារាងតុល្យការដែលគេ បានបង្រួមជាសមីការ ។

តារាង ២៖ តារាងតុល្យការធនាគារកណ្តាល

| Asset | | Liabilities | |
|---|---|---|---|
| Goal and foreign exchange | 105 | Currency held by non-bank sector | 240 |
| Government securities | 200 | Depository institution reserve | 60 |
| Loan to depository institution | 5 | Other liabilities | 12 |
| Other | 2 | | |
| Total | 312 | Total | 312 |

តារាង ៣ តារាងតុល្យការរួមសម្រាប់ស្ថាប័នតំកល់ប្រាក់និងផ្នែកឯកជនមិនមែនធនាគារ

| Consolidated balance sheet for depository institution | | | |
|---|---|---|---|
| Assets | | Liabilities | |
| Reserves at Central bank | 60 | Deposit of non-bank private sector | 600 |
| Loan and investments | 540 | Loan from the Central bank | 0 |
| Other assets | 10 | Other liabilities | 10 |
| Total | 610 | Total | 610 |
| Consolidated balance sheet for non-bank private sector | | | |
| Assets | | Liabilities | |
| Currency deposit at Central bank | 240 | Bank loan | 500 |
| Checkable deposit at depository institution | 600 | Other liabilities | 1,200 |
| Government securities | 110 | | |
| Other | 450 | | |
| Total | 1,700 | Total | 1,700 |

ចំនុចគន្លឹះនរបស់ធនាគារកណ្តាលចំពោះគោលនយោបាយរូបិយវត្ថុ គឺលទ្ធភាពរបស់ខ្លួនដើម្បីមានឥទ្ធិពលដល់ប្រាក់ បំរុងរបស់ស្ថាប័នទទួលប្រាក់បញ្ញើនានា ។ ការកំនត់ខ្លះនៃទស្សនទានទាំងនេះត្រូវបានគេផ្តល់ ដោយបែបនេះ :

**-រូបិយវត្ថុគោល** (Monetary Base or the reserve base) ក៏ត្រូវបានគេហៅថា រូបិយវត្ថុដែលមានឥទ្ធិពលខ្ពស់។ រូបិយវត្ថុគោល រួមមានប្រាក់បំរុង របស់ស្ថាប័នប្រាក់បញ្ញើទាំងអស់បូកនឹងរូបិយប័ណ្ណ សំរាប់ធ្វើ ចរាចរ។ រូបិយប័ណ្ណកំពុងធ្វើចរាចរ គឺជារូបិយប័ណ្ណមាននៅក្នុងដៃសាធារណៈជន គឺមិននៅក្នុងធនាគារកណ្តាល និងមិននៅក្នុងរតនាគាររបស់រដ្ឋាភិបាលនោះទេ ។

នៅក្នុងសេដ្ឋកិច្ចដែលបានរៀបរាប់ដោយតារាងតុល្យការនៅតារាង 3-2 នោះការផ្គត់ផ្គង់រូបិយវត្ថុ M ស្មើទៅ នឹងរូបិយប័ណ្ណ C ដែលគេកំនត់ដោយផ្នែកឯកជនមិនមែនជាធនាគារ បូកនឹងតំលៃគណនីចុះបញ្ជី D ដែលសាធារណជន មិនមែនជាធនាគារទុកនៅក្នុងស្ថាប័នទទួលប្រាក់បញ្ញើ ។

ដូច្នេះគេបាន M = C + D

នៅក្នុងតារាង ខាងលើតួលេខដែលមានគឺ 840 = 240 + 600

ការកំនត់ដ៏សំខាន់មួយទៀតគឺ Monetary Base ដែលជាការសរុបនូវតំលៃរូបិយប័ណ្ណកំនត់យកផ្នែកមិនមែន ជាធនាគារ (C) បូកនឹងតំលៃប្រាក់បំរុងរបស់ស្ថាប័នទទួលប្រាក់បញ្ញើ (R) ។

នៅក្នុងទំរង់សមីការ នោះគេបាន Monetary Base B = C + R

នៅក្នុងតារាង ខាងលើ តំលៃរបស់វាគឺស្មើ 300 = 240 + 60

ហេតុនេះ យើងបាន មេគុណរូបិយវត្ថុ គឺ $MM = \frac{M}{B} = \frac{C+D}{C+R}$

**-ប្រាក់បំរុងលើស:** ការខុសគ្នារវាងទំហំនៃប្រាក់បំរុងសរុប និងប្រាក់បំរុងដែលគេបានតំរូវជាទូទៅគេ ហៅថាប្រាក់ បំរុងលើស ឬប្រាក់បំរុងលើស = ប្រាក់បំរុងពិត - ប្រាក់បំរុងដែលគេបានតំរូវ

**-ប្រាក់បំរុងដែលគេឱ្យខ្ចី**: ប្រាក់បំរុងដែលគេបានខ្ចី គឺជាប្រាក់បំរុងដែលស្ថាប័នទទួលប្រាក់បញ្ញើធ្វើ ការខ្ចីពីធនាគារ កណ្តាល ។

**-ប្រាក់បំរុងដែលគេមិនធ្វើការខ្ចី**: ធនាគារនានាក៏អាចធ្វើការខ្ចីពីគ្នាទៅវិញទៅមក តាមរយៈ ទីផ្សារអន្តរជាតិ ធនាគារ ។ ចំពោះប្រព័ន្ធធនាគារទាំងមូល អ្នកផ្គត់ផ្គង់ប្រាក់បំរុងចុងក្រោយគឺធនាគារកណ្តាល អាចផ្តល់នូវបំណុល ផ្ទាល់របស់ខ្លួន តាមរយៈប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារ កណ្តាល ដោយទិញនូវធនប័ណ្ណពីធនាគារនានា នៅក្នុងប្រតិបត្តិការទូទាត់ដែលបានដឹងថា ជាប្រតិបត្តិការទីផ្សារចំហ ។ ប្រភេទនៃប្រាក់បំរុងបែបនេះធម្មតា គេហៅ ថាប្រាក់បំរុងដែលមិនមាន លក្ខណៈខ្ចី ។

### ៥.២.៣. ហេតុអ្វីបានជាខ្ញុំមានកាតព្វកិច្ចប្រាក់បំរុង?

ហេតុអ្វីបានជាដាក់ឱ្យមានកាតព្វកិច្ចប្រាក់បំរុងដល់ស្ថាប័នទទួលប្រាក់បញ្ញើ ? គេហាក់ដូចជាគិតថា ស្ថាប័នទទួល ប្រាក់បញ្ញើនឹងទុកដោយស្ម័គ្រចិត្តនូវប្រាក់បញ្ញើរបស់ខ្លួន ។ ស្ថាប័នទទួលប្រាក់បញ្ញើមានបទពិសោធន៍គ្រប់គ្រាន់ដើម្បី បញ្ជាក់នូវចំនួនមូលនិធិ ដែលគេត្រូវការឱ្យមានប្រាក់បំរុងដើម្បីឆ្លើយតបទៅនឹងការដកសាច់ប្រាក់ និងការដកប្រាក់ បញ្ញើ។ លទ្ធភាពប្រាក់ចំណេញនៅតែបន្ត និងទាមទារឱ្យមានសន្ទនីយភាពគ្រប់គ្រាន់ដើម្បីបំពេញតំរូវការ របស់អ្នកផ្ញើរ ។

**តើកាតព្វកិច្ចប្រាក់បំរុងនេះបានការពារអ្នកបញ្ញើដែរទេ?**

**(Do this reserve requirement protect the deposit?)**

ជាការពិតណាស់ ការអះអាងដែលថា កាតព្វកិច្ចប្រាក់បំរុងគឺសំខាន់ណាស់ដើម្បីការពារអ្នកផ្ញើរ ។

**-មូលហេតុ (Reason):** កាតព្វកិច្ចប្រាក់បំរុងត្រូវបានគេពិនិត្យថា ជាឧបករណ៍គោលនយោបាយរូបិយវត្ថុ របស់ធនាគារកណ្តាល ។ បើសិនជាប្រាក់បំរុងដែលគេទាមទារនេះមានស្ថេរភាព នោះមេគុណរូបិយវត្ថុក៏មានស្ថេរភាព ដែរ ។ នេះមានន័យថា ធនាគារកណ្តាលអាចត្រួតពិនិត្យការផ្គត់ផ្គង់រូបិយវត្ថុដោយកាន់តែមានភាពពិតច្រើនជាងមុន នៅពេលដែលគេបានភ្ជាប់ទៅនឹងប្រតិបត្តិការទីផ្សារបើកចំហ ។

**-បំរែបំរួល (Change):** បំរែបំរួលកាតព្វកិច្ចប្រាក់បំរុងប៉ះពាល់ដល់ការផ្គត់ផ្គង់រូបិយវត្ថុតាមរបៀបពីរយ៉ាង: ធ្វើឱ្យប្រែប្រួល (1) កំរិតប្រាក់បំរុងលើស និង (2) មេគុណរូបិយវត្ថុ

### ៥.២.៤. ឥទ្ធិពលនៃបំរែបំរួលប្រាក់បំរុងដែលគេទាមទារ

ពីនេះ ធនាគារកណ្តាលអាចធ្វើឱ្យប្រែប្រួលដល់កាតព្វកិច្ចប្រាក់បំរុង បើសិនជាគេចង់ធ្វើឱ្យប្រែប្រួលឱ្យ បានលឿនដល់ការផ្គត់ផ្គង់រូបិយវត្ថុ ។

ឧបមាថា បើសិនជាធនាគារកណ្តាលចង់រឹតត្បិតរូបិយវត្ថុតាមរបៀបមួយយប់មួយថ្ងៃ នោះគេអាចបង្កើននូវអត្រា ប្រាក់បំរុងដែលគេទាមទារចំពោះធនាគារធំៗ ។ គេក៏ពិតជាអាចបង្កើននូវកាតព្វកិច្ចប្រាក់បំរុង លើបញ្ញើតាមពេល កំនត់ ។ ម្យ៉ាងទៀតបើសិនជាធនាគារកណ្តាលចង់បន្ធូរបន្ថយលក្ខខ័ណឥណទាន នោះគេអាចធ្វើតាមរបៀបប្រាក់បំរុង នេះបាននិងតាមរបៀបនៃការកាត់បន្ថយនូវអត្រាប្រាក់បំរុងតាមច្បាប់កំនត់នេះ ។

## ៥.៣ គោលនយោបាយអត្រាអប្បហាររបស់ធនាគារកណ្តាល

គេកំនត់នូវការធ្វើអប្បហារ ដូចជាដំណើរការនៃការឱ្យខ្ចីរបស់ធនាគារកណ្តាល ចំពោះស្ថាប័នទទួលប្រាក់បញ្ញើ នានា ។

គោលនយោបាយអប្បហារសំដៅទៅដល់ទំរង់ និងលក្ខខ័ណ្ឌមួយចំនួន ហើយនៅក្រោមទំរង់និងលក្ខខ័ណ្ឌបែបនេះ នោះធនាគារកណ្តាលធ្វើការឱ្យខ្ចីដល់ស្ថាប័នទទួលប្រាក់បញ្ញើ ។ អត្រា អប្ប

ហាររបស់ ធនាគារកណ្តាល គឺជាអត្រា ដែលធនាគារកណ្តាលធ្វើការទារថ្លៃទៅលើប្រាក់កំចីរបស់ខ្លួនចំពោះស្ថាប័នទទួលប្រាក់បញ្ញើ ។

### ៥.៣.១. គោលបំណងនៃយន្តកម្មអប្បហារ (Goals of the discount mechanism)

យើងពិនិត្យមើលនូវគោលបំណងមួយចំនួន ដែលបង្កើតឡើងសំរាប់បច្ចេកទេសនេះ ។ គេបានកំរិតដូចខាងក្រោម:

-ធ្វើជាឧបករណ៍គោលនយោបាយរូបិយវត្ថុ (Serve as a tool of monetary policy)

-ជាវ៉ាល់មួយដែលមានការធានាក្នុងអំឡុងពេលមានការកំរិតរូបិយវត្ថុ (Serve as a safety valve during period of monetary restraint)

-ឆ្លើយតបទៅនឹងការឡើងចុះនូវប្រាក់បញ្ញើ និងប្រាក់ឱ្យខ្ចី ឬការបង្ហូរចេញនូវប្រាក់បំរុង (Meet fluctuation in deposits and loans or reserve drains)

-ធ្វើឱ្យអ្នកខ្ចីនៃដំណាក់កាលទាល់ចុងក្រោយចំពោះធនាគារជាសមាជិកទាំងមូល

(Serve as lender of last resort to member banks as whole)

-ធ្វើជាអ្នកឱ្យខ្ចីនៃដំណាក់កាលទីទាល់ចុងក្រោយចំពោះធនាគារមិនមែនជាសមាជិក

ស្ថាប័នទទួលប្រាក់បញ្ញើមិនមែនជាធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត

(Serve as lender of last resort to nonmember banks. non-bank depository institutions and other financial institutions)

អត្រាអប្បហារជាពិសេសបំរើដូចជាការបំពេញដល់យុទ្ធសាស្រ្ត OMO នៅក្នុងការប្រតិបត្តិគោលនយោបាយ រូបិយវត្ថុ ។ កំចីរបស់ធនាគារកណ្តាលចំពោះស្ថាប័នទទួលប្រាក់បញ្ញើមានបំរើយ៉ាងសំខាន់ដូចជា:

- ជាប្រភពនៃមូលនិធិជាបណ្តោះអាសន្ន (a sources of temporary funds) ដើម្បីជួយដល់ប្រាក់បញ្ញើ ណាមានលក្ខណៈ ធំៗ និងគ្មាន រំពឹងគិតដល់ដែលស្ថាប័ននីមួយៗជួបប្រទះ
- ស្ថេរភាពនៃវ៉ាល់ (A safety of valve) សំរាប់ស្ថាប័នទទួលប្រាក់បញ្ញើនៅក្នុងអំឡុងពេលមានការកំរិត រូបិយវត្ថុ ។

### ៥.៣.២. លក្ខណៈ និងចំនុចសំខាន់នៃអត្រាអប្បហារ

ទំនាក់ទំនងដ៏កៀករវាងប្រភេទនៃប្រាក់កំចីដែលធ្វើអប្បហារដោយធនាគារពាណិជ្ជនានា និងធនាគារកណ្តាលគឺមើលទៅហាក់ដូចជាយន្តកម្មដែលជានិច្ចកាលនឹងកែតំរូវនូវប្រាក់បំរុងរបស់ធនាគារ និងការផ្គត់ផ្គង់ឥណទានរបស់ធនាគារចំពោះចំនួនមួយដែលមានក្នុងការធ្វើឱ្យមានស្ថេរភាពសេដ្ឋកិច្ច។

នៅក្នុងអំឡុងពេលមានអតិផរណាដោយក្រុមហ៊ុនមួយចំនួនជួបប្រទះនូវការពង្រីកឥណទាន នោះធនាគារកណ្តាល អាចធ្វើសកម្មភាពតបវិញ ដើម្បីកំរិតដល់ការពង្រីកឥណទានរបស់ធនាគារ ដោយតាមរយៈ នៃការបង្កើននូវអត្រាអប្បហារ ។

### ៥.៣.៣. បំរែបំរួលអត្រាអប្បហារ

ធនាគារកណ្តាលអាចលើកទឹកចិត្ត ឬធ្វើឱ្យខូចទឹកចិត្តដល់ការខ្ចីរបស់ធនាគារពាណិជ្ជនានា ប៉ុន្តែគេមិនអាចបង្កើត ឡើងនូវកំរិតដ៏ច្បាស់លាស់ នៃប្រាក់បំរុងដែលគេទាមទារចង់បាននោះទេ ។ ដូចពាក្យចាស់ និយាយថា អ្នកអាចដឹកសេះ ទៅកាន់ទឹកបាន តែអ្នកមិនអាចធ្វើឱ្យសេះនោះផឹកទឹកបានទេ" ។

## ៥.៤ ប្រតិបត្តិការទីផ្សារបើកចំហ (Open Market Operation: OMO)

ស្រដៀងគ្នានេះដែរ បំរែបំរួលនៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុអាចឱ្យគេនាំមកនូវដំណើរការដោយផ្ទាល់ទៅលើ កំរិតប្រាក់បំរុងនៅក្នុងប្រព័ន្ធមួយ ។ ធម្មតា តាមរយៈអ្វីដែលគេហៅថា **ប្រតិបត្តិការទីផ្សារបើកចំហ** ។ គេបានកំនត់ទីផ្សារបើកចំហដូចជាការទិញលក់ធនប័ណ្ណរបស់រដ្ឋាភិបាល ដោយធនាគារកណ្តាល ដើម្បីមានឥទ្ធិពលទៅលើកំរិត ប្រាក់បំរុងនៅក្នុងប្រព័ន្ធធនាគារ។

### ៥.៤.១. ឥទ្ធិពលដោយផ្ទាល់បីយ៉ាងរបស់ទីផ្សារបើកចំហ

នៅពេលដែលធនាគារកណ្តាលធ្វើការទិញ និងលក់ធនប័ណ្ណនៅលើទីផ្សារបើកចំហ នោះសេដ្ឋកិច្ចប៉ះពាល់ទៅ លើរបៀបដោយផ្ទាល់បីយ៉ាងៈ

-ការធ្វើឱ្យប្រែប្រួលដល់ប្រាក់បំរុងរបស់ស្ថាប័នទទួលប្រាក់បញ្ញើនានា

-ប្រែប្រួលដល់ អត្រាការប្រាក់

-ប្រែប្រួលដល់ការរំពឹងគិតទុកពីសេដ្ឋកិច្ច

**ក.ប្រែប្រួលដល់ប្រាក់បំរុង (Change in reserve)**

ការកំនត់នូវហេតុផលដែលគេបានបំពេញរួចរាល់ហើយ នោះបានបញ្ជាក់ថាការលក់ធនប័ណ្ណដោយ ធនាគារកណ្តាល ទៅឱ្យស្ថាប័នទទួលប្រាក់បញ្ញើ ឬទៅឱ្យផ្នែកឯកជនដែលមិនមែនជាធនាគារបានបន្ថយប្រាក់បំរុងស្ថាប័នទទួលប្រាក់ បញ្ញើជាទូទៅ និងធម្មតានាំទៅដល់ការបំព្រួញនៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុ ។ ដំណើររួញនៃការផ្គត់ផ្គង់រូបិយវត្ថុ ចុងក្រោយអាចនាំទៅដល់ការកាត់បន្ថយនូវសកម្មភាពសេដ្ឋកិច្ច ។

**ខ.បំរែបំរួលអត្រាការប្រាក់ (Interest rate change)**

ធនាគារកណ្តាលក៏អាចមានឥទ្ធិពលដល់អត្រាការប្រាក់។តាមគោលការណ៍ ធនាគារកណ្តាល អាចធ្វើប្រែប្រួលដល់ អត្រាការប្រាក់រយៈពេលខ្លី មធ្យម និងវែងដោយការលក់ ឬទិញនូវធនប័ណ្ណ ទាំងស្រុង នៅក្នុងទីផ្សារបែបណាមួយ ។

**គ.បំរែបំរួលពីការរំពឹងគិត (Change in expectation)**

ការកើនឡើងនូវការទិញធនប័ណ្ណរបស់ធនាគារកណ្តាលអាចត្រូវបានគេបកស្រាយថាដូចជា ការនូវគោលនយោបាយរូបិយវត្ថុមានលក្ខណៈពង្រីកដែលធ្វើឱ្យអត្រាការប្រាក់ថយចុះ ផលិតកម្ម និង ការវិនិយោគកើនឡើង និងការ ចំណាយរបស់អតិថិជនកើនឡើងដែរ ។ ម្យ៉ាងទៀត គោលនយោបាយ រូបិយវត្ថុ ដែលបានពង្រីកនេះ អាចធ្វើឱ្យមាន ការរំពឹងគិតទុកនូវការកើនឡើងយ៉ាងខ្ពស់នាពេល អនាគតនូវការផ្គត់ផ្គង់រូបិយវត្ថុ និងការកើតឡើងនូវអតិផរណា ។

### ៥.៤.២. ប្រភេទនៃទីផ្សារបើកចំហរ (Types of OMO)

មានប្រភេទជាមូលដ្ឋានពីរយ៉ាងនៃប្រតិបត្តិការទូទាត់បែប OMO

**ក.ការទិញលក់ទាំងស្រុង (Outright gross purchases or sales)** : ធនាគារកណ្តាល ទិញ ឬ លក់ធនប័ណ្ណ នៅក្នុងយុទ្ធសាស្ត្រ OMO និងដោយឥតមានលក្ខខ័ណ្ឌចំពោះប្រតិបត្តិការទូទាត់ ។ បើ សិនជាធនាគារកណ្តាលលក់ធន ប័ណ្ណទៅឱ្យអ្នកទិញម្នាក់ នោះអ្នកទិញនឹងគ្មានកាតព្វកិច្ចដើម្បីលក់ ធនប័ណ្ណទៅឱ្យធនាគារកណ្តាលនៅពេលក្រោយទេ ។

**ខ.ការឯកភាពទិញត្រលប់ (Repurchase agreement: REPOs):** នៅក្នុងការឯកភាពទិញ ត្រលប់វិញ ធនាគារកណ្តាលទិញធនប័ណ្ណពីអ្នករកស៊ី ហើយអ្នករកស៊ីបានឯកភាពទិញធនប័ណ្ណ ត្រលប់មកវិញតាមថ្ងៃ និងពេល វេលាដែលបានកំនត់ ។

### ៥.៤.៣. ឥទ្ធិពលរបស់ទីផ្សារបើកចំហរ ( Effect of OMO )

សកម្មភាពទីផ្សារបើកចំហរបស់ធនាគារកណ្តាលមានឥទ្ធិពលទៅលើសេដ្ឋកិច្ចតាមរបៀបបី យ៉ាង :

-ការចាត់ចែងរបាយធនប័ណ្ណរបស់ធនាគារកណ្តាល ធ្វើឱ្យធនាគារកណ្តាលជះឥទ្ធិពលទាំងទៅ លើប្រាក់បំរុង របស់ស្ថាប័នទទួលប្រាក់បញ្ញើ និងទាំងទៅលើ Monetary Base ។

-សកម្មភាពទីផ្សារបើកចំហ មានឥទ្ធិពលទៅលើថ្លៃ និងទិន្នផលនៃធនប័ណ្ណ

-OMOs ក៏អាចមានឥទ្ធិពលដ៏ពេញលេញដល់ការរំពឹងគិតទុកលើផ្នែកឯកជនបានយ៉ាងច្បាស់។

គ្រប់ប្រទេសជឿនលឿនតែងមានធនាគារកណ្តាល ។ បេសកកម្មដ៏សំខាន់ គឺដើម្បីត្រួតពិនិត្យនូវការផ្គត់ ផ្គង់ រូបិយវត្ថុ និងលក្ខខ័ណ្ឌឥណទានរបស់ជាតិ ។




## ៥.៥ ការត្រួតពិនិត្យរបស់ធនាគារកណ្តាល

យើងគិតពិចារណានូវគោលបំណងជាទូទៅរបស់ធនាគារកណ្តាល ដូចជាការពង្រឹកនូវស្ថេរភាពរបស់ប្រព័ន្ធធនាគារ និងការកាត់បន្ថយនូវហានិភ័យនូវការប្រេះស្រាំរបស់ធនាគារ ។ ឧបករណ៍ជាកណ្តាលនៃទំរង់ ត្រួតពិនិត្យដ៏ទំនើបគឺតំរូវឱ្យមានមូលធនគ្រប់គ្រាន់ដើម្បីទប់នូវហានិភ័យហើយ បច្ចេកទេសដែលធនាគារកណ្តាលប្រើក្នុងគោលបំណងដើម្បី ធ្វើឱ្យមានស្ថេរភាពដល់ធនាគារនោះគឺការប្រតិបត្តិរបស់ខ្លួនជាអ្នកឱ្យខ្ចីនៃដំណាក់កាលទាល់ច្រកចុងក្រោយរបស់ធនាគារនានា ។

### ៥.៥.១ ទាមទារឱ្យមានមូលធនគ្រប់គ្រាន់ដើម្បីកែតំរូវដល់ហានិភ័យ

ការទាមទារឱ្យមានមូលធនគ្រប់គ្រាន់ ហើយជាពិសេស ការតំរូវឱ្យមានមូលធនគ្រប់គ្រាន់ដើម្បីជួយសំរួលនូវហានិភ័យ បានក្លាយទៅជាឧបករណ៍ដែលមានឥទ្ធិពលខ្លាំងនៅក្នុងដៃរបស់ធនាគារកណ្តាល។

យើងចង់ឱ្យអ្នកពិចារណានូវប្រភេទគោលនយោបាយពីរខុសៗគ្នា សំរាប់ពង្រឹងធនាគារ និងធានាថា ហានិភ័យដែល គេកំពុងប្រឈមមុខទៅនឹងអ្នកបញ្ញើរបស់ខ្លួន គឺត្រូវកាត់បន្ថយ។ ប្រាក់បំរុងដែលគេបាន តំរូវអាចធ្វើការធានាថា

ធនាគារទុកទ្រព្យល្មមគ្រប់គ្រាន់នៅក្នុងទំរង់ជាទ្រព្យសកម្មដើម្បីធានាថា គេអាចធ្វើការបង់ជាសាច់ប្រាក់ទៅឱ្យអ្នក ផ្ញើរ នៅពេលមានការដកប្រាក់បញ្ញើសុទ្ធ (Net withdrawal) នោះ ។

ការកំនត់នូវការទាមទារឱ្យមានមូលធនគ្រប់គ្រាន់ដើម្បីធានាថា ទុនរបស់ក្រុមហ៊ុនគឺច្រើនល្មមគ្រប់គ្រាន់ដើម្បី ស្រូបយកនូវការខាតបង់បែបនេះ និងទប់ស្កាត់នូវការក្ស័យធន (Bankruptcy) ។

ក្រោយពីគេបានបង្កើតនូវគំនិត នៃការទាមទារឱ្យមានមូលធនគ្រប់គ្រាន់ នោះជំហានបន្ទាប់មកទៀត គឺដើម្បីបង្កើត នូវកាតព្វកិច្ចឱ្យមានមូលធនគ្រប់គ្រាន់ ដើម្បីកែតំរូវនូវកំរិតហានិភ័យទៅលើទ្រព្យរបស់ធនាគារ គឺការទាមទារឱ្យមាន មូលធនគ្រប់គ្រាន់ដើម្បីដោះស្រាយនូវហានិភ័យ ។ បើសិនជាធនាគារយកមួយផ្នែកនៃ ទ្រព្យដ៏ខ្ពស់របស់ខ្លួនធៀបទៅ នឹងទំរង់ហានិភ័យទាប នោះគឺការទាមទារឱ្យមានមូលធនគ្រប់គ្រាន់នឹងថយចុះ៖ តែបើសិនជាគេដាក់ឱ្យមាននូវបំណែក ជាច្រើនទៅលើទ្រព្យណាដែលមានហានិភ័យខ្ពស់វិញ ការតំរូវឱ្យមាន មូលធនគ្រប់គ្រាន់របស់ខ្លួននឹងកើនឡើងខ្ពស់។

### ៥.៥.២. ដើរតួនាទីជាអ្នកឱ្យខ្ចីដល់អ្នកទាល់ច្រកចុងក្រោយ

និយ័តកម្ម (Regulation) ទៅលើភាពគ្រប់គ្រាន់មូលធនរបស់ធនាគារ គឺ គ្រាន់ជាផ្នែកមួយ ដែលជាយុទ្ធសាស្ត្រ របស់ធនាគារកណ្តាលប៉ុណ្ណោះ ក្នុងការគាំទ្រប្រព័ន្ធធនាគារប្រឆាំងនឹងការបរាជ័យ ។ គោលនយោបាយជាមូលដ្ឋាននៅ ក្នុងទិដ្ឋភាពបែបនេះ គឺកាតព្វកិច្ចរបស់ធនាគារ កណ្តាល ដើម្បីធ្វើសកម្មភាពជាម្ចាស់បំណុលចំពោះអ្នក ដែលជួបនូវភាព ទាល់ច្រកចុងក្រោយ ។

ការវិវត្តន៍នូវមុខងារជាអ្នកឱ្យខ្ចីដល់អ្នកទាល់ចុងក្រោយត្រូវបានគេភ្ជាប់ទៅ នឹងសំនួរដែលថា ហេតុអ្វីបានជាឱ្យមាន ធនាគារកណ្តាល ។ ការលើកឡើងជាមូលដ្ឋានរបស់យើងគឺថា ការត្រួតពិនិត្យជាទូទៅនៃប្រព័ន្ធធនាគារ និងប្រការនៃ សន្ទនីយភាពនៅក្នុងវិបត្តិមួយ គឺជាសកម្មភាពដែលធ្វើឱ្យមានភាពជាអព្យាក្រិតភាព របស់ធនាគារកណ្តាល ។

ការពិនិត្យប្រព័ន្ធធនាគារ ក៏ត្រូវស្ថិតនៅក្នុងទីតាំងដើម្បីរៀបចំនូវការកែច្នៃឡើងវិញនៃមូលនិធិចំពោះធនាគារ ដែលមានការបាត់បង់នូវប្រាក់បញ្ញើ ។ ម្យ៉ាងទៀត ធនាគារកណ្តាលក៏ត្រូវជាម្ចាស់បំណុល ចំពោះអ្នកទាល់ច្រក ចុងក្រោយដែរ ដើម្បីធ្វើការផ្តល់សន្ទនីយភាពដល់ធនាគារនៅក្រោមសម្ពាធ និងក្រោមការរារាំងមិនឱ្យដួលរលំ នៃ ប្រព័ន្ធធនាគារ ។

## ៥.៦ ប្រព័ន្ធធនាគារជាតិ

### ៥.៦.១. ប្រវត្តិនៃប្រព័ន្ធធនាគារនៅកម្ពុជា

ប្រទេសកម្ពុជាបានផ្លាស់ប្តូរពីសម័យកាលមួយ ទៅសម័យកាលមួយទៀត ដោយពុំបានស្ថិតថេរយូរអង្វែងឡើយ ។ ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្ររបស់ខ្លួនគួរជាទីកត់សំគាល់មានទាំងចំបាំងរាប់រយឆ្នាំ ដណ្តើមទឹកដី ពីសំណាក់ប្រទេស ជិតខាងយួន និងសៀម ហើយថែមទាំងត្រូវបានស្ថិតក្នុងការគ្រប់គ្រង របស់អាណានិគមបារាំង ជិតមួយសតវត្សដែលសម័យនោះហៅថា សម័យអាណានិគមបារាំង ។ អំណាចទាំងអស់នៃប្រទេសស្ថិតក្នុងការកាន់កាប់ និងត្រួត ត្រាដោយប្រទេសបារាំង ។ ទន្ទឹមនោះ ការគាបសង្កត់ របស់បារាំងបានធ្វើអោយមានការរើបំរាស់ចេញពីនឹម អាណា និគម ដោយការដឹកនាំដ៏ឈ្លាសវៃរបស់ ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ ដែលបានទទួលឯករាជ្យ ពេញលេញ នៅថ្ងៃទី ៩ វិច្ឆិកា ១៩៥៣ ។ ជាមួយគ្នានោះ ក្រោមការដឹកនាំរបស់ព្រះបាទ នរោត្តម សីហនុ សង្គមរាស្ត្រនិយមក៏បានលេចរះចិញ្ចែងចិញ្ចាចជាពន្លឺនៃក្តីសង្ឃឹមរបស់ប្រជាពលរដ្ឋខ្មែរ។ សង្គមរាស្ត្រនិយមបាន អភិវឌ្ឍន៍ និងស្តារ ហេដ្ឋារចនាសម្ព័ន្ធជាតិ អោយកាន់តែមានភាពរីកចំរើន និងជឿនលឿនស្ទើរគ្រប់វិស័យ ។

### ៥.៦.ដំណាក់កាលមុនឆ្នាំ ១៩៧៥

នៅក្នុងសម័យនោះ ធនាគារជាតិត្រូវបានបង្កើតឡើង ដោយព្រះរាជក្រមលេខ ៩២២ ន.ស ចុះថ្ងៃ ទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៥៤ បន្ទាប់ពីវិទ្យាស្ថានបោះប្រាក់ឥណ្ឌូចិនត្រូវបានបិទទ្វារ នៅពេលដែលប្រទេសទាំង ៣ គឺ កម្ពុជា ឡាវ វៀតណាម បានទទួលឯករាជ្យរៀងៗខ្លួន ពីអាណានិគមនិយមបារាំង ។

ក្នុងដំណាក់កាលដំបូងនោះ ធនាគារជាតិ នៃកម្ពុជា បានបោះផ្សាយប្រាក់រៀលឯករាជ្យមួយ ដើម្បីបញ្ចប់ជាស្ថាពរនូវការចាយវាយក្រដាសប្រាក់រួម រវាង ប្រទេសទាំង បី គឺក្រដាស់ប្រាក់ ពីយ៉ាស្រ្ទី (Piastre) ។

នៅដំណាក់កាលមុនឆ្នាំ ១៩៧៥ ប្រព័ន្ធធនាគារនៅកម្ពុជារួមមាន :

-ធនាគារជាតិនៃកម្ពុជា

-គ្រឹះស្ថានឥណទានទាំងបីស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីររាជសហករណ៍ ដែលត្រូវបានបង្កើតតាំងពីឆ្នាំ១៩៥៦ គឺ :

- សហករណ៍ផលិតកម្ម
- សហករណ៍ឧបភោគ-បរិភោគ
- សហករណ៍ ឥណទាន

- ធនាគារពាណិជ្ជ : មានធនាគារពាណិជ្ជកម្មចំនួន ៨ ធ្វើសកម្មភាពនៅក្នុងអំឡុងពេលនោះ ។ ក្នុង ចំណោមធនាគារទាំង ៨ គេឃើញមាន ៤ ជា៨នាគារក្នុងស្រុក និង ៤ទៀត ជាធនាគារបរទេស ។

⇒ ធនាគារក្នុងស្រុក :

- ធនាគារកម្ពុជាពាណិជ្ជ (Cambodian Commercial Bank)
- ធនាគារភ្នំពេញ (Phnom Penh Bank)
- ធនាគារសុវណ្ណភូមិ (Sovannaphoum Bank)
- ធនាតារខ្មែរ (Banque Khmère)

⇒ ធនាគារបរទេស :

- ធនាគារជាតិសំរាប់ពាណិជ្ជកម្ម និង ឧស្សាហកម្ម (Baque Nationale pour le Commerce et L'Industrie : BNCI) ក្រោយមកប្រែថា Banque Nationale de Paris របស់បារាំងវិញ
- ធនាគារឥណ្ឌូចិន (Banque de L'Indochine)
- ធនាគារ ឆាទើរ៉ែត (Chartered Bank)
- ធនាគារហុងកុង និង សៀងហៃ (Hong Kong & Shanghai Bank)




រូបភាព ១២៖ គំនូសបង្ហាញប្រព័ន្ធធនាគារនៅកម្ពុជាមុនឆ្នាំ ១៩៧៥

ក្រោយមកដោយសារតែវិបត្តិធ្ងន់ធ្ងរក្នុងវិស័យធនាគារនៅខែវិច្ឆិកា ឆ្នាំ ១៩៦៣ (សុងសាក់) ធនាគារឯកជន ក្នុងស្រុក និងបរទេសទាំង ៨ ត្រូវបានបិទទ្វារ និងបានធ្វើជាតូបនីយកម្មដើម្បីបង្កើតឡើងជាធនាគារ ដែល កាន់កាប់ដោយរដ្ឋ មានជាអាទិ៍ គឺ :

-ធនាគារខ្មែរសំរាប់ពាណិជ្ជកម្ម

-ធនាគារឥណទានជាតិ

- ធនាគារអភិវឌ្ឍន៍

-ធនាគារកសិកម្មជនបទ

ធនាគារជាតិនៃកម្ពុជា មានការប្រែប្រួលជាសំខាន់ក្នុងអំឡុងឆ្នាំ ១៩៦៤ ដោយបានប្រែក្លាយ ពីទម្រង់ស្ថាប័ន ពាក់កណ្តាលស្វ័យយ័តទៅជាធនាគាររដ្ឋក្រោមទម្រង់ទ្រាយជាស្ថាប័នសាធារណៈ ដែលមានលក្ខណៈឧស្សាហកម្ម និង ពាណិជ្ជកម្ម ។

ក្នុងចំណោមគ្រឹះស្ថានឥណទានទាំងបីនៃមន្ទីរាជសហករណ៍ គឺ សហករណ៍ឥណទានបានធ្វើសកម្មភាពឥណទាន យ៉ាងទូលំទូលាយទូទាំងប្រទេស ដើម្បីគាំទ្រដល់រាស្ត្រតូចតាច ។ សកម្មភាពឥណទាននេះជាសំខាន់ ធ្វើឡើងមុនការ បង្កើតធនាគារកសិកម្មជនបទនាឆ្នាំ ១៩៧០ ។

ចាប់ពីឆ្នាំ ១៩៧០ មកប្រព័ន្ធធនាគារបានធ្វើសេរីភាវូបនីយកម្មជាថ្មីដើម្បីបង្កលក្ខណៈអោយធនាគារឯកជន ធ្វើសកម្មភាពទន្ទឹមនឹងធនាគាររដ្ឋ ក្រោមការបញ្ជាណែនាំ និងត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ( ទេសាភិបាល : លោក សឺន សាន ) ។

### ៥.៦.១.២-ដំណាក់កាលពីឆ្នាំ ១៩៧៥-១៩៧៩

របបប៉ុលពតពីឆ្នាំ ១៩៧៥-១៩៧៩ បានបំផ្លិចបំផ្លាញសង្គមកម្ពុជាខ្ទិចខ្ទីលើគ្រប់វិស័យ។ របបនេះបានធ្វើ អោយប្រវត្តិសាស្ត្រក្រឡាប់ចាក់ ដែលញ៉ាំងអោយសង្គមជាតិទាំងមូលវិលទៅរកសង្គមបុព្វកាលតែមួយប៉ព្រិចភ្នែក គឺជា សង្គមដែលគ្មានទីផ្សារ គ្មានការដោះដូរទំនិញ គ្មានការចាយវាយប្រាក់កាសគ្មានសាលារៀន ហើយថែមទាំងកាប់ សំលាប់ប្រជាជនអស់ជាច្រើននាក់ ដោយគ្មានរើសមុខ ។ របបគ្រប់គ្រង ប៉ុលពត ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ បានបំផ្លិចបំផ្លាញប្រព័ន្ធធនាគារខ្មែរអោយធ្លាក់ដល់ចំណុចសូន្យ មិនត្រឹមតែក្រដាសប្រាក់ទេ ដែលត្រូវបានកំទេចមិន អោយចរាចរ ឬ បោះបង់ចោលរាយប៉ាយពេញផ្លូវ សូម្បីតែអាគារដ៏ស្កឹមស្កៃក្រហមចិញ្ចាចរបស់ធនាគារ ជាតិនៃកម្ពុជាក៏ត្រូវបិទទ្វារ និងបំផ្លិចបំផ្លាញ ។ យើងវិវត្តិវិលទៅរកបែបផែននៃសេដ្ឋកិច្ច Barter ដែលគេបានបោះបង់ចោលជាយូរយាណាស់មកហើយ ។

### ៥.៦.១.៣-ដំណាក់កាលក្រោយឆ្នាំ ១៩៧៩

ផ្តើមចេញពីចំនុចសូន្យ និងដោយបាតដៃទទេ ធនាគារជាតិត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៧៩ និងមានឈ្មោះថា " ធនាគារជាតិនៃប្រជាជនកម្ពុជា" ។ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៨០ (៦ខែក្រោយ) ប្រាក់រៀលថ្មីត្រូវបានបោះពុម្ព និងដាក់អោយចរាចរ ។

ប្រព័ន្ធធនាគារនៅកម្ពុជាក៏ ចាប់កំណើតឡើងវិញពីពេលនោះមក តាមរយៈការរៀបចំរចនាសម្ព័ន្ធក្បាលម៉ាស៊ីន ដឹកនាំ និងសកម្មភាពប្រតិបត្តិការនៅទីស្នាក់ការកណ្តាល (កាលនោះតាំងនៅអាគារអតីត ធនាគារខ្មែរសំរាប់ ពាណិជ្ជកម្ម Banque Khmère pour le commerce : BKC ) និងការពង្រីកបណ្តេញ នៅតាមខេត្ត-ក្រុង ទូទាំងប្រទេស ។ ក្នុងអំឡុងពេលនោះ ប្រព័ន្ធធនាគារ កម្ពុជា មានលក្ខណៈជា "ប្រព័ន្ធ ធនាគារតែ១ថ្នាក់" (A Mono bank Systems) ។ ធនាគារជាតិនៃកម្ពុជា ដើរតួនាទីទាំងធនាគារកណ្តាលទាំងធនាគារពាណិជ្ជជាមួយនឹងសាខា ធនាគារ ខេត្ត-ក្រុងរបស់ខ្លួន និងជារតនាគាជាតិ ។

ចាប់ពីឆ្នាំ ១៩៨៩ ប្រព័ន្ធធនាគារត្រូវបានកែទម្រង់ជាបន្តបន្ទាប់ពោលគឺបានផ្ទេរធនាគារខេត្ត-ក្រុង ទៅជា ធនាគារឯកទេស ខេត្ត-ក្រុង ដែលធ្វើសកម្មភាពតាមរបបស្វ័យភិបាលសេដ្ឋកិច្ច និងស្វ័យភាពហិរញ្ញវត្ថុ លើតំបន់ ដែនដីរបស់ខ្លួន ។ ធនាគារជាតិបំពេញតួនាទីណែនាំ និងត្រួតពិនិត្យធនាគារឯកទេសទាំងនោះ ។

មុខងារជាបេឡានៃថវិការដ្ឋ ក៏បានផ្ទេរទៅអោយក្រសួងហិរញ្ញវត្ថុវិញនៅចុងឆ្នាំ ១៩៩១ ហើយធនគារជាតិ ទទួលយកឈ្មោះចាស់ជាផ្លូវការគឺ "ធនាគារជាតិនៃកម្ពុជា។ វិញតាមច្បាប់ចុះថ្ងៃទី ៣១ ខែ

ធ្នូ ឆ្នាំ ១៩៩២ ស្តីពីការកែប្រែអង្គការចាត់តាំង ភារកិច្ចរបស់ធនាគារជាតិ នៃប្រជាជនកម្ពុជា និងបានផ្លាស់ទីតាំងមកនៅកន្លែង ចាស់បន្ទាប់ពីសាងសង់អាគារថ្មីមានលំនាំដូចអាគារដើមរបស់ខ្លួន ។

ការវិនិយោគបរទេសលើវិស័យធនាគារ ក៏បានចាប់ផ្តើមតាំងពីពាក់កណ្តាលឆ្នាំ ១៩៩១ ដែរ អាស្រ័យដោយ ការផ្លាស់ប្តូររបបសេដ្ឋកិច្ចប្រមូលផ្តុំមកជារបបទីផ្សារ ។គេសង្កេតឃើញក្នុងអំឡុងពេលនោះ មានធនាគារ ប្រមាណ ៦០ ដែលបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មធនាគារ ( ទេសាភិបាលចា រៀង ) ។ ក្នុងចំណោមធនាគារទាំងនោះមាន ចំនួនជាងពាក់កណ្តាលគ្រាន់តែសុំអាជ្ញាប័ណ្ណ ដើម្បីទុកដាក់លក់យកចំណេញ ហើយបានដកហូតអាជ្ញាប័ណ្ណ វិញក្នុងពេល ក្រោយមក ។

## ៥.៦.២. ធនាគាររបស់រដ្ឋ

### ៥.៦.២.១-ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (Foreign Trade Bank of Cambodia: FTB)

ដូចបានបង្ហាញក្នុងរចនាសម្ព័ន្ធ របស់ធនាគារជាតិនៃកម្ពុជារួចហើយ ធនាគារពាណិជ្ជកម្មក្រៅប្រទេស គឺជា អង្គភាពមួយចំណុះអគ្គលេខាធិការដ្ឋាននៃធនាគារជាតិនៃកម្ពុជា ។ ដូច្នេះ FTB គឺជាចំណែក មួយរបស់ NBC ដែល មានទំរង់ដូចប្រទេសអនុវត្តផែនការប្រមូលផ្តុំ ហើយកំពុងតែឈានទៅអនុវត្តសេដ្ឋកិច្ចទីផ្សារ ។ ក្នុងដំណើររៀបចំ ប្រព័ន្ធធនាគារដែលមាន ២ ថ្នាក់ (Two-tier Banking System) គឺទាមទារ ឱ្យមានការបំបែក FTB ចេញពី NBC ឱ្យបានច្បាស់លាស់ដើម្បីអនុញ្ញាតឱ្យ NBC បំពេញតួនាទីដ៏ពេញ លេញជាធនាគារកណ្តាល ។កន្លងមក FTB ពុំទាន់បានកែទំរង់ដើម្បីបង្កើនភាពប្រកួតប្រជែងជាមួយធនាគារពាណិជ្ជកម្ម ចំនួន ៣១ ទៀត ដែលកំពុងធ្វើប្រតិបត្តិការ នៅឡើយទេ ។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយក៏FTB ទទួលបានទំនុកចិត្តយ៉ាងច្រើនពីអតិថិជនក្នុងស្រុកក៏ដូចជាអង្គការ ក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិដែរ ។ កន្លងមក FTB បានដើរតួយ៉ាងសំខាន់ក្នុងការរក្សាស្ថេរភាពប្រព័ន្ធធនាគារ នៅកម្ពុជា ។ ក្នុងពេលដែលមាន ការប្រយុទ្ធគ្នា ក្នុងស្រុកនាឆ្នាំ ១៩៩៧ FTB ជាធនាគារតែមួយគត់ដែលប្តេជ្ញាបន្តផ្តល់ សេវាកម្ម ជានិរន្តន៍ដល់ អតិថិជនរបស់ខ្លួន ម្យ៉ាងទៀតដោយសារសេដ្ឋកិច្ចកម្ពុជា ប្រកបដោយដុល្លារូបនីយកម្មដ៏ខ្ពស់ នោះ ធនាគារពាណិជ្ជភាគច្រើនធ្វើប្រតិបត្តិការជាមួយប្រាក់ដុល្លាអាមេរិក ធនាគារខ្លួនទៀតមានសកម្មភាព តែជាប្រាក់ រៀលតែបន្តិចបន្តួចប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា ជាបង្គោល តែមួយ ដែលអនុវត្ត នយោបាយបដិដុល្លារូបនីយកម្មរបស់ធនាគារជាតិនៃកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ។ FTB នៅតែជាធនាគារដែល មានចំណេញក្នុងខណៈដែលធនាគារតូចៗមួយចំនួនជួបនូវការលំបាក អាស្រ័យដោយសកម្មភាពជំនួញធ្លាក់ចុះ បណ្តាលមកពីឥទ្ធិពលនៃវិបត្តិនយោបាយក្នុងស្រុក និងវិបត្តិហិរញ្ញវត្ថុក្នុងតំបន់ និងលើសកលលោក ។

តាមមតិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ IMF ក្រុមហ៊ុនត្រួតពិនិត្យគណនេយ្យដែលគាំទ្រដោយសាជីវកម្ម ហិរញ្ញវត្ថុអន្តរជាតិ IFC បានផ្តល់អនុសាសន៍ នូវជំហាននានា ដើម្បីធ្វើសវនកម្ម និងវាយតម្លៃសំដៅជំរុញ ធ្វើឯកជន ភាវូបនីយកម្ម FTB ឱ្យបាននៅឆ្នាំ ២០០១។ ទោះជាធនាគារពាណិជ្ជកម្មក្រៅ

ប្រទេស មិនទាន់ត្រូវបានធ្វើ ឯកជនភាវូបនីកម្មនៅឡើយ ក៏វាត្រូវបានផ្តាច់ចេញពីធនាគារជាតិ ហើយផ្ទេរទៅអោយ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គ្រប់គ្រងមួយរយៈពេលកន្លងមកហើយ ។

### ៥.៦.២.២-ធនគារអភិវឌ្ឍន៍ជនបទ (Rural Development Bank: RDB)

ធនាគារអភិវឌ្ឍន៍ជនបទ (RDB) ត្រូវបានបង្កើតឡើងនៅខែមករា ១៩៩៨ ។ ធនាគារនេះស្ថិតក្រោមការ ត្រួតពិនិត្យបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការត្រួតពិនិត្យពីធនាគារជាតិនៃកម្ពុជា ។ គោលដៅចំបងរបស់ RDB គឺជំរុញការអភិវឌ្ឍន៍កសិកម្មជនបទ និងសកម្មភាពសេដ្ឋកិច្ចជាទូទៅ ។ ដើម្បីសំរេចនូវ គោលដៅនេះធនាគារ RDB មានមុខងារសំខាន់ៗដូចតទៅនេះ :

ក-បង្កើតបណ្តាញស្ថាប័នហិរញ្ញវត្ថុវិមជ្ឈការ និងលើកឡើងនូវក្របខ័ណ្ឌគតិយុត្ត សំរាប់គាំទ្រាល់សកម្មភាព ក្នុងផ្នែកនេះ ។

ខ-ពិភាក្សាជាមួយអ្នកផ្តល់ជំនួយ ដើម្បីទទួលបាននូវធនធានចាំបាច់សំរាប់គាំទ្រដល់សកម្មភាព ឥណទានរបស់ ប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ។

គ-ផ្តល់ហិរញ្ញប្បទាន និង បុនហិរញ្ញប្បទានចំពោះ ប្រតិប្តិការមីក្រូហិរញ្ញវត្ថុ ។

ឃ-ផ្តល់ជំនួយបច្ចេកទេសសំរាប់ការគ្រប់គ្រង និង ការសំរបសំរួលសកម្មភាពមីក្រូហិរញ្ញវត្ថុ ។

ង-បំពេញមុខងារជាអ្នកទំនាក់ទំនង និងត្រួតពិនិត្យចំពោះស្ថានប័នមីក្រូហិរញ្ញវត្ថុទាំងនោះតាមសិទ្ធិដែល ប្រគល់ជូនដោយធនគារជាតិនៃកម្ពុជា ។

ច-ផ្តល់ការបណ្តុះបណ្តាលចំពោះបុគ្គលិករបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។

ឆ-គ្រប់គ្រងទីភ្នាក់ងារបញ្ចោញនៅតាមខេត្ត និង កេណ្ឌប្រមូលសញ្ញ័យពីសាធារណជន ។

ជ-អនុវត្តរាល់ប្រតិបត្តិការធនាគារ ហិរញ្ញវត្ថុ ឥណទាន ភាគកម្មជានាវ៉ាប់រង និងប្រតិបត្តិការជើងសារ ដែលទាក់ទងនឹងកម្មវត្ថុរបស់ខ្លួន ។

ដើមទុនរបស់ធនាគារ RDB ត្រូវបានបើកចំហរចំពោះគ្រប់ស្ថាប័នប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ វិមជ្ឈការ វិនិយោគិនក្នុងស្រុក និង អន្តរជាតិដែលមានបំណងចូលរួមក្នុងការអភិវឌ្ឍន៍ជនបទ ។

## ៥.៦.៣. សាខាធនគារបរទេស និង ធនាគារក្នុងស្រុក

(Foreign branches and local banks)

### ៥.៦.៣.១-សាខាធនាគារបរទេស (Foreign branches)

ធនាគារបរទេសដែលធ្វើអាជីវកម្មនៅកម្ពុជាតាមរយៈសាខារបស់ខ្លួន ត្រូវចំណុះក្រោម ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលតំរូវឱ្យធនាគារទាំងនោះ ទទួលនូវអាជ្ញា

ប័ណ្ណសំរាប់សាខារបស់ ខ្លួនពីធនាគារជាតិនៃកម្ពុជា។ គិតមកត្រឹម ខែ ធ្នូ ឆ្នាំ ២០០៣ មានសាខាធនាគារ បរទេសចំនួន ៣ នៅកម្ពុជាគឺ :

១- ធនាគារ ពាណិជ្ជកម្មទីមួយ សាខាភ្នំពេញ

(First Commercial bank P. Penh branch)

២- ធនាគារ ក្រុងថៃ ចំកាត់ មហាជន សាខាភ្នំពេញ

(Krung Thai Bank public Co. Ltd. P. Penh Branch)

៣- ធនាគារ មេយប៉ែង សាខាភ្នំពេញ (May Bank P. Penh Branch)

គេបានកត់សំគាល់ឃើញថា ក្រៅពីចំនួនសាខាធនាគារបរទេសខាងលើនេះ មានសាខាធនាគារ ៤ បានបញ្ឈប់ សកម្មភាពរបស់ខ្លួនគឺ :

១-ធនាគារនគរហ្លួងថៃ (Siam City Bank) បញ្ឈប់ពីថ្ងៃ ០១-១១-៩៨

២- ធនាគារលីពប៉ូប៉ែង (PT Lippo Bank) បញ្ឈប់ពីថ្ងៃ ២៥-៩-៩៩

៣- ធនាគារបាងកកចំកាត់ (Bangkok Bank Ltd) បញ្ឈប់ពីថ្ងៃ ០៨-១២-០០

៤- ធនាគារកសិករថៃចំកាត់ (Thai Farmer Bank Ltd) បញ្ឈប់ពីថ្ងៃ ៣០-០៣-០០ និងមានសាខាមួយដែលសុំប្តូរទៅជាការិយាល័យតំណាងវិញ គឺធនាគារ ស្តង់ដាឆាទីរ៉ែត សាខាភ្នំពេញ (Standard chartered Bank)

### ៥.៦.៣.២-ធនាគារក្នុងស្រុក (Local banks)

ច្បាប់ថ្មីស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវបានអនុម័ត នៅខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ក្រោមឥទ្ធិពលនៃ ច្បាប់នេះ ធនាគារពាណិជ្ជត្រូវបានកំណត់និយមន័យថា ជាអង្គភាពស្របច្បាប់ដែលត្រូវបានផ្តល់អាជ្ញាប័ណ្ណឱ្យធ្វើ ប្រតិបត្តិការធនាគារជាមុខរបរជាប្រក្រតី ។ ក្នុងនាមសាធារណជនទូទៅក្នុងនាមខ្លួនផ្ទាល់ ធនាគារ អាចធ្វើសេវា ហិរញ្ញវត្ថុ ឬ សេវាធនាគារ លើកលែងតែសេវាធានារ៉ាប់រង ។

សព្វថ្ងៃនេះ ធនាគារក្នុងស្រុកមាននៅតែ ១៤ ប៉ុណ្ណោះ និង មានស្នាក់ការកណ្តាលតាំងនៅភ្នំពេញទាំងអស់

- ធនាគារ វឌ្ឍនៈអាស៊ី (Advanced Bank of Asia)

- ធនាគារ កម្ពុជាអាស៊ី (Cambodia Asia Bank)

- ធនាគារ កាណាឌីយ៉ា (២) (Canadia Bank Ltd)

- ធនាគារ កម្ពុជាពាណិជ្ជ ( ១) (Cambodia Commercial Bank)

- ធនាគារ កម្ពុជាមេគង្គ (៣) (Cambodia Mekong Bank)

- ធនាគារ កម្ពុជាសាធារណៈ (៦) (Cambodian Public Bank)

- ធនាគារសាជីវកម្មសិង្ហបូរី (Singapore Banking Corporation)

- ធនាគារសហពាណិជ្ជ (៤) (Union Commercial Bank)

- ធនាគារវឌ្ឍនៈ (Vattanak Bank)

- ធនាគារ អេស៊ីលីដា (ACLEDA Bank Ltd)

### ៥.៦.៣.៣- ប្រព័ន្ធធនាគារវិមជ្ឈការ (Decentralized Bank Systems: DBS)

ធនាគារជាតិនៃកម្ពុជាបានបង្កើតការិយាល័យត្រួតពិនិត្យប្រព័ន្ធធនាគារវិមជ្ឈការ (DBS) នៅខែ វិច្ឆិកា ១៩៩៧ ចំណុះក្នុងនាយកដ្ឋានត្រួតពិនិត្យធនគារជាតិនៃកម្ពុជា។ ការិយាល័យប្រព័ន្ធធនាគារ វិមជ្ឈការនេះ មាន តួនាទីដូចតទៅនេះ :

១- សំរបសំរួលការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឱ្យមានជំនាញក្នុងវិស័យនៃប្រព័ន្ធធនាគារ វិមជ្ឈការ ។

២- ប្រមូលពត៌មានទាំងអស់ស្តីពីប្រព័ន្ធធនាគារវិមជ្ឈការ

៣- សំរបសំរួលប្រតិបត្តិការវិមជ្ឈការ ដោយអនុលោមតាមបទបញ្ញា-អាជ្ញាប័ណ្ណ ដើម្បីអនុវត្តត្រឹមត្រូវនូវប្រព័ន្ធគណនេយ្យ ការគ្រប់គ្រង វិធានការប្រុងប្រយ័ត្ន និង នយោបាយរូបិយវត្ថុ ដូចដែលធនាគារពាណិជ្ជបានអនុវត្តកន្លងមក ។

៤- សំរបសំរួល និងគាំទ្រចំពោះរាល់កិច្ចការដែលទាក់ទងនឹងនិយ័តតិកម្ម គតិយុត្ត និងហិរញ្ញវត្ថុ ចំពោះស្ថាប័ននៃប្រព័ន្ធធនាគារវិមជ្ឈការ ។

តាំងពីពេលបង្កើតរហូតមកដល់បច្ចុប្បន្ននេះ គេសង្កេតឃើញសកម្មភាពខ្លះៗរបស់ប្រព័ន្ធធនាគារវិមជ្ឈការ ដូចតទៅនេះ :

- សំរបសំរួល និងផ្តល់យោបល់ចំពោះគ្រប់សកម្មភាពឥណទានជនបទ ( ដូចជាសិក្ខាសាលា សន្និបាត ប្រជុំ ទស្សនកិច្ចសិក្សា ...) ។
- សំរួលជាប្រចាំជាមួយប្រតិបត្តិករ និងអ្នកផ្តល់ជំនួយក្នុងរាល់បញ្ហាទាក់ទងនឹងឥណទានជនបទ ។
- រៀបចំសិក្ខាសាលាជាច្រើនលើកច្រើនសារ ដែលស្តីពី
    - ប្រព័ន្ធហិរញ្ញវត្ថុវិមជ្ឈការ (១៥-១៦/១២/៩៧ )
    - សញ្ញ័យ និង បញ្ហាញឥណទានសង្គម ( ២៩/០១/៩៨ )
    - នយោបាយរាជរដ្ឋាភិបាលក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ( ២៨-៣០/០៣/៩៨)
    - គំរោងរបាយការណ៍ហិរញ្ញវត្ថុ ( ២៩-៣០/០៩/៩៨ )
    - ការបង្កើតស្ថាប័នមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ( ០៨/០២/៩៩ )
    - ស្ទូនហិរញ្ញវត្ថុក្នុងមាគ៌ាឆ្ពោះទៅបង្កើតស្ថាបន័មីក្រូហិរញ្ញវត្ថុ (១៧/០៣/៩៩)

- ការកេណ្ឌប្រមូលសញ្ញ័យ (២៨/០៤/៩៩)
- ក្របខ័ណ្ឌនយោបាយ និងការអនុវត្តន៍មាគ៌ាណែនាំសំរាប់មីក្រូហិរញ្ញវត្ថុ
- (១៤/០៦/៩៩) ដោយសហការជាមួយអង្គការ PRACA ។
- យុទ្ធសាស្ត្រនៃការត្រួតពិនិត្យ ការពិគ្រោះយោបល់ និង ការវាយតំលៃ និងការសំរបសំរួល សំរាប់កម្មវិធីមីក្រូហិរញ្ញវត្ថុ ... ។

ការអនុវត្តកន្លងមកឃើញថា មានត្រីស្ថានហិរញ្ញវត្ថុមួយចំនួន :

- បំពានបទបញ្ញាត្តិនៃច្បាប់ជាធរមាន ឬ បទបញ្ជារបស់ធនាគារកណ្តាល
- មានការខ្វះខាតក្នុងការបំពេញកាតព្វកិច្ចផ្សេងៗ
- មិនគោរពវិធានការនយោបាយរូបិយវត្ថុ ឬ វិធានការប្រុងប្រយ័ត្ននានាដែលបានកំណត់ ។

ឧទាហរណ៍ : បេសកកម្មរបស់ធនាគារជាតិនៃកម្ពុជា មានភាពចាំបាច់ដោយខានមិនបាន ដើម្បីដាក់ឱ្យអនុវត្ត ដោយឥតលក្ខខ័ណ្ឌនូវនយោបាយរូបិយវត្ថុរបស់ខ្លួន និងវិធានការព្រមទាំងសេចក្តីសំរេចនានា ដែលស្តែងចេញពីនយោបាយរូបិយវត្ថុ និងនយោបាយនៃវិធានការប្រុងប្រយ័ត្នរបស់ធនាគារកណ្តាល ។ មិនតែប៉ុណ្ណោះ ធនាគារជាតិនៃកម្ពុជា បំពេញសកម្មភាពបន្ទាប់បន្សំផ្សេងៗទៀតដូចជា :

- ទំនាក់ទំនងផ្នែកហិរញ្ញវត្ថុជាមួយអង្គភាពសាធារណៈ ធនាគារកណ្តាលមានភារកិច្ចធ្វើជាទីប្រឹក្សារបស់ រាជរដ្ឋាភិបាលក្នុងវិស័យរូបិយវត្ថុ និងហិរញ្ញវត្ថុ ពោលគឺផ្តល់ពត៌មាន និងផ្តល់យោបល់ជូន រាជរដ្ឋាភិបាល អំពីបញ្ហា ទាំងឡាយដែលមានអនុភាពក្នុងការធ្វើឱ្យសំរេចគោលដៅនយោបាយហិរញ្ញវត្ថុ ។
- ធនាគារកណ្តាលអាចផ្តល់ឥណទានដែលមានកាលវសានមិនហួសពី ៣ខែជូនទៅ រតនាគារជាតិ ដោយគិត ការប្រាក់តាមអត្រាបុនហិរញ្ញប្បទាន ។
- ក្នុងក្របខ័ណ្ឌនៃកិច្ចប្រតិបត្តិការផ្សារចំហរ (Open Market) ឬ កិច្ចប្រតិបត្តិការអប្បហារ ឬ ឥណទាន ជាមួយនឹងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធនាគារកណ្តាលអាចលក់-ទិញ ទទួល ឬ ដាក់ប៉ង់ស្យុង នៃមូលប័ត្ររដ្ឋ ដែលត្រូវបានគេបោះផ្សាយជាសាធារណៈពីមុនមក ហើយដែលត្រូវផុតកំណត់សងក្នុងកំឡុង ៩០ថ្ងៃ ។ ម្យ៉ាងទៀត ធនាគារកណ្តាលអាចធ្វើអន្តរាគមលើទីផ្សារនេះ ដើម្បីបន្ថយសាច់ប្រាក់ងាយស្រួលក្នុងប្រព័ន្ធធនាគារ ដោយលក់ មូលប័ត្ររដ្ឋដែលបានចេញផ្សាយរួចហើយ ឬ មួយដើម្បីបង្កើនសាច់ប្រាក់ងាយ ស្រួលរបស់ប្រព័ន្ធធនាគារដោយទិញ យកមូលប័ត្ររដ្ឋដែលចេញផ្សាយរួចហើយ និងដែលមានកាលវសាន តិចជាង៩០ថ្ងៃ ។ ធនាគារកណ្តាលអាចបំពេញសាច់ប្រាក់ងាយស្រួលក្នុងប្រព័ន្ធធនាគារតាមរយៈការធ្វើអប្បហារ ឬតាមរយៈប្រតិបត្តិការប៉ង់ស្យុង ។សារព័ន្ធនៃប្រតិបត្តិការទាំងនេះ អាចធ្វើបានតែលើរូបិយវត្ថុ ជាតិប៉ុណ្ណោះ។

# ជំពូក ៦ ឥណទានជនបទនៅកម្ពុជា

## ៦.១ ប្រវត្តិឥណទាននៅកម្ពុជា

- ប្រវត្តិដំបូងនៃការផ្តល់ឥណទានបានចាប់ផ្តើមនៅ ឆ្នាំ ១៩៨៩ ដោយអង្គការ UNICEF សហការ ជាមួយក្រសួងកិច្ចការនារី ។ ការចាប់ផ្តើមនេះជារបៀបឥណទានគោ ព្រោះថា ក្រោយរបប ប៉ុលពតបានបន្សល់ទុកនូវស្ត្រីមេម៉ាយជាច្រើនដែលជាមេគ្រួសារ ហើយ គេមាន កង្វះកំលាំង ពលកម្មបុរស និង កំលាំងអូសទាញសំរាប់ការងារកសិកម្ម ។
- នាឆ្នាំ ១៩៩០ អង្គការ WVIC(World Vision International Cambodia) បានគិតគូរពីការ អភិវឌ្ឍន៍សហគមន៍ជាមួយនឹងធនាគារស្រូវពូជ និង ជី ។ ការផ្តល់ ពូជ និង ជី បានចូលរួម ចំណែកកំនើនទិន្នផល រក្សាគុណភាពបរិស្ថានធម្មជាតិ ការលុបបំបាត់ ចោលនូវទុរ្ភិក្ស និង ការ កែលំអជីវភាពសំរាប់អ្នកជនបទ ។
- នៅឆ្នាំ ១៩៩១ អង្គការ GRET (Group Echange des Technique) ដែលទទួលឥណទាន ពី ភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសបារាំង (Agence Francaise de Dévelopment) បានបង្កើត អង្គ ការមួយដែលមានឈ្មោះថា អង្គការមូលដ្ឋានឥណទានជនបទ (EMT) ។ អង្គការនេះបាន សាកល្បងដំបូងនៅស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ ការផ្តល់កំចីជាមួយការប្រាក់ដើម្បីជួយ រំលែកភាពទាល់ច្រករបស់កសិករក្នុងការងារផលិតកម្ម ចាប់តាំងពីផលិតកម្មស្ករត្នោត រហូត ដល់ការផ្តល់កំចីស្រូវពូជ និង ជី ។
- ក្រោយមកមានធនាគារ និង អង្គការធំៗជាច្រើន បានចូលរួមចំណែកប្រតិបត្តិមីក្រូហិរញ្ញវត្ថុ ដូចជាៈ ACLEDA SEILANITHIH HATHAKAKSEKAR កម្មវិធី PRASAC CRS ANS ។ល ។ រហូតមកដល់ពេលនេះ ទំហំឥណទានដែលបានផ្តល់មានចំនួនប្រមាណ ២៩ លាន ដុល្លាសហរដ្ឋ និង គ្របដណ្តប់ប្រមាណ ៣៧០០០០ គ្រួសារ រឺ សមមូលនឹង ២១ ភាគរយនៃ ចំនួនប្រជាកសិករទូទាំងប្រទេសនៅតាមជនបទ ( សុន គន្ធរ ធនាគារអភិវឌ្ឍន៍ ជនបទ ២០០១) ។ តាមការសង្កេតជាទូទៅទៅលើប្រវត្តិនៃការផ្តល់ឥណទាននៅកម្ពុជា យើង អាច សន្និដ្ឋានថា យើងនៅតែមានខ្វះខាតដ៏វែងឆ្ងាយ និង ទាមទារពេលវេលាយូរសំរាប់ជួយកាត់ បន្ថយ ភាពក្រីក្រ និង ការអភិវឌ្ឍន៍ជនបទតាមរយៈឥណទាន ។

### ៦.១.១ និដ្ឋភាពទូទៅ

ប្រទេសកម្ពុជាជាប្រទេសតតិយលោកមួយដែលមានប្រជាជន ៨៥ ភាគរយនៃរាស្ត្រសរុប ១២.១ លាន នាក់រស់នៅតាមជនបទ ។ គេប្រកបរបរ កសិកម្ម នេសាទ ប្រមូលអនុផលព្រៃឈើ និង សិប្ប-កម្មខ្នាតតូច ជាលក្ខណៈប្រពៃណី ។ លទ្ធផលជាវិជ្ជមានមានកំរិតស្តួចស្តើង និង ចំរេលាយូរ ដែលរាជរដ្ឋាភិបាលបាន ទទួលគឺការកាត់បន្ថយភាពក្រីក្ររាស្ត្រខ្មែរបានថយចុះពី ៣៨ ភាគរយនាឆ្នាំ ១៩៩៣ មកត្រឹម ៣៦ ភាគរយនាឆ្នាំ ១៩៩៩ ។ ស្ថេរភាពសេដ្ឋកិច្ច និង ការលូតលាស់សេដ្ឋកិច្ច ប្រកបដោយចិរភាពគឺជាឧត្តមភាព មួយថ្មីទៀតដែលមានឥទ្ធិពលមិនផ្ទាល់ទៅលើការអភិវឌ្ឍន៍ជនបទ

នៅកម្ពុជា ដូចជា: កំនើនវិនិយោគលើ វិស័យកសិកម្ម កសិ-ឧស្សាហកម្ម និង ទេសចរណ៍បានផ្តល់ប្រភពចំណូលមួយថ្មីសំរាប់អ្នកជនបទ ។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយន្តការកាត់បន្ថយភាពក្រីក្រចំនួនពីរគន្លឹះ :

- ម៉ាក្រូហិរញ្ញវត្ថុដែលផ្អែកទៅលើកម្មវិធីវិនិយោគសាធារណៈ ។ គោលបំនងគឺស្តារពល់ហេត្ថារចនាសម្ព័ន្ធជនបទ និង សេដ្ឋកិច្ចសង្គមជនបទ ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធដូចជា កសិកម្ម ធនធានទឹក អភិវឌ្ឍន៍ជនបទ សុខាភិបាល កិច្ចការនារី -យុទ្ធជន និង មូលនិធិសង្គ
- មីក្រូហិរញ្ញវត្ថុជនបទដោយផ្អែកទៅលើការចូលរួមធនាគារអភិវឌ្ឍន៍ ដែលចូលរួមក្នុងការផ្តល់សេវាកម្មឥណទាន ។ គេប្រើប្រាស់សេវាកម្មនេះ ដើម្បីគាំទ្រការអភិវឌ្ឍន៍កសិកម្ម និង សេដ្ឋ-កិច្ច ជនបទ ជាមួយនឹងជំហរទីផ្សារសេរី និង និរន្តភាពសេដ្ឋកិច្ច ។
- មីក្រូហិរញ្ញវត្ថុ គឺជាយន្តការមួយដ៏ទន់ភ្លន់ និង សន្សំសំចៃសំរាប់រយៈពេលយូរអង្វែង ដែលអាចចូលរួម អភិវឌ្ឍន៍សហគមន៍កម្ពុជាលើគ្រប់វិស័យជនបទ ។ ដំណើរការនេះមានលក្ខណៈថ្មីស្រឡាងសំរាប់ កម្ពុជា ចាប់តាំងពីពាក់កណ្តាលទសវត្សទី ២០ យើងនេះ តែវាហាក់ដូចជាមានសភាពរស់រវើក និង មានការគាំទ្រច្រើនពីប្រជាជនជនបទនៃកម្ពុជា ។ បញ្ហាយុទ្ធសាស្រ្តសំខាន់ៗនៃឥណទានជនបទ គឺសំដៅធ្វើយ៉ាង ណាអោយការអនុវត្តន៍ការងារនេះមាននិរន្តភាព និង ស្ថេរភាព។

## ៦.២ ឥណទាន-សេវាមីក្រូហិរញ្ញវត្ថុ

ឥណទាន គឺជាកាផ្តល់កំចី រឺ ទទួលហិរញ្ញវត្ថុបញ្ញើពីសមាជិកដែលបានស្ម័គ្រចិត្តចូលរួមជាមួយគ្រឹះស្ថាន មីក្រូហិរញ្ញណាមួយ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គឺជាអន្តរការីធនាគារដែលមានបានទទួលប្រាក់ពីអតិថិជន រឺ ក្រុមហ៊ុនណាមួយ ហើយ.ផ្តល់កំចីដល់អ្នកត្រូវការប្រាក់សំរាប់ដំណើរការអាជីវកម្ម ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរួមមាន: ស្ថាប័នហិរញ្ញវត្ថុឯកជន (Private Financial Institution) ធនាគារពាណិជ្ជកម្ម (Commercial Banks) និង អង្គការក្រៅរដ្ឋាភិបាល (Non-Government Organization) ។ កាលណាស្ថាប័នទាំងនេះចាប់ផ្តើមដំណើរការឥណទាន គេបានប្រែក្លាយជាផ្នែកមួយនៃសាខាសហគមន៍ ឥណទាន (Credit Unions) ដែលស្ថិតនៅក្រោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាតិជាអ្នកត្រួតពិនិត្យ ។ ដោយផ្អែកទៅលើទ្រឹស្តីសហគមន៍ឥណទានរួមមាន: Long-term Credit Banks, Credit Association, Credit Cooperatives, Agricultural Credit Cooperatives and other Development Bank Projects ។ ដោយផ្អែកទៅលើរបាយការណ៍របស់ ធនាគារអភិវឌ្ឍន៍អាស៊ី ២០០១ បានអោយដឹងថា: ធនាគារពាណិជ្ជកម្មចំនួន ១៩ នៅកម្ពុជា បានផ្តល់សេវាកម្មឥណទានតែនៅ តំបន់ទីប្រជុំជនខេត្ត-ក្រុង រីឯពស្រ្តជនបទពុំមានលទ្ធភាពខ្ចីប្រាក់ពីធនាគារពាណិជ្ជទាំងនោះបានឡើយ ។ សេវាកម្មហិរញ្ញវត្ថុបច្ចុប្បន្នរួមមាន: ឥណទានទោល ឥណទានក្រុម ការសន្សំប្រាក់ ការហ្វឹកហ្វឺន ការចុះតាមដាន និង ផ្តល់យោបល់ដល់ប្រជាជនដែលបានខ្ចីប្រាក់ ។ អត្រាការប្រាក់ដែលប្រតិបត្តិករកំពុង អនុវត្តន៍រវាង ៣-៥ ភាគរយក្នុង ១ ខែ អាស្រ័យទៅតាមគោលនយោបាយ និង ចំណាយគ្រប់គ្រងឥណ ទានរបស់ពួកគេ ។ សព្វថ្ងៃនេះស្ថាប័នរដ្ឋ អង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិចំនួនប្រមាណ ៧២ កំពុង ចូលរួមបំរើ

សេវាកម្មមីក្រូហិរញ្ញវត្ថុដល់ជនបទទាំង ២៤ ខេត្ត-ក្រុង តាមរយៈការផ្តល់ឥណទាន និង យុទ្ធនាការលើប្រាក់សន្សំសំចៃ ( ការិយាល័យត្រួតពិនិត្យនៃធនាគារឯកទេស ២០០០)។ យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍ជនបទ ( ២០០០) ការលើកទឹកចិត្ត និង ការគៀគងទឹក ប្រាក់នៃការសន្សំសំចៃគឺជាប្រភពដ៏សំខាន់សំរាប់ផ្តល់សេវាឥណទាននៅជនបទ តែគោលដៅស្ថិតនៅក្នុង គំរោងដែលមិនទាន់បានអនុវត្តន៍នៅឡើយ និង មិនទាន់មានសកម្មភាពប្រមូលពី សាធារណៈជនក្រៅពី សមាជិកនៅឡើយ ។ តំរូវការដើមទុនសរុបសំរាប់ដំណើរការនេះ មានប្រមាណ ១២៥ លានដុល្លា ។ តែរហូតមកដល់ពេលនេះ យើងបានទទួលសម្បទានពី :

- រដ្ឋាភិបាល ៥ លានដុល្លា ដែលក្នុងនោះ ១លានយូរ៉ូជាជំនួយឥតសំណងពី Agence Francaise de Dévelopment តាមរយៈក្រសួងសេដ្ឋកិច្ច ។
- ជំនួយឥតសំណង ០.៩ លានដុល្លាសហរដ្ឋសំរាប់កម្មវិធីកំនៃទំរង់កៅស៊ូជាលក្ខណៈគ្រួសារ ។ គេបានសាកល្បងលើកដំបូងនៅខេត្តកំពង់ចាម ។
- International Fund for Agricultural Development (IFAD) បានផ្តល់ ១.៣ លានដុល្លាសំរាប់ គំរោងឥណទានជនបទគាំទ្រកម្មវិធីសិលានៅខេត្ត ពោធិសាត់ បាតលដំបង បន្ទាយមានជ័យ និងសៀមរាប និងកំចី ២០លានពីធនាគារអភិវឌ្ឍន៍អាស៊ីដែលបានដំណើរការឆ្នាំ ២០០១ កន្លងមក។ យើងសង្កេតឃើញថា: គ្រាន់តែធនាគារអភិវឌ្ឍន៍ជនបទមួយប៉ុណ្ណោះ បានផ្តល់កំចីរួចហើយ ចំនួន ២៩ លានដុល្លា និង រដ្ឋាភិបាលបានផ្តល់ ២៧ លានដុល្លា បន្ថែមទៀតទៅលើប្រភពទុន មីក្រូហិរញ្ញវត្ថុ។ ប្រភពទុនដែលអាចជួយស្ថាប័នអោយបានផ្តល់ឥណទានទូលំទូលាយ ត្រូវការប្រមាណ ៧០ លានដុល្លា ។

## ៦.៣. គោលនយោបាយរដ្ឋាភិបាលក្នុងវិស័យឥណទានជនបទ

វិស័យឥណទានមានមុខងារបង្កើន ផលិតភាពផលិតកម្មពង្រីកប្រាក់ចំណូលសំរួលជីវភាពរស់នៅ និង កាត់បន្ថយភាពក្រីក្រនៅជនបទ ។ គំរោងឥណទានត្រូវបានគេរំពឹងទុកថា វាបានចូលរួមចំណែកដល់ ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តភាព និង ចិរភាព ។ រដ្ឋាភិបាលបានចេញនូវគោលនយោបាយ ចំបងចំនួនបីគឺ: ធានានូវវឌ្ឍនភាពនៃវិស័យឥណទាន ប្រសិទ្ធភាពនៃសកម្មភាពឥណទាន និង ធានា ចិរភាពនៃសកម្មភាពឥណទានជនបទ។ យើងសូមលំអិតគំរោងទាំងនេះដូចតទៅ៖

### ក. ធានានូវវឌ្ឍនភាពនៃវិស័យឥណទាន

- បន្តគ្រប់គ្រងនយោបាយម៉ាក្រូសេដ្ឋកិច្ចអោយមានលំនឹងភាព
- បន្តយន្តការអត្រាការប្រាក់នៅលើទីផ្សារសេរី
- និតិគំរោងថ្មីៗសំរាប់ស្ថាប័នមីក្រូឥណទាន
- ជំរុញអោយធនាគារបន្តការគាំទ្រវិស័យឥណទាន
- ពង្រីកសន្សំសំចៃរបស់រាស្ត្រដែលជាប្រភពទុនក្នុងស្រុកដ៏សំខាន់សំរាប់សេវាឥណទាន

## ខ. បង្កើនប្រសិទ្ធភាពនៃសកម្មភាពឥណទានជនបទ

- លើកកំពស់កម្មវិធីហ្វឹកហ្វឺនដល់ប្រតិបត្តិករអោយមានសមត្ថភាពក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បន្តទាក់ទាញធនធានហិរញ្ញវត្ថុ និង បច្ចេកទេសពីក្រៅប្រទេស
- ជំរុញអោយអង្គធរដៃនដីសហការក្នុងការងារឥណទាន និង ប្រតិបត្តិករ

## គ. ចីរភាពនៃសកម្មភាពឥណទានជនបទ

- បង្កើតគណៈកម្មាធិការឥណទានជនបទ
- បង្កើតការិយាល័យត្រួតពិនិត្យធនាគាររឹមជ្ឈការ
- បង្កើតធនាគារអភិវឌ្ឍន៍ជនបទ
- ពង្រឹងក្របខ័ណ្ឌច្បាប់សំរាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

## ៦.៤. មីក្រូហិរញ្ញវត្ថុ និង ការអភិវឌ្ឍន៍ជនបទនៅកម្ពុជា

យើងនឹងធ្វើការសិក្សាអំពីទំនាក់ទំនងមីក្រូហិរញ្ញវត្ថុ និង ការអភិវឌ្ឍន៍ជនបទតាមរយៈការស្វែងយល់អំពី មុខងារ រឺ តួនាទីឥណទានជនបទ ការពិភាក្សាឥណទានទោល-ក្រុមការសន្សំសំចៃរបស់កសិករ និង ការពង្រីកមុខព្រួញសេវាកម្មមីក្រូហិរញ្ញវត្ថុ ។

➢ សិក្សាពីតួនាទីឥណទានជនបទ
  - ផ្តល់ទុនដល់កសិករសំរាប់ទិញឧបករណ៏ និង មធ្យោបាយ ។
  - ផ្តល់ទុនឱ្យកសិករអាចរក្សាទុកនិងអាចលក់ផលិតផលកសិកម្មរបស់ខ្លួននៅពេលណាដែលមានតម្លៃ សមស្របតាមបំណង ។
  - ផ្តល់ធនធានហិរញ្ញវត្ថុសំរាប់បង្កើតពង្រីក និង កែលំអមុខរបររបស់កសិករឱ្យបានប្រសើរឡើង ។
  - ផ្តល់ការហ្វឹកហ្វឺនវិជ្ជាជីវៈលើកម្មវិធីផលិតកម្មកសិកម្មដើម្បីឱ្យកសិករចេះរៀបចំយន្តការអនុវត្តគំរោងអភិវឌ្ឍន៍សេដ្ឋកិច្ចបានត្រឹមត្រូវស្របនឹងការបែងចែកនៃការប្រើប្រាស់ ឥណទានតាមគ្រួសារនិមួយៗ ។
  - ជួយផ្តល់ពត៌មាននិងវិធីសាស្ត្រផ្សេងៗ ដូចជា របៀបបង្កើតមុខរបររបៀបផលិតទំនិញនិងការជួញដូរនៅទីផ្សារ ។
  - កាត់បន្ថយការប្រើប្រាស់ឥណទានដែលមានការប្រាក់ខ្ពស់ហួសហេតុពីបណ្តាឈ្មួញនានា
  - បង្កើនការងារជូនប្រជាជនតាមជនបទដើម្បីកាត់បន្ថយការចាកចេញពីស្រុកភូមិកំណើតស្វែងរក ការងារនៅតាមទីផ្សារ ។
  - បង្កើនផលិតផលក្នុងស្រុកតាមរយៈការផ្តល់សេវាហិរញ្ញវត្ថុក្នុងដំណើរវិវត្តន៍និងបែងចែកផលិតផលកសិកម្ម ។
  - ពង្រឹងសាមគ្គីភាព និងអនុវត្តន៍ច្បាប់បានប្រសើរឡើងក្នុងចំណោមសមាជិកសហកមន៍ ។

➢ ឥណទានទោល:

គឺផ្តល់ជូនអតិថិជនឯកត្តជនហើយតំរូវឱ្យមានទ្រព្យសម្បត្តិដាក់ធានា ដើម្បីការពារនៅពេលមាន ការខកខានមិនបានសងបំណុលត្រឡប់វិញ ។ឥណទានប្រភេទនេះត្រូវបានផ្តល់សំរាប់មុខរបរជំនួញខ្នាតតូចនិងមធ្យម ។ចំពោះរយៈ កាលនៃការខ្ចីមិនលើសពីមួយឆ្នាំដែលមានទំហំឥណទានជាមធ្យម ពី១០០ទៅ៥០០ដុល្លារអាមេរិក (ករណីអង្គការអេស៊ីលីដាពី៤០០០ទៅ៧០០០០ដុល្លារអាមេរិក) និងអត្រាការប្រាក់អាស្រ័យលើគោលនយោបាយរបស់ប្រតិបត្តិករនីមួយៗ ។

➢ ឥណទានក្រុម:

ប្រភេទឥណទាននេះគឺសំរាប់ប្រជាពលរដ្ឋក្រីក្រដែលមានមុខរបរជំនួញតូចតាចរឺមុខរបរកសិកម្ម ដោយមិនតំរូវឱ្យមានទ្រព្យសម្បត្តិដាក់ធានាទេ ប៉ុន្តែអតិថិជនត្រូវចងក្រងជាក្រុមពី៣នាក់ទៅ ១០នាក់សំរាប់ធានាគ្នាទៅវិញទៅមកនៃសមាជិកទាំងអស់នៅក្នុងក្រុមនិងត្រូវបានចេញសងជួស រីឯទំហំឥណទានក្រុមជាមធ្យមចាប់ពី២០ទៅ១០០ដុល្លារអាមេរិក ។ អត្រាការប្រាក់ចន្លោះពី ៣% ទៅ ៥% ក្នុងមួយខែអាស្រ័យលើគោលនយោបាយរបស់ប្រតិបត្តិករ និមួយៗ ។

➢ សញ្ច័យ រឺ ការសន្សំសំចៃ:

ប្រតិបត្តិករឥណទានភាគច្រើនមានកម្មវិធីសញ្ច័យដែលតំរូវឱ្យសមាជិកសន្សំមុនទើបអាចទទួល ការខ្ចីឥណទានមកវិញបាន ។ការប្រាក់លើប្រាក់បញ្ញើចន្លោះពី១%ទៅ៣% ក្នុងមួយខែ ។ការប្រាក់ សន្សំនេះត្រូវបានប្រើដើម្បីយកទៅបង្វិលឱ្យសមាជិកខ្ចីវិញទៅតាមការព្រមព្រៀងក្នុងចំណោម សមាជិកទាំងអស់ដែលបានដាក់សញ្ច័យ ។ទំហំទឹកប្រាក់សន្សំមានពី១០០០ទៅ២០០០រៀលរឺអាចលើសពីនេះតាមស្ម័គ្រចិត្តសំរាប់សមាជិក ។សេវាសញ្ច័យនេះត្រូវបានពង្រឹងក្នុងក្របខ័ណ្ឌការ បង្កើតប្រព័ន្ធសន្សំប្រាក់នៃសង្គហៈឥណទាន (Credit Mutual) រឺឥណទានសហជីព (Credit Union) ។

❖ សេវាមីក្រូហិរញ្ញវត្ថុផ្សេងៗ

➢ ការងារហ្វឹកហ្វឺន:

គោលបំណងនៃការហ្វឹកហ្វឺនក្នុងវិស័យនេះគឺដើម្បីកសាងសមត្ថភាពសល់គ្រប់អតិថិជនដើម្បីបង្កើតមុខរបរនិងជាពិសេសផ្តល់គំនិតក្នុងការប្រើប្រាស់ទុនឱ្យបានត្រឹមត្រូវមានប្រសិទ្ធិភាពចេះ ត្រួតពិនិត្យមើលស្ថានភាពហិរញ្ញវត្ថុនិងមុខរបរប្រចាំថ្ងៃរបស់ខ្លួន ។កម្មវិធីហ្វឹកហ្វឺននេះបានរៀបចំ ឡើងស្របទៅតាមតំរូវការនិងទំហំអាជីវកម្ម ។

➢ ការចុះតាមដាននិងផ្តល់យោបល់:

- ជួយអតិថិជនក្នុងការប្រើប្រាស់ទុនដែលបានខ្ចីពីប្រតិបត្តិករមីក្រូហិរញ្ញវត្ថុឱ្យមានប្រសិទ្ធិភាព។
- ជួយដោះស្រាយនិងផ្តល់យោបល់ដល់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ អំពីការរៀបចំដំណើរការសកម្មភាពការងារ ។ចុះជួបពិគ្រោះតាមដានការអនុវត្តរបស់អតិថិជនប្រចាំដើម្បីជួយផ្តល់ជាយោបល់ ។

- វាយតម្លៃទៅលើការប្រើប្រាស់ប្រាក់កម្ចីសំរាប់បង្កើនចំណូលនិងការកែលំអកំរិតជីវភាពរស់នៅអោយកាន់តែប្រសើរឡើងជាលំដាប់ ។

ការអនុវត្តមីក្រូហិរញ្ញវត្ថុជនបទជាការងារមួយដ៏លំបាកនិងស្មុគ្រស្មាញ ព្រោះប្រតិបត្តិការឥណទានជនបទ ពុំអាចទាញយកបាននូវប្រាក់ចំនេញហួសហេតុពីប្រតិបត្តិករបានទេ ដោយហេតុថាកម្ចីខ្លះមានភាពប្រថុយ ប្រថានខ្ពស់និងគ្មានទាំងការដាក់វត្ថុញ្ញារបស់អ្នកខ្ចីទៀតផង។ម្យ៉ាងទៀតចំណាយប្រតិបត្តិការឥណទានខ្ពស់ ពេក ( រហូតដល់ទៅ ៦០% នៃរំណាយសរុប) និង ដោយហេតុថាកម្ពុជាមុនមានធនជានមនុស្ស និង ហេដ្ឋា រចនាសម្ព័ន្ធផ្លូវគមនាគមន៍គ្រប់គ្រាន់ ។ល ។ ទាំងនេះជាកត្តាដែលធ្វើឱ្យអត្រានៃការប្រាក់មានកំរិតខ្ពស់រហូត ដល់២២ ទៅ ៤៨% ក្នុងមួយឆ្នាំ ( ផ្ទុយទៅវិញអត្រាការប្រាក់ ដែលធ្វើឡើងដោយធនាគារពាណិជ្ជឯកជន អត្រាការប្រាក់កម្ចី គឺត្រឹមតែ១៨% ក្នុងមួយឆ្នាំប៉ុណ្ណោះ) ។ ក្នុងករណីចំណូលនៅតែមានកំរិតទាបជាង ចំណាយនោះប្រតិបត្តិករចាំបាច់ត្រូវតែបង្វិលទុនមកដាក់បង្គ្រប់វិញ ។ ដោយសារកត្តាទាំងនេះហើយទើប យើងពុំឃើញមានធនាគារពាណិជ្ជកម្មឯកជនណាមួយ ក្រៅពីធនាគារកាណាឌីយ៉ា ដែលបានចូលរួមផ្តល់ សេវាកម្មឥណទានជនបទនេះ ។

ប្រតិបត្តិការភាគច្រើនពឹងផ្អែកយ៉ាងខ្លាំងទៅលើជំនួយបរទេសទាំងស្រុងសំរាប់ធ្វើសកម្មភាពឥណទា-ន។ បើយោងទៅលើឥទ្ធិពលជំនួយបរទេសទាំងនេះយើងពិតជាសំគាល់ និង បារម្ភថាៈលទ្ធភាពមិនអាចធ្វើទៅ បានសំរាប់ចិរភាពឥណទានជនបទ (Continuation growth of rural credit) ដោយម្យ៉ាងជំនួយតែង មានកំនត់ទាំងទៅលើបរិមាណសាច់ប្រាក់ និង ពេលវេលា ។ ដូច្នេះ មានតែសញ្ជ័យនៅក្នុងស្រុកតែមួយគត់ ដែលជាប្រភពទុនដ៏ចំបង ។បញ្ហានេះរាជរដ្ឋាភិបាលកំពុងជំរុញសញ្ជ័យក្នុងស្រុកនិងបានកំណត់យ៉ាងច្បាស់នូវ គោលនយោបាយជំរុញលើទឹកចិត្តដល់ប្រតិបត្តករទាំងអស់ធ្វើការកេណ្ឌមូលសញ្ជ័យ ដែលជាការជោនាក្នុង វិស័យឥណទានជនបទនេះ ។ប្រតិបត្តិករមួយចំនួនបានយកចិត្តទុកដាក់លើការប្រមូលប្រាក់សន្សំពីសមាជិករបស់ខ្លួនដែលមានចំនួន ១៣៩.៥៦០ នាក់ និងមានប្រាក់ប្រមាណ១.៤៣៣.៥៣៥ ដុល្លាអាមេរិក ។

ស្ថាប័នភាវូបនីយកម្មនៃស្ថាប័នមីក្រូហិរញ្ញវត្ថុ គឺជាកាតព្វកិច្ចដ៏សំខាន់បំផុតដែលតំរូវអោយប្រតិបត្តិករឥណទានមួយចំនួនដែលមានលទ្ធភាពអាចប្រែក្លាយខ្លួនជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយមានការទទួលស្គាល់ និង មានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាដើម្បីពួកគេអាចទទួលទុនពីបណ្តាស្ថាប័នហិរញ្ញវត្ថុជាតិនិងអន្តរជាតិ ទាំងឡាយជាពិសេសពីធនាគារអភិវឌ្ឍន៍ជនបទ។ ទាំងនេះជាសេចក្តីត្រូវការមួយសំរាប់ការអភិវឌ្ឍន៏ សេដ្ឋកិច្ច ប្រកបដោយជោគជ័យនិងមាននិរន្តភាពទៅថ្ងៃអនាគត ។

ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុក៏ដូចជាធនាគារអភិវឌ្ឍន៍ជនបទនៅពេលជួបបញ្ហាលំបាកមួយចំនួនក្នុងការអនុវត្ត សេវា ឥណទានជនបទទាំងនេះគឺៈ

១. ការផ្តល់ឥណទាន លើវិស័យកសិកម្មមានហានិភ័យខ្ពស់

២. ចំនាយលើប្រតិបត្តិការនិងរដ្ឋបាលក្នុងការផ្តល់និងគ្រប់គ្រងឥណទានមានកំរិតខ្ពស់នៅឡើយ

៣. ការខ្វះខាតផ្នែកធនធានមនុស្សលើវិស័យធនាគារ និងមីក្រូឥណទាន

៤. ការខ្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសនៅតាមជនបទ

៥. ខ្វះការចូលរួម ពីធនាគារពាណិជ្ជ ក្នុងវិស័យនេះ ។ល ។

## ៥. ផែនការសកម្មភាពជាយុទ្ធសាស្រ្ត

ដោយមានការចូលរួមយ៉ាងសកម្មពីធនាគារជាតិនៃកម្ពុជា ធនាគារអភិវឌ្ឍន៍ជនបទ ក៏ដូចជាម្ចាស់ជំនួយផង ដែរ តាមរយៈប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលការណ៍ និង ផែនការ សកម្មភាព ជាយុទ្ធសាស្រ្តមួយចំនួន ដែលរួមមានដូចខាងក្រោមៈ

១. ពង្រីកសេវាឥណទាន ឱ្យមានកម្ចីរយៈពេលមធ្យម និងវែងថែមទៀត

២. កាត់បន្ថយអត្រាការប្រាក់

៣. ជំរុញលើកទឹកចិត្តការប្រកួតប្រជែងឱ្យបានទូលាយក្នុងចំណោមប្រតិបត្តិករមីក្រូហិរញ្ញវត្ថុទាំងអស់ ដើម្បីកាត់បន្ថយការប្រាក់និងអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព និង លក្ខណៈនិរន្តភាព។

៤. ផ្សារភ្ជាប់កសិផលទៅនឹងទីផ្សារក្នុងស្រុក និងក្រៅស្រុកតាមរយៈការផ្តល់ឥណទាន ទ្រទ្រង់បណ្តាញអាជីវកម្ម និងកែច្នៃកសិផល ។

៥. ផ្តល់ការហ្វឹកហ្វឺនផ្នែកបច្ចេកទេសដល់ ប្រតិបត្តិករដើម្បីអនុវត្តអោយមានប្រសិទ្ធភាព

៦. ជំរុញយន្តការប្រមូលសញ្ច័យក្នុងស្រុក ។

៧. បន្តការទាក់ទាញប្រភពហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសពីក្នុងនិងក្រៅប្រទេស និង

៨. ជំរុញផ្ទេរអំណាចមូលដ្ឋានឱ្យដើរតួនាទីជាអ្នកសំរបសំរួលក្នុងការសហការនិងសំរប សំរួលការងារ ជាមួយប្រតិបត្តិករមីក្រូហិរញ្ញវត្ថុនានា ។

ការអនុវត្តនូវប្រព័ន្ធច្បាប់ដ៏សមស្របមួយគឺជានាដល់សកម្មភាពមីក្រូហិរញ្ញវត្ថុដែលបានប្រព្រឹត្តទៅក្នុងលក្ខណៈនិរន្តភាព។ រាជរដ្ឋាភិបាលត្រូវជុំរុញនិងសំរួលការចេញអាជ្ញាប័ណ្ណដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ។

# ជំពូក ៧ ឥណទានក្នុងសេដ្ឋកិច្ច

## ៧.១ គោលដៅនៃការសិក្សា

ក្រោយពីសិក្សានូវមេរៀននេះ អ្នកនឹងអាចដឹងនូវៈ

- កំណត់ឱ្យច្បាស់នូវលក្ខខ័ណ្ឌឥណទាន និង ពន្យល់អំពីសារៈសំខាន់លើទិដ្ឋភាពនៃប្រតិបត្តិការឥណទាន
- ពន្យល់អំពីអ្វីដែលហៅថាប្រភេទខុសគ្នានៃឥណទាន នឹងអាចចាត់ជាក្រុមឥណទានបាន
- ពន្យល់ពីតួនាទីឥណទាន និង សារៈសំខាន់របស់ឥណទានក្នុងសេដ្ឋកិច្ច
- ពិភាក្សាអំពីខួបអាជីវកម្ម និងការប្រឹងប្រែងរបស់រដ្ឋាភិបាលសហព័ន្ធដើម្បីឱ្យផ្នែកសេដ្ឋកិច្ចមានស្ថេរភាព
- ពណ៌នាអំពី អ្វីជាឥណទានសំរាប់អ្នកប្រើប្រាស់ និង ឥណទានអាជីវកម្ម
- ពន្យល់អំពីគ្រោះថ្នាក់ដែលកើតឡើងពីអ្នកប្រើប្រាស់
- ពន្យល់ លើកឧទាហរណ៍ សេចក្តីត្រូវការ នៃការអប់រំដល់ការប្រើប្រាស់ឥណទាន និងការពង្រីកការ ប្រើប្រាស់ឥណទាន

យើងរស់នៅសព្វថ្ងៃក្នុងពិភពឥណទាន ។ ជារៀងរាល់ថ្ងៃ ជារៀងរាល់ពេល យើងបានពាក់ព័ន្ធច្រើន ឡើងៗ ក្នុងសេចក្តីរំពឹងនៃពិភពឥណទានទាំងនេះ ។ បទពិសោធន៍របស់យើងរាល់ថ្ងៃកំពុងបង្កើនការប្រើប្រាស់ឥណទាន ដល់អ្នកប្រើប្រាស់ អ្នកជំនួញ និង អ្នកបោះឆ្នោត ។ ដូចនេះយើងទាំងអស់គ្នាគួរយល់អំពី អ្វីជាឥណទាន ហើយគួរប្រើឥណទានយ៉ាងណា និង ច្បាប់ដាក់ជានិយ័តកម្មក្នុងការប្រើឥណទាន ។

នៅក្នុងប្រវត្តិសាស្ត្រ ឥណទានបានបែងចែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចអាមេរិក ហើយបានធ្វើអោយ ប្រជាជនអាមេរិកមានជីវភាពរស់នៅកំរិតខ្ពស់។ ឥណទានជាអ្នកចិញ្ចឹមអាជីវកម្ម ដោយផ្តល់នូវមធ្យោបាយក្នុងការចាប់ផ្តើមអាជីវកម្ម ថែទាំ និងផ្ទេរទៅដោយសហគ្រាសអាជីវកម្ម ។ អាជីវកម្មជាច្រើនបានប្រើប្រាស់ឥណទាន ដើម្បីបន្តការលក់ ដូចជា អ្នកផលិត អ្នកចែកចាយ និងឈ្មួញលក់រាយ។ លក្ខខណ្ឌឥណទានបានផ្តល់ពេលវេលា ជាច្រើនដល់ការលក់សារពើភ័ណ្ឌមុនសំណងត្រូវសងតាមការគ្រោងទុក ។ អាជីវកម្មជាច្រើនបានទទួលផល ប្រយោជន៍ពីផែនការឥណទានដែលផ្តល់ទៅអ្នកប្រើប្រាស់ ហើយជួយជំរុញការលក់ និងបើកទីផ្សារថ្មីដល់អ្នកប្រើប្រាស់ជាច្រើន។ ការលក់ទាំងនេះបានបង្កើន អោយមានការងារធ្វើ និងជួយដល់ សេដ្ឋកិច្ចអាមេរិករំកិលឆ្ពោះ ទៅមុខជាលំដាប់ ។

អ្នកប្រើប្រាស់ជាជនជាតិអាមេរិកបានកើនស្តង់ដារស់នៅក្នុងកំរិតមានផ្ទះ រថយន្ត និងទំនិញមានដែល មានគុណភាពជាប់បានយូរ ហើយនៅពេលពួកគេគ្មានជំរើសទិញដោយសាច់ប្រាក់ ។ ឥណ

ទានបានជួយ បុគ្គលទាំងឡាយណាដែលត្រូវការភ្លាមៗ និងផ្តល់ឱ្យនូវមធ្យោបាយគ្រប់គ្រងហិរញ្ញវត្ថុដល់ពួកគេទៀតផង ។ មាននិស្សិតមហាវិទ្យាល័យជាច្រើនបានប្រើកម្មវិធីកំចី ដើម្បីបង់ថ្លៃសាលា ។

រដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ បានខិតខំពង្រីកការប្រើឥណទានទៅលើកម្មវិធីហិរញ្ញវត្ថុរដ្ឋាភិបាល និងសំរបសំរួលដូចជា សាលារៀនថ្មីៗ ពង្រីកកម្មវិធីសុខភាព និងកម្មវិធីសុខមាលភាព សាងសង់ផ្លូវធំ អន្តរជាតិជាច្រើន ទាំងនេះជាឧទាហរណ៍ដែលរដ្ឋាភិបាលត្រូវចំណាយ។ រដ្ឋាភិបាលប្រចាំតំបន់រដ្ឋ រដ្ឋាភិបាលសហព័ន្ធជាទូទៅប្រើប្រាស់ធនប័ណ្ណបំណុល (debt securities) ដើម្បីខ្ចីមូលនិធិនៅពេលចំណូលពីពន្ធមិនគ្រប់គ្រាន់ ។

លក្ខណៈឆ្ពោះទៅប្រើឥណទានជាបន្តបន្ទាប់ បានផ្លាស់ប្តូរវិនាដកម្មជាច្រើន។ មិនជាយូរប៉ុន្មានមានអ្នកប្រើប្រាស់ឥណទានជាច្រើនមិនអាចទិញបាន ដោយសារពួកគេគ្មានប្រាក់ ប៉ុន្តែថ្ងៃនេះ មានបុគ្គល និងអាជីវកម្មជាច្រើនបានស្ថិតនៅក្នុងរបាំងកម្មវិធីឥណទាន ហើយក៏អាចទិញទំនិញ និងសេវាយ៉ាង រហ័សដោយប្រើលទ្ធភាពឥណទាន ។ ក្នុងករណីរដ្ឋាភិបាលជួបឱនភាព នេះជាឱកាសរបស់រដ្ឋាភិបាល ដែលត្រូវទទួលយកឥណទានថ្មី និងត្រៀមខ្ចីជាស្រេចដើម្បីផ្ទៀងផ្ទាត់ជាមួយចំណូលនៅពេលអនាគត ។

ការប្រើប្រាស់ឥណទាន បានប្រែក្លាយជាផ្នែកមួយយ៉ាងសំខាន់សំរាប់សេដ្ឋកិច្ចអាមេរិក ។ វាជាប្រេង រំអិលសំរាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច ។ ការប្រើឥណទាន គឺមិនអាចជៀសផុតពីគ្រោះថ្នាក់ ទោះបីយ៉ាងណា បុគ្គលទាំងឡាយដែលប៉ុនប៉ងប្រើកម្មវិធីឥណទានជានិច្ចជាកាលនោះ និងរកឃើញថាកំហុសឥណទាន អាចនាំទៅរកការក្ស័យធន ស្ថានភាពប្តីប្រពន្ធ (Marital problem) កង្វល់ (Stress) និងបញ្ហាផ្សេងៗទៀត ។ ចំណែកក្នុងអាជីវកម្មបានរកឃើញថា ការអនុញ្ញតិអោយទិញដោយមិនបានទទួលប្រាក់ ជាលទ្ធផល គឺផលវិបាកហិរញ្ញវត្ថុនៅថ្ងៃក្រោយ ។ ហេតុផលទាំងនេះយើងត្រូវឆ្លៀតឱកាសរកផល ប្រយោជន៍ពីគុណសម្បត្តិឥណទាន ប៉ុន្តែត្រូវជៀសវាងអន្ទាក់គ្រោះថ្នាក់ដែលកើតមានតាមរយៈមិនដឹង មុន និងហេតុការដោយថាហេតុពាក់ព័ន្ធឥណទាន ។

## ១. និយមន័យឥណទាន (Definitions of Credit)

- ឥណទានជាមធ្យោបាយដោះដូរ ជាមួយនឹងការទទួលយកដោយមានដែនកំណត់ ។
- ឥណទានជាមធ្យោបាយដោះដូរដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការផ្ទេរតំលៃពីអ្នកទិញទៅអ្នកលក់ ។ ប៉ុន្តែ មិនងាយស្រួលសំរាប់នរណាក៏បាននោះទេ ។
- មន្ត្រីឥណទានត្រូវធ្វើការស៊ើបអង្កេត និងបញ្ចូលការអនុវត្ត ដោយដៅការប៉ាន់ស្មានហានិភ័យអតិថិជនមុន នឹងទទួលយកការសន្យាសងពីអតិថិជន ។
- ឥណទានផ្តល់សិទ្ធពិសេស រកចំណូល និង ការពារអ្នកមានបំណងប្រើសណ្ឋានដោះដូរដោយឥណទាន។

## ២. ប្រតិបត្តិការឥណទាន (The Credit Transactions)

- ដំណើរការ ចាប់ផ្តើមពីអ្នកលក់បានធ្វើ ឬ ផលិតទំនិញ សេវាកម្ម ឬ មានមូលនិធិ (លុយ) ដែល អាចទិញបាន ។
- អ្នកទិញជាអ្នកត្រួតពិនិត្យលក្ខខ័ណ្ឌផ្តល់ទំនិញពីអ្នកលក់ និងធ្វើសេចក្តីសំរេច ដើម្បីបំពេញការ ដោះដូរ ឬ ប្រតិបត្តិការ ។
- អ្នកទិញផ្តល់នូវមធ្យោបាយដោះដូរ (Medium of exchange) ( ដូចជា របស់របរអ្វីដែល មានតំលៃដែលអ្នកលក់អាចទទួលយកបានក្នុងការដោះដូរទៅវិញទៅមកនូវទំនិញនិងសេវា។
- អ្នកទិញអាចជំនួសឥណទានជំនួសការផ្តល់ប្រាក់សុទ្ធ ជាមួយការសន្យាសងតាមលក្ខខ័ណ្ឌពេល អនាគត ។
- ឥណទាន ឬ ការសន្យាសងនឹងកំណត់ទទួលយកនៅពេលអ្នកលក់សំរេចថា ការសន្យារបស់អ្នកទិញ មានវត្ថុមានតំលៃពិត និងមានតំលៃអាចទទួលយកបាននៅក្នុងការដោះដូរ ។
- បើសិនឥណទានទទួលយកនោះ កិច្ចព្រមព្រៀងរវាងអ្នកលក់និងអ្នកទិញនឹងធ្វើទៅតាមគោលការណ៍សំណងតាមពេល វេលានាអនាគត ។
- ម្យ៉ាងទៀត ពេលប្រតិបត្តិការឥណទានបានព្រមព្រៀង អ្នកលក់ក្លាយជាម្ចាស់បំណុល (Creditor) និងជាភាគីទទួលតំលៃពីការជំពាក់ ឬ ទទួលសំណងនៅក្នុងប្រតិបត្តិការឥណទាន ។ អ្នកទិញក្លាយ ជាកូនបំណុល (Debtor) និងជាភាគីជំពាក់តំលៃ ។
- លក្ខណៈសម្បត្តិដែលគួរទទួលឥណទានបាន (Creditworthiness) គឺជាលទ្ធភាពរបស់ អាជីវកម្ម ឬ អ្នកប្រើប្រាស់បានទទួលទំនិញ និងសេវាកម ឬ លុយ ដោយការសន្យាសងសំណង នៅពេលអនាគត ។

ពេលដែលអាចទិញជឿបាន គឺពឹងផ្អែកលើចំណូលផ្សេងៗរបស់អ្នកស្នើសុំ ភាពជំពាក់បំណុល (Indebtedness) និងបង្ហាញអោយឃើញអំពីការស្ម័គ្រចិត្តសងឥណទានឱ្យអស់តាមការ រៀបចំ ។

## ៣. សមាសភាគនៃដំណើរឥណទាន ( Components of the Credit Process )

មានកត្តាជាច្រើន គួរសំរេចដោយម្ចាស់បំណុល មុននឹងទទួលយកការសន្យារបស់អ្នកស្នើសុំ ដើម្បី សងបំណុលដោយប្រើឥណទានជំនួសប្រាក់សុទ្ធ។ គឺមានតែប្រតិបត្តិការឥណទានមួយគត់ ដែលអាច កំណត់ភារកិច្ចការទទួលខុសត្រូវ ហើយពាក់ព័ន្ធមន្ត្រីគ្រប់គ្រងឥណទាន ។

### ៣.១-ហានិភ័យ (Risk)

- អ្នកទិញ ឬ កូនបំណុល មិនសងនៅក្នុងពេលបញ្ចប់ ។ ដូច្នេះ អ្នកលក់ និងបាត់បង់តំលៃ ទំនិញ សេវា និង មូលនិធិដើមដែលបានផ្ទេរទៅកូនបំណុល ។
- បាត់បង់ពេលវេលា រួមនឹងថ្លៃដើមត្រូវចំណាយបន្ថែមដើម្បីទារបំណុលមកវិញ ។ ក្នុងទិដ្ឋភាពបែបនេះដំណើរការឥណទានត្រូវព្យាយាមអនុវត្តដោយបញ្ចូលចំនួនហានិភ័យទៅ ក្នុងឥណទានរបស់អតិថិជន ។

### ៣.២-ពេលវេលា (Time)

- ក្នុងប្រតិបត្តិការឥណទាន អ្នកលក់ត្រូវរងចាំទទួលការសងត្រឡប់ ។
- ក្នុងកំឡុងពេលនេះអ្នកលក់អាចខាតបង់ចំណូលដែលរកបានពីការវិនិយោគ និងអាចតំរូវខ្ចី មូលនិធិបន្ថែមដើម្បីសងវិក័យប័ត្រផ្ទាល់ខ្លួន ។

### ៣.៣-ការធានា ឬ វត្ថុបញ្ចាំ (Security or Collateral)

- អ្នកលក់ ឬ អ្នកឱ្យខ្ចី ត្រូវការការធានា ឬ វត្ថុបញ្ចាំជាផ្នែកមួយនៃប្រតិបត្តិការឥណទាន ។
- វត្ថុបញ្ចាំជាវត្ថុមានតំលៃដែលអ្នកខ្ចីជាម្ចាស់ ( អ្នកទិញ ) ជាកម្មសិទ្ធិមួយដើម្បីកាត់បន្ថយ ហានិភ័យនៃការបាត់បង់ ។
- កូនបំណុលដាក់កម្មសិទ្ធិផ្ទាល់ខ្លួននេះទៅអ្នកផ្តល់ឥណទាន រួមជាមួយការយល់ព្រមប្រគល់ អោយអ្នកផ្តល់ឥណទាននូវតំលៃដែលមានក្នុងកម្មសិទ្ធដើម្បីធានានូវហេតុការមិនសង ។
- អ្នកគ្រប់គ្រងឥណទាន ឬ អ្នកផ្តល់កំចី នឹងក្លាយជាអ្នកពាក់ព័ន្ធជាមួយតំលៃនៃវត្ថុបញ្ចាំដែល បាន ផ្តល់ដោយកូន បំណុល ។

### ៣.៤-ចំណាយប្រតិបត្តិការ (Operating Expense)

- អ្នកលក់ និងកើនចំណាយបន្ថែមជាច្រើនបន្ទាប់ពីទទួលការសន្យាសងរបស់កូនបំណុល។ ដូច ជា ប្រាក់កំរៃត្រូវចំណាយដល់មន្ត្រីឥណទាន កើនឡើងការចំណាយលើសលើប្រតិបត្តិការ និង ចំណាយបោះពុម្ភក្រដាសបំពេញដែលចាំបាច់កុំព្យូទ័រ និង សំភារៈស្នុគ្រស្មាញដទៃទៀត ចំណាយមួយទៀតមិនអាចជៀងវាងបាន គឺ កំរៃលើផ្នែកច្បាប់ និងចំណាយលើការទារប្រាក់ ។

### ៣.៥-ការទទួលស្គាល់តាមផ្លូវច្បាប់ (Legal Considerations)

- ប្រតិបត្តិការឥណទានជះឥទ្ធិពលដោយច្បាប់ដើម្បីការពារទាំងកូនបំណុលនិងម្ចាស់បំណុល។

- ច្បាប់ទាំងនេះនឹងពន្យល់អំពីវិធីជៀសវាងការផាកពិន័យ និងរាល់ចំណាយថ្លៃដើមបន្ថែមដែលពាក់ព័ន្ធទំនាស់។ ការបញ្ចុះបញ្ចូលតំរូវឱ្យមានដើម្បីឱ្យយល់ច្បាស់អ្នកធ្វើការ និងអ្នកស្នើសុំឥណទានទំនាក់ទំនងប្រតិបត្តិការឥណទានដោយគុណភាព ។
- ច្បាប់នេះនឹងផ្លាស់ប្តូរ ហើយមនុស្សម្នាក់ៗត្រូវទទួលខុសត្រូវត្រួតពិនិត្យលើការផ្លាស់ប្តូរច្បាប់តាម បញ្ញត្តិដើម្បីកែតំរូវនយោបាយឥណទានទៅតាមទំរង់ដែលត្រូវការ ។

### ៣.៦-អតិផរណា (Inflation)

- អតិផរណា ជាទូទៅកើតឡើងពីតំលៃទំនិញ និងសេវាកម្ម ។
- ប្រសិនរយៈពេលសងប្រាក់ពន្យាក្នុងកំឡុងពេលមួយ អំណាចទិញនឹងបាត់បង់ ។
- បើថ្លៃកើនឡើងតំលៃពិតនៃដុល្លានីមួយៗកាន់តែយ៉ាប់យឺន នៅពេលតំរូវការការទិញទំនិញ និងសេវាកាន់តែច្រើនបើសិនអ្នកផ្តល់អោយនរណាម្នាក់ខ្ចី ១ ដុល្លា អត្រាអតិផរណា ៥% នោះលទ្ធផល ១ឆ្នាំក្រោយមកបានទទួលបានតែ ៩៥ សេនប៉ុណ្ណោះ ។

### ៣.៧-បន្ទុកហិរញ្ញវត្ថុ (Finance Charge)

- បន្ទុកហិរញ្ញវត្ថុជាចំនួនបន្ថែម អាចបង់ថែមលើតំលៃដែលកូនបំណុល ឬអ្នកខ្ចីបានទទួល ។
- បន្ទុកហិរញ្ញវត្ថុ នឹងជួយគ្រប់គ្រងចំណាយថ្លៃដើម ដូចដែលបានរៀបរាប់ខាងលើ ការខាតបង់សងមិនតាមគំរោង ចំណាយប្រតិបត្តិការខាតបង់ចំណូលរកបានពីការវិនិយោគ និងកំរៃចំណាយលើច្បាប់ ។
- បើសិនបន្ទុកហិរញ្ញវត្ថុមិនបញ្ជាក់ច្បាស់ គេអាចមិនបញ្ចូលកំរៃទៅក្នុងទំនិញ សេវាកម្មរបស់ក្រុមហ៊ុនឡើយ ។

## ៤. ការចាត់ជាក្រុមឥណទាន classification of Credit

តារាង ៤៖ជួរទីផ្សារ




តារាងទី៣ បង្ហាញអំពីចង្វាក់នៃការនាំផលិតផលតាមរយៈ តំណាក់កាលផលិត និងការបែងចែកផលិតផលទៅអោយអ្នកទិញ និងអ្នកប្រើប្រាស់ចុងក្រោយ នៅជំហាននៃដំណើការនីមួយៗ ។

- អាជីវកម្មនឹងទិញទំនិញ ហើយបង្កើនតំលៃទំនិញ បន្ទាប់មកលក់ទៅអាជីវកម្មបន្ទាប់នៅក្នុងជួរទីផ្សារ ។
- ឥណទានអាជីវកម្មរៀបរាប់អំពីទំនាក់ទំនងឥណទាន ពាក់ព័ន្ធការទិញទំនិញសំរាប់លក់ជាថ្មី ឬ ការផ្តល់មូលនិធិ ដើម្បីប្រតិបត្តិរួមជាមួយការប្រើប្រាស់ឥណទានជាមធ្យោបាយដោះដូរ ។
- អ្នកចែកចាយអាចទិញទំនិញបរិមាណច្រើនពីអ្នកផលិតផ្សេងៗជាច្រើនដែលពាក់ព័ន្ធ និងចែកចាយផលិតផលទៅហាងលក់រាយដែលពាក់ព័ន្ធ ។
- អ្នកចែកចាយ និងអាជីវកម្ម អាចក្លាយជាម្ចាស់បំណុល និងកូនបំណុលដោយសារនាំទំនិញតាមរយៈជួរទីផ្សារ។ ការចាត់ជាក្រុមឥណទាន អាស្រ័យលើគោលបំណងឥណទាន និង វិធីសាស្ត្រសំណង ។

## ៤.១-ឥណទានឯកជន (Private Credit)

ឥណទានសាធារណៈគឺជាឥណទានដោយបុគ្គល ឬអាជីវកម្ម ។

** **ឥណទានសំរាប់អ្នកប្រើប្រាស់** (Consumer Credit)

អ្នកប្រើប្រាស់ចង់បាន ឬត្រូវការទិញទំនិញគ្រប់ប្រភេទជាមួយការសន្យាសងដោយផ្តល់ចំណូល របស់គាត់នាអនាគត ។ ឧទាហរណ៍ថ្លៃទឹក ភ្លើង រថយន្ត ផ្ទះ សេវាកម្ម និងមុខទំនិញផ្សេងទៀត ដែលត្រូវការ ។

**(១) ឥណទានរាយ (Retail Credit)**

ឥណទានរាយជាប្រភេទឥណទានមួយដែលអ្នកប្រើប្រាស់ទិញទំនិញសំរេច និងសេវាកម្មដោយ ផ្ទាល់ពីអ្នកលក់ ដោយប្រើឥណទានវិល (Revolving credit) កិច្ចសន្យាសងរំលស់ ឬ ឥណទានសេវា។

(i) **ឥណទានវិល (Revolving Credit)**

ឥណទានវិល តែងបានហៅថា ឥណទានគ្មានកំណត់ open-end credit ឬ ជំរើស-លក្ខខ័ណ្ឌឥណទាន (Option-terms): គឺជាការព្រមព្រៀងឥណទានដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទិញទំនិញផ្សេងៗដោយប្រើ ឥណទានរហូតដល់ចំនួន អតិបរិមាមួយបានកំណត់ ( ឧទា Credit Cards) ។

(ii) **ឥណទានសងរំលស់រាយឬឥណទាន closed-end (Retail Installment Credit or closed-end credit)**

ការទិញទំនិញមានទ្រង់ទ្រាយធំ មានទំនិញជាច្រើន ហើយទំនិញដែលទិញជាសេរីថេរ (Series of fixed) សំណងទៀងទាត់រយៈពេលវែងកំណត់តាមពេលវេលា។ ជាទូទៅកិច្ចសន្យាធ្វើមួយម្តងៗ លើទំនិញដែលបានទិញជាមួយសំណង បន្ទុកហិរញ្ញវត្ថុ និងលក្ខខ័ណ្ឌកិច្ចព្រមព្រៀងសំរាប់បញ្ជាក់ គោលការណ៍មិនសង ។

(iii) **ឥណទានសេវា (Service Credit)**

លទ្ធផលបានមកពីអ្នកផ្តល់សេវាយល់ព្រមផ្តល់ ហើយរងចាំសំណងពីអតិថិជន ។ ដូចជា វិជ្ជបណ្ឌិត មន្ទីរពេទ្យ ។ គ្មានកិច្ចសន្យាជាផ្លូវការ និងសំណងត្រូវសងតាមចំនួនក្នុងវិក័យប័ត្រ ។

(២) **ឥណទានសាច់ប្រាក់ (Cash Credit)**

ជាការរៀបចំមួយ ត្រង់ថាអ្នកខ្ចីទទួលមូលនិធិពីអ្នកផ្តល់កំចី ហើយដោះដូរជាមួយកិច្ចព្រមព្រៀង សងមូលនិធិនៅពេលក្រោយ ជាទូទៅមានការប្រាក់ ឬបន្ទុកហិរញ្ញវត្ថុ ។ មូលនិធិដែលបានខ្ចីដោយ អតិថិជនអាចប្រើសំរាប់គោលបំណងផ្សេងៗដូចជា វិស្សមកាល អាពាហ៍ពិពាហ៍ ការបន្ទាន់ និងការទិញ ចំបងដទៃទៀត ។

(i) **កំចីសងរំលស់ (Installment Credit)**

ជាកំចីរៀបចំឡើង ជាសេរីនៃថេរ សំណងទៀងទាត់ធ្វើដោយអ្នកខ្ចី សងមូលនិធិតាមពេលវេលាកំណត់នាពេលអនាគត ( កំចីរថយន្ត កំចីសំរាប់និស្សិត ) ។

(ii) **កំចីសងតែមួយដង ឬលិខិតកំចី (Single-Payment Loans or not loan)**

ជាទូទៅកំចីមានរយៈពេលខ្លី ហើយមូលនិធិនេះជាបុរេប្រទានមូលនិធិ មានរយៈពេលមួយឆ្នាំ ឬតិចជាង រួមជាមួយកិច្ចព្រមព្រៀង សងមូលនិធិមកវិញតែមួយដងនៅពេលបញ្ចប់វេលា ។

(iii) **ឥណទានអចលនទ្រព្យ (Real Estate Credit)**

- មូលនិធិដែលផ្តល់ឱ្យអ្នកខ្ចីនូវកំចី ដោយប្រើអចលនទ្រពជានា ឬ ដាក់បញ្ចាំសំរាប់កំចី ។
- មូលនិធិខ្ចីនេះដើម្បីទិញទំនិញ ជួសជុលផ្ទះ ឬ យកទៅប្រើលើបំណងផ្សេងៗ អ្នកខ្ចីពាក់ព័ន្ធរបស់បញ្ចាំដែល ហៅថាកំចី ( និក្ខេប ) (mortgage loan) ជាអចលនទ្រព្យជានា បំណុលដើម្បីទិញផ្ទះសំរាប់គ្រួសារ ។ ។
- មានកំចីនិក្ខេបផ្សេងទៀត មូលនិធិបានប្រើក្នុងបំណងៈ ទិញរថយន្ត ការសិក្សានៅវិទ្យាល័យ ឬ រៀបចំជួសជុល ផ្ទះ ឱ្យប្រសើរ ។

** **ឥណទានអាជីវកម្ម (Business Credit)**

អ្នកផ្គត់ផ្គង់ អ្នកផលិត អ្នកលក់ និងរោងចក្រផលិត ត្រូវការវត្ថុធាតុដើម និងសារពើភ័ណ្ឌ ដើម្បីនាំទៅសហគ្រាសរបស់ពួកគេ ។ ពីព្រោះ ពេលវេលាតែងពន្យាពេល រវាងផលិតកម្ម និងការនាំមូលនិធិពី ការលក់ដូរច្នេះឥណទាន តំរូវឱ្យមាន ។

**ក. ឥណទានទំនិញសំរាប់លក់ (Merchandise Credit)**

ការប្រើទំនាក់ទំនងទិញទំនិញ វត្ថុធាតុដើមនិងសារពើភ័ណ្ឌសំរាប់លក់ជាថ្មី។ជាទូទៅអាជីវកម្ម បានទទួលទំនិញ និងយល់ព្រមសងតាមលក្ខខណ្ឌលក់ផ្សេងៗ ដែលលក្ខខណ្ឌនោះផ្តល់ដោយអ្នកលក់ អនុញ្ញតិអោយអតិថិជនសងតាមថ្ងៃខែឆ្នាំ ពេលក្រោយ ។

**ខ. មូលនិធិហិរញ្ញវត្ថុ (Financial Capital)**

មូលធនហិរញ្ញវត្ថុ គឺជាលុយដែលត្រូវការចាំបាច់សំរាប់ចាប់ផ្តើមដំណើរការ ថែទាំ និងប្រតិបត្តិអាជីវកម្ម ។ មូលនិធិដែលត្រូវការដើរសំរាប់ៈ ប្រាក់ខែ ទីផ្សារ ថ្លៃដំណើរការអាជីវកម្ម និងចំណាយ ផ្សេងៗដែលត្រូវចំណាយ ។

### ៤.២-ឥណទានសាធារណៈ (Public Credit)

ពាក់ព័ន្ធរដ្ឋាភិបាលខ្ចីលុយ នៅពេលចំណូលពន្ធមិនគ្រប់គ្រាន់ ដើម្បីសងលើកម្មវិធី និងការសន្យា សងមូលនិធិទៅឱ្យអ្នកវិនិយោគជាមួយការប្រាក់នៅពេលអនាគត ។

## ៥. តួនាទីឥណទាននៅក្នុងសេដ្ឋកិច្ច (The Role of Credit in the Economy)

- ឥណទានក្លាយជាផ្នែកមួយដែលមិនអាចជៀសផុតនៅក្នុងការស់នៅរាល់ថ្ងៃ។ វាអាចប្រើបាន ទាំងល្អ ឬ អាក្រក់ អាស្រ័យលើហេតុផលដែលត្រូវការ និង លទ្ធភាពអ្នកខ្ចីសងត្រឡប់តាម ពេល វេលាកំណត់ ។

ឥណទានអាជីវកម្ម ឧទាហរណ៍ តាមការពិចារណាជាឥណទានទូទាត់ដោយខ្លួនឯង (self-liquidating credit) វគ្គដំបូងចាប់ផ្តើមពី បំណងពាក់ព័ន្ធជាមួយការទិញទំនិញ និង សេវាកម្ម រហូតដល់លក់ជាថ្មី ហើយមធ្យោបាយអាចផ្តល់សំណងដោយស្វ័យប្រវត្តិគឺនៅពេលទំនិញបាន លក់អស់ចុងក្រោយ

### ៥.១- អ្វីទៅជាឥណទានសំរាប់អ្នកប្រើប្រាស់ (What Credit Does for Consumers)

**ក. កើតឡើងស្តង់ដារស់នៅ (Raise Standard of Living)**

ជាទូទៅអ្នកប្រើប្រាស់ទទួលផលប្រយោជន៍ពីការប្រើប្រាស់ឥណទាន (ប្រើចំណូលអនាគត សំរាប់ សងទំនិញ និងសេវាកម្មដែលត្រូវការ) ។ ការកើនឡើង ស្តង់ដារស់នៅនេះ ដោយផ្អែកលើ លទ្ធភាពរក ចំណូល ឬមូលនិធិនៅពេល អនាគត ។

**ខ. ដោះស្រាយពេលមានអាសន្ន (Handle Emergencies)**

ឥណទានពាក់ព័ន្ធនឹងភាពអាសន្ន និងវិបត្តិ នឹងត្រូវការប្រើឥណទាន ។ ដូចជា ជួសជុល រថយន្ត បញ្ហាថ្នាំពេទ្យ និងគ្រោះថ្នាក់ត្រូវការចំណាយជាបន្ទាន់ ។

**គ. ភាពងាយស្រួល (Conveniences)**

អ្នកប្រើប្រាស់អាចធ្វើដំណើរជុំវិញពិភពលោកដោយប្រើប័ណ្ណឥណទាន ដើម្បីបង់ថ្លៃប្រេងសាំង ឧស្ម័ន សណ្ឋាគារ សំបុត្រយន្តហោះ និងវត្ថុអនុស្សាវរីយ៍ជាដើម ។ ប័ណ្ណឥណទានកាត់បន្ថយការយកលុយ យ៉ាងច្រើនតាមខ្លួន ។

### ៥.២-អ្វីទៅជាឥណទានសំរាប់អាជីវកម្ម (What Credit Does for Business)

**ក. ការពង្រីកទីផ្សារ(Expand Markets)**

អាជីវកម្មជាច្រើនទុកចិត្តលើឥណទាន ដើម្បីពង្រីកទីផ្សារ និងស្វែងរកអ្នកប្រើប្រាស់របស់ ពួកគេ។ បើសិនគេផ្តល់នូវជំរើសទិញដោយឥណទានសំរាប់អតិថិជនរបស់ពួកគេ ពេលនោះមនុស្ស ជាច្រើននឹងអាចទិញ ។ អតិថិជនជាច្រើនកង្វះមូលនិធិដើម្បីទូទាត់ជាសាច់ប្រាក់ ឬពេញចិត្តប្រើ ឥណទាន ក្នុងការទិញ ដូច្នេះគេអាចសងនៅពេលក្រោយ ។

**ខ. ការផ្គត់ផ្គង់សារពើភ័ណ្ឌ និងសំភារៈ (Obtain Inventory and Supplies)**

កម្មវិធីឥណទានដែលផ្តល់ដោយអ្នកផ្គត់ផ្គង់ អាជីវកម្មអាចទទួលបានសារពើភ័ណ្ឌ និងទំនិញគ្រប់ ប្រភេទតាមសេចក្តីត្រូវការប្រតិបត្តិអាជីវកម្មរបស់ពួកគេ ។

អាជីវកម្មជាច្រើនអាចពង្រីកការផ្គត់ផលិតផល និងការស្តុកទំនិញជាច្រើន បើសិនគេអាចទិញដោយប្រើឥណទាន ។

**គ. ការទទួលមូលនិធិហិរញ្ញវត្ថុ (Acquire Finance Capital)**

អាជីវកម្មជាច្រើនត្រូវការដើមទុនដើម្បីចាប់ផ្តើមដំណើរការ ថែទាំ និងពង្រីកប្រតិបត្តិការ ។ ទីតាំងថ្មីនិយោជិកថ្មីនិងចំណាយទីផ្សារដែលមិនមានលក្ខណៈងាយស្រួលបើគ្មានកំចីសំរាប់អាជីវកម្ម។

### ៥.៣-អ្វីទៅជាឥណទានសំរាប់សេដ្ឋកិច្ច (What Credit Does for Economy)

យោងលើឥណទានជាប្រេងរំអិលសំរាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ឥណទានបង្កើនចលនាលុយ និងជាមុខព្រួញផលិតកម្មរវាងប្រព័ន្ធសេដ្ឋកិច្ច ។ ឥណទានតែងផ្តល់មធ្យោបាយដើម្បីស្ថេរភាពដល់ កំរិតសកម្មភាពសេដ្ឋកិច្ចដោយធ្វើការកំណត់បន្ទុកអត្រាការប្រាក់ខុសគ្នាៗសំរាប់បំរើឥណទាន ។

**ក. ការពង្រឹងស្ថេរភាពនីយកម្មសេដ្ឋកិច្ច (Economic Stabilization Efforts)**

ខួបអាជីវកម្ម យោងលើភាពប្រែប្រួល ឡើង និង ចុះ នៅក្នុងកំរិតនៃចំណាយសរុប និងសកម្មភាពផលិតកម្ម ដែលកើតឡើងរវាងប្រព័ន្ធសេដ្ឋកិច្ចរបស់យើង ។ វាមិនងាយស្រួលដើម្បីទស្សន៍ទាយអោយបានទៀងទាត់ អំពីទំហំ ឬ ថេរៈវេលា នៃសកម្មភាពសេដ្ឋកិច្ចដែលប្រែប្រួលនោះទេ ។

កំឡុងពេលដំណើរធ្លាក់ចុះ (Recessions) សកម្មភាពសេដ្ឋកិច្ចបានស្ថិតនៅចំណុចទាប (low point) និងមានបញ្ហាជាច្រើនបានកើតឡើង ជាពិសេសភាពគ្មានការងារធ្វើមានកំរិតខ្ពស់ និង អាជីវកម្មធ្លាក់ចុះ ។

- នៅពេលសេដ្ឋកិច្ចមានដំណើរធ្លាក់ចុះដូច្នេះ អ្នកសេដ្ឋកិច្ចជាច្រើនអាចឃើញកំណើនការចំណាយ និងកំណើនសកម្មភាព សេដ្ឋកិច្ច ។
- កំឡុងពេលកំរិតខ្ពស់បំផុត (Peak) កំរិតសកម្មភាពសេដ្ឋកិច្ចកើនខ្ពស់ (High level) អាចនាំទៅរក អតិផរណា (Inflation) ជាទូទៅអ្នកសេដ្ឋកិច្ចជាច្រើនចង់ឱ្យចំណាយកាន់តែតិច ។
- រដ្ឋាភិបាលមានបំណងធ្វើអោយការប្រែប្រួលនៅក្នុងសេដ្ឋកិច្ចប្រសើរឡើងវិញ ដោយប្រើឧបករណ៍បន្សំបញ្ចូលគ្នា ដើម្បីផ្លាស់ប្តូរកំរិតចំណាយ និងសកម្មភាពសេដ្ឋកិច្ច ។ ឧបករណ៍នេះគឺ គោលនយោបាយសារពើពន្ធ (Fiscal policy) ឬ នយោបាយ រូបិយវត្ថុ (Monetary policy)
- រដ្ឋាភិបាលត្រូវត្រួតពិនិត្យសេដ្ឋកិច្ច ដោយត្រួតសេរីនៃសូចនករសេដ្ឋកិច្ច និងព្យាយាមធ្វើអោយការប្រែប្រួល កំរិតចំណាយ ទៅតាមតំរូវការ ។
- កំឡុងដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ច ចំណាយសរុបកើនឡើង និងកំឡុងពេលដំណើរខ្ពស់បំផុតការចំណាយ និងបន្ថយ។ តួនាទីរបស់ឥណទានមានសារៈសំខាន់ជាពិសេសនៅក្នុងគោលនយោបាយរូបិយវត្ថុ បង្កើតគោលដៅឱ្យមានឥទ្ធិពលលើការចំណាយ និងធ្វើការត្រួតពិនិត្យអត្រា ការប្រាក់ ។

### (i) គោលនយោបាយសារពើពន្ធ (Fiscal Policy)

- ចាប់ពីចំណាយធំៗទាំងអស់ បើគិតលើការចំណាយសរុបរបស់រដ្ឋាភិបាល គោលនយោបាយនេះ អាចពង្រីកការចំណាយ ឬកាត់បន្ថយការចំណាយដោយផ្ទាល់នៅក្នុងសេដ្ឋកិច្ច ។ម្យ៉ាងទៀត កំឡុងពេលដំណើរធ្លាក់ចុះសេដ្ឋកិច្ច (Recessions) រដ្ឋាភិបាលតែងកាត់បន្ថយពន្ធ និងពង្រីកការចំណាយ ។
- បើសិនចំណូលពីពន្ធទាប បុគ្គលប្រើមូលប្បទានប័ត្របៀវត្សកើនឡើងយ៉ាងខ្លាំង ដោយការដកពន្ធពីចំណូលតិច ។
- នៅពេលពន្ធលើចំណូលទាបប្រជាពលរដ្ឋនឹងចំណាយប្រាក់ចំណូលថ្មីនេះភ្លាម ពេលនោះសេដ្ឋកិច្ច នឹងជះឥទ្ធិពលអាក្រក់ឡើងវិញ ធ្វើអោយសេដ្ឋកិច្ចមានទំនោរទៅរកអតិផរណា ។
- កំឡុងពេលមានទំនោរទៅរកអតិផរណា(Inflationary)ពន្ធនឹងកើនឡើងចំណាយរដ្ឋាភិបាលនឹងថយចុះ ។




រូបភាព ១៣៖ ខួបអាជីវកម្ម

(ii) **នយោបាយរូបិយវត្ថុ (Monetary Policy)**

- នយោបាយរូបិយវត្ថុត្រួតពិនិត្យដោយធនាគាកណ្តាល និងពាក់ព័ន្ធការប្រើឧបករណ៍នយោបាយ ខុសៗគ្នា ដើម្បីពង្រីក ឬ បង្រួមការផ្គត់ផ្គង់រូបិយវត្ថុ និងដើម្បីត្រួតពិនិត្យអត្រាការប្រាក់ ។
- កំឡុងពេលដំណើរធ្លាក់ចុះ (Recession) ពេលនោះចំណាយត្រូវការជាច្រើន ការផ្គត់ផ្គង់រូបិយវត្ថុត្រូវពង្រីក ដើម្បីអោយអត្រាការប្រាក់ទាប ហើយលើកទឹកចិត្តដល់ការចំណាយ ។
- កំឡុងពេលមានទំនោរទៅរកអតិផរណា (Inflationary period) អត្រាការប្រាក់នឹងកើនធ្វើ អោយប៉ះពាល់ខ្លាំងដល់កំរិតចំណាយដែលត្រូវបែងចែកលើថ្លៃធ្វើឱ្យថ្លៃកើនឡើង ។
- អត្រាការប្រាក់ និងការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានត្រួតពិនិត្យដោយប្រើឧបករណ៍៣ជាដំបូង រួមមាន: (១) ផ្លាស់ប្តូរអត្រាអប្បហារ (២) ប្រតិបត្តិការទីផ្សារបើកចំហ (Open-market operations) និង (៣) ផ្លាស់ប្តូរកាតព្វកិច្ចប្រាក់បំរុង (Reserve requirements) ។
  - អត្រាអប្បហារ (Discount rate) គឺជាបន្ទុកការប្រាក់ដែលធនាគារកណ្តាលយកកំរៃកំចី ពីធនាគារពាណិជ្ជ ។
    - នៅពេលអ្នកផ្តល់កំចីបង្កើនអត្រាអប្បហារការប្រាក់នោះធ្វើឱ្យ រថយន្ត ផ្ទះ និងសំណង ផ្សេងៗចាប់ផ្តើម កើនឡើងភ្លាមដែរ ហើយការចំណាយក៏ថយចុះ ។
  - ប្រតិបត្តិការទីផ្សារបើកចំហ (Open-market operations) រួមបញ្ចូលការទិញ និងការលក់ធនប័ណ្ណរបស់រដ្ឋាភិបាលដោយធនាគារកណ្តាល ។ បើសិនធនាគារកណ្តាលមាន បំណងពង្រីកការផ្គត់ផ្គង់រូបិយវត្ថុ ដោយអត្រាការប្រាក់ទាប ធនាគារកណ្តាលនឹងទិញ ធនប័ណ្ណរដ្ឋាភិបាលសាធារណៈ ដូច្នេះ មូលនិធិជ្រៀតចូលក្នុងចរាចរ ។.
    - មានរូបិយវត្ថុជាច្រើននៅក្នុងសេដ្ឋកិច្ច ដែលលទ្ធផលស្ថិតក្នុងអត្រាការប្រាក់ទាប។ ការលក់ធនប័ណ្ណរដ្ឋាភិបាល នឹងកាត់បន្ថយការផ្គត់ផ្គង់រូបិយវត្ថុ ។ ការកាត់បន្ថយ

ការ ផ្គត់ផ្គង់រូបិយវត្ថុ ជាបញ្ហាដល់អត្រាការប្រាក់កើនឡើង និងប៉ះពាល់ដល់ការចំណាយរបស់ អាជីវកម្ម និងអ្នកប្រើប្រាស់ ។

- កាតព្វកិច្ចទុនបំរុង (Reserve requirements) គឺជាមូលធិនិតំកល់ទុកនៅក្នុងស្ថាប័ន ឬតំកល់ទុកជាមួយធនាគារកណ្តាល ។
  - ស្ថាប័នហិរញ្ញវត្ថុត្រូវរក្សាផ្នែកមួយនៃធុនបំរុងដែលតំកល់ និង អាចឱ្យខ្ចីតែចំនួនដែលលើសប៉ុណ្ណោះ (ប្រើវិធីសាស្រ្តដំបូងសំរាប់ការពង្រីកការផ្គត់ផ្គង់រូបិយវត្ថុ) ។
  - កាតព្វកិច្ចធុនបំរុងទាប កំឡុងពេលដំណើរធ្លាក់ចុះនៃសេដ្ឋកិច្ច មធ្យោបាយខ្លាំងមួយ ត្រូវពង្រីក ការផ្គត់ផ្គង់រូបិយវត្ថុ និងអត្រាការប្រាក់ឱ្យទាប ។

## ៦. គ្រោះថ្នាក់នៅក្នុងការប្រើឥណទាន (Dangers in Using Credit)

- ជាក់ស្តែងឥណទានអាចមិនល្អប៉ុន្មានទេនៅពេលប្រើជាចំនោទបញ្ហាជាច្រើនសំរាប់អាជីវកម្ម អ្នកប្រើប្រាស់ និង សហគម ។
- រាល់ភាគីប្រើឥណទានគួរប្រុងប្រយ័ត្ន និងប្រាកដថា ឥណទានដែលកំពុងប្រើសំរាប់តែគោលបំណងផលិតភាព ហើយត្រូវថៃទាំជាមួយការប្រុងប្រយ័ត្ន ។

### ៦.១- គ្រោះថ្នាក់ក្នុងការប្រើឥណទានសំរាប់អ្នកប្រើប្រាស់ (Dangers of Credit Use for consumer)

- អ្នកប្រើប្រាស់អាចប្រើឥណទានមិនបានទូលំទូលាយ និងទទួលមកវិញនូវបទពិសោធន៏មិនល្អ។
- ដោយការប្រើប្រាស់ឥណទានមិនបានល្អនេះ មានអ្នកប្រើប្រាស់មួយចំនួនបានរកឃើញថាមានបញ្ហាជាយថាហេតុមួយ ចំនួនធ្វើឱ្យគេមិនអាចសងមូលនិធិដែលខ្ចី ឬ សងមូលនិធិទៀងទាត់លើ ទំនិញបាន។ ឥណទានជាអន្ទាក់មួយធ្វើឱ្យអ្នកប្រើប្រាស់គ្មានផ្លូវ ដោយសារកំហុសរបស់ ឥណទានលទ្ធផលចុងក្រោយ គឺទៅរកការក្ស័យធនបាត់បង់ទ្រព្យសម្បត្តិ មហន្តរាយចំណង អាពាហ៍ពិពាហ៍ និងគ្មានអត្រាឥណទាន កើតឡើង ។
- ការជាប់សន្យាជាច្រើនជាមួយចំណូលអនាគតរបស់ពួកគេ នៅក្នុងដំណើរឥណទាន ពួកគេបាត់បង់ លទ្ធភាពសន្សំមូលនិធិសំរាប់គោលដៅហិរញ្ញវត្ថុយ៉ាងសំខាន់ ។
- ការពង្រីកជំរើសទិញជាឥណទាន ជាហេតុផលសំខាន់ណាស់សំរាប់គ្រួរសាជាច្រើន ត្រូវយល់ដឹង អំពីការរៀបខ្ទង់ថវិកា និង អនុវត្តការប៉ាន់ស្មានការគ្រប់គ្រងហិរញ្ញវត្ថុ ។

### ៦.២- ថ្នាក់ការប្រើឥណទានសំរាប់អាជីវកម្ម (Dangers of credit Use for Business )

- បើសិនមានអតិថិជនមួយចំនួនប្រើឥណទានក្នុងការទិញទំនិញ និងសេវាកម្ម ហើយមិនសងតាម ការព្រមព្រៀង នោះចំណូលដុល្លាររបស់អាជីវកម្មជាច្រើនត្រូវបាត់បង់ ។

- មានហេតុផលសំខាន់ជាច្រើនទៀត ដែលអត្រាបរាជ័យខ្ពស់ក្នុងចំណោមអាជីវកម្មខ្នាតតូច ដោយសារអសមត្ថភាពក្នុង ការអនុវត្តការគ្រប់គ្រងនយោបាយឥណទានឱ្យបានល្អ ។
- ត្រូវមានវិធីទប់ទល់ការពារក្នុងការធ្វើឱ្យច្បាស់ថា អតិថជនណាដែលផ្តល់គុណប្រយោជន៍ នៅពេលមាន ឱកាសប្រើកម្មវិធីឥណទាន ។
- ការបន្តចំណាយថ្លៃដើម និងការប្រមូលគណនីឥណទានត្រូវពិនិត្យឱ្យច្បាស់ថា ចំណូលមិនប្រោះ ចេញ ។

## ៦.៣-សេចក្តីត្រូវការ ការអប់រំ (Need for Educations)

- មានការបញ្ជាក់ច្បាស់ថា ទាំងអ្នកផ្តល់ និង អ្នកប្រើឥណទានត្រូវតែប្រុងប្រយ័ត្ន ។ ឥណទានគឺបង្កើនសារៈសំខាន់ និង ហាក់ដូចជាកំពុងជំនួសសាច់ប្រាក់ដូចជាមធ្យោបាយដោះដូរ ។
- អ្នកប្រើប្រាស់ អ្នកធ្វើអាជីវកម្ម និងអ្នកបោះឆ្នោតជាច្រើន នឹងទទួលផលប្រយោជន៍ជាច្រើនពីចំណេះ ដឹងបន្ថែមពីឥណទានដែលជាផ្នែកមួយសំខាន់សំរាប់ប្រព័ន្ធសេដ្ឋកិច្ចរបស់យើង ។
- ចំណេះដឹងសំរាប់អ្នកប្រើប្រាស់គួរពាក់ព័ន្ធការបណ្តុះបណ្តាលស្តីពីថវិកា ពន្យល់អំពីលក្ខខ័ណ្ឌកិច្ចសន្យារបស់ឥណទាន និងការស្ម័គ្រចិត្តសងលើកិច្ចសន្យាដែលបានព្រមព្រៀង ។
- ត្រូវយល់ដឹង តើនយោបាយឥណទានណាដែលអាចសំរេចបាន តើគួរធ្វើការស៊ើបអង្កេតអ្នកស្នើសុំ យ៉ាងដូចម្តេច និង តើត្រូវទារមូលនិធិតាមគំរោងប្រតិបត្តិការឥណទានយ៉ាងដូចម្តេច ?

# ជំពូក ៨
# ការគ្រប់គ្រង និងការលើកទឹកចិត្តនៃឥណទានសំរាប់អ្នកប្រើប្រាស់

## ៨.១ គោលដៅនៃការសិក្សា

ក្រោយពីសិក្សានូវមេរៀននេះ អ្នកនឹងអាចដឹងនូវៈ

- ពន្យល់អំពីតំរូវការ សំរាប់ការស្ទាបស្ទង់ការអនុវត្តការគ្រប់គ្រងឥណទានដើម្បីសំរេចទិសដៅផ្នែក ឥណទាន ។
- ពិភាក្សាអំពីភាពខុសគ្នា និងស្រដៀងគ្នា នៅក្នុងមុខងាររៀបចំឥណទានរាយឥណទានសាច់ប្រាក់ និងការិយាល័យ ផ្តល់ឥណទានសេវា ។
- ពន្យល់អំពីរបៀបប្រើនយោបាយឥណទាន បទបញ្ញាត្តិ និង ទំរង់ការផ្សេង
- ពិភាក្សាអំពីគុណសម្បត្តិ និងគុណវិបត្តិ នៃវិធីសាស្ត្រខុសៗគ្នាសំរាប់រៀបចំផ្នែកឥណទាន
- ពិពណ៌នាពីសារៈសំខាន់នៃការបង្កើតការវាស់វែង ត្រួតពិនិត្យនៅក្នុងសកម្មភាពផ្នែកឥណទាន
- បង្ហាញ និងអធិប្បាយសារៈសំខាន់នៃសមាគមវិជ្ជាជីវៈនៃឥណទានអ្នកប្រើប្រាស់
- ពិភាក្សាអំពីតំរូវការបន្ថែមសំរាប់អតិថិជនឥណទាន និងប្រភពដែលទទួលបានពីពួកគេ
- ពិពណ៌នាអំពី ទីផ្សារចំរុះ ជាមួយបន្សំ ផលិតផល ថ្លៃ ទីកន្លែង និងការលើកទឹកចិត្តនៅក្នុងប្រតិបត្តិការផ្នែកឥណទាន
  - មេរៀននេះផ្តោតទៅលើការដាក់ទិសដៅ និងសកម្មភាពយ៉ាងប្រុងប្រយ័ត្នរបស់អ្នកគ្រប់គ្រង ឥណទាន អ្នកប្រើប្រាស់ ។
  - ពិចារណាអំពីទិដ្ឋភាពមួយចំនួននៃការគ្រប់គ្រងឥណទានអ្នកប្រើប្រាស់ និង ពិភាក្សាតើអ្នក គ្រប់គ្រង បង្កើតគោលការណ៍ណែនាំ និងទំរង់ការបែបណាដែលជួយគោលដៅទាំងនេះ ។
  - កម្មវិធីឥណទានក្លាយជាផលិតផលដែលអាចលក់នៅលើទីផ្សារ ចាប់ពីអតិថិជនឥណទានជាច្រើនបាននាំមកប្រសិទ្ធិភាពប្រតិបត្តិការ ហើយមានការលក់នៅលើទីផ្សារច្រើន ធ្វើអោយចំណូល កើនឡើង ។

### ១. ការគ្រប់គ្រងឥណទានរាយ (Retail Credit Management)

- ការគ្រប់គ្រងឥណទាន នៅក្នុងឥណទានរាយ គឺជាផ្នែកមួយពង្រឹងការលក់ទំនិញ និងសេវាកម្ម ។
- ការផ្សព្វផ្សាយ បានបញ្ជាក់ថា "ផែនការឥណទានងាយស្រួល គឺជាផែនការដែលអាច" បង្កើនចរាចរអោយអតិថិជន និងការលក់ ។

- នៅក្នុងតំបន់ឥណទាន ការផ្សព្វផ្សាយគឺជាល្បឿនក្នុងការធ្វើសេចក្តីសំរេចការអនុញ្ញាតិឱ្យមានការទិញ និងធ្វើឱ្យផលិតផលផ្លាស់ទីជាមួយប្រតិបត្តិការឥណទានដែលមាន ហើយជាផ្នែកតែមួយ គត់សំរាប់ដំណើរការ ។
- បើសិនមានចំណូលគ្រប់គ្រាន់ទំនិញជាច្រើននឹងបានធ្វើដើម្បីលក់ រួមជាមួយហានិភ័យដែលនឹង ទទួលក្នុងចំណោមការយល់ព្រមឱ្យអតិថិជនប្រើឥណទាន ។
- វិធីសាស្រ្តសំខាន់ដែលយើងបានប្រើដើម្បីប្រមូលពត៌មានគឺដំណើរស៊ើបអង្កេត និងការត្រួត ពិនិត្យការទិញជឿ និង សកម្មភាពគ្រប់គ្រងឥណទានល្អៗដែលចាំបាច់ ។

## ២. ការរៀបចំសកម្មភាពផ្តល់កំចីសាច់ប្រាក់

- ការឱ្យខ្ចីជាសាច់ប្រាក់ គឺតំរូវការអនុវត្តស្ទាបស្ទង់ការគ្រប់គ្រងឥណទាន ។
- ចំពោះស្ថាប័នហិរញ្ញវត្ថុធំៗ មានបែបផែនអនុវត្តរូបិយ៍ដូចជា បានបង្កើតគោលនយោបាយ និងទំរង់ការល្អៗ ។
- ចំណែកសាខាតូចៗវិញ ដូចជា ក្រុមហ៊ុនផ្តល់ហិរញ្ញវត្ថុឱ្យអ្នកប្រើប្រាស់ មានបុគ្គលិកប្រហែលតែ ៣-៤ នាក់ធ្វើការផ្នែក ឥណទាន ប៉ុន្តែគោលនយោបាយឥណទានជាទូទៅតំរូវដោយមានកិច្ចសហប្រតិបត្តិការ ត្រួតដំណើរផ្តល់កំចី ។
- ដូច្នេះ ការស្វែងរកប្រភេទអតិថិជន និងប្រភេទកំចីដែលធ្លាប់ធ្វើកំណត់ដោយនយោបាយគ្រប់គ្រងឥណទាន និងការអនុវត្តដែលគួរប្រើ ។
- អ្នកផ្តល់កំចីដែលធ្លាប់ទទួលហានិភ័យខ្ពស់ជាងហានិភ័យធម្មតា អាចបង្កើនការស៊ើបអង្កេតអោយបានច្រើន ឬ ឱ្យសំណងតបតាមគំរោងឱ្យបានរហ័ស ។

## ៣. ការគ្រប់គ្រងឥណទានសេវា

- ភាពខុសគ្នា នៅក្នុងការគ្រប់គ្រងឥណទានសេវាគឺកម្មវិធីឥណទាន និងការគ្រប់គ្រងឥណទានអ្នក ប្រើប្រាស់ទៅលើប្រការមួយចំនួនមិនគួរឱ្យចង់បាន ។
- នៅក្នុងការគ្រប់គ្រងឥណទានរាយ ប្រភេទនៃកម្មវិធីឥណទានដែលរៀបចំបានអនុវត្តដើម្បីបង្កើនការលក់ ។
- ការពង្រីកអ្នកប្រើប្រាស់ឥណទាន ផ្អែកលើបំណងប្រាថ្នាឱ្យថ្លៃដើមទាប ហើយធ្វើឱ្យចំណូលប្រសើរឡើងពីការថែមចំណូលបន្ទុកហិរញ្ញវត្ថុ ។
- នៅក្នុងឥណទានសេវា អ្នកផ្តល់សេវាត្រូវមានកាតព្វកិច្ចជាលក្ខណៈប្រពៃណី និងអនុវត្តដោយផ្តល់ពេលវេលាបន្ថែមឱ្យអតិថិជនសង(ឬ ភាគីទី៣ជាអ្នកសងដូចជាក្រុមហ៊ុនធានារ៉ាប់រង) ។

## ៨.២ សកម្មភាពគ្រប់គ្រងឥណទាន

### ៨.២.១ ការបង្កើតនយោបាយ, បទបញ្ញត្តិ និងទំរង់ការ

- អ្នកគ្រប់គ្រងគួរតែបង្កើតនយោបាយ ឬគោលការណ៍ណែនាំផ្សេងៗដើម្បីជួយផ្នែកឥណទានអោយសំរេចគោលដៅ ។
- នយោបាយជួយធ្វើឱ្យច្បាស់មិនផ្លាស់ប្តូរ និងដាក់ចេញដើម្បីជំរុញផ្នែកឥណទានឱ្យមានប្រសិទ្ធិភាព និងជំរុញសកម្មភាពអាចរកកំរៃបាន ។
- នយោបាយបានអនុញ្ញាតិឱ្យអ្នកគ្រប់គ្រងឥណទានមានអំណាចក្នុងសកម្មភាពការងារ កាត់បន្ថយ ករណីកើតឡើងនូវភាពមិនប្រក្រតី ហើយអ្នកធ្វើការឥណទានតំរូវមុខងារឥណទាន ។

#### ៨.២.១.១-នយោបាយឥណទាន (Credit Policy)

- នយោបាយឥណទាន គឺរៀបរៀងជារបាយការណ៍គោលនយោបាយសំរាប់អនុវត្តដោយផ្នែកឥណទាន ដើម្បីកំណត់ប្រភេទឥណទាន ។
- នយោបាយកំណត់របស់បញ្ចាំ និងលក្ខណៈហានិភ័យដែលអាចទទួលយកបាន ។
- ម្យ៉ាងទៀត នយោបាយឥណទាន នឹងដៅនូវបេសកកម្ម និងបំណងគ្រឹះរបស់ផ្នែកឥណទាន។

#### ៨.២.១.២-នយោបាយស៊ើបអង្កេត (Investigation Policy)

- នយោបាយស៊ើបអង្កេត គឺរៀបរៀងជាគោលការណ៍ណែនាំ ដើម្បីជួយដល់អ្នកស៊ើបអង្កេតប្រមូល នូវប្រសិទ្ធិភាពពត៌មានដើម្បីមកដល់សំលេងសំរេច ។
- នយោបាយស៊ើបអង្កេតឥណទានអាចកំណត់គុណប្រយោជន៍ឥណទានដែលសំខាន់ និងបង្កើត ស្តង់ដាស៊ើបអង្កេតអោយអប្បបរមា ។
- នយោបាយឥណទានដែលត្រូវការ (ប្រវត្តិទីលំនៅ ត្រូវបញ្ជាក់តិចបំផុត ២ឆ្នាំ) នយោបាយអាចត្រូវការការិយាល័យកស៊ីស៊ើបអង្កេតឥណទាន ដើម្បីផ្តល់របាយការណ៍អតិថិជន និងប្រាក់ ខែដែលផ្ទៀងផ្ទាត់ទៅនឹងកិច្ចសន្យាជាមួយនិយោជក ។
- សេចក្តីលំអិត ពឹងផ្អែកលើប្រភេទ និងចំនួនឥណទានដែលបានផ្តល់ដោយមន្ត្រីឥណទាន ។

#### ៨.២.១.៣- នយោបាយប្រមូល (Collection Policy)

- នយោបាយប្រមូលបំណុល បានរៀបរៀងជាគោលកាណ៍ណែនាំជួយដល់អ្នកធ្វើការឥណទានសំរេចមធ្យោបាយប្រមូលឥណទានមួយណាដែលអាចធ្វើការបាន និងតើគួរដំណើរការបែបណា នៅពេលប៉ងប្រមូលបំណុលដែលជំពាក់ ។
- នយោបាយប្រមូលនឹងអនុវត្តគ្រប់គ្រងតំណាក់កាលប្រមូល មធ្យោបាយ និងបង្ហាញអំពីរយៈពេល ដែលគណនីអាចស្ថិតនៅក្នុងតំណាក់នីមួយៗនោះ ។
- បើសិនសំណងស្ថិតនៅក្នុងរយៈពេល១០ថ្ងៃផុតកំណត់ការហៅទូរស័ព្ទនឹងធ្វើឡើង ។ បើសិន
- សំណង ១២០ ថ្ងៃហួសថ្ងៃកំណត់ នយោបាយអាចតំរូវសំរេចពីច្បាប់ដើម្បីទារបំណុល ។

- នយោបាយប្រមូលនឹងណែនាំវិធីសាស្ត្រ ដែលអាចទទួលយកបានដើម្បីប្រើ និងចង្អុលបង្ហាញអ្វី ដែលផ្នែកឥណទាន ត្រូវការប្រាកដក្នុងការបំពេញសកម្មភាព ។

#### ៨.២.១.៤- បទបញ្ញត្តិ (Rules)

- បទបញ្ញត្តិ គឺជាទំរង់ការសកម្មភាពហាមឃាត់ និងកំណត់លើតវិយាបទមួយដែលគួរទទួលយក ។
- នៅក្នុងផ្នែកឥណទានមានបទបញ្ញត្តិជាច្រើនបានបង្កើតដើម្បីប្រាកដអនុលោមទៅតាមច្បាប់រដ្ឋ និងច្បាប់សហព័ន្ធផ្សេងៗ ។
- បញ្ញត្តិលើអ្នកទារបំណុល និយាយអំពីការហៅទូរស័ព្ទទៅអតិថិជននៅពេលវេលាមិនប្រក្រតី ដែលធ្វើអោយអតិថិជនមានការរំខានប្រការនេះកំណត់ដោយច្បាប់ ។

#### ៨.២.១.៥- ទំរង់ការ(Procedures)

- ជាគំរោងការណែនាំជាជំហានៗ ឱ្យស្របទៅតាមទិសដៅនៅពេលបំពេញភារកិច្ច ។
- ទំរង់ការផ្សេងៗទៀតនឹងពាក់ព័ន្ធ ការបន្ថែមអតិថិជនថ្មីតាមរយៈដោយសំរង់ស្ថិតិដោយផ្នែកកុំព្យូទ័រ ឬបង្កើតបញ្ជីថ្មី ។
- ការណែនាំទាំងនេះនឹងបញ្ជាក់ច្បាស់ថា រាល់សកម្មភាពស្មុគស្មាញគឺបំពេញដោយកំរិតខុសអប្បបរមា និងកំណត់គោលការណ៍ណែនាំឱ្យខ្ជាប់ខ្ជួន ។

## ៨.៣. ការរៀបចំនៅក្នុងផ្នែកឥណទាន

- ការរៀបចំនៅក្នុងផ្នែកឥណទានតំរូវអ្នកគ្រប់គ្រងឥណទានសំរេច អ្នកណាមានភារកិច្ចនៅក្នុងផ្នែកឥណទាន និងមុខងារគ្រប់គ្រងដែលពាក់ព័ន្ធសកម្មភាពជាក្រុម ហើយបញ្ចូលពួកគេជាបុគ្គល និយោជិក។
- មានផ្នែកឥណទានខ្នាតតូច និងមិនត្រូវការមានរចនាសម្ព័ន្ធ គឺគ្រាន់តែមានអ្នកធ្វើការ ៣-៤ នាក់ទទួល បន្ទុកសកម្មភាពទាំងមូលគ្រប់គ្រាន់ ។
- ប៉ុន្តែ នៅក្នុងផ្នែកឥណទានខ្នាតធំ រចនាសម្ព័ន្ធគឺចាំបាច់ណាស់ក្នុងបញ្ញត្តិដើម្បីរកចំណេញលើភាពប៉ិនប្រសព្វរបស់និយោជិក និងធ្វើឱ្យប្រាដកថា គោលដៅផ្នែកឥណទាននឹងបានសំរេច ។

### ៨.៣.១ ចាត់តាំងតាមមុខងារ

- ការចាត់តាំងផ្នែកមុខងារនៅក្នុងផ្នែកឥណទាន មានន័យថា អ្នកធ្វើការខុសគ្នា ឬ ក្រុមនៃអ្នក ធ្វើការ ហើយអាចបំពេញមុខងារសំរាប់អតិថិជនទាំងអស់ ។
- គុណសម្បត្តិចំពោះវិធីសាស្ត្រចាត់តាំងមុខងារនេះ គឺបង្កើតជំនាញនៅក្នុងសកម្មភាពអនុវត្តតាម មុខងារ ក្នុងចំណោមមុខងារដែលបានចាត់នេះ ( អ្នកធ្វើការផ្នែកប្រមូលក្លាយជាអ្នកឯកទេស ប្រមូលបំណុល) ។
- ដូច្នេះ ការចាត់តាំងតាមមុខនាទីអាចអនុញ្ញាតិឱ្យក្រុមហ៊ុនប្រើជំនាញដ៏ល្អរបស់អ្នកធ្វើការនៅក្នុង សកម្មភាព ឬ វិស័យ ។

### ៨.៣.២ ការរៀបចំអតិថិជន

- រើសអតិថិជនដោយអ្នកធ្វើ ការផ្នែកឥណទានខុសគ្នា ។
- និយោជកអាចយកសំណើសុំទៅធ្វើការស៊ើបអង្កេត ហើយធ្វើសេចក្តីសំរេច និងទទួលខុសត្រូវលើការទារសំណងពីអតិថិជនដែលបានរាយឈ្មោះនោះ ។
- ការរៀបចំវិធីសាស្ត្រនេះ គឺមានប្រយោជន៍ជាពិសេសនៅក្នុងវគ្គបញ្ចុះបញ្ចូល និងការអភិវឌ្ឍន៍និយោជិក ។ ពេលពួកគេបានបញ្ចុះបញ្ចូលហើយ គេមានឯកទេសប្រតិបត្តិ ជាងឯកទេសជំនាញ និងគេបានធ្វើអ្វីៗជាច្រើន ។
- មានក្រុមហ៊ុនភាគច្រើនបន្សំបញ្ចូលគ្នានៃវិធីសាស្ត្ររៀបចំ (ភូមិសាស្ត្រ ផលិតផលជាមូលដ្ឋាន) ។
- អ្នកគ្រប់គ្រងឥណទានគួរ មានតុល្យភាពរវាងគុណសម្បត្តិ និងគុណវិបត្តិនៃវិធីសាស្ត្រនីមួយៗដើម្បីសំរេចវិធីសាស្ត្រ មួយណាដែលល្អសំរាប់ភារកិច្ច ដែលត្រូវបំពេញទាំងមូល ។

## ៨.៤ ការបង្កើតការត្រួតពិនិត្យការវាស់វែង

- បង្កើតវិធីសាស្ត្រសំរាប់ផ្តោតលើការឆ្ពោះទៅរកការវិវត្តន៍គោលដៅ ។
- ការត្រួតពិនិត្យ (Controlling) គឺជាសកម្មភាពគ្រប់គ្រងដែលពាក់ព័ន្ធការបង្កើតស្តង់ដាសំរាប់ការវាស់វែងការវិវត្តន៍ ការគ្រប់គ្រងត្រួតពិនិត្យសកម្មភាព និងការស្វែងរកមធ្យោបាយដើម្បីមានសកម្មភាពត្រឡប់លើការតាមដាន បើសិនរកឃើញ ការងាកចេញពីស្តង់ដា។ ពង្រឹងបុគ្គលជានិយោជិក គួរវាយតំលៃ និងធ្វើការបណ្តុះបណ្តាល ដើម្បីធ្វើឱ្យជំនាញប្រសើរឡើង ។
- វិធីសាស្ត្រថ្មី ឬ បច្ចេកទេសថ្មីអាចជំរុញការសំដែងនៅក្នុងផ្នែកអនុវត្ត ។
- ដូច្នេះស្ថិតិដែលមានចំនួនច្រើន តែងប្រមូលបានពីលទ្ធផលប្រមូលបំណុល នូវចំនួនសំណើសុំដែល ត្រូវយកជាមួយការទទួលយល់ព្រម និងការចំណាយពាក់ព័ន្ធនៅក្នុងប្រតិបត្តិផ្នែកឥណទាន ។

## ៨.៥ ទីផ្សារកម្មវិធីឥណទាន

ទីផ្សារគឺជាសកម្មភាពដែលចាំបាច់សំរាប់អាជីវកម្មជាច្រើន។ ទីផ្សារ គឺជាដំណើរការដែលបង្កលក្ខណៈ ងាយស្រួលដល់ចលនាទំនិញ និងសេវាកម្មពីអ្នក ប្រើផលិតផល ។ មានសមាសភាគ៤ នៅក្នុងទីផ្សារដូចជា ផលិតផល ថ្លៃ ទីកន្លែង និងការលើកទឹកចិត្ត ។ កម្មវិធីឥណទានមិនខុសពីផលិត ផល និងសេវាកម្មដទៃៗទៀតទេ ។ នៅពេលមានកម្មវិធីឥណទានមួយបានបង្កើត ពេលនោះអាជីវកម្ម ក៏ត្រូវការ បង្កើនចំនួនអ្នកប្រើប្រាស់ និងអតិថិជនដែរ ។

តារាង ៥៖ បង្ហាញអំពី ការផ្សព្វផ្សាយ ការលើកទឹកចិត្តការប្រើឥណទាន (Newspaper Ad Promoting Use of Credit)

Introductcing at all

Jubilee Foods...

VISA

Master Card DICOUVER TYME

*MASTERCAR *VISA *DISCOUV *TYM

NOW YOU CAN PAY FOR YOUR GROCERIES WITHOUT WRITING A CHECK OR USING CASH.

USE YOUR MASTERCARD ON

Master Card

*THURSDAY,OCTOBER 7 *FRIDAY,OCTOBER 8 *SATURDAY,OCTOBER 9 AND GET AN UNLIMITED 5% OFF OF YOUR TOTAL FOOD BILL AT THE REGISTER!

AT JUBILEE FOODS “ YOU’RE GONNA LOVE WHAT WE HAVE INSTORE” SO CHECK OUT OUR OTHER GREAT FEATURE.

Source: Green Bay Press Gazette , October 6, 1993.

### ៨.៥.១ តើអតិថិជនឥណទានណាមួយដែលគួរស្វែងរក?

- មូលដ្ឋានគ្រឹះរបស់សំណួរសំរាប់អាជីវកម្មជាច្រើន ដែលប្រាថ្នាចង់បានអតិថិជនយ៉ាងច្រើន តើគួរ ធ្វើអោយគុណសម្បត្តិមានតំលៃជាងគុណវិបត្តិ ?
- ដូច្នេះនៅក្នុងប្រតិបត្តិការឥណទានជាទូទៅ គឺលទ្ធផល ថ្លៃដើម សក្តានុពលបញ្ហាទំនាក់ទំនងជា សាធារណៈ និងបញ្ហាចលនាសាច់ប្រាក់កើនឡើង ។
- អ្នកផ្តល់កំចីជាសាច់ប្រាក់ គួរតែប្រកាន់ខ្ជាប់ការងារតាមដានអ្នកខ្ចីថ្មី១ ចាប់ពីការពន្យាពេលឥណទានជាបំណងគ្រឹះមួយសំរាប់អ្នកខ្ចីមានវត្តមាន ។
- ក្រុមហ៊ុនលក់រាយ និងក្រុមហ៊ុនផ្តល់សេវាកម្មអាចសំរេចថាគួរ "ជំរុញ " ឬ មិនជំរុញកម្មវិធីឥណទាន ។

#### បង្កើតចំណូលពីការលក់

- ជាទូទៅឥណទានផ្តល់ឱ្យអតិថិជន ច្រើនជាងឱ្យអតិថិជនចំណាយសាច់ប្រាក់ ។
- ការផ្តល់កម្មវិធីឥណទានតែងបើកនៅក្នុងទីផ្សាររហូតសំរាប់បុគ្គលជាច្រើនដែលស្ម័គ្រចិត្តចំណាយ ចំណូលអនាគតសំរាប់សងបំណុល បើសិនពួកគេគ្មានសាច់ប្រាក់គ្រប់គ្រាន់ ។

- ដូច្នេះប្រយោជន៍ទាំងមូលនឹងកើនឡើង បើសិនអតិថិជនឥណទានប្រុងប្រយ័ត្នជ្រើសរើសការទិញ ដោយឥណទានបានល្អ និងបើសិនការចំណាយរបស់គេបានត្រួតពិនិត្យម្មត់ចត់ ។

### ការលក់ទំនិញមានគុណភាព

- អតិថិជនឥណទានតែងចូលចិត្តទិញទំនិញមានគុណភាព នៅពេលគេដាក់កំហិតចំនួនឥណទាន ដែលអាច ។
- ជាទូទៅ អតិថិជនឥណទានតែងមានតំលៃមនសិកាតិចតួច នៅពេលគេស្ម័គ្រចិត្តចំណាយលុយ ជាច្រើន ។
- ការទិញទំនិញដែលមានគុណភាពនឹងធ្វើឱ្យចំណូលប្រសើរឡើង កាត់បន្ថយការត្រឡប់វិញ និងប្រាក់ឧបត្ថម្ភបន្ថែមសំរាប់ទំនិញគ្មានគុណភាពនិងជំរុញតាមការពេញចិត្តរបស់អតិថិជន។

### បង្កើតភាពស្មោះត្រង់របស់អតិថិជន

- និន្នាការអតិថិជន គឺត្រូវបង្កើតភាពស្មោះត្រង់ទៅបុគ្គលលក់ទំនិញ និងអ្នកផ្តល់កំចី ។
- ចំណេះដឹងបន្ថែម គេជាអ្នកផ្តល់លក្ខណៈសម្បត្តិទទួលឥណទាន និងគេអាចបង្កើនការយល់ព្រម ដែលមកដល់ជាមួយការបើកគណនីឥណទាន អាស្រ័យលើការកើនឡើងភាពស្មោះត្រង់នេះឯង ។
- អតិថិជនឥណទានជាច្រើនចង់ត្រឡប់មកប្រើឥណទាន ហើយគេត្រូវពលិកម្មលើអាជីវកម្មរបស់ គេ ជាច្រើននៅគ្រឹះស្ថានដែលផ្តល់ឱ្យប្រើកម្មវិធីឥណទាន ។

### ធ្វើឱ្យមានស្ថេរភាពចលនាសាច់ប្រាក់

- កម្មវិធីឥណទាននឹងជួយរក្សាស្ថេរភាពចលនាសាច់ប្រាក់មិនឡើងមិនចុះ ។ បើសិនអតិថិជនទិញទំនិញសំរាប់លក់ ពីអ្នកលក់ ដោយប្រើកម្មវិធីឥណទានផ្ទាល់ខ្លួន សំណងនឹងយឺតជាច្រើនខែតាមការទិញជាក់ស្តែង ។
- ហេតុផលបំរែបំរួលស្ថិតក្នុងចំនួននៃការលក់ (ឧទាហរណ៍ ការលក់ទំនិញជាច្រើនកំឡុងពេលបុណ្យ Christmas) ។
- អ្នកប្រើប្រាស់ឥណទាន ជានិច្ចជាកាលប្រើប័ណ្ណឥណទាន និងកម្មវិធីឥណទានផ្សេងៗ ដើម្បីស្ថេរភាព នៃការចំណាយផ្ទាល់ខ្លួនរបស់គេ បើសិនគេមានបទពិសោធន៍ក្នុងការកាត់បន្ថយចំណូល ។

### កាត់បន្ថយថ្លៃដើម (Reduce Operational Costs)

- ចំនួនអតិថិជនដែលប្រើឥណទានច្រើនតែងចំណាយថ្លៃដើមទាប ។
- ប្រសិទ្ធិភាព គឺឥណទានកុំព្យូទ័រភាវូបនីយកម្ម អនុញ្ញាតិប្រើដោយប្រព័ន្ធអាចទទួលផ្ទុករាប់រយអតិថិជន និងថ្លៃដើមដែលចំណាយទាប ហើយកើនឡើងប្រតិបត្តិការជាច្រើន ។

- ការចំណាយលើអាជីវកម្ម ដូចជា ថ្លៃឈ្នួល ប្រាក់ខែសំរាប់អ្នកធ្វើការ និង ចំណាយលើការប្រមូលតែងកើនឡើងជាងកំណើនអតិថិជនដែលតែងកើនឡើងយឺត ។

## ៨.៦ ប្រភពបន្ថែមសំរាប់ការលក់ជាឥណទាន

- អាជីវកម្មមួយបានកំណត់ថា ការបន្ថែមការលក់ជាឥណទាននិងបង្កើនអតិថិជនគឺជាវិធីសាស្រ្តមួយគួរបង្កើតនូវទីផ្សារកម្មវិធីឥណទាន ដើម្បីជំរុញបង្កើនចំនួនឥណទាន ។ ការលក់នេះបានពីអតិថិជនថ្មី អតិថិជនឥណទានអសកម្មភាព និងអ្នកប្រើប្រាស់ដែលមានសកម្មភាព ។

### ៨.៦.១ អតិថិជនថ្មី

- បើសិនមានអតិថិជនជាច្រើនដាក់ពាក្យសុំទទួលសិទ្ធឥណទាន ពេលនោះ ការលក់ដោយឥណទាន នឹងកើនឡើង ។
- លក់ទំនិញ ជាមួយកិច្ចសន្យាសងរំលស់ ឬចេញប័ណ្ណឥណទាន នោះមានអតិថិជនថ្មីជាច្រើនទទួល បានលទ្ធផលនៅក្នុងចំនួនឥណទានដ៏លើសលប់ ។
- យើងត្រូវការបង្កលក្ខណៈងាយស្រួលដល់អតិថិជនណាដែលមានប័ណ្ណឥណទានបីផ្សេងគ្នារួចហើយ ដែលកម្មវិធីរបស់យើងត្រូវការចង់បាន ។
- បង្កើតវិធីសាស្រ្តដើម្បីកំណត់ ការតាំងទីលំនៅថ្មីនៅក្នុងសមាគម គូរស្រករថ្មី និងអ្នកដទៃទៀតដែលកំពុងស្វែងរកការរកស៊ីដំបូងដោយប្រើឥណទាន ។
- ការផ្តល់ប័ណ្ណឥណទាន ទៅនិស្សិតមហាវិទ្យាល័យ តាមរយៈនិស្សិតមានចំណូលតិចតួចនៅក្នុង ករណីជាច្រើន សំរាប់ឱកាសក្នុងជីវិតរបស់អតិថិជន ។

### ៨.៦.២ អតិថិជនអសកម្ម

- ការយល់ព្រមផ្តល់គណនីឥណទាន និងផ្តល់កំចីដល់អតិថិជន នៅក្នុងករណីដែលអតិថិជនបញ្ឈប់ ការប្រើឥណទានដែលអាចនោះ។ អ្នកចេញប័ណ្ណបានបានចំណាយមូលនិធិ និងថាមពលអស់ ហើយក្នុងដំណើរជំរុញនេះ ដូច្នេះមានតែបង្កើនឱ្យប្រើប្រាស់ថែមទៀតដើម្បីទទួលបានអ្វីដែល ប្រាថ្នាចង់បាន ។
- អតិថិជនទាំងនេះ អាចមានបំណងចាកចេញពីកម្មវិធីឥណទានរបស់អ្នកទៅក្រុមហ៊ុនផ្សេង ។ ភាពដ៏ប្រសើរអាចដោះស្រាយបញ្ហាគឺ រក្សាការសំងាត់និង ភាពស្មោះត្រង់ដែលជាផលចំណេញ ។

### ៨.៦.៣ អតិថិជនមានសកម្មភាព

- អតិថិជនកំពុងប្រើកម្មវិធីឥណទាន ហើយជានិច្ចជាកាលបង្កើននូវការប្រើ ( អត្រាការប្រាក់ល្អ)
- ការផ្តល់កំចីឱ្យអតិថិជន អាចរួមជាមួយវិក័យប័ត្រផ្សេងៗ ដើម្បីបង្កើនចំនួនកំចីជាមួយក្រុមហ៊ុន អ្នកនឹងទូទាត់នៅក្នុងគណនីផ្សេងទៀត ។
- ប័ណ្ណឥណទានអាចប្រើយ៉ាងច្រើន បើសិនគេកាន់ប័ណ្ណធនាគារផ្សេងៗគ្នានៅក្នុងកាបូបរបស់គេ ហើយងាយស្រួលជំនួសប័ណ្ណមួយទៅប័ណ្ណមួយដើម្បីទូទាត់ ។

- ដូច្នេះការវាស់វែងក្នុងការត្រួតពិនិត្យត្រូវបានប្រើដើម្បីការពារអតិថិជនឥណទាននូវការពន្យាពេលសមតុល្យគណនី ផ្សេងដែលពាក់ព័ន្ធចំនួនទឹកប្រាក់ ។
- អតិថិជនមានសកម្មភាពជាច្រើន អាចមានសុវត្ថិភាពជឿជាក់ជាមួយបំណុលឥណទានមិនទាន់ សង។

## ៨.៧. ទីផ្សារចំរុះ

- ទីផ្សារចំរុះនៃផលិតផល ថ្លៃ ទីកន្លែង និងការលើកទឹកចិត្ត នឹងជួយវិភាគក្រុមហ៊ុន
- ហើយវិធីសាស្ត្រនេះធ្វើឱ្យការលក់ជាឥណទានប្រសើរឡើង ។ មាន ៤ P's តំណាងឱ្យតំរូវការគំរោង សំរាប់ ជាគ្រឿងមើលការស្មុគ្រស្មាញចំរុះពាក់ព័ន្ធនៅក្នុងទីផ្សារផលិតផល និងសេវាកម្ម ។

### ៨.៧.១- ផលិតផល

- ការផ្តល់ឥណទានជាផលិតផល មានលក្ខណៈស្មុគ្រស្មាញជាងការស្មាន ។
- កំចីនេះរួមមាន ផ្តល់កំចីជាផ្ទះ ជាមួយកម្មវត្ថុបន្ថែមពន្ធបញ្ចូលដកពីអ្នកខ្ចី ។
- ការបន្ថែមបញ្ចូលជាលក្ខណៈសេវាកម្មជិតស្និទ្ធ និងការជឿជាក់ការថៃទាំរបស់ក្រុមហ៊ុនសំរាប់សុខមាលភាពរបស់អតិថិជនគឺធ្វើតាមការដោះដូរតាមលក្ខណៈរបស់ផលិតផលដែលផ្តល់ ។
- ដូច្នេះក្រុមហ៊ុននីមួយៗគួរវិភាគយ៉ាងប្រុងប្រយ័ត្ន អ្វីសំរាប់អនុវត្តដល់ក្រុមអតិថិជន គឺការស្វែងរកពួកគេ ។
- ផលិតផលដូចគ្នាអាចមានទីផ្សារខុសគ្នា ដោយដៅបញ្ជាក់ពីលក្ខណៈខុសគ្នា នៅក្នុងសីមា អនុវត្ត របស់ទីផ្សារ ។
- ផលិតផលនីមួយៗគឺមានលក្ខណៈបន្សំស្មុគ្រស្មាញ សេវាកម្ម និងគុណសម្បត្តិ ។
- ក្រុមហ៊ុនត្រូវយល់អ្វីជាការអនុវត្តទៅលើក្រុមអតិថិជនចង់បាន ហើយអាចដំណើរការជាមួយការ លើកទឹកចិត្តដោយបង្កើនការផ្តល់ ។

### ៨.៧.២-ថ្លៃ

- ថ្លៃរបស់កម្មវិធីឥណទាន និង ថ្លៃរបស់ផលិតផល គឺជាថ្លៃដូចគ្នា ។ ផ្តល់ការបញ្ជាក់ពីទំរង់

  ហានិភ័យ ដើម្បីឱ្យអតិថិជនអាចទទួលកំចី ឬគណនីឥណទានពីប្រភពជាច្រើន ដែលប្រភពនោះ យកកំរៃបន្ទុកដូចគ្នា ។

- អតិថិជនអាចប្រើប័ណ្ណឥណទានដើម្បីទិញគ្រឿងសង្ហារឹមជាច្រើនពីអ្នកលក់រាយ ជាមួយការផ្តល់ សេរីឥណទាន ( ថ្លៃដើមឥណទានបានបញ្ចូលក្នុងថ្លៃទំនិញសំរាប់លក់ ) ។
- កំចីនិក្ខេបជាផ្ទះ (កំចីដោយមានវត្ថុបញ្ចាំផ្ទះ) មានការប្រែប្រួលតិចតួចពីអ្នកផ្តល់កំចីមួយទៅអ្នកផ្តល់កំចីផ្សេងទៀត។ ក្នុងករណីនេះ ផ្នែកផ្សេងទៀតរបស់ទីផ្សារចំរុះគួរដៅបញ្ជាក់ដូចគ្នាដែរ ។

### ៨.៧.៣- ទីកន្លែង

- ការពិចារណាពាក់ព័ន្ធទៅនឹងខ្សែរយៈដែលបានប្រើដើម្បីចែកចាយផលិតផល និងសេវាកម្ម ។
- ក្រុមហ៊ុនអាចសាងសង់សាខាការិយាល័យជាច្រើនជុំវិញសមាគម ដើម្បីជំរុញឱ្យមានដំណើរចេញ ចូលរបស់អតិថិជន ។
- គ្រប់តំបន់ទាំងអស់អាចទទួលប័ណ្ណឥណទាន ហើយគេអាចងាយស្រួលឃើញ ។
- ការសុំឥណទានតាមទូរស័ព្ទជាការសម័ញ្ញមានប្រសិទ្ធភាពដំណើរការនិងធ្វើឱ្យការផ្តល់ផលិតផល ទាក់ទាញយ៉ាងពិសេស ។
- ដំណើរការទីផ្សារ ត្រូវស្វែងរកមធ្យោបាយ ដើម្បីជំរុញដល់ចែកចាយទំនិញ និងសេវាកម្ម ។

### ៨.៧.៤- ការលើកទឹកចិត្ត

- ការលើកទឹកចិត្ត ជាកត្តាបន្សំចូលគ្នា នឹងអតិថិជនងាយស្រួលទិញ ឬយកគុណសម្បត្តិពីការអនុវត្ត ផែនការឥណទានរបស់អ្នក ។
- វិធីសាស្ត្រ គួរបង្កើតឱ្យមានលំហូរអតិថិជនមកទីកន្លែងអាជីវកម្មរបស់អ្នក ។
- ការផ្សាយពាណិជ្ជកម្មៈ សំដៅលើការប្រាប់អតិថិជនឱ្យដឹងអំពីទំនិញ និងសេវា។ ការផ្សព្វផ្សាយតាមគ្រឿងផ្សាយពត៌មាន តាមរយៈសំភារៈបោះពុម្ព ទូរសារដោយផ្ទាល់ ផ្ទាំងក្រដាស វិទ្យុ ផ្សព្វផ្សាយតាមទូរទស្សន៍ និង មធ្យោបាយដទៃទៀត ( ផ្តល់មុខងារចំណេះដឹងជាច្រើន ) ។
- បុគ្គលិកទទួលបន្ទុកការលក់ personal selling សំខាន់ណាស់ក្នុងសហសម័យនេះសំរាប់ បង្កើតអាជីវកម្ម ។ ដូច្នេះ គំរូបង្កើតនិយោជិកតំណាងលក់ ។
- បង្កើនចំនួនទិញរបស់អតិថិជនដោយបង្ហាញផលិតផល ឬការបង្កើនការប្រើប្រាស់ផលិតផលដែលប្រើ ក្នុងចំណោមអតិថិជនល្អៗ ។
- អតិថិជនធនាគារបានប្រាប់ទៅបុគ្គលិកធនាគារថា គេនឹងធ្វើដំណើរ ដូច្នេះបុគ្គលិកធនាគារត្រូវលក់មូលប្បទានប័ត្រទេសចរណ៍ ។
- អ្នកលក់រាយអាចផ្សព្វផ្សាយបន្ថែម នូវការបញ្ចុះតំលៃ ( ប្រើគណនីឥណទាន ឬប័ណ្ណឥណទាន ) ។
- "back-door-sales" ពិសេស អាចនឹងផ្តល់ នៅពេលអតិថិជនឥណទាន បានអញ្ជើញមកហាង កំឡុងពេលផ្សព្វផ្សាយហើយនឹងនៅពេលដែលហាងបានបិទ ។
- ផ្តល់អំណោយតូចៗ បើសិនអ្នកប្រើប្រាស់បង់កំរៃលើការទិញម្តងយ៉ាងតិចបំផុតក្នុងកំឡុងពេលដែលផ្តល់នេះ ។
- ការបង្កើតកម្មវិធីទំនាក់ទំនងល្អជាសាធារណៈ ជាផ្នែកផ្សេងមួយទៀត នៃប្រសិទ្ធិភាពលើកទឹកចិត្តដល់ការលក់ ។
- ស្ថាប័នឥណទានជាច្រើន បានលើកទឹកចិត្តដល់និយោជិករបស់ពួកគេ ដើម្បីក្លាយជាអ្នកចាត់ចែង នៅក្នុងសហគមន៍ ការបរិច្ចាកពេលវេលា និងប្រាក់កាស ក្នុងបុព្វហេតុសង្គ្រោះគាំពារសហគមន៍ អោយមានតំលៃ ។

# ជំពូក ៩ការស៊ើបអង្កេតឥណទានអ្នកប្រើប្រាស់

## ៩.១ គោលដៅនៃការសិក្សា

ក្រោយពីសិក្សានូវមេរៀននេះអ្នកនឹងអាចដឹងនូវៈ

- កំណត់គុណសម្បត្តិឥណទានដែលគួរស៊ើបអង្កេត
- ទំរង់ការពត៌មានផ្តត់ផ្តង់ដោយអ្នកស្នើសុំឥណទាន ដើម្បីអ្នកវិភាគឥណទាន
- សង្ខេបអំពីគុណសម្បត្តិ និង គុណវិបត្តិនៃការស៊ើបដោយផ្ទាល់
- ពិភាក្សា ព័ត៌មានដែលបានផ្តត់ផ្តង់ពីក្នុងវិស័យពិតៗ
- ពន្យល់អំពីភាពខុសគ្នារវាង ការពិត និង មតិយោបល់
- បង្ហាញអំពីសារៈសំខាន់នៃលក្ខ័ខណ្ឌសេដ្ឋកិច្ច ក្នុងសេចក្តីសំរេច
- ពន្យល់ភាពខុសគ្នារវាង ការស៊ើបអង្កេត និងការបញ្ជាក់អះអាង

- ការស៊ើបអង្កេតឥណទាន គឺជំហាននៃការទទួលយកជាបន្តបន្ទាប់ដើម្បីត្រួតពិនិត្យពត៌មានដែល ផ្តល់នៅក្នុងសំណើសុំឥណទាន និងកំណត់ តើមានអតិថិជនណាបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុចប់ ប្រតិបត្តិការ ដូចបានបន្ថែមនៅក្នុងសំលេងធ្វើសេចក្តីសំរេចឥណទាន ។
- អ្នកមានឯកទេសវិភាគឥណទានគួរសួរខ្លួនគាត់ផ្ទាល់ អ្វីដែលគេត្រូវការដឹងនៅក្នុងបញ្ញាត្តិដើម្បី ធ្វើការសំរេចចិត្តឥណទាន អោយបានត្រឹមត្រូវ ។
- ទំហំនៃការស៊ើបអង្កេតអាចបានអភិបាល ដោយកំរិតចាំបាច់ពិតប្រាកដនៃការសំរេចឱ្យបានត្រឹមត្រូវ ។

### ៩.១.១ ភាពពិត ឬយោបល់

- ការស៊ើបអង្កេតឥណទានត្រូវតែគិតក្នុងអារម្មណ៍ថា ឯកសារយោង អ្នកផ្តល់ពត៌មាន និង ទីភ្នាក់ងាររាយការណ៍ឥណទានទាំងអស់នេះ មិនមែនជាអ្នកបង្កើតពត៌មានឥណទានទេ ។
- មានតែអ្នកប្រើប្រាស់ម្នាក់ប៉ុណ្ណោះ តាមរយៈទំនាក់ទំនង និងសកម្មភាពឥណទាន បានបង្កើតពត៌មាន និងអាចប្រើដើម្បីទស្សន៍ទាយឥរិយាបទសំណងរបស់អ្នកស្នើសុំឥណទាន ។
- ការពិត (fact) គឺជាពត៌មានដែលបានដៅការផ្ទៀងផ្ទាត់ពត៌មានពិត ។
- មតិយោបល់ (A opinions) គឺជាជំនឿ ឬការសន្និដ្ឋានដែលមិនបានចង្អុលភ័ស្តុតាងដោយ តឹងតាង ឬការយល់ដឹងជាវិជ្ជមាន ។
- របាយការណ៍មួយដែលអ្នកសុំ "ពុំបានសងទៀងទាត់" ជាមតិយោបល់ (Opinion) លុះត្រាបានគាំទ្រជាមួយទិន្នន័យពិត ។ មតិយោបល់ (Opinion) អាចជាសំលេងមួយ ផ្អែកលើកម្មវត្ថុការពិត (facts) និងលទ្ធផល ត្រូវធ្វើយ៉ាងប្រុងប្រយ័ត្នជាមួយការវិភាគស្ថានភាព ។
- មតិយោបល់ជះឥទ្ធិពល បើគុណសម្បត្តិនៃប្រតិបត្តិឥណទានដែលរំពឹងទុក ។ ប៉ុន្តែមយោបល់គ្រាន់តែជាប្រភេទនៃការពិត (facts) ។

- នៅពេលធ្វើការស៊ើបអង្កេតឥណទាន អ្នកប្រតិបត្តិឥណទានអាចធ្វើគំរោងដើម្បីប្រមូលការពិត (facts) ជាជាងប្រមូលមតិយោបល់ (Opinion) ។
- ការសួរសំណួរពត៌មានអំពីអ្វីៗ គេមិនសួរនូវសំណួរណាដែលចង់ដឹងអំពីមតិយោបល់ជាងចង់ដឹង ការពិត ហើយសំណួរនេះភាគច្រើន អ្នកផ្តល់ពត៌មាននឹងមិនឆ្លើយតប ។

## ៩.១.២ អ្វីជាការស៊ើបអង្កេត (What to Investigate)

នៅលើសំណួរថា អ្វីជាទំនៀមទំលាប់នៃការស៊ើបអង្កេត គឺបានរៀបរាប់នៅក្នុង C's នៃការវិភាគឥណទាន ។ ការហៅថា C's នៃឥណទាន គឺបានមកពីអ្នកគ្រប់គ្រងឥណទានរាប់ពាន់ និងប្រឹក្សាជាច្រើន លើកច្រើនសានៅក្នុងសៀវភៅសិក្សាលក្ខន្តិកៈ និងសន្ទរកថា ។ តាមវិធីសាស្ត្រវិនិច្ឆ័យជាច្រើនបានពិភាក្សាអំពីវិធីសាស្ត្រឥណទាន ៥ C's រួមមានៈ ចរិតលក្ខណៈ សមត្ថភាព ដើមទុន វត្ថុបញ្ចាំនិងលក្ខខ័ណ្ឌ ។ C's មួយចំនួនផ្សេងទៀតយោងលើ វត្ថុបញ្ចាំ និងសុភនិស្ស័យ ។ C's ទាំងនេះ ជួយដល់អ្នកគ្រប់គ្រងឥណទាន បំពេញមនសិកាត្រួតពិនិត្យឱ្យបានឆាប់ដូចដែកឆក់ដើម្បីកំណត់បើសិន ប្រភេទពត៌មានបានមើលរំលង ។ ការបញ្ជាក់គុណសម្បត្តិឥណទាន ត្រូវស៊ើបអង្កេតឱ្យបានច្រើនមុននឹង សំរេចផ្តល់ឥណទាន ។

### ចរិតលក្ខណៈ (Character)

- ចរិលក្ខណៈ (Character) គឺជាចំនួនអរូបីយ៍នៃការកំណត់ចរិកផ្ទាល់ខ្លួន ទាក់ទងទៅនឹង សេចក្តី សុច្ចរិត និងភាពខ្លាំងប្រកបដោយសីលធម៌របស់បុគ្គលម្នាក់ៗ ។
- កត្តដែលបញ្ចូលក្នុងចរិកលក្ខណៈ (Character) ស្តីអំពីទំលាប់ផ្ទាល់ខ្លួន និងអាកប្បកិរិយាសំដែងចេញ ដូចជា ការផឹក លេងល្បែងជាដើម ។
- ចរិកលក្ខណៈឥណទាន (Credit Character) និយាយឱ្យចំទៅសំដៅលើចេតនារបស់អ៊ិចិជនឥណទាន សងសំណងតាមការព្រមព្រៀង និន្នាការធ្វើការប្រកាសដោយគ្មានការធានា ឬប្រគល់ ទំនិញត្រឡប់ដោយគ្មានហេតុផល និន្នាកបានប្រាកដ និងទិដ្ឋភាពមិនគោរពសិទ្ធអ្នកដទៃ ។
- មានការលំបាកណាស់សំរាប់អ្នកគ្រប់គ្រងឥណទានកំណត់ និងវាយតំលៃចរិកលក្ខណៈ ។
- ការស៊ើបអង្កេតឥណទានអាចជាអ្នកបកប្រែយ៉ាងជិតស្និទ្ធប្រកបដោយការបកស្រាយបង្ហាញពីគុណសម្បត្តិយ៉ាងសុក្រឹត្យ ។

### សមត្ថភាព លទ្ធភាព (Capacity)

- សមត្ថភាព (Capacity) គឺជាលទ្ធភាពមួយរបស់អ្នកសុំឥណទាន បញ្ជាក់ពីកាតព្វកិច្ចសងជាដុល្លារ ។
- ការវាស់វែងសមត្ថភាពអ្នកសុំ ជាទូទៅពាក់ព័ន្ធទៅនឹងការស៊ើបអង្កេតលើចំណូលនិងការងារ។
- លទ្ធភាពអ្នកសុំយល់ព្រមសង គឺជាការកំណត់កំរិតចំណាយ និងភាពជំពាក់បំណុលផ្សេងៗ ។

- ប្រសិទ្ធភាពចំណូលអាចគ្រប់គ្រាន់គ្របទៅលើបំណុលដែលមានស្រាប់ (ចំណូលទាប ឬបំណុល មានកំរិតខ្ពស់) ។
- ដូច្នេះ ចំណូលអាចនិរន្តភាព និងអាចអាចព្យាករណ៍ទុកជាមុន ។

### ដើមទុន (Capital)

- ដើមទុន (Capital) គឺជាភាពខ្លាំងខាងផ្នែកហិរញ្ញវត្ថុរបស់អ្នកសុំឥណទាន (កំរិតទ្រព្យសកម្មបំរុងទុក reserve assets) ។
- ទ្រព្យសកម្មជាទ្រព្យសកម្មរូបិយ៍ (tangible assets) (រួមមាន សមតុល្យគណនីសំចៃ (savings account balances) ។ និង
- ទ្រព្យសកម្មអរូបីយ៍ (Intangible assets) (រួមមានៈ លទ្ធភាពស្វែងរកការងារផ្សេងៗ ធ្វើបានយ៉ាងរហ័ស ពីព្រោះជំនាញជាឯកទេសភាវូបនីយកម្ម (Specialized skills) និង ចំណេះដឹង) ។
- ទ្រព្យសកម្មទាំងនេះ បង្កលក្ខណៈងាយស្រួលដល់អ្នកសុំឥណទានអាចពឹងពាក់បាន បើសិនហិរញ្ញវត្ថុមានភាពមិនអនុគ្រោះ ។

### វត្ថុបញ្ចាំ (Collateral)

- វត្ថុបញ្ចាំ (Collateral) គឺជាកិច្ចការរបស់អ្នកមានសិទ្ធក្នុងទ្រព្យសម្បត្តិ នៅក្នុងហេតុការណ៍អតិថិជនឥណទានមិនសង ។
- វត្ថុបញ្ចាំ ជាវត្ថុមួយធានាលើកំចី ឬជាកាតព្វកិច្ចឥណទាន អាចទិញទំនិញបានយ៉ាងច្រើនដោយ ប្រើឥណទាន ឬ ទិញ ដោយទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលមាន (មិនប្រើជាវត្ថុបញ្ចាំទៅលើកំចី ពីមុន) ។

### លក្ខខ័ណ្ឌ (Conditions)

- លក្ខខ័ណ្ឌ conditions ជាប្រភេទវិភាគឥណទាន មើលថាតើអ្នកសុំមានសមត្ថភាពសមទៅនឹងប្រព័ន្ធសេដ្ឋកិច្ចទេ តើព្រឹត្តិការណ៍សេដ្ឋកិច្ច នឹងជះឥទ្ធិពលចំពោះលទ្ធភាព និងចេតនាសងរបស់ អ្នកសុំឬទេ ?
- ពន្យល់ថា អ្វីដែលគាត់ធ្វើកំឡុងពេលខែវងារ អាយុ ជំនាញការងារហួសសម័យ ខ្វះចំណេះដឹង និងលក្ខខ័ណ្ឌផ្សេងៗ ដែលជះឥទ្ធិពលលើលទ្ធភាពអ្នកសុំក្នុងការរក្សាចំណូល ។

### សុភវិនិច្ឆ័យ ការវិនិច្ឆ័យ (Common Sense)

- សុភវិនិច្ឆ័យ (Common sense) តំរូវលើការវិនិច្ឆ័យល្អ ។ នេះជាឧបករណ៍វិភាគឥណទាន ជាធម្មតា បានសំដែងវែកញែកបន្ទាប់ពីគណនីបានកំណត់ជាគណនីបំណុលពិបាកទារដែលមិនអាចត្រួតត្រាបាន ។
- ការទទួលខុសត្រូវរបស់អ្នកផ្តល់ឥណទាន គឺដើម្បីកំណត់ថាការបន្តឥណទានគឺមិនត្រឹមត្រូវ។
- កង្វះការត្រួតពិនិត្យទំលាប់ចំណាយរបស់ខ្លួន នាំឱ្យគ្មានការអនុញ្ញាតិឥណទាន ។
- អ្នកវិភាគឥណទានអាចជំនួស សុភវិនិច្ឆ័យរបស់ខ្លួនសំរាប់ជាសុភវិនិច្ឆ័យរបស់អ្នកខ្ចី ។
- C's នៃការវិភាគឥណទាន

* ចរិកលក្ខណៈ character * សមត្ថភាព capacity * ដើមទុន capital

* វត្ថុបញ្ចាំ collateral * លក្ខខ័ណ្ឌ condition * សុភវិនិច្ឆ័យ common sense

### ទំនាក់ទំនងសំខាន់នៃ C's សំរាប់ការវិភាគឥណទាន (Relative Importance of the C's of Credit Analysis)

- នៅក្នុងឥណទានអ្នកប្រើប្រាស់ អ្នកវិភាគឥណទានសង្កត់ធ្ងន់ទៅលើចរិក និងសមត្ថភាព ឥណទាន ជាងកត្តាជាច្រើនដែលមានឥទ្ធិពលលើដើមទុនរបស់អ្នកស្នើសុំ ។
- អ្នកគ្រប់គ្រងឥណទានភាគច្រើន តែងទទួលយកសំណងពីការស្ម័គ្រចិត្ត និងលទ្ធភាពដែលអាច របស់អ្នកសុំជាងពឹងលើការយកមកធ្វើជាកម្មសិទ្ធវិញ (Repossession) ( គឺជាដំណើរស្រប ច្បាប់បានប្រើ ដើម្បីប្រកាសយកការធានា ឬ វត្ថុបញ្ចាំនៅក្នុងព្រឹត្តការណ៍មិនសងកំចី)។
- ការស្ម័គ្រចិត្តសងនឹងពុះពារលើសមត្ថភាពដែលអន់ថយ និងទីបំផុតសងគណនីពេញចំនួន ។
- កង្វះចរិកលក្ខណៈឥណទាន អាចជៀសវាង ឬយឺតយ៉ាវសងបើសិនសមត្ថភាពគ្រប់គ្រាន់ ។

### ៩.១.៣ គុណសម្បត្តិនៃការស៊ើបអង្កេតឥណទាន (Credit to Investigate)

- ការវិភាគឥណទាន C's បានផ្តល់ជាក្របខ័ណ្ឌការងារទូទៅសំរាប់ការស៊ើបអង្កេតឥណទាន ។
- អ្នកគ្រប់គ្រងឥណទាន អាចប្រើគុណភាពឥណទានដែលបញ្ជាក់ក្នុងបញ្ជីដើម្បីស៊ើបអង្កេត បើសិន លោកអ្នកត្រូវការប្រមូលការពិត (Fact) ដើម្បីធ្វើការសំរេចឥណទានឱ្យបានល្អ ។
- ការស្នើសុំឥណទានដែលធ្លាប់ប្រើគឺ ប្រមូលពត៌មានលំអិតឥណទាន ដែលជួយអ្នកវិភាគឥណទានវាយតំលៃហានិភ័យ ដែលពាក់ព័ន្ធនៅក្នុងមូលនិធិឱ្យកំចី ឬ ការបើកគណនីកំចីសំរាប់អតិថិជន ។
- ប្រើប្រព័ន្ធផ្តល់ពិន្ទុឥណទាន ជាមធ្យោបាយជ្រើសរើសដំបូង និងច្រានចោលសំណើរសុំដែលមាន ចំនួនពិន្ទុខ្វះអប្បបរមា ( ក្រុមហ៊ុនធំៗ ) ។
- បញ្ចូលពត៌មានចូលក្នុងប្រព័ន្ធកុំព្យូទ័រ ហើយកុំព្យូទ័រនឹងគណនាផ្តល់ពិន្ទុឥណទាន ។

- បើសិនអាចមានពិន្ទុគ្រប់គ្រាន់ កុំព្យូទ័រនឹងអនុញ្ញាតិបើកគណនីថ្មី កំណត់កំរិតឥណទាន ចេញប័ណ្ណឥណទាន និងបង្កើតប្រអប់រក្សាឯកសារដោយគ្មានអន្តរាគមន៍ពីអ្នកវិភាគឥណទាន ។
- ការផ្តល់ពិន្ទុឥណទានមានការកំរិត ទោះបីមានការពេញចិត្តពីអ្នកប្រតិបត្តិជាច្រើន ក៏ប្រព័ន្ធនេះនៅតែមិនអាចទស្សន៍ទាយពីលក្ខណៈសម្បត្តិដែលអាចទទួលឥណទានបានល្អឥតខ្ចោះដែរ ។

## ការកត់ត្រាសំណង (Payment Record)

- មានចំណុចសំខាន់ជាច្រើនសំរាប់ពិចារណានៅទីនេះគឺថាតើអ្នកប្រើប្រាស់អាចមិនសង និងថាតើ គាត់នឹងសងទេ ។
- ការស៊ើបអង្កេតឥណទានគួរស្វែងរកការពិតអំពីប្រភេទគណនីពាក់ព័ន្ធ ចំនួនជំពាក់ថ្មី១ ចំនួនហួស កាលកំណត់ឥណទានខ្ពស់បំផុតកំពុងមានថ្មីៗ និងរបៀបសង ។
- របៀបសងគួរបានចាប់ផ្តើម ជាពិសេសសងក្នុង៣០ទៅ៦០ ថ្ងៃ សងក្នុង៩០ថ្ងៃជាដើម ។
- បទពិសោធន៍ដែលមានរាល់ថ្ងៃអាចបង្កើតបាន (ចំណូល និងការខាតបង់បន្ទុកការប្រមូលតាមរយៈការវិនិច្ឆ័យ ឬការយកមកធ្វើជាកម្មសិទ្ធិវិញបានកើតឡើងពេលកន្លងមក ចាត់ទុកជាបទពិសោធន៍ ថ្មីៗ) ។

## ទ្រព្យសកម្មបំរុង (Reserve Assets)

- មានបីបួនករណីប៉ុណ្ណោះ ដែលម្ចាស់បំណុលអាចឆ្លើយតបលើទ្រព្យសម្បត្តិបំរុងសំរាប់កាតព្វកិច្ច សងបំណុលរបស់អ្នកប្រើប្រាស់ឥណទាន ។
- ក្នុងករណីជាច្រើន ទ្រព្យសកម្មបំរុង មិនត្រូវការទាំងម្ចាស់បំណុល និងកូនបំណុល ។
- ក្នុងករណីខ្លះ ជាពិសេសជាមួយអតិថិជនមានវ័យចំណាស់ ដែលគាត់រស់នៅពឹងលើប្រាក់និវត្តន៍ ឬចំណូលពីការបណ្តាក់ទុន ដូច្នេះការស៊ើបអង្កេតទ្រព្យសកម្មបំរុងអាចនឹងចាំបាច់ក្នុងបញ្ញតិ ដើម្បី បង្កើតលទ្ធភាពទទួលបន្ទុកកាតព្វកិច្ចឥណទាន ។
- នៅពេលពិចារណាលើទ្រព្យកម្មសិទ្ធ អ្នកវិភាគគួរជៀសវាងកំណត់អ្វីៗជាវិជ្ជមានទាំងស្រុង នៅពេលនេះ គួរវិភាគដោយប្រុងប្រយ័ត្ន ហើយ អាចសង្កត់ធ្ងន់ជាលក្ខណៈអវិជ្ជមាន ។
- អ្នកមានសិទ្ធិជាម្ចាស់ផ្ទះ អាចមានសំណងនិក្ខេបជាបន្ទុក (ប្រើចំណូលជាច្រើនជាមួយការជាប់សន្យា) ។

## សមធម៌នៅក្នុងការទិញ (Equity in Purchase)

- បញ្ហាចំបងៗ ជាពិសេសអ្នកប្រើប្រាស់ទិញដោយសងរំលស់។ ការទិញទំនិញជាច្រើនប្រភេទដែលមានទ្រង់ទ្រាយធំហើយផ្តល់ហិរញ្ញវត្ថុតាមរយៈឥណទានសងរំលស់ ពាក់ព័ន្ធនឹង លក្ខខ័ណ្ឌ កិច្ចសន្យាលក់ ។
- លក្ខខ័ណ្ឌកិច្ចព្រមព្រៀងលក់ (Conditional sales agreement) គឺកិច្ចសន្យា ដែលមាន គំរោង លក្ខខ័ណ្ឌ និងកាតព្វកិច្ចសំណងលើការទិញទំនិញឥណទាន ។

- ជាក់ស្តែងមិនអាចផ្តល់ភាពជាម្ចាស់តាមប្រភេទទំនិញដែលបានទិញទេ រហូតដល់សំណងបានសងអស់ ។ ដូច្នេះ ទំនិញស្ថិតនៅក្រោមការគ្រប់គ្រងរបស់អ្នកលក់រហូតដល់សំណងបានសងអស់ ។
- សមធម៌នៅក្នុងការទិញ ស្តីពីតំលៃទីផ្សារទ្រព្យសម្បត្តិ ។

### វត្ថុបញ្ចាំ (Collateral)

- វត្ថុបញ្ចាំ ខ្វះរនៅក្នុងប្រតិបត្តិការឥណទានរាយ និងឥណទានសេវាកម្ម វាតែងពាក់ព័ន្ធក្នុងកំចីជា សាច់ប្រាក់របស់អ្នកប្រើប្រាស់ ។
- វត្ថុបញ្ចាំ រួមមាន ទ្រព្យសកម្មរូបីយ៍ ជាកម្មសិទ្ធរបស់បុគ្គលដែលបានផ្តល់ ដើម្បីបន្ថែមការធានាដល់ស្ថានភាពខ្វីនេះជាគុណសម្បត្តិឥណទានផ្សេងទៀតដែលគួរពិចារណា ។

### បំណងសំរាប់ឥណទាន (Purpose for the Credit)

- មានបំណងខ្លួនតំណាងវិនិយោគ ហើយជាក់ស្តែងជំរុញនូវស្ថានភាពហិរញ្ញរបស់អ្នកស្នើសុំ ។
- ឧទាហរណ៍ ផ្តល់កំចីដល់ការរៀបចំនិងជួសជុលផ្ទះលទ្ធផលអនុវត្តបង្កើនតំលៃចលនៈទ្រព្យ ។
- បំណងផ្សេងៗទៀតកំចីវិសម្បកាល តំណាងអោយការចំណាយលើចំនួនប្រើប្រាស់សុទ្ធ ដោយគ្មានតំលៃមូលនិធិត្រឡប់បន្ទាប់ពីមូលនិធិបានចំណាយ ។
- ភាពអាក្រក់ដែលកើតមានជានិច្ចនោះ មានសំណើសុំសំរាប់មូលនិធិខ្លះអាចបណ្តាលមកពីកង្វះ ការអនុវត្តគ្រប់គ្រងរូបិយវត្ថុ ។
- ឧទាហរណ៍ កំចីរួមគ្នាដើម្បីជួយក្រុមគ្រួសារដែលជួបប្រទះការចំណាយប្រចាំខែទាប ។
- សួររកមូលនិធិដើម្បីបង់ឱ្យទៀងទាត់ ដូចជាថ្លៃផ្ទះជួល ។

## ៩.១.៤ អនុភាពនៃលក្ខខ័ណ្ឌសេដ្ឋកិច្ច (Influence of Economic Conditions)

- ថ្ងៃនេះអ្នកវិភាគឥណទានជាច្រើនអាចទទួលរូបភាព ជាបុគ្គលទទួលខុសត្រូវសមរម្យមួយតាមរយៈសំណួរដោយសេរី ។
- គេតែងប្រឈមមុខចំពោះបញ្ហានៃការបកស្រាយរាល់ពត៌មាននៅក្នុងលក្ខខណ្ឌបរិយាកាសសេដ្ឋកិច្ចបច្ចុប្បន្ន ។
- បរិយាកាសសេដ្ឋកិច្ចអាចជាផ្នែកមួយនៃចំណេះដឹងរបស់អ្នកវិភាគជាទូទៅ ។
- អ្វីទៅជាផលប៉ះពាល់ដល់រោងចក្រឧស្សាហកម្ម ? អ្វីដែលអាចទាយទុកអំពីការបញ្ឈប់ការងារបុគ្គលិក ? តើអាកាសធាតុនេះរាំងស្ងួត ឬសើម ហើយអ្នកកសិដ្ឋានចាប់ផ្តើមជួបផលវិភាគបែបណា ?
- អ្នកវិភាគ គួរដឹងថា "អ្វីទៅជាអាជីវកម្ម ?" ដែលមាននៅក្នុងតំបន់ឧស្សាហកម្ម និងជុំវិញតំបន់ឧស្សាហកម្មរបស់ខ្លួន ។
- ការជឿជាក់លើនយោបាយ ទស្សនៈអន្តរជាតិ ស្ថានភាពហិរញ្ញវត្ថុ និងបទពិសោធន៍នៅក្នុងសមិទ្ធិកម្ម តួនាទីរបស់គេបច្ចុប្បន្ន ជាពណ៌នៃទស្សនៈ ។

- ផ្ទុយមកវិញ ជាមួយទស្សនៈរយៈពេលខ្លី និងរយៈពេលវែងនៃលក្ខខ័ណ្ឌសេដ្ឋកិច្ច អ្នកគ្រប់គ្រងអាចបកស្រាយអំពីពត៌មានដែលគេទទួលបានពីសំណើសុំឥណទានដើម្បីធ្វើការសំរេចទទួល ឬច្រានចោលឥណទាន ។

### ៩.១.៥ តើត្រូវធ្វើការស៊ើបអង្កេតប៉ុន្មាន (How Much to Investigate)

ការស៊ើបអង្កេតឥណទាន (Credit Investigation) គឺជាអាជីវកម្មមួយ ជំនួយដល់ការស្ទាបស្ទង់ ការសំរេចឥណទាន ។

- អ្នកវិភាគឥណទានអាចប្រឈមមុខនឹងបញ្ហា តើការស៊ើបអង្កេតប៉ុន្មានដែលត្រូវការ ។
- អ្នកប្រតិបត្តិឥណទាន ជានិច្ចជាកាល បានធ្វើដំណើរលើខ្សែលួស នៅក្នុងការសំរេច នៅពេលគេ មានពត៌មានគ្រប់គ្រាន់បំពេញនូវលក្ខខ័ណ្ឌ ត្រឹមត្រូវ និងមានថ្លៃដើម ។
- ពត៌មានមិនគ្រប់គ្រាន់អាចជាមូលហេតុភ័ន្តច្រឡំនៅក្នុងការវិនិច្ឆ័យ ។
- ការពង្រីកការចំណាយលុយ និងការចំណាយពេលវេលាលើការស៊ើបអង្កេត មានន័យថា ការសំរេចនឹងពន្យាជាមួយផលវិបាកនៃការបាត់បង់កេរ្តិ៍ឈ្មោះ និងការរង្គាសចិត្តពីអតិថិជន ជាមួយអ្នកតំណាងលក់ ។
- បើសិនពត៌មានបំពេញគ្រប់គ្រាន់ មិនមានចំណាយលុយ ឬពេលវេលាបន្ថែមទេ ។
- ជាឱកាសដ៏ល្អ គួរសន្សំថវិកាលើការស៊ើបអង្កេត សំរាប់ជំនួសកន្លែងដែលមានករណីកើតឡើងស្ទួន ។
- ការប្រមូលរាល់ភ័ស្តុតាងជាវិជ្ជមានវាមិនមែនជាសេចក្តីប្រាថ្នាទេមុននឹងការមកដល់ការសំរេចចិត្តផ្តល់ឥណទាន ។

### ៩.១.៦ កន្លែងណាដែលត្រូវស៊ើបអង្កេត (Where to Investigate)

- វាគួរស្វែងរកប្រភពពត៌មានច្បាស់ៗ ដែលធ្វើឱ្យពត៌មានដំណើរការល្អ ឬ អាចទទួលបាន ពត៌មាន ត្រឹមត្រូវ ពេញលេញ លឿនយ៉ាងរហ័ស និងចំណាយថ្លៃដើមអប្បបរមា ។
- ពត៌មានជាវត្ថុធាតុដើមនៃការសំរេចឥណទាន ។
- មូលដ្ឋានដ៏ល្អបំផុតសំរាប់ចលនាលំហូរ នៃពត៌មានឥណទានច្បាស់លាស់ នោះគឺការដោះដូរ ពត៌មាន ។
- ប្រភពពត៌មានដែលត្រឹមត្រូវបំពេញគ្រប់ជ្រុងជ្រោយ លឿន និងជាហេតុផលដែលមានតំលៃរួមមាន អ្នកសុំឥណទានរបស់គេផ្ទាល់ ការស៊ើបអង្កេតដោយផ្ទាល់ បញ្ជីក្នុងសៀវភៅធំ (in-file ledgers) និងភ្នាក់ងាររកស៊ីលក់របាយការណ៍ឥណទានអ្នកប្រើប្រាស់ ធនាគារ និង ប្រភពទំនិញ ផ្សេងៗ ។

### ៩.១.៧ ការផ្គត់ផ្គង់ពត៌មានដោយអ្នកស្នើសុំឥណទាន

#### ការស្នើសុំឥណទាន (The Credit Application)

- ការិយាល័យឥណទានជាច្រើនប្រើទំរង់ការជាផ្លូវការសំរាប់បើកគណនីឥណទាន ។

- ការចុះហត្ថលេខាជាកត្តាមួយសំខាន់ណាស់នៅក្នុងប្រតិបត្តិការឥណទាន ( ការសងរំលស់ទៀងទាត់ និង ឥណទានវិល ) ហើយជាលទ្ធផលនោះគឺ បន្ទុកហិរញ្ញវត្ថុ ។

### ក. ករណីសំរាប់សំណើសុំជាផ្លូវការ (The Case for a Formal Application)

- ដំណើរការស្នើសុំឥណទានជាផ្លូវការ (Formal application) ពាក់ព័ន្ធទៅនឹងទំរង់បែបបទឥណទានទូលំទូលាយ ដែលបានប្រើវាសំរាប់ប្រមូលពត៌មានឥណទាន អំពីគុណសម្បត្តិ ឥណទានរបស់អ្នកស្នើសុំ ទៅតាមការសំភាសន៍ដោយផ្ទាល់ ។
- បំពេញពត៌មានដែលអាចយកបានដ៏ល្អបំផុតដោយការសួរទៅអ្នកស្នើសុំដើម្បីបំពេញសំណើសុំអោយគ្រប់ជ្រុងជ្រោយ ។

### ខ. ករណីសំរាប់សំណើសុំមិនផ្លូវការ (The case for an Information Application)

- របៀបសំណើសុំមិនផ្លូវការ (Informal application) ជាដំណើរការមួយពាក់ព័ន្ធបែបបទ ឥណទានខ្លី ដែលបំពេញដោយអតិថិជន និងនាំទៅឱ្យអ្នកផ្តល់ឥណទានសំរាប់ដំណើរការ ឥណទាន ទន្ទឹមនឹងនេះ ក្រុមហ៊ុនក៏បានបង្ហាញទៀតថាវាជាឧបករណ៍ផ្សព្វផ្សាយការលក់ ។
- ក្រុមហ៊ុនខ្លះជឿយ៉ាងខ្លាំងថា ការស៊ើបអង្កេតឥណទានដែលមិនផ្លូវការគឺប្រាថ្នាចង់បាន ។ ហើយគេបង្ហាញថាឥណទានដូចជា ឧបករណ៍មួយផ្សព្វផ្សាយលើកទឹកចិត្តចំពោះការលក់ ។
- ការផ្សាយពាណិជ្ជកម្មមានលក្ខណៈងាយស្រួល និងអ្នកប្រើប្រាស់អាចទទួលមើល អាន ដឹង ដូច្នេះឥណទានក៏គួរមានលក្ខណៈងាយស្រួលទទួលយកបាន ។

### គ. តើពត៌មានអ្វីគួរតែត្រូវបានស្នើ? (What Information Should Be Requested?)

- មានពត៌មានបន្ថែមតិចតួច ដើម្បីផ្ទៀងផ្ទាត់បញ្ជាក់នូវពត៌មាន គឺទីកន្លែងធ្វើការងារ និងមុខងារជាអាជីពពត៌មានដែលដ៏ល្អមួយទៀតរយៈពេល ( និងអាស័យដ្ឋានពីមុន ឬ ការងារដែលធ្វើ បើសិនតិចជាងមួយឆ្នាំ ) ។

#### ហត្ថលេខា និង កិច្ចសន្យា (Signature and Contact)

- ការអនុវត្តដែលល្អចំពោះឥណទាន គឺឱ្យអ្នកសុំឥណទានចុះហត្ថលេខាលើពាក្យសុំ ។
- យើងអាចបន្ថែមពាក្យនៅខាងលើកន្លែងចុះហត្ថលេខា ដើម្បីធ្វើឱ្យសំណើសុំជាកិច្ចសន្យាផ្លូវការមួយ ។

#### ការសំភាសន៍ឥណទាន (The Credit Interview)

- ការសំភាសន៍ឥណទានគួរស្របទៅតាមចរិកលក្ខណៈរបស់សំណើសុំ និងទស្សនជាមតិយោបល់ របស់ការិយាល័យឥណទាន ។
- ការបង្កើតចំលើយលើសំណួរតាមរយៈការសំភាសន៏ និងកត់ត្រាពត៌មានលើបែបបទសុំ ។

- សួរអ្នកស្នើសុំឱ្យបង្ហាញបែបបទសុំដំបូងជាសេចក្ដីសង្ខេបដែលបានសភាសន៍ជាមួយអ្នកវិភាគឥណទាន ហើយអ្នកវិភាគបានពិនិត្យបែបបទសុំ និងសួរសំណួរបន្ថែមទៀត ។
- លទ្ធភាពរបស់មន្ត្រីឥណទានសំរាប់តែធ្វើការសំភាសន៍ ហើយសំខាន់នោះ បង្កលក្ខណៈងាយស្រួលដល់ក្រុមហ៊ុននៅក្នុងការសំរេចលើសំណួរដែលសួរ ។
- ជំនាញអ្នកសំភាសន៍ អាចរក្សានូវព័ត៌មានជាច្រើន នឹងដឹងអំពីឥរិយាបទឥណទានដែលខុស និងត្រូវ ។
- ក្រដាសបំពេញបែបបទគួរទុកកន្លែងទំនេរខ្លះសំរាប់កត់ត្រាព័ត៌មានលើស ( អ្នកធ្វើសំភាសន៍គួរ តែកត់ត្រាព័ត៌មានបន្ថែមបន្ទាប់ពីអតិថិជនចាកចេញ ) ។
- លំនឹងប្រាក់ចំណូល គឺជាភាពសំខាន់នៃចំនួនទឹកប្រាក់នៅក្នុងការវាយតំលៃហានិភ័យឥណទាន ដូច្នេះ វាអាចសំដែងតួនាទីយ៉ាងសំខាន់នៅក្នុងការសិក្សាអំពីឥណទាន ។
- ការលក់ជាឥណទានជះឥទ្ធិពលដោយផ្ទាល់ចំពោះអ្នកមានលទ្ធភាពផ្នែកហិរញ្ញវត្ថុ ពាក់ព័ន្ធការសងរំលស់ និងការទិញឥណទានវិល ឬ កើតឡើងចំនួនទឹកប្រាក់នៅលើការបើកគណនីទិញ
- បច្ចេកទេសនៃការលក់ គួរទាក់ទាញចំនួនមនុស្សបានយ៉ាងច្រើនជាមួយចំណូលទៀងទាត់ដើម្បី ធ្វើអោយផលិតផលផ្លាស់ទីពីការរក្សាទុករបស់ហាងលក់រាយទៅដៃអតិថិជន ។
- ការសំរេចថាតើធ្វើការស៊ើបអង្កេតឥណទាន និងបើស៊ើប  អ្វីទៅជាមូលដ្ឋានលើការវិភាគនៃសំណើ សុំ ។
- សំណើសុំ និងការសំភាសន៍ជាប្រភពដំបូងសំរាប់ធ្វើការកំណត់សកម្មភាពអនាគតជាមួយការផ្ដួចផ្ដើមសុំរបស់អ្នកស្នើសុំឥណទាន ។

# ជំពូក ១០ ប្រវត្តិនៃវិវត្តន៍របស់ប្រព័ន្ធមូលនិធិអន្តរជាតិ

## ១០.១ មូលនិធិរូបិយវត្ថុអន្តរជាតិ

មូលនិធិរូបិយវត្ថុអន្តរជាតិបានបង្កើតឡើងដំណាលគ្នាជាមួយធនាគារពិភពលោកក្នុងឆ្នាំ ១៩៤៤ ។ មូលនិធិនេះ មានបេសកម្មសំខាន់ៗមួយចំនួនដូចជាៈ

1. ពង្រឹងរាល់កិច្ចសហប្រតិបត្តិការណ៍រូបិយវត្ថុអន្តរជាតិតាមរយៈស្ថាប័នអចិន្ត្រៃយ៍ដើម្បីធ្វើការសហការដោះស្រាយបញ្ហារូបិយវត្ថុ ។
2. លើកទឹកចិត្តការពង្រឹងស្មើភាពពាណិជ្ជកម្មដែលមានទិសដៅឈានទៅរកការលូតលាស់សេដ្ឋកិច្ច ដាក់ស្តែងធនធានការងារដ៏សំបូរបែប ។
3. ពង្រឹងស្ថេរភាពអត្រាប្តូរប្រាក់តាមរយៈកិច្ចសហប្រតិបត្តិការណ៍អន្តរជាតិ ។
4. លើកទឹកចិត្តដល់ប្រព័ន្ធពហុចំណាយប្រតិបត្តិការរវាងបណ្តាប្រទេសជាសមាជិក និង លុបបំបាត់ចោលការគាបសង្កត់ទៅលើអត្រាប្តូរប្រាក់ដែលជាសញ្ញាណមិនល្អដល់សេដ្ឋកិច្ចជាតិ ។
5. បង្កើតមូលនិធិរបស់មូលនិធិរូបិយវត្ថុអន្តរជាតិបណ្តោះ អាសន្នសំរាប់បណ្តាប្រទេសជាសមាជិកនៅពេលដែលប្រទេសទាំងនេះកំពុងជួបប្រទះនូវវិបត្តិតុល្យភាពថវិកាដែលចាត់ទុកដូចជាវិធានការការពារទៅការប៉ះពាល់ដល់សេដ្ឋកិច្ចជាតិ និងអាចឈានដល់ការប៉ះពាល់សេដ្ឋកិច្ចអន្តរជាតិ ។
6. ដោយផ្អែកទៅលើកត្តាទាំងប្រាំខាងលើ ការកាត់បន្ថយអតុល្យភាពថវិការវាងបណ្តាប្រទេសទាំងអស់ជាសមាជិក គឺជាកាតព្វកិច្ចចាំបាច់ ។

មូលនិធិរូបិយវត្ថុអន្តរជាតិមានលេខកូដសំងាត់សំរាប់សំគាល់សេដ្ឋកិច្ច ដែលត្រូវតែព្រមព្រៀងផ្តល់ដោយ ប្រទេសជាសមាជិក និង ជាថ្នូរវិញនូវជំនួយហិរញ្ញវត្ថុ ។ មូលនិធិរបស់អង្គការនេះ បានមកពីប្រទេសចំនួន ១៥១ ដែលភាគច្រើនមានការគាំទ្រ និង ចូលរួមដោយបណ្តាប្រទេសឧស្សាហកម្មទាំងអស់ និង បណ្តា ប្រទេសនានានៅអាស៊ី អាព្រិច និង អឺរ៉ុប លើកលែងតែប្រទេសស្វីសដែលទទួលលក្ខខ័ណ្ឌជាយូរ៉ូអន្តរជាតិ

គណនីសមាជិកភាពទាំងមូលមានចំនួន ៨០ ភាគរយនៃផលិតកម្មសរុបរបស់ពិភពលោកនិងមានចំនួន ៩០ ភាគរយនៃពាណិជ្ជកម្មពិភពលោក។ កូតា និង ការសុំជាវត្រូវបានកំនត់ដោយការប្រើប្រាស់តារាង រូបមន្តគណិតសាស្ត្រស៊ាំញ៉ាំមួយដែលគេថ្លឹងថ្លែងទៅលើចំណូលជាតិនិងលទ្ធភាពសំណងវិញ។

## ១០.២. ធនាគារពិភពលោក

ធនាគារពិភពលោកចាប់បដិសន្ធិកាលតាំងពីឆ្នាំ ១៩៤៤ និង ជាកម្មសិទ្ធរបស់ប្រទេសចំនួន ១៥០ ។ កាលពីពេលមុនធនាគារនេះមានឈ្មោះថាធនាគារអន្តរជាតិសំរាប់ស្ថាបនាឡើងវិញ និង អភិវឌ្ឍន៍ ហើយបេសកម្មជាចំបងនៃធនាគារនេះ  គឺផ្តល់ហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង ផ

លិតភាពនៅ ក្នុងបណ្តាប្រទេសជាសមាជិក តាមរយៈការលក់កិច្ចសន្យាជំពាក់ទាំងឡាយទៅដល់រដ្ឋាភិបាល និង អ្នកវិនិយោគទុនឯកជន។ មូលដ្ឋានហិរញ្ញវត្ថុនៃធនាគារពិភពលោករួមមានៈ ការស៊ុំជាវពីប្រទេសនានាជា សមាជិក ការបន្សល់ចំណូល និង ការហូរចូលចំណូលដោយការសងវិញនូវកំចី។ មូលធនទាំងនេះចូលរួម ចំណែកយ៉ាងសំខាន់បំផុតសំរាប់ធនធានធនាគារពិភពលោក។

គោលបំណងជាសារវន្តៃរបស់ធនាគារពិភពលោក គឺ សំរាប់តែលំអរាល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅបណ្តា ប្រទេសតតិយលោក ។ មូលនិធិដែលធនាគារបង្កើតឡើង គឺជាប្រភពហិរិញ្ញវត្ថុដ៏ធំបំផុតសំរាប់ប្រទេស កំពុងអភិវឌ្ឍន៍ ជាពិសេស ក្នុងរវាងឆ្នាំ ១៩៧៩ រហូតដល់ ១៩៨៦ កិច្ចសន្យាផ្តល់កំចីបានកើនឡើងរហូត ដល់ ៤២ ភាគរយ ដោយមានតួលេខជាទឹកប្រាក់ ១១.៥ កោដិ ដល់ ១៦.៣ កោដិ ។ ធនាគារពិភពលោក បានផ្តល់នូវគំរោងកំចីយ៉ាងសាមញ្ញ និង គំរោងកំចីសំរាប់កែទំរង់រចនាសម្ព័ន្ធនយោបាយមូលដ្ឋាន ( រចនា សម្ព័ន្ធនានា ដែលមិនមែនជានយោបាយកំពូលរបស់រដ្ឋ ជាពិសេសថ្នាក់រិះមន្ត្រីចុះ ) ដែលមានទិសដៅ ផ្តោតជាសំខាន់ទៅលើប្រទេសតតិយលោកដែលជំពាក់ប្រាក់ជាច្រើន ។ នៅឆ្នាំ ១៩៨៦ ធនាគារពិភព លោកបានប្រកាសពិនិត្យជាថ្មីអំពីទំនាក់ទំនងនៃជំនួយជាមួយនឹងតួនាទីចលករបង្កើនការលូតលាស់ អភិវឌ្ឍន៍សេដ្ឋកិច្ច នៅបណ្តាប្រទេសជំពាក់ទាំងអស់ដែលមានចំណូលមធ្យម ។ ធនាគារបានប្រតិបត្តិ ដូចជាៈ

- ជំនួញសំរាប់ការអភិវឌ្ឍន៍ ការប្រតិបត្តិ និង អង្កេតទៅលើការកែទំរង់រដ្ឋបាលនៅក្នុងបណ្តាប្រទេសជាសមាជិកទាំងអស់ ដែល ធនាគារយល់ឃើញថាៈ គេបានបង្ហាញ និង សំរេចបាននូវឆន្ទៈក្នុងនយោបាយកំនែទំរង់របស់គេ។
- ធនាគារពិភពលោកអាចពង្រីកនូវការផ្តល់កំចីទៅលើកម្មវិធីខាងលើ
- ធនាគារពិភពលោកមានសក្តានុពលភាពជាតួនាទីកតាលីកម្មួយក្នុងការផ្តល់កំចីជាអន្តរជាតិ លុះត្រាណាតែប្រទេសទទួលកំចីនោះបានបំពេញចិត្ត និង យល់ព្រមពីប្រទេសដែលមានឥណទានជាច្រើននៅក្នុងធនាគារពិភពលោក ។

ដោយសារពេលវេលាក្នុងការសិក្សារបស់យើងមានកំនត់ យើងពិតជាមិនអាចវិភាគស៊ីជំរៅទៅក្នុងទស្សនៈវិស័យនៃធនាគារពិភពលោក និង មូលនិធិរូបិយវត្ថុអន្តរជាតិបានទេ ក៏ដូចជាបទពិសោធន៍ការជោគជ័យ និង បរាជ័យនៃប្រទេសក្រីក្របានទេ ។ បើលោក -អ្នកចង់ស្វែងយល់អាចសិក្សាបន្តនៅក្នុង សេដ្ឋកិច្ចអភិវឌ្ឍន៍ ។ ប៉ុន្តែជាគោលការណ៍ អ្នកសិក្សាត្រូវចាំថាៈ ធនាគារពិភពលោក និងមូលនិធិរូបិយ វត្ថុអន្តរជាតិបានចាត់ថ្នាក់កំរិតកំចី និង ជំនួយតាម ប្រទេស អភិវឌ្ឍន៍ និង ប្រទេសតតីយលោក ទំហំនៃ ការលូតលាស់សេដ្ឋកិច្ចក្នុងលក្ខ័ខណ្ឌប្រទេសនីមួយៗ លទ្ធភាពរំលោះបំណុល និង កិច្ចសន្យារបស់ រដ្ឋាភិបាលនីមួយៗផងដែរ ។

# ជំពូកទី ១១ គោលបំណងនយោបាយរូបិយវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ

## ១១.១ គោលបំណងនយោបាយរូបិយវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ

នយោបាយរូបិយវត្ថុជាផ្នែកមួយ នៃនយោបាយគ្រប់គ្រងតំរូវការរួមដែលធនាគារប្រើប្រាស់នៅពេលដែលស្ថានភាពរូបិយវត្ថុ និង ហិរញ្ញវត្ថុមានដំណើរការមិនប្រក្រតី ដូចជាអតិផរណាកើនឡើងរដ្ឋាភិបាលមានកង្វះខាតថវិកាជាចាំបាច់ ។ នយោបាយនេះពាក់ពន្ធជាសំខាន់ទៅលើដំណើរប្រតិបត្តិ ការទីផ្សាររូបិយវត្ថុ ការទិញ និង លក់ប័ណ្ណជានារបស់រដ្ឋាភិបាល និង អត្រាការប្រាក់ ។ រាល់ដំណើរ ការខាងលើនេះអស់លោកអ្នកសិក្សាបានសិក្សារួចមកហើយនៅក្នុងម៉ាក្រូសេដ្ឋកិច្ច ។ ដូច្នេះ យើង អាចឈោងចាប់ទៅរកគោលដៅជាយុទ្ធសាស្ត្រទូទៅតែម្តងនៃនយោបាយរូបិយវត្ថុ។ អាស្រ័យដោយ លោក Taylor, J. (1998) បានបញ្ជាក់ថាយុទ្ធសាស្ត្រជាទូទៅនៃធនាគារកណ្តាលដែលចាប់ធ្វើ ប្រតិបត្តិការនយោបាយរូបិយវត្ថុមានគោលបំនងផ្តោតទៅលើ៖

- ការបង្កើតការងារលើវិស័យធនាគារ និង សេវាហិរញ្ញវត្ថុ ព្រមទាំងការងារសង្គមដទៃទៀត
- ការវិវត្តន៍សេដ្ឋកិច្ច
- ស្ថេរភាពថ្លៃទំនិញ និង សេវាកម្មនានា
- ស្ថេរភាពអត្រាការប្រាក់
- សុវត្ថិភាព និង ស្ថេរភាពទីផ្សារហិរញ្ញវត្ថុ
- ស្ថេរភាពទីផ្សារប្តូរប្រាក់អន្តរជាតិ

គួរកត់សំគាល់ថារាល់គោលដៅជាសារវន្តខាងលើនេះសុទ្ធតែមានភាពប្រទាក់ប្រទង់ជាមួយនយោបាយដទៃទៀតរបស់រដ្ឋាភិបាល ។ ដូច្នេះ ទោះបីជាធនាគារកណ្តាល រឺ ធនាគារជាតិមានអនុភាពបែបណា ក៏ដោយ មានយុទ្ធសាស្ត្រខ្លះដែលធនាគារអន្តរាគមន៍ក៏មិនសំរេចបានទាំងស្រុងនោះទេ ។ ឧទាហរណ៍ ការវិវត្តន៍សេដ្ឋកិច្ចមិនគ្រាន់តែពាក់ព័ន្ធទៅលើធនាគារបន្ថយការប្រាក់ប៉ុណ្ណោះទេ យើងត្រូវការអោយរដ្ឋាភិបាលខិតខំបន្ថែមទៀតទៅលើនយោបាយដទៃទៀតដូចជា នយោបាយសារពើពន្ធ ការធានាដល់សុវត្ថិភាពវិនិយោគិន ការនាំចេញសុទ្ធសាធ ។ល ។

## ១១.២. ការបង្កើតការងារ

រដ្ឋាភិបាលបានផ្តល់សិទ្ធដល់ធនាគារកណ្តាលជាអ្នកដើរតួសំខាន់ ក្នុងទីផ្សារហិរញ្ញវត្ថុ ហើយ គោលដៅ ដែលរដ្ឋាភិបាលចង់បាន គឺ អោយធនាគារនេះបង្កើតគោលនយោបាយនានាដើម្បីបង្កើតការងារអោយបានច្រើន ។ ធនាគារកណ្តាលត្រួតពិនិត្យ :

- ស្ថាប័នហិរញ្ញវត្ថុដទៃទៀតមិនអោយដួលរលំ ព្រោះជាប្រភពការងារសំរាប់រាស្ត្រ ។ ជួនកាល ធនាគារកណ្តាល បញ្ចេញលុយតំកល់ទុក សំរាប់ជួយស្រោចស្រង់អន្តរការីហិរញ្ញវត្ថុ ដែលរកកល នឹងរលំ ។
- ការប្រកួតប្រជែងប្រកបដោយសុក្រិតភាព ដើម្បីជៀសវាងនូវអំពើផ្តាច់មុខ ហើយប៉ះពាល់ដល់ ការងាររបស់ប្រជាពលរដ្ឋ និង ផលវិបាកដល់សង្គម-សេដ្ឋកិច្ច ។
- ពង្រីកសាខាធនាគារឯកទេសកម្មតាមបណ្តាខេត្តដែលក្តីសង្ឃឹមរបស់រាស្ត្រ ក្នុងការរកការងារ។ ធនាគារកណ្តាល គឺជួយសំរួលដល់ធនាគារឥណទាននានា និង ធនាគារឯកជន រឺ ពាណិជ្ជកម្ម ទាំងឡាយដែលមានលទ្ធភាពពង្រីកសាខាខាងក្រៅរាជធានីភ្នំពេញ ។
- ធ្វើទំនាក់ទំនងជាមួយធនាគារបរទេស ស្របគ្នាជាមួយការបណ្តុះបណ្តាលបុគ្គលិកដើម្បីអោយគេមានលទ្ធភាព ចូលសហការងារជាមួយធនាគារឆ្លើយឆ្លង ។ បទពិសោធន៍បុគ្គលិក គឺជាធនធាន ដ៏មានតំលៃសំរាប់អភិវឌ្ឍន៍វិស័យធនាគារនៅកម្ពុជា និងពង្រឹងរចនាសម្ព័ន្ធធនាគារ។ យើងគួរ យកគំរូតាមសិង្ហបូរី វៀតណាម និង ហ្វីលីពីន។
- ធនាគារកណ្តាលត្រូវតែបញ្ចុះបញ្ចូលធនាគារបរទេស និង អន្តរជាតិ ទាំងអស់អោយទទួលកិច្ចសន្យាបណ្តុះបណ្តាលបុគ្គលិក និង ផ្តល់ការងារដល់អ្នកទាំងនោះ ។ ចំពោះធនធានដែលមានស្រាប់ ធនាគារត្រូវតែបញ្ចូលទៅសហការជាមួយធនាគារទាំងនោះ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលកំពុងមានសាខានៅកម្ពុជា ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ីដែលមានសាខានៅប្រទេសយើង ។ ការប្រើប្រាស់អ្នកជំនាញក្រៅប្រទេសមិនគ្រាន់តែបង្កនូវការបាត់បង់ការងារមួយចំនួន និង ទ្រព្យសម្បត្តិដែលត្រូវហូរចេញក្រៅនោះទេ ថែមទាំងស្មារតីអភិវឌ្ឍន៍ដែលត្រូវការពីបុគ្គលិកត្រូវបាត់តាំងពីពេលបច្ចុប្បន្ន និង ទៅអនាគត។ យើងគ្រាន់តែលើកយកផលវិបាកនៃការបាត់ការងារ មួយប៉ុណ្ណោះ វាអាចកើតឡើងបញ្ហាជាច្រើនដូចជា:
    - ការបាត់បង់ចំណូល
    - ការបាត់បង់ទ្រព្យធនបុគ្គលិក
    - កំនើនឧក្រិដ្ឋកម្ម
    - កំនើនភាពតានតឹងដល់សង្គម និង គ្រួសារ
    - ការបាត់បង់ភាពថ្លៃថ្នូររបស់មនុស្ស
- ការធ្វើសនិទានកម្មការងារ និង ការភ្ជាប់ការងារតាមដែលអាចធ្វើបាន ដូចជា: ការពង្រីក សេវាកម្ម និង ការបែងចែកការងារដែលមានចំនុះ ធំ ។ ជាគោលការណ៍ ការជំនួសបុគ្គលិកចូលនិវត្តន៍ និង កន្លែងទំនេរបណ្តោះអាសន្ន គឺជានិន្នភាពស្រូបយកយុវ-បញ្ញាជនរបស់យើង ។

ប្រទេសដែលមានសេដ្ឋកិច្ចរីកចំរើន គេទុកឱកាសអោយយុវ-បញ្ញាវន្តមានក្តីសង្ឃឹម និង ទទួលនូវបទពិសោធន៍ ។ ភាគច្រើន តំលៃអាស៊ីនាសម័យទំនើប (Modern Asian Value) ដែលបានថ្លែងដោយលោកប្រធានាធិបតេយ្យចិន តេងស៊ាវពីងនិងថ្មីៗនេះដោយលោក ចាងស៊ីមិញ ថា: ប្រភពហិរញ្ញវត្ថុមួយដែលប្រជាជាតិក្រីក្រនៅអាស៊ីនឹកមិនដល់ គឺក្តីសង្ឃឹមដែល ត្រូវផ្តល់ជូនដល់យុវ-បញ្ញាជន ទើប

យើងអាចមើលលោកខាងលិចដែលធ្វើដំណើរចោលយើងជា ច្រើនសតវត្ស ។ ការប្រើមនុស្សចាស់ និង មានបទពិសោធន៍លើសពី ២០ ឆ្នាំ ផ្តល់ទារុណភាព ផលិតភាព និង ជំរុញនូវគំលាតឆ្ងាយក្នុងជីវភាព។

## ១១.៣ វិបត្តិសេដ្ឋកិច្ច

ធនាគារ និង ទីផ្សារហិរញ្ញវត្ថុទាំងអស់ ជាប្រភពមួយដ៏សំខាន់បំផុតក្នុងការធានាដល់ការលូតលាស់ សេដ្ឋកិច្ច ។ ការវិនិយោគរបស់ស្ថាប័នហិរញ្ញវត្ថុជាតិ និង អន្តរជាតិ សុទ្ធតែនាំមកនូវមិនគ្រាន់តែការងារទេ ថែមទាំងការប្រើប្រាស់ប្រភពធនធានក្នុងស្រុកដ៏ទៃទៀតដូចជាៈ អចលនទ្រព្យ ទុន និង ដី ។ រាស្ត្រនៅក្នុងស្រុកសប្បាយចិត្តនឹងការទទួលកំរៃពីការប្រើប្រាស់ធនធានក្នុងស្រុករបស់ស្ថាប័ន ទាំងនេះ ។ ការតំកល់ប្រាក់ជាប្រភពមួយដ៏សំខាន់សំរាប់ម៉ាក្រូសេដ្ឋកិច្ច ដោយសារវាអាចជួយអ្នក ជំនួញ និង វិនិយោគិនដ៏ទៃទៀត ។ រាស្ត្រដ៏ទៃទៀតអាចទទួលបានកំរៃពីបញ្ញើប្រាក់ហើយ អត្រា ការប្រាក់នេះហើយជាប្រភពចំណូលរបស់គេ និង ជាកេរ្តិ៍មរតកសំរាប់កូនចៅរបស់គេពង្រីកជំនួញ តទៅទៀត ។ ការវិវត្តន៍សេដ្ឋកិច្ចវាអាស្រ័យទៅនឹងកំនើននៃចំណាយសំរាប់ការប្រើប្រាស់ និង ការរីកចំរើននៃ វិនិយោគ ។ ការទទួលបាននូវការងារ ការទទួលកំរៃពីការប្រើប្រាស់ធនធានក្នុងស្រុក របស់ស្ថាប័នធនាគារ និងការទទួលកំរៃពីបញ្ញើប្រាក់ គឺជួយបង្កើនចំណាយសំរាប់ការប្រើប្រាស់ រីឯការ វិនិយោគរបស់ស្ថាប័នហិរញ្ញវត្ថុជាការរាប់បញ្ចូលនូវកំនើនវិនិយោគសរុបក្នុងប្រទេស ។ចាប់តាំងពីពេលរលំផុតទៅនៃប្រទេសរុស្ស៊ីសហរដ្ឋអាមេរិចឆ្លៀតយកឱកាសពង្រីកហិរញ្ញវត្ថុ ជាពិសេសជំនាន់លោក ដូណាល់ រីហ្គេន បានផ្តល់នូវការលើកទឹកចិត្តចំពោះអ្នកបង់ពន្ធ ដោយមិន ចាំបាច់អោយគេផាត់ចំណាយអត្រាការប្រាក់សំរាប់ការបង់ពន្ធទៅលើប័ណ្ណជានានោះទេ ។

## ១១.៤ ស្ថេរភាពតំលៃទំនិញ-សេវាកម្ម

គោលការណ៍មួយយ៉ាងសំខាន់ក្នុងស្ថេរភាពនីយកម្មសេដ្ឋកិច្ច គឺ ធ្វើយ៉ាងណាអោយតំលៃទំនិញ និង សេវាកម្មមានស្ថេរភាព រឺ មានលំនឹង ។ ជាងពីរទសវត្សកន្លងមកនេះ ប្រទេសស្ទើរតែទាំងអស់ពិតជា មានការលំបាកក្នុងការធ្វើអោយទំនិញ និង សេវាកម្មមានស្ថេរភាព ដោយសារអតិផរណាចេះតែបន្ត កើនឡើងជាលំដាប់ ។ កាលណាថ្លៃទំនិញកើនឡើង បណ្តាលអោយប៉ះពាល់ជីវភាពប្រជាជន និង បន្ថយនូវការសន្សំសំចៃ និង បន្ថយនូវដំណើរលូតលាស់សេដ្ឋកិច្ច ។ គេសង្កេតឃើញថា អស្ថេរភាព តំលៃទំនិញបង្កផលវិបាកធ្ងន់ធ្ងរដល់មន្ត្រីរាជការដែលមានបៀវត្សទឹងផ្តល់ អ្នកលក់ដូរតូចតាច និង រាស្ត្រក្រីក្រ ។ កាលណាអតិផរណាកើនឡើង ថ្លៃទំនិញកើនឡើងយ៉ាងឆាប់រហ័ស ហើយជាពិសេស នៅពេលដែលមានកំនើនខ្លាំងនៃអតិផរណា (Hyper-inflation) ។ គួរកត់សំគាល់ថាៈ អស្ថេរភាព តំលៃអាចជាប់ទាក់ទងផងដែរទៅនឹង តំលៃប្រេង-សាំងនាំចូលដែលចេះតែកើនឡើង ការប្រកួត ប្រជែងតំរូវការ និង ភាពពេញនិយមក្នុងសង្គម និង កំនើនលឿននៃចំណូលរបស់រាស្ត្រថ្នាក់ក

ណ្តាលជាសត្យានុម័ត ធនាគារជាតិ និង រាជរដ្ឋាភិបាលជាពិសេសក្រសួងដែលពាក់ព័ន្ធមានគោលដៅតែមួយ គត់គឺធ្វើយ៉ាងណាអោយមានស្ថេរភាពតំលៃតាមរយៈ គំរោងរុញច្រានរូបិយវត្ថុបរទេសពីទីផ្សារ (Portfolio shifting away foreign currencies) សន្ទស្សន៍ថ្លៃទំនិញ (Price Indexing) ការត្រួតពិនិត្យថ្លៃទំនិញ និងឧបត្ថម្ភដល់ផលិតករ (Price Control and Subsidies to Producers) និង ពង្រឹងរូបិយវត្ថុជាតិ ក៏ដូចជាកិត្តិយស ធនាគារ ។

## ១១.៥ ស្ថេរភាពអត្រាការប្រាក់

អ្នកសេដ្ឋកិច្ចពិតជាមានសភាពតានតឹង និង មិនពេញចិត្តនៅពេលណាដែលមានអស្ថេរភាពអត្រាការ ប្រាក់ ព្រោះវាជាផលប៉ះពាល់ដល់វិនិយោគ តំរូវការរូបិយវត្ថុ និង ផែនការអភិវឌ្ឍន៍ប្រទេស ។ ជាទូទៅ គេសំគាល់ឃើញថា កាលណាអត្រាការប្រាក់គ្មានលំនឹង វិនិយោគិន និង ពាណិជ្ជករគ្មាន បំណងខ្ចីប្រាក់នោះទេ ព្រោះកំរិតសំណងមានភាពប្រថុយប្រថាន ។ ម្យ៉ាងទៀត តំរូវការរូបិយវត្ថុ មានការផ្លាស់ប្តូរប្រសិនបើអត្រាការប្រាក់គ្មានលំនឹងច្បាស់លាស់ ។ ផែនការអភិវឌ្ឍន៍រយៈពេលវែង និង ជំនួយរយៈពេលវែងពិតជាមានការលំបាក ដូចជា ការអភិវឌ្ឍន៍ជនបទ គំរោងឥណទាន និង ការពង្រីកជំនួញ ។ នាពេលថ្មីៗនេះ ក្រុមហ៊ុនសំណង់នៃប្រទេសអាល្លឺមង់ភាគច្រើនបានបិទទ្វារ ដោយសារកត្តាប៉ះពាល់ជាច្រើន ប៉ុន្តែកត្តាមួយដែលសំខាន់ជាងគេ គឺ អស្ថេរភាពអត្រាការប្រាក់ក្នុង កិច្ចសន្យាកំចីរយៈពេលវែងដែលបង្កការលំបាកដល់ក្រុមហ៊ុនសំណង់ក្នុងការលើកគំរោងសាងសង់ លំនៅឋានមានចំនួនច្រើន និងចំណាយបំរែបំរួលមានកំរិតខ្ពស់ (BBC, London, 12pm mean time, October 2001) ។ អស្ថេរភាពអត្រាការប្រាក់នៅអឺរ៉ុបបណ្តាលមកពីការធ្លាក់ចុះសេដ្ឋកិច្ច នៅអាមេរិច និង ជប៉ុន ជាពិសេសវិស័យទេសចរណ៍-សណ្ឋាគារនៅអឺរ៉ុប។

## ១១.៦ សុវត្ថិភាព និង ស្ថេរភាពទីផ្សារហិរញ្ញវត្ថុ

រដ្ឋាភិបាលបានចាត់ទុកធនាគារកណ្តាលជាប្រព័ន្ធសុវត្ថិភាពហរិញ្ញវត្ថុមួយដ៏សំខាន់បំផុត ជាពិសេស ប្រាក់តំកល់ទុកនៅក្នុងធនាគារ គឺជាប្រភពហរិញ្ញវត្ថុដ៏រឹងមាំមួយ ។ វិធីមួយដែលធនាគារជួយធ្វើ អន្តរាគមន៍សំរាប់រដ្ឋាភិបាល គឺការបញ្ចេញសាច់ប្រាក់មួយចំនួនដើម្បីទប់ស្កាត់រាល់ចលាចលហិរញ្ញវត្ថុដែលកើតមានឡើង ។ ក្នុងស្ថានភាពមួយដែលអត្រាការប្រាក់គ្មានលំនឹង ធនាគារចាំបាច់ត្រូវតែបញ្ចេញប្រាក់បំរុងសំរាប់ផ្តល់កំចីបន្ថែម ដើម្បីធ្វើការការពារប័ណ្ណភាគហ៊ុន និង អន្តរការីហិរញ្ញវត្ថុ ដែលអាចទទួលនូវភាពរឹករវ ដោយសារតែរំលោះសាច់ប្រាក់បណ្តាលមកពីការធ្លាក់ចុះការប្រាក់ ។

## ១១.៧ ស្ថេរភាពទីផ្សារប្តូរប្រាក់អន្តរជាតិ

ស្ថេរភាពអត្រាប្តូរប្រាក់បរទេសមានសារសំខាន់ជាអាយុជីវិតសំរាប់រដ្ឋាភិបាលម៉ាក្រូសេដ្ឋកិច្ច និង ជាក្តីសង្ឃឹមរបស់រាស្ត្រទាំងអស់ ។ កាលពីផ្នែកទី២ យើងបានសិក្សារួចហើយថាៈ កាលណាអត្រាប្តូរ ប្រាក់មានការប្រែប្រួលមិនទៀងទាត់នឹងធ្វើអោយប៉ះពាល់ទៅដល់ :

- ពាណិជ្ជកម្មអន្តរជាតិ ដែលជាចំណូលមួយក្នុង ផសស (GDP)
- វិនយោគនៅក្នុងប្រទេស
- ពាណិជ្ជករតូចតាច

រដ្ឋាភិបាលពង្រឹងអត្រាប្តូរប្រាក់បរទេសអោយមានលំនឹងច្បាស់លាស់ក្នុងគោលបំណង :

- រក្សាបាន និង ពង្រឹងការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិ ជាពិសេសផលិតផលដែលត្រូវនាំចេញទៅបរទេស ។ សហរដ្ឋអាមេរិច ជប៉ុន សហគមន៍អឺរ៉ុប និង ចិន កំពុងតែតំឡើងកជាក់គ្នាទៅលើការនាំទំនិញចេញទៅបរទេស ជាពិសេសប្រទេសចិនតែម្តងដែលកំពុងតែបានក្លាយជា សមាជិកអង្គការពាណិជ្ជកម្មពិភពលោក (World Trade Organisation) ដែលគេបានបិទសមាជិកភាពជិតកន្លះសតវត្ស ។ នៅពេលដែលអត្រាប្តូរប្រាក់សហរដ្ឋអាមេរិចកំពុងតែ ជ្រួលច្របល់ដោយសារព្រឹត្តការណ៍វាយប្រហារទៅលើអាហ្គានីស្ថាន អឺរ៉ុប និង ចិនកំពុងពង្រឹងអត្រាប្តូរប្រាក់បរទេសអោយមានស្ថេរភាព ដើម្បីឈរជើងនៅលើទីផ្សារប្រកួតប្រជែង ។
- សំរួលដល់ការលក់ទំនិញ និង ការជឿជាក់របស់អតិថិជន ។ នៅពេលដែលអត្រាប្តូរប្រាក់មានលំនឹង វិនិយោគិនបានលើកគំរោងសំរាប់ការនាំចេញជាមួយភាគីទទួលទំនិញ ហេតុនេះកំរិតប្រាក់ចំណេញរបស់គេគ្មានការផ្លាស់ប្តូរទេ ផ្ទុយទៅវិញអតិថិជនដែលជាវទំនិញបានទទួលនូវថេរភាពនៃអំណាចទិញដូរនៅពេលដែលចំណូលរបស់គេមានសភាពនឹងថ្កល់ ។
- ជំនឿទុកចិត្តនៃអ្នកវិនយោគ (Investment Confidence) គឺជាតំណែងមួយដ៏សំខាន់សំរាប់ អាទិភាពរបស់រដ្ឋាភិបាលក្នុងការពង្រឹងនូវការលូតលាស់យូរអង្វែងនៃសេដ្ឋកិច្ច ។ លោក-អ្នក សាកល្បងគិតមើលថា តើព្រឹត្តិការណ៍ថ្ងៃ ១១ កញ្ញា ២០០១ នេះមានជះឥទ្ធិពលអាក្រក់អ្វីខ្លះ? ប្រជាជនអាមេរិចជាច្រើនទទួលស្គាល់ថា ជំនឿទុកចិត្តនៃអ្នកវិនយោគិនទៅលើជំនួញសហរដ្ឋអាមេរិចអាចទទួលរងនូវការប៉ះពាល់រយៈពេល ១-២ ឆ្នាំ ទើបស្តារឡើងវិញបាន ។ ជាបណ្តើរអ្នកចូលភាគហ៊ុននៅក្នុងវិស័យទេសចរណ៍-អាកាសចរ សណ្ឋាគារនៅអាមេរិច-អាស៊ី និង អឺរ៉ុបព្រមទាំងក្រុមហ៊ុនសំណង់ ក្រុមហ៊ុនសំអាង-កែសម្ផស្ស ក្រុមហ៊ុនអចលនទ្រព្យ និង ក្រុមហ៊ុនរថយន្ត-ដែកថែប ។ល ។ បានធ្លាក់ចុះភាគហ៊ុនវិនិយោគយ៉ាងខ្លាំង ដោយសារតែការប្រមូលផ្តុំនៃព្រឹត្តិការណ៍មិនល្អ និង អត្រាប្តូរប្រាក់ថយចុះ ធៀបទៅនឹងប្រទេសជាដៃគូប្រកួត ប្រជែងរបស់ខ្លួន ។ សហរដ្ឋអាមេរិចយល់ឃើញថា គេមានធ្លាក់ចុះជំនឿទុកចិត្តនៃអ្នក វិនិយោគ បើធៀបទៅនឹងអឺរ៉ុប ដែលកន្លងមកគេមិនសូវផ្តល់សុបិន្តល្អប៉ុន្មាននោះទេ។

## ១១.៨ គោលដៅជាយុទ្ធសាស្ត្រសំខាន់ៗរបស់រដ្ឋាភិបាល

ដោយសារពេលវេលាយើងខ្លីពេក ការសិក្សារបស់យើងបង្រួមត្រឹមចំនុចសំខាន់មួយចំនួនៈ

- ការស្តារ និង ពង្រឹងកិត្តិយសធនាគារ
- ការគ្រប់គ្រងស្ថាប័នហិរញ្ញវត្ថុ និង ឥណទានប្រកបដោយតំលាភាព និង សុក្រិតភាពសង្គម
- អន្តរាគមន៍ជាបន្ទាន់ទៅអត្រាប្តូរប្រាក់ និង ការប្រាក់ រួមទាំងអតិផរណា
- ការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ និង ពង្រីកស្ថាប័នហិរញ្ញវត្ថុជាតិ
- កែលំអរចនាសម្ព័ន្ធធនាគារ និង អធិការកិច្ច រួមទាំងការពង្រីកការងារ
- សហការជាមួយស្ថាប័នពាក់ព័ន្ធជាតិ និង អន្តរជាតិ
- ពង្រឹងការងារស្រាវជ្រាវ និង អភិវឌ្ឍន៍វិស័យធនាគារ និង ហិរញ្ញវត្ថុ

## ១១.៩ ប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ

ប្រព័ន្ធដែលធនាគារបានធ្វើការទាក់ទងក្នុងកំរិតអន្តរជាតិគឺៈ

- អន្តរាគមន៍ក្នុងទីផ្សារប្តូរប្រាក់បរទេស (Intervention in the Foreign Exchange Market) ដែលធនាគារកណ្តាលត្រូវតែប្រកាន់យកជាចាំបាច់ ហើយមុខងារនេះគេហៅថា អន្តរាគមន៍ការប្តូរប្រាក់ (Foreign Exchange Intervention) ។ សូមលោកអ្នកអានឡើងវិញ អំពីការគ្រប់គ្រងអត្រាប្តូរប្រាក់បរទេសរបស់ធនាគារជាតិ ។ ការសហការជាមួយស្ថាប័ន និង គោលនយោបាយរូបិយវត្ថុអន្តរជាតិ ។ សូមលោក-អ្នកអានអំពី និង ។ យើងនឹងមានការពន្យល់បន្ថែមពីសាស្ត្រាចារ្យក្នុងពេលឧទ្ទេសនាម ។

# បណ្ណាល័យសាស្ត្រ


Anniballi, F., Fiore, A., Löfström, C., Skarin, H., Auricchio, B., Woudstra, C., Bano, L., Segerman, B., Koene, M., Båverud, V., Hansen, T., Fach, P., Åberg, A. T., Hedeland, M., Engvall, E. O., & De Medici, D. (2013). Management of Animal Botulism Outbreaks: From Clinical Suspicion to Practical Countermeasures to Prevent or Minimize Outbreaks. *Biosecurity and Bioterrorism: Biodefense Strategy, Practice, and Science*, *11*(S1). https://doi.org/10.1089/bsp.2012.0089

Duong Nghia Quoc. (1996). Huong Dan Chan nuoi va Phong Tri Benh gia Cam TP. *Ho Chi Minh, Nha Xuat ban Nong Nghiep.*

Farrel, D.J., and Stapteton, Paul. (1985). Duck Production Science and World Practice. *The University of New England. Pro. of a work shop at Ciparas, Bogor, Indonesoa, Nov. 18-22.*